AngkorLink.com CambodiaBuddhist.org ABCCambodia.com



# ពុទ្ធសាសនា ២៥០០

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥៤៥

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# ពុទ្ធសាសនា ២៥០០

ភ្នំពេញ

ការផ្សាយរបស់ ពុទ្ធសាសនបណ្ឌិត្យ កម្ពុជរដ្ឋ

ព. ស. ២៥០០ គ. ស. ១៩៥៧

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# ពុទ្ធសាសនា ២៥០០

បោះពុម្ពលើកទី ៣ ចំនួន ៥០០ ច្បាប់
តាមច្បាប់ដើមបោះពុម្ពលើកទី ១ ឆ្នាំ ១៩៥៧

ភ្នំពេញ
ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
គ.ស. ២០០១

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# បញ្ជីមាតិកា


| មាតិកា | ទំព័រ |
|---|---|
| **អារម្ភបទ** | ក |
| **វគ្គទី ១ ពុទ្ធប្រវត្តិ:** | ១ |
| ក– អំពីទ្រង់ប្រសូត | ១ |
| ខ– អំពីទ្រង់បានត្រាស់ដឹង | ២ |
| គ– អំពីទ្រង់សំដែងព្រះធម្មចក្ក | ៥ |
| ឃ– អំពីទ្រង់បរិនិព្វាន | ៧ |
| **វគ្គទី ២ ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ:** | ៩ |
| ក– ប្រភពផ្សាយពុទ្ធសាសនាចូលមកប្រទេសខ្មែរ | ១០ |
| ខ– សម័យនគរភ្នំ | ៣៦ |
| គ– សម័យចេនឡា | ៥៧ |
| ឃ– សម័យមហានគរ | ៦២ |
| ង– សម័យបច្ចុប្បន្ន | ១០៨ |
| ច– ពុទ្ធសាសនានឹងប្រជាជនខ្មែរ | ១១០ |
| ឆ– ពុទ្ធសាសនានឹងរដ្ឋ | ១១១ |
| ជ– ពុទ្ធសាសនានឹងយុវជនខ្មែរ | ១១២ |
| ឈ– ពុទ្ធសាសនានឹងសង្គមខ្មែរ | ១១៣ |
| ញ– ពុទ្ធសាសនាបុរាណ ២.៥០០ វស្សា | ១១៥ |
| **វគ្គទី ៣ សិល្បៈពុទ្ធសាសនា:** | ១២១ |
| ក– អំពីពាក្យថា សិល្បៈ | ១២១ |
| ខ– អធិប្បាយលក្ខណៈសិល្បៈ | ១២២ |
| គ– អំពីព្រះពុទ្ធរូប | ១២៨ |
| ឃ– ប្រទេសកម្ពុជាមានព្រះពុទ្ធរូប ៨ បែប | ១២៩ |


Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

មាតិកា ទំព័រ


ង– អំពីស្តូបចេតិយ ១៣២
ច– អំពីចេតិយ ៤ ប្រភេទ ១៣៣
ឆ– អំពីប្រាង្គ ប្រាសាទ ១៣៥
ជ– អំពីវិហារ សាលា គំនូរ ១៣៦
ឈ– ប្រយោជន៍នៃពុទ្ធសាសនា ១៣៨

វគ្គទី ៤ វប្បធម៌ពុទ្ធសាសនា: ១៤៥

ក– វប្បធម៌ឥណ្ឌៀសម័យបុរាណ នឹងសម័យពុទ្ធកាល ១៤៥
ខ– វប្បធម៌ពុទ្ធសាសនាផ្សាយមកកាន់សុវណ្ណភូមិ ១៤៧
គ– មូលហេតុព្រះត្រៃបិដកស្វឹករឹត ១៤៩
ឃ– វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ ១៥០
ង– ព្រឹត្តិការណ៍វប្បធម៌ពុទ្ធសាសនានៅកម្ពុជរដ្ឋ ១៥៣
ច– វប្បធម៌ពុទ្ធសាសនាសម័យក្រោយអង្គរ ១៥៥
ឆ– វប្បធម៌ពុទ្ធសាសនាខាងទ្រឹស្តី ១៥៧
ជ– វប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ ១៥៨
ឈ– អ្នកទាន ១៥៨
ញ– អ្នកសីល ១៥៩
ដ– អ្នកភាវនា ១៦១

វគ្គទី ៥ សទ្ធម្មប្បជោត: ១៦៤

ក– សទ្ធម្មុប្បត្តិ = កិរិយាកើតឡើងនៃព្រះសទ្ធម្ម ១៦៥
ខ– សទ្ធម្មបរិច្ឆេទ = កិរិយាកម្រិតព្រះសទ្ធម្ម ១៧៧
គ– ពុទ្ធសកដ្ឋបនៈ = កិរិយាតាំងពុទ្ធសករាជ ១៨០
ឃ– បញ្ចវត្ថុប្បតិដ្ឋាន = ប្រតិស្ឋានវត្ថុ ៥ យ៉ាង ១៨២
ង– បញ្ចអន្តរធាន = អន្តរធាន ៥ យ៉ាង ១៨៦

វគ្គទី ៦ ចិត្តដឹកនាំលោក: ១៩២

ក– លោកគឺអ្វី? ១៩២


Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

មាតិកា ជំព័រ


ក– ចិត្តគឺអ្វី ? ១៩៥

ខ– អាការរបស់ចិត្ត ១៩៨

ឃ– គួរធ្វើចិត្តឲ្យស្ងប់ក្នុងអំណាចខ្លួន ១៩៩

ង– ចំណង់របស់ចិត្ត ២០១

ច- លោកត្រូវចិត្តដឹកនាំដូចម្តេច ? ២០៣

ឆ- ចិត្តដឹកនាំសត្វលោក ២០៣

ជ- ចិត្តដឹកនាំទកាសលោក ២០៥

វគ្គទី ៧ ការបោះពុម្ពព្រះត្រៃបិដក នៅប្រទេសខ្មែរ ២១០


## បញ្ជីរូប


រូបព្រះសិរីព្រះពុទ្ធរូប នៅប្រាសាទបាយ័ន អង្គរធំ

រូបព្រះសក្យមុនីចេតិយនៅមុខស្ថានីយរថភ្លើង ភ្នំពេញ ជ

រូបព្រះសិទ្ធត្ថទ្រង់ប្រសូត ១

រូបព្រះសិទ្ធត្ថទ្រង់បានត្រាស់ ៣

រូបព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះធម្មចក្ក ៥

រូបព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាន ៨

រូបព្រះចេតិយពុទ្ធគយា នៅទីពោធិព្រឹក្ស ប្រទេសឥណ្ឌា ១២០

រូបព្រះពុទ្ធរូបនាគប្រក់ នៅប្រាសាទបាយ័ន អង្គរធំ ១២៨

រូបព្រះស្តូបធម្មេយ នៅក្រុងសារនាថ ប្រទេសឥណ្ឌា ១៥៤

រូបព្រះស្តូបសញ្ជី នៅរដ្ឋភោបាល ប្រទេសឥណ្ឌា ១៩៣

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# សេចក្ដីប្រារព្ធ

## ចំពោះការបោះពុម្ពឡើងវិញ

ក្នុងឆ្នាំកន្លងទៅនេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា បានស្រាវជ្រាវរើសរកក្បួនខ្នាតទាក់ទង នឹងអក្សរសាស្ត្រសាសនា មកបោះពុម្ពឡើងវិញ ដើម្បីរក្សាស្នាដៃរបស់បុព្វបុរសខ្មែរយើង ។ ក្នុងបណ្ដាសៀវភៅដែលបានបោះពុម្ពយូរមកហើយ សៀវភៅ " ពុទ្ធសាសនា ២៥០០ " គឺជាឯកសារដ៏សំខាន់មួយស្ដីពីប្រវត្តិ ពុទ្ធសាសនា នៅប្រទេសកម្ពុជា ។

ក្នុងការបោះពុម្ពសៀវភៅនេះឡើងវិញ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះប្រសិនបើមានកំហុសអក្ខរាវិរុទ្ធ កំហុសក្នុងការរៀបរៀងឃ្លាក្ដី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពឯកសារល្អៗបែបនេះផ្សេងទៀត ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជនផង ដើម្បីរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ ឱ្យបានគង់វង្ស និងរីកចំរើនផង ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអរគុណ ចំពោះលោកយី ធន់ ដែលបានផ្ដល់ឯកសារដ៏មានសារៈសំខាន់នេះ ដើម្បីបោះពុម្ពផ្សាយឡើងវិញ ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ២០០១

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

សៀវភៅនេះ

ផ្សាយចេញពី ក្រុមពុទ្ធសាសនបណ្ឌិត្យ ដោយ

ជំនួយ ក្រុមមូលនិធិអាស៊ី ចែកជា

សាធារណៈ ឥតយកថ្លៃ ទុកជាអនុស្សរណកុសល

ក្នុង ពិធីបុណ្យ ព.ស. ២៥០០ ដែល

កម្ពុជរដ្ឋធ្វើនៅថ្ងៃ ១៤ កើត ដល់ ៥ រោច ខែពិសាខ

ឆ្នាំរកានព្វស័ក ពុទ្ធសករាជ ២.៥០០

គឺថ្ងៃទី ១២ ដល់ ១៨ ខែឧសភា

គ្រិស្តសករាជ ១៩៥៧

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com



ព្រះសីរ្សព្រះពុទ្ធរូប (រចនាខ្មែរ) នៅប្រាសាទបាយ័ន អង្គរធំ គ្រិស្តសតវត្សទី ១១

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# អារម្ភបទ

ព្រះពុទ្ធសាសនា ជាសាសនាមានបទនាយកធម៌ធំៗ ច្រើនជាអនេក មានអហឹសាជាដើម គឺជាសាសនាខាងបទមិនបៀតបៀន ប្រកបដោយមេត្តាករុណា ហើយជាទស្សនវិជ្ជាសម្រាប់បណ្តុះនិស្ស័យមនុស្សឲ្យកាន់សុចរិតយុត្តិធម៌ ឲ្យខ្ពង់ខ្ពស់ ដែលអ្នកត្រូវការសន្តិភាពគួរសិក្សា គួរប្រតិបត្តិតាម ដើម្បីសុខចម្រើនដល់ខ្លួន ដល់ជាតិ និងដល់ប្រទេស ។

ព្រះសម្ពុទ្ធជាម្ចាស់សាសនា ព្រះអង្គត្រាស់ដឹងឡើងក្នុងមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌៀសព្វថ្ងៃនេះ មុនពុទ្ធសករាជ ៤៥ឆ្នាំ ព្រះអង្គជាវេជ្ជគរុ(គ្រូលើគ្រូពេទ្យ)ក្នុងលោក ទ្រង់បានប្រទានឱសថគឺព្រះសទ្ធម្ម ស្រោចស្រង់មនុស្សលោកដែលមានរោគខាងផ្លូវចិត្តគឺកិលេសតណ្ហាឲ្យស្រះជាបាន សមគួរតាមឧបនិស្ស័យ ហើយទ្រង់បរិនិព្វានទៅ នៅសល់តែព្រះពុទ្ធសាសនា ជាសាស្តាជំនួសព្រះអង្គរហូតដល់សព្វថ្ងៃ ។

ក្រោយពុទ្ធបរិនិព្វានប្រមាណជាង ២០០ឆ្នាំ ព្រះពុទ្ធសាសនាមានឥទ្ធិពលពេញប្រទេសឥណ្ឌៀទាំងមូល ព្រះបាទអសោករាជាធិរាជទ្រង់បានគ្រប់គ្រងលើភាគដែនដីដ៏ធំនៃប្រទេសឥណ្ឌៀ ទ្រង់បានចាត់ការផ្សាយព្រះពុទ្ធសាសនា ដោយទ្រង់បញ្ជូនសមណទូតឲ្យនិមន្តទៅកាន់នានាប្រទេសក្នុងអាស៊ីទ្វីប ។

ប្រវត្តិនៃព្រះបាទអសោករាជាធិរាជ បានត្រូវគេស្គាល់ពេញសកល

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



លោកដោយសារចារឹកដ៏ច្រើន ដែលព្រះអង្គទ្រង់ព្រះបញ្ជាឲ្យឆ្លាក់លើសសរថ្មនឹងផែនថ្មទាំងឡាយ ដែលមានមកដល់សព្វថ្ងៃស្ទើរតែពេញប្រទេសឥណ្ឌា ។

ប្រទេសឥណ្ឌាសម័យបច្ចុប្បន្នគេបានបម្លងរូបកង់ចក្រដែលព្រះបាទអសោកពជាធិរាជសាងទុកនៅលើកំពូលសសរថ្មមួយ មកធ្វើជាទង់ជាតិរបស់គេ ជានិមិត្តរូបបង្ហាញសកលលោកឲ្យឃើញច្បាស់ថា ការកសាងឯករាជ្យប្រទេសឥណ្ឌា គឺយកតម្រាប់តាមគោលច្បាប់ព្រះពុទ្ធសាសនា ។

ដោយសារព្រះបាទអសោកពជាធិរាជ ទ្រង់បានចាត់ការបញ្ជូនសមណទូត ឲ្យនិមន្តមកផ្សាយព្រះពុទ្ធសាសនាក្នុងនានាប្រទេសនៅអាស៊ីទ្វីប ដូចរៀបរាប់មកខាងលើនេះជាដើមហើយ បានជាព្រះពុទ្ធសាសនាមកប្រតិស្ឋាននៅប្រទេសកម្ពុជាយើង តាំងពីសម័យបន្ទាប់នោះមករហូតដល់សព្វថ្ងៃ ។

ក្នុងបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនានៅអាស៊ីទ្វីប, ប្រទេសខ្មែរយើងបានឈ្មោះថា ជាប្រទេសកាន់ព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់មួយ, ពលរដ្ឋប្រទេសនេះជឿព្រះពុទ្ធសាសនាមុតមាំណាស់ បុណ្យអ្វីក៏ដោយឲ្យតែជាបុណ្យខាងព្រះពុទ្ធសាសនា ពុទ្ធបរិស័ទទូទាំងប្រទេសទោះបីមានជីវភាពដុនដាបយ៉ាងណាក៏ស៊ូប្តូរជីវិតនឹងបុណ្យនោះជាដរាប បានលះបង់ទ្រព្យសម្បត្តិឥតស្តាយ ដើម្បីញ៉ាំងការបុណ្យនោះឲ្យរុងរឿងតែរៀងខ្លួន មកពីគេជឿថា ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម «សមណគោតម» ដែលជាម្ចាស់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សាសនា ព្រះអង្គជាមហាសាស្ដាក្នុងលោក មានព្រះញាណខ្ពស់បំផុតរកសាស្ដាឯទៀតស្មើគ្មាន ហើយទឹងមកពីគេជឿថា កាលបើគេធ្វើតាមព្រះពុទ្ធឱវាទទៅ ហើយគេនឹងបានជួបប្រទះនូវកំពូលធម៌ដ៏ស្ងប់បំផុត គឺព្រះនិព្វាន ។

មួយទៀត គេជឿថា ព្រះពុទ្ធសាសនាមានជន្មាយុត្រឹម ៥០០០ វស្សា , ត្រង់ពុទ្ធសករាជកន្លងទៅបាន ២៥០០ វស្សា គេសន្មតថាពាក់កណ្ដាលសាសនា ហើយគេចង់ឲ្យព្រះពុទ្ធសាសនាមានជន្មាយុវែងជាង ៥០០០ វស្សាទៅទៀត ដើម្បីនឹងបានជាយានដ៏ឧត្ដមនាំសត្វទៅរកសេចក្ដីបរិសុទ្ធជាទីបំផុតនៃសង្សារវដ្ដ ។

ក្នុងរយៈកាលពាក់កណ្ដាលសាសនានេះ ខេមរជនទូទាំងប្រទេសកម្ពុជាមានចិត្តរំភើបជាបំផុត ដោយយល់ថាដែលខ្លួនគេរស់រានមានជីវិតរហូតដល់បានទាន់រយៈកាលពាក់កណ្ដាលសាសនានេះជាភ័ព្វល្អណាស់ , ហើយថែមទាំងបានជួបប្រទះនឹងបុណ្យរំលឹករយៈកាល ២៥០០ វស្សា នៃពុទ្ធបរិនិព្វានផងទៀត ដែលប្រទេសកម្ពុជាធ្វើនៅទីក្រុងភ្នំពេញ ជាបុណ្យដែលធ្វើបានតែម្ដងទេក្នុងមួយជីវិតរបស់ពុទ្ធិកជនម្នាក់ៗ ដែលមានភ័ព្វបានទាន់រយៈកាលពាក់កណ្ដាលសាសនានេះ ។

មួយវិញទៀត គេជឿតាមក្បួនមួយហៅក្បួនពុទ្ធទំនាយដែលចាស់ៗតែងនិយាយប្រាប់គ្នាតៗមក ដូចបរិយាយតទៅនេះ :

ក) អ្នកដែលមានអាយុរស់នៅទាន់ពាក់កណ្ដាលសាសនា បានឈ្មោះថា ជាមនុស្សមានសំណាងខ្ពស់ណាស់ ដល់ពេលចែកឋានទៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កាន់លោកខាងមុខក៏រឹតតែខ្ពង់ខ្ពស់ណាស់ទៅទៀត ។ សេចក្តីនេះបើពិចារណាតាមផ្លូវធម៌ឃើញថាពិតច្រើន ព្រោះថាលុះតែអ្នកដែលមានជីវិតរស់នៅទាន់រយៈកាលពាក់កណ្តាលសាសនា ទើបអាចធ្វើបុណ្យរំលឹករយៈកាល ២៥០០ វស្សានៃពុទ្ធបរិនិព្វាន ដែលសន្មតថាជាបុណ្យពាក់កណ្តាលព្រះសាសនាបាន ហើយអ្នកដែលបានធ្វើបុណ្យនេះទៀតពិតជាមានចិត្តសង្វេគព្រមទាំងរីករាយជាបំផុតផងក្នុងពេលដែលធ្វើ ដោយគេនឹកដល់ភ័ព្វសំណាងរបស់គេរៀងខ្លួន ដែលបានឆ្លងកាត់វាលធំនៃឧប-សគ្គនានាមកដល់ពាក់កណ្តាលព្រះសាសនានេះដោយសុវត្ថិភាព ជាបុញ្ញ-លាភយ៉ាងប្រសើរក្រៃលែង ។

២) ជិតដល់ពាក់កណ្តាលព្រះសាសនាមានចោរទាំងឡាយទឹងធម្មិកក្នុងក្តាយទាំង ៨ ទិស នាំគ្នាបង្ហិលខួរក្បាលមនុស្សឲ្យខូចខ្លួន ឲ្យបង់ជីវិតអស់ជាច្រើន ទាំងព្រះពុទ្ធសាសនាក៏បានជួបប្រទះនឹងឧបសគ្គនានាជាអនេក គឺមានខ្មាំងសត្រូវក្រៅព្រះពុទ្ធសាសនាចូលមកលុកលុយ ជួនកាលគេហ៊ានទម្លាយវត្តអារាមនឹងព្រះសង្ឃខ្មែរផង ដោយបំណងចង់ឲ្យព្រះពុទ្ធសាសនាវិនាសអន្តរាយ , ប៉ុន្តែជាការអស្ចារ្យគួរឲ្យស្ញើចក្រៃពេក ដែលមានគេធ្វើបាបណាស់ ព្រះពុទ្ធសាសនាក៏រឹតតែមានអានុភាពខ្លាំងឡើង ព្រោះអំណាចព្រះពុទ្ធសាសនាជាពាក្យពិត សមដូចពុទ្ធភាសិតថា សច្ចំ វេ អមតា វាចា (ពាក្យសច្ចៈមិនចេះស្លាប់) , សតញ្ច ធម្មោ ន ជរំ ឧបេតិ (ធម៌សប្បុរសមិនចេះចាស់) ។ ប្រសិនបើ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះពុទ្ធសាសនាគ្មានពាក្យសច្ចៈទេ ម៉្លេះសមអ្នកក្រៅព្រះពុទ្ធសាសនាគេទម្លាយឲ្យសាបសូន្យអស់រលីងទៅហើយ, តែនេះមិនដូច្នោះ ព្រះពុទ្ធសាសនាត្រឡប់ជាមានជ័យជំនះយ៉ាងសម្បើមទៅវិញ ហើយរុងរឿងស្អាតថៃសរហូតមកដល់ ២៥០០ វស្សានេះ ជាការណ៍អស្ចារ្យគួរឲ្យរំភើបចិត្តក្រៃលែង ។

គ) ដល់ពាក់កណ្ដាលសាសនាមានអ្នកមានបុណ្យ១ព្រះអង្គមកលើកព្រះពុទ្ធសាសនា ។ ពាក្យនេះបើពិចារណាឲ្យល្អិតក៏រឹតតែឃើញពិតណាស់ទៅទៀត គឺថា ជិតដល់ពាក់កណ្ដាលសាសនា ប្រទេសខ្មែរយើងបានឯករាជ្យពេញលក្ខណៈដោយសារព្រះសន្តិនយោបាយ នៃសម្ដេចព្រះនរោត្តម-សីហនុ ឧបយុវរាជ ដែលជាអ្នកមានបុណ្យ១ព្រះអង្គទ្រង់មានព្រះបរិយាសម្មាបដិបត្តិ ទ្រង់បានឧបត្ថម្ភព្រះពុទ្ធសាសនាគ្រប់យ៉ាង មានទ្រង់ព្រះផ្នួសជាដើម ហើយទីងទ្រង់ប្រកបដោយសប្បុរិសធម៌ពេញលក្ខណៈ ដែលតាមភាសាបាលីហៅថា ធម្មិក គឺទ្រង់ជាតួព្រះបាទធម្មិក ១ ព្រះអង្គដែលយើងធ្លាប់បានដឹងឮតៗគ្នា តាមក្បួនពុទ្ធទំនាយមកនោះឯង ។ សម្ដេចព្រះឧបយុវរាជជាបិតាឯករាជ្យជាតិ ទ្រង់បានដោះទុក្ខយើង និងប្រទេសយើងឲ្យបានសុខសន្តិភាពជាស្ថាពរ ដែលគ្រប់ប្រទេសមហាអំណាចក្នុងសកលលោកបានទទួលស្គាល់រាប់អានព្រះអង្គ យកជាមហាមិត្តដ៏ប្រសើរ គេនាំគ្នាថ្វាយអំណោយដ៏ប្រណីតៗ ចំពោះព្រះអង្គ ព្រមទាំងជួយចំពោះប្រទេសកម្ពុជាដោយសម្ភារៈផ្សេង ៗ ផងទៀត ។ ក្រៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពីទ្រង់មានព្រះចរិយាដូចពោលហើយ សម្តេចទ្រង់មានព្រះឱស្ឋដូចជាចិត្តមានព្រះរូបព្រះនោមជាទីស្នេហាដល់អ្នកដែលបានទស្សនាព្រះអង្គថែមទៀត ហើយព្រះអង្គមានព្រះប្រាជ្ញាញាណមោះមុតដូចព្រះខាន់ពេជ្រទម្លុះទម្លាយនូវបញ្ហាអាថ៌កំបាំងជាអាយុជីវិតនៃប្រទេសជាតិ ធ្វើប្រទេសជាតិមាតុភូមិឲ្យបានរួចរំដោះចាកភ័យន្តរាយជាអនេករាប់មិនឈ្នះ ទ្រង់ឈមព្រះភក្ត្រទៅកាន់ទិសណា ទ្រង់ស្តេចយាងទៅកាន់ទីណា ប្រទេសណាតែងតែមានជោគជ័យជាដរាប ។ យើងរាល់គ្នាគួរតែខំធ្វើបុណ្យឲ្យបានកាន់សច្ចៈ ដោយម៉ឺងម៉ាត់ គ្រាន់បានជាបរិពាររេហ៍ពលរបស់ព្រះអង្គ ដើរតាមមាគ៌ានយោបាយនៃព្រះអង្គរហូតទៅ ។

ឃ) នរណាបានរស់នៅទាន់ពាក់កណ្តាលសាសនាហើយបានប្រព្រឹត្តធម៌ ៣ យ៉ាង គឺ ១- មិនប្រមាថឪពុកម្តាយរំលាយព្រះ, ២- មិនលួចប្លន់ទ្រព្យសម្បត្តិគេ, ៣- មិនសម្លាប់សត្វបំបាត់ជីវិតគេ ទាំងបានធ្វើទានរក្សាសីលធ្វើខ្លួនឲ្យបរិសុទ្ធផង, អ្នកនោះនឹងបានសុខចម្រើន ព្រោះតទៅមុខមានទំនាយថា នឹងផុសក្អមមាសក្អមប្រាក់កែវកងពិទូរ្យសុរិគាន ហើយមនុស្សគ្រប់រូបនឹងគ្មានរោគាព្យាធិ បើដល់ពេលមរណៈនឹងទទួលមរណកាលដោយអាយុក្ខ័យរបស់ខ្លួន ។ សេចក្តីនេះគួរយល់ថា ក្នុងអនាគតដ៏ខ្លី ប្រហែលជានឹងផុសរបស់ទាំងនេះនៅប្រទេសខ្មែរយើងមិនទេដឹង ? ព្រោះយើងបានឃើញព្រាងៗខ្លះតាំងពីឥឡូវនេះទៅហើយ គឺថានៅប្រទេសយើង គ្រោងការ ២ ឆ្នាំនៃទំនប់ទឹកក្នុងទីទាំងពួងក្តីកំពង់ផែនៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មាត់សមុទ្រកំពង់សោមក្តី សុទ្ធតែទុកជាក្អំមាសក្អំប្រាក់របស់ខ្មែរទាំងអស់ គួរកត់សំគាល់បានថាទំនប់ទឹកទាំងឡាយអាចឲ្យខ្មែរធ្វើស្រូវបាន ២ រដូវ ក្នុង១ឆ្នាំ ដាំដំណាំកើតផលចម្រើន ហើយផលិតផលដែលកើតអំពីព្រះធរណីខ្មែរនឹងត្រូវដឹកនាំតាមកំពង់នាវាខ្មែរ ទៅលក់ឯផ្សារសកលលោក យកមាសប្រាក់មកប្រទេសខ្មែរបានតាមចិត្តខ្មែរ ។ មិនតែប៉ុណ្ណោះអគ្គការអនាម័យខ្មែរ ក៏បានទទួលជំនួយឱសថដ៏ស័ក្តិសិទ្ធិអំពីអគ្គការសុខភាពពិភពលោកជាច្រើនដើម្បីបំបាត់រោគាព្យាធិរបស់ពលរដ្ឋ ហើយអាចរម្ងាប់រោគាព្យាធិដែលជាតិយើងយល់ថាជារោគមើលមិនជាឲ្យជាបាន, ឃើញថាសេចក្តីពិតនេះតែផុសឡើងបន្តិចម្តងៗជាលំដាប់លំដោយដែរហើយ គួរឲ្យយកជាការណ៍ពិតបានមែន ។ យើងមានសង្ឃឹមដ៏មុតមាំថាខ្លួនយើងនឹងវវៀគណាញាតិយើង ព្រមទាំងជាតិប្រទេសកម្ពុជាយើងមុខជានឹងបានជួបប្រទះនូវជោគជ័យដ៏អស្ចារ្យ ដូចក្បួនពុទ្ធទំនាយបានទាយទុកនោះជាប្រាកដពុំខានទេដឹង ?

ង) ដល់ពាក់កណ្តាលសាសនា ។ រុងរឿង ។ ពាក្យនេះក៏ពិតណាស់ទៀត ព្រោះថា វេលាពុទ្ធសករាជជិតគ្រប់ ២៥០០ វស្សា អាស្រ័យដោយព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយមេត្តាករុណាច្រើន មានគោលសន្តិភាព ទូន្មានឲ្យលះបង់គតិសង្គ្រាមដែលនាំឲ្យកើតសេចក្តីត្រជាក់ត្រជុំដល់ប្រជាពលលោក ក៏បណ្តាលឲ្យប្រទេសទាំងពួងក្នុងសកលលោកដែលមិនទាន់កាន់ព្រះពុទ្ធសាសនា នាំគ្នាយកចិត្តទុកដាក់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គិតគូរការកាន់តាមខ្លះឡើង ប្រទេសដែលកាន់ស្រាប់ហើយ ដូចប្រទេសសិរីលង្កាជាដើមក៏បណ្ដាលឲ្យផ្ដើមបង្កើតពុទ្ធិកសមាគមពិភពលោកឡើងពី ព.ស. ២៤៩៤ គ.ស. ១៩៥០ សម្រាប់ឧបត្ថម្ភព្រះពុទ្ធសាសនា ហើយអំពាវនាវរកប្រទេសនានា ឲ្យបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគតាមប្រទេសរៀងខ្លួនផង, ប្រទេសទាំងពួងមានប្រទេសកម្ពុជាយើង ប្រទេសថៃ ប្រទេសភូមា ប្រទេសជប៉ុនជាដើម ក៏បានបង្កើតឡើងសម្រាប់ប្រទេសរបស់ខ្លួន តាមសមត្ថភាពរៀងខ្លួន ហើយគ្រប់តែប្រទេសបានណាត់គ្នាថា ត្រូវផ្ដើមមហាសន្និបាតពុទ្ធសាសនារៀងរាល់ប្រទេស គឺរវាង២ឆ្នាំធ្វើក្នុងប្រទេស ១ ហើយ ២ ឆ្នាំទៀតទៅធ្វើនៅប្រទេស ១ ទៀត ដោយអញ្ជើញគណៈប្រតិភូពីគ្រប់ប្រទេសទៅរួមប្រជុំពិភាក្សារកសេចក្ដីចម្រើនដល់ព្រះពុទ្ធសាសនា រកសន្តិភាពដល់សកលលោក ហើយគ្រប់តែប្រទេសសុទ្ធតែបានបញ្ជូនសមណនិស្សិតឲ្យទៅទាក់ទងទៅសិក្សានៅមហាវិទ្យាល័យ នៃប្រទេសលង្កានឹងឥណ្ឌាជាដើម ព្រមទាំងឲ្យទៅប្រកាសផ្សាយព្រះពុទ្ធសាសនាដល់ប្រជាជននៅប្រទេសដែលមិនទាន់កាន់ ៗ តាមចំនងនេះប្រជាជននៅប្រទេសខ្លះខាងបច្ចិមទិសក៏បានកាន់ខ្លះឡើង ព្រមទាំងបានបង្កើតពុទ្ធិកសមាគមឡើងនៅប្រទេសរៀងខ្លួនផង ហើយនាំគ្នាផ្សាយដល់ប្រជាជននៅក្នុងប្រទេសរបស់ខ្លួនតទៅ ៗ

រដ្ឋាភិបាលប្រទេសភូមាបានផ្ដើមធ្វើឆដ្ឋសង្គាយនាឡើង ដើម្បីឲ្យរួប

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះសក្យមុនីចេតិយ តំកល់ព្រះបរមសារីរិកធាតុ នៅមុខស្ថានីយរថភ្លើងយានយាន ក្រុងភ្នំពេញ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្រេចក្នុងពុទ្ធសករាជគម្រប់ ២៥០០ ដោយនិមន្តព្រះសង្ឃជាប្រតិភូពីប្រទេសនានាទៅប្រជុំផ្ទៀងផ្ទាត់បាលីព្រះត្រៃបិដក ហើយគេនឹងប្រែចាកភាសាបាលីទៅជាភាសាភូមា នឹងភាសាអង់គ្លេស ដោះពុម្ពផ្សាយពាសពេញលោក ហើយគេបានចាត់ចែងធ្វើបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ នៅវេលាបញ្ចប់ឆដ្ឋសង្គាយនាបាលីនោះ ។

រដ្ឋាភិបាលសហរដ្ឋភូមា បានចាត់ចែងធ្វើបុណ្យសម្ពោធពុទ្ធសករាជគម្រប់២៥០០ ហៅថា ពុទ្ធជយន្តិ អស់ចំរវេលា៧ខែ គឺតាំងពីខែឧសភា ត្រូវនឹងខែពិសាខ ព.ស. ២៤៩៩ គ.ស. ១៩៥៦ ដោយគេសំគាល់ថា ២៥០០ ក្នុងឆ្នាំនោះ គឺមុនប្រទេសខ្មែរយើងជិត ១ ឆ្នាំ ដល់ខែវិច្ឆិកា ត្រូវនឹងខែកត្តិកឆ្នាំដដែលទើបធ្វើបង្ហើយបុណ្យ. ក្នុងឱកាសបុណ្យនោះ គេបានអញ្ជើញប្រតិភូប្រទេសកាន់ព្រះពុទ្ធសាសនាទាំងខាងអឺរ៉ុប ទាំងខាងអាស៊ីទៅរួមប្រជុំធំនៅខែឧសភា១លើក ខែវិច្ឆិកា១លើក ។ ប្រទេសលង្កា ប្រទេសជប៉ុនក៏បានធ្វើបុណ្យនេះបន្ទាប់គ្នានឹងប្រទេសភូមាដែរ ។ ឯប្រទេសថៃ លាវ ធ្វើបុណ្យនេះដំណាលគ្នានឹងប្រទេសកម្ពុជា ។ ករណីទាំងនេះជាគ្រឿងបញ្ជាក់ឲ្យឃើញថា រវាងពុទ្ធសករាជគម្រប់ ២៥០០ នេះព្រះពុទ្ធសាសនារុងរឿង ។

ឯប្រទេសកម្ពុជាយើង បានចាត់ចែងធ្វើបុណ្យសម្ពោធពុទ្ធសាសនាយុកាលគម្រប់ ២៥០០ នៅទីក្រុងភ្នំពេញ ជាបុណ្យធំអស្ចារ្យ សមតាមឆន្ទៈនឹងជំនឿរបស់ពុទ្ធសាសនិកជននៅកម្ពុជរដ្ឋទាំងមូល ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បុណ្យនេះជាបុណ្យផ្លូវការរបស់កម្ពុជរដ្ឋ, រាជរដ្ឋាភិបាលបានតែងធ្វើក្នុងព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្ដេចព្រះមហាក្សត្រិយានី, សម្ដេចព្រះឧបយុវរាជ និងក្នុងសេចក្ដីទំនុកបំរុងនៃសម្ដេចសង្ឃនាយកទាំងពីរគណៈ ធ្វើអស់ថេរវេលា ៧ ថ្ងៃ គឺតាំងផ្ដើមដំបូងនៅថ្ងៃ ១ ១៤ ៦ ឆ្នាំរកានព្វស័ក ពុទ្ធសករាជ ២៥០០ ត្រូវនឹងថ្ងៃទី ១២ ខែឧសភា គ្រិស្តសករាជ ១៩៥៧ ដល់ថ្ងៃ ៧ ៥ ៦ ត្រូវនឹងថ្ងៃទី ១៨ ខែឆ្នាំ និងសករាជដដែល ជាថ្ងៃបង្ហើយបុណ្យ ។

បុណ្យនេះ ធ្វើជា ២ ផ្នែក គឺ

១– បុណ្យព.ស.២៥០០;

២– បុណ្យឆ្លងព្រះសក្យមុនីចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ។

បុណ្យទាំង២ផ្នែកនេះ ប្រជុំធ្វើនៅព្រះសក្យមុនីចេតិយ ត្រង់មុខស្ថានីយរាជអយស្ម័យយាន ក្រុងភ្នំពេញ ។

ព្រះចេតិយនេះដែលបានជាមាននាមថា "ព្រះសក្យមុនីចេតិយ" ព្រោះជាព្រះចេតិយដែលស្ថាបនាឡើងទុកជាទីរលឹកដល់ថ្ងៃដែលព្រះបរម-សារីរិកធាតុនៃព្រះសម្ពុទ្ធ និងព្រះអរហន្តធាតុនៃព្រះអគ្គសាវ័កទាំងគូបាននិ-មន្តពីប្រទេសឥណ្ឌាមកប្រថាប់នៅក្នុងព្រះរាជធានីភ្នំពេញ អស់វេលា៧ថ្ងៃ គឺពីថ្ងៃអាទិត្យទី ៥ ដល់ថ្ងៃសៅរ៍ទី ១១ខែតុលា ព.ស.២៤៩៥ គ.ស. ១៩៥២ ទើបបាននិមន្តត្រឡប់ទៅប្រទេសឥណ្ឌាវិញ ។ កាលដែលទ្រង់និមន្តមកប្រថាប់ ៧ ថ្ងៃនោះ ពុទ្ធបរិស័ទនៅប្រទេសខ្មែរយើងទាំងព្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



រាជា ទាំងប្រជារាស្ត្រទូទៅទាំងប្រទេសមានសេចក្តីជ្រះថ្លាមហិមាក្រើករំពើកអស់ទាំងស្រុកតូចធំនិគមជនបទនានា នាំគ្នាច្រើនម៉ឺនសែននាក់មកនមស្ការបូជាគារវៈដោយមហាសក្ការៈគ្រប់យ៉ាង មានមាសប្រាក់ជាដើម, ចំណែកហិរញ្ញវត្ថុដែលបាន ១.៦៦៧.៣០៩៛២១ ហើយដែលគណៈកម្មការបានបែងចែកជាចំណែកផ្សេងៗ តាមស្ថានដែលត្រូវចែកទាំងក្នុងប្រទេសក្រៅប្រទេសនោះ ជាអាទិ គឺ ១ ចំណែកចំនួន ៩០ ម៉ឺនរៀលគេបានយកទៅធ្វើមន្ទីរពេទ្យព្រះសង្ឃ, ១ ចំណែកទៀតចំនួន ២០ ម៉ឺនរៀលគេបានយកមកចាត់ការស្ថាបនាជាមហាចេតិយ នៅមុខស្ថានីយរាជអយស្ម័យយាន ក្រុងភ្នំពេញ សម្រាប់ដំកល់ព្រះបរមសារីរិកធាតុ ទើបសន្មតនាមថា «ព្រះសក្យមុនីចេតិយ» ។

នៅឱកាសបុណ្យទាំង ២ ផ្នែក ព្រះរាជធានីក្រុងភ្នំពេញ ផ្លាស់ទេសភាពនឹងលំអប្លែកលើសធម្មតា ហើយនៅទីព្រះសក្យមុនីចេតិយដែលជាទីប្រជុំបុណ្យធំនោះសោតក៏រុងរឿងដោយគ្រឿងសក្ការបូជា ជាអនេកព្រមទាំងកុះករឈ្មួសដោយមនុស្សមនាមហាជននឹងពុទ្ធបរិស័ទច្រើនម៉ឺនរូបទាំងបព្វជិតទាំងគ្រហស្ថ ដែលនិមន្ត-អញ្ជើញអំពីគ្រប់ទិសានុទិសក្នុងកម្ពុជរដ្ឋទាំងមូលនឹងអំពីប្រទេសនានាមកធ្វើទានធ្វើកិច្ចនមស្ការបូជាគារវៈ សូត្រធម៌ ស្តាប់ធម៌ទេសនា នឹងបាឋកថា ដោយជ្រះថ្លាចំពោះបុណ្យពាក់កណ្តាលសាសនាផង បុណ្យបញ្ចុះព្រះបរមសារីរិកធាតុផង ។

របៀបបុណ្យនេះ សឹងមានបែងក្នុងកម្មវិធីសព្វគ្រប់ស្រាប់ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធសាសនបណ្ឌិត្យមានអំណរមហិមាចំពោះការបុណ្យពាក់កណ្ដាលសាសនា នឹងបុណ្យឆ្លងព្រះសក្យមុនីចេតិយនេះ ។ ដើម្បីជាកស្តុតាងនៃអំណរនឹងជាទីរលឹកដល់ថ្ងៃបុណ្យទាំង២ផ្នែកនេះ អ្នកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យបានសុំអស់លោកនិពន្ធបណ្ឌិត ដូចមាននាមខាងមុខឲ្យរៀបរៀងចាត់ការបោះពុម្ពសៀវភៅនេះ ចែកផ្សាយជាធម្មបណ្ណាការ ដើម្បីឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យរុងរឿងតទៅ ។

សមាសភាពនៃនិពន្ធបណ្ឌិត នឹងអត្ថបទ :

១– ឧត្តមប្រជា ចាប-ពិន អារម្ភកថា, ពុទ្ធប្រវត្តិ, ការបោះពុម្ពព្រះត្រៃបិដកនៅប្រទេសខ្មែរ;

២– ព្រះមហា ប៉ាង-ខាត់ ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ;

៣– ព្រះឧបាលិវង្ស សូរ-ហាយ សិល្បៈពុទ្ធសាសនា;

៤– ព្រះញាណវីរិយៈ ប៉ន់-សាខុំ វប្បធម៌ពុទ្ធសាសនា;

៥– ព្រះមហា អ៊ុក អ៊ឹន សទ្ធម្មប្បជ្ជោត;

៦– ព្រះទេពសត្ថា គឹម-តូរ ចិត្តដឹកនាំលោក ។

ពុទ្ធសាសនបណ្ឌិត្យ សូមបង្អោនកុសលដែលកើតអំពីការព្យាយាមរៀបរៀងសៀវភៅនេះ ជាព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្ដេចព្រះមហាក្សត្រិយានី សូមទ្រង់គង់នៅជាបរមសុខក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែង ។

សូមថ្វាយកុសលដ៏ប្រសើរនេះ ជាព្រះរាជកុសលចំពោះសម្ដេចព្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បយុវជន បិតាឯករាជ្យជាតិ សូមទ្រង់បានប្រកបដោយបវរសុខសួស្តី ជ័យជំនះគ្រប់ប្រការជានិរន្តរ៍ ។

សូមជូនឥដ្ឋមនុញ្ញផលចំពោះរាជរដ្ឋាភិបាល សូមបានប្រកបដោយសេចក្តីសុខសេចក្តីចម្រើន ព្រមទាំងសូមឲ្យបានសម្រេចសុភកិច្ចគ្រប់យ៉ាងផង ។

សូមពលរដ្ឋកម្ពុជប្រទេសបានសេចក្តីសុខសេចក្តីចម្រើន ។

សូមឯករាជ្យប្រទេសកម្ពុជាបានរុងរឿងរហូតកល្បាវសាន ។

សូមសន្តិភាពកើតមានដល់សកលលោក ។

សូមព្រះពុទ្ធសាសនារុងរឿងរីកសាយពេញពិភពលោក ។

ព. ប.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

-ព្រះសិទ្ធត្ថ(សម្មាសម្ពុទ្ធ)ទ្រង់**ចាប់ប្រតិសន្ធិ**
នៅថ្ងៃព្រហស្បតិ៍ ១៥កើត ពេញបូណ៌មី
ខែ**អាសាឍ** ឆ្នាំរការ
(ចាប់ប្រតិសន្ធិ មិនមែនខែ**ពិសាខ** ទេ)
ព្រះសិទ្ធត្ថ(សម្មាសម្ពុទ្ធ)**ទ្រង់ ប្រសូត**
នៅថ្ងៃ សុក្រ ១៥កើត ពេញបូណ៌មី
ខែ**ពិសាខ** ឆ្នាំចរ(គំរប់១០ខែគត់)

# វគ្គទី ១

## ពុទ្ធប្រវត្តិ
## អំពីទ្រង់ប្រសូត

កែតំរូវ by Mr. AP. info@angkorPost.com
ខែអាសាឍ July7(0.5 ពាក់កណ្ដាលខែ៧)
July7(0.5 )-8(1.5) 9(2.5) 10(3.5) 11(4.5)
1(6.5) 2(7.5) 3(8.5) 4(9.5) May5(10)
(ពាក់កណ្ដាលខែ៥)=10ខែគត់
(គំរប់១០ខែគត់-យើងធម្មតា ៩ខែ ១០ថ្ងៃ)

ព្រះសិទ្ធត្ថ ( សម្មាសម្ពុទ្ធ ) ទ្រង់ចាប់បដិសន្ធិនៅថ្ងៃព្រហស្បតិ៍ពេញបូណ៌មិ ខែពិសាខ ឆ្នាំរកា មុនពុទ្ធសករាជ ៨០ ឆ្នាំ ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះនាងមាយាទេវី ព្រះរាជានៃសក្យវង្ស គ្រងក្រុងកបិលពស្តុ ដែនសក្កៈ គឺប្រទេសនេប៉ាល់សព្វថ្ងៃ ទ្រង់ប្រសូតនៅថ្ងៃសុក្រ ពេញបូណ៌មីខែពិសាខ ឆ្នាំច នាលុម្ពិនីវ័នឧទ្យាន ដែលបិតនៅក្នុងអាណាខេត្តនៃប្រទេសនេប៉ាល់ ជិតព្រំប្រទល់នេប៉ាល់ និងឥណ្ឌា សម័យបច្ចុប្បន្ន ។



ការប្រសូតនៃព្រះសិទ្ធត្ថកើតមានឡើងក្នុងពេលព្រះនាងមាយាទេវី

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជាព្រះវរមាតាទ្រង់ធ្វើដំណើរដោយរាជបរិពារ ចេញពីក្រុងកបិលពស្តុ រាជ-ធានីព្រះបាទសុទ្ធោទនៈជាព្រះស្វាមី ទៅកាន់ក្រុងទេវទហៈព្រះរាជធានីព្រះរាជបិតារបស់ព្រះនាង ។ កាលព្រះនាងយាងដល់លុម្ពិនីវ័ន ត្រង់ព្រំដែនកបិលពស្តុនឹងទេវទហៈ, វេលាថ្ងៃត្រង់ជាក់ ព្រះនាងក៏ប្រសូតព្រះរាជបុត្រពិសិដ្ឋ គឺ «ព្រះសិទ្ធត្ថ» ក្រោមដើមសាលព្រឹក្ស ១ ដើម ។

ក្នុងពុទ្ធសករាជ ២៩៣ មុនគ្រិស្តសករាជ ២៥០ ឆ្នាំ ព្រះបាទអសោករាជាធិរាជប្រទេសឥណ្ឌា បានទ្រង់ស្តេចយាងទៅកាន់លុម្ពិនីវ័ន ទ្រង់បានចារឹកសសរថ្ម ១ កំពស់ប្រមាណ ១០ ម៉ែត្រទុកជាទីសំគាល់នៅទីប្រសូតនៃព្រះសក្យមុនីសម្ពុទ្ធ ជាពុទ្ធបូជនីយដ្ឋានទី ១ សម្រាប់ពុទ្ធបូជនីយសក៍នានាធ្វើពុទ្ធបូជា ។

## អំពីទ្រង់បានត្រាស់ដឹង

កាលព្រះសិទ្ធត្ថរាជកុមារមានវ័យចម្រើនឡើងទ្រង់សិក្សាវិជ្ជាអក្សរ-សាស្ត្រនិងវិជ្ជាយុទ្ធសាស្ត្រក្នុងសំណាក់សាស្ត្រាចារ្យនាម «វិស្វាមិត្រ» លុះមានព្រះជន្ម ១៦ ឆ្នាំ ទ្រង់បានទទួលរាជាភិសេកជាមួយនឹងព្រះនាងពិម្ពាយសោធរាដែលមានព្រះជន្មដំណាលគ្នា សោយរាជ្យជាធំលើសក្យ-វង្ស ត្រង់ក្រុងកបិលពស្តុ តំណាងព្រះបាទសុទ្ធោទនៈជាព្រះរាជបិតា នៅថ្ងៃអាទិត្យ ពេញបូណ៌មី ខែកត្តិក ឆ្នាំជូត ។ ទ្រង់សោយរាជ្យបាន ១៣ ឆ្នាំ ព្រះជន្ម២៩ ឆ្នាំ បានព្រះរាជបុត្រ ១ ព្រះអង្គព្រះនាម «រាហុល» ហើយទ្រង់ចេញទៅទ្រង់ព្រះផ្នួសក្នុងថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអស្សុជ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ឆ្នាំថោះ នាឆ្នេរស្ទឹងអនោមា នៅថ្ងៃដែលព្រះរាជបុត្រទ្រង់ប្រសូតនោះ, ព្រះអង្គទ្រង់ព្រះផ្នួសហើយទ្រង់ស្វែងរកមោក្ខធម៌ដោយការប្រព្រឹត្តទុក្ករកិរិយាអត្តកិលមថានុយោគ ដើម្បីពិសោធរកពោធិញ្ញាណ អស់ចិរវេលា ៦ឆ្នាំ ក្នុងទុរុវេលាប្រទេស មគធរដ្ឋ ។ ក្រោយពេលទ្រង់លះការប្រព្រឹត្តទុក្ករកិរិយាចេញហើយបែរមកបំពេញមជ្ឈិមាបដិបទាវិញ ទ្រង់បាន



ត្រាស់ជាព្រះសព្វញ្ញុពុទ្ធប្រាកដឡើងក្នុងលោក នៅថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរក មុនពុទ្ធសករាជ ៤៥ ឆ្នាំ ក្រោមពោធិព្រឹក្ស ១ ដើម នៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ខាងលិចស្ទឹងនេរញ្ជរា នាមណ្ឌលគយា ដែលសព្វថ្ងៃហៅ «ពុទ្ធគយា» ឋិតនៅចម្ងាយជាង ១០ គីឡូម៉ែត្រ ខាងត្បូងក្រុងគយា ក្នុងរដ្ឋពិហារ ប្រទេសឥណ្ឌា ។

ពុទ្ធគយាជាពុទ្ធបូជនីយដ្ឋានទី ២ សម្រាប់ពុទ្ធបូជនីយេសក៍នានាធ្វើពុទ្ធបូជា ដែលសកលលោកស្គាល់បានដោយសារព្រះបាទអសោកពជាធិរាជទ្រង់បានសាងព្រះចេតិយ ១ ធំខ្ពស់ហៅ «ចេតិយពុទ្ធគយា» និងចេតិយតូចៗ ជាច្រើន នៅមានដល់សព្វថ្ងៃ ។

ក្រោយពុទ្ធបរិនិព្វាន, ពុទ្ធបរិស័ទបានសាងវិហារជាច្រើននៅទីទ្រង់ត្រាស់ដឹងនោះ, តែវិហារទាំងនោះបាក់បែកអស់ទៅហើយ, នៅសល់តែវិហារ ១ មានព្រះពុទ្ធរូបមារវិជ័យ១ព្រះអង្គធំ លាបទឹកមាស ទ្រង់ព្រះភក្ត្រ ព្រះហស្តស្តាំចង្អុលផែនដី ជាកស្តុតាងចំពោះកិច្ចដែលព្រះសម្ពុទ្ធទ្រង់ឈ្នះមារហើយទ្រង់ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ។

សព្វថ្ងៃទីពុទ្ធគយាមានដើមពោធិ៍១ ដើមថ្មីដុះចេញពីដើមពោធិ៍ចាស់ដែលក្រៀមទៅហើយ ។

ក្នុងបច្ចុប្បន្នកាល ទីពុទ្ធគយាជាទីប្រជុំគណៈកម្មការទីប្រឹក្សាខាងព្រះពុទ្ធសាសនា ដែលប្រទេសនានាជាប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងសកលលោកមានប្រទេសកម្ពុជាយើងជាដើម បានបញ្ជូនប្រតិភូទៅរួមប្រជុំផង ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អំពីទ្រង់សំដែងព្រះធម្មចក្ក

បន្ទាប់ពីទ្រង់បានត្រាស់ដឹង ព្រះសម្មាសម្ពុទ្ធទ្រង់ពិចារណាអនុត្តរធម៌ និងនិស្ស័យសត្វនៅសត្តមហាឋានមានរតនបល្ល័ង្កជាដើម អស់ថិរវេលា ៧ ថ្ងៃ ៧ដង ( ជា ៤៩ ថ្ងៃ ) រួចហើយទ្រង់ស្តេចយាងទៅគង់នៅអជបាលនិគ្រោធ ៧ ថ្ងៃទៀត (រួមជា ៥៦ ថ្ងៃ) បន្ទាប់មកស្តេចយាងនៅថ្ងៃសៅរ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំរក ទៅសំដែងព្រះធម្មចក្កបឋមទេសនាពណ៌នា



អំពីទុក្ខទាំង ១៣ កង, អំពីហេតុឲ្យកើតទុក្ខគឺតណ្ហា, អំពីទីរលត់ទុក្ខគឺព្រះនិព្វាន និងអំពីមធ្យោបាយដើម្បីរលត់ទុក្ខ គឺមគ្គប្រកបដោយអង្គ ៨ (ចតុ-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ភាយសច្ច) ប្រោសបញ្ចវគ្គិយភិក្ខុ (មានគ្នា ៥ នាក់) នៅឥសិបតនៈមិគទាយវ័ន ។ សព្វថ្ងៃព្រៃនេះទៅជាទីពិសេស ១ ហៅ «សារនាថ» នៅចម្ងាយ ១០ គីឡូម៉ែត្រពីស្ថានីអយស្ម័យយានក្រុងពារាណសី ដែលសព្វថ្ងៃ ហៅ «បេណារេស» ។

គេបានពូនដីខ្ពស់ជាព្រះស្តូប ១ ហៅ «ចៅខាន់ស្តូប» ត្រង់ទីដែលព្រះសម្មាសម្ពុទ្ធទ្រង់ជួបនឹងបញ្ចវគ្គិយភិក្ខុជាដំបូង ។ ស្តូបនោះនៅខាងត្បូងបន្តិចពីមិគទាយវ័ន ។

ទីទ្រង់សំដែងព្រះធម្មចក្កជាពុទ្ធបូជនីយដ្ឋានទី ៣ ព្រះបាទអសោករាជាធិរាជទ្រង់បានសាងព្រះស្តូប ១ ត្រង់ទីនោះហៅ «ធម្មេយស្តូប» ហើយនៅជិតព្រះស្តូបនោះទ្រង់បានសាងសសរថ្ម ១ ចារឹកអក្សរជាគ្រឿងសំគាល់ នៅកំពូលសសរថ្មនោះមានរូបសឹង្ហមុខ ៤ ឈរទល់ខ្នងគ្នាបែរមុខទៅទិសទាំង ៤ ក្រោមជើងសឹង្ហមានរូបកង់ចក្រ, ឥឡូវរូបសឹង្ហ នឹងរូបកង់ចក្រនោះ គេយកទៅដាក់ទុកនាភណ្ឌទិកេតសារនាថ, សព្វថ្ងៃរដ្ឋាភិបាលឥណ្ឌាបានចម្លងរូបសឹង្ហ នឹងកង់ចក្រនោះធ្វើជាទង់ជាតិ នឹងជារូបត្រាឥណ្ឌា ជានិមិត្តរូបបង្ហាញសកលលោកឲ្យឃើញថា ការកសាងឯករាជ្យប្រទេសឥណ្ឌា គឺយកតម្រាប់តាមគោលច្បាប់ព្រះពុទ្ធសាសនា ។

សម័យបុរាណ ទីសំដែងព្រះធម្មចក្កមានវត្តអារាមនឹងព្រះស្តូបជាច្រើនដែលពុទ្ធបរិស័ទកសាង តែបែកបាក់អស់ទៅហើយ, សម័យបច្ចុប្បន្ន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នៅមានតែធម្មេក្ខស្តូបដូចពណ៌នាខាងដើម ដែលព្រះបាទអសោកទ្រង់សាងក្នុងពុទ្ធសតវត្សរ៍ទី ៣ ហើយនឹងមូលគន្ធកុដិមហាវិហារ ដែលអនាគារិកធម្មបាលបណ្ឌិតជាតិលង្កាទ្វីបកសាងក្នុងរវាងពុទ្ធសតវត្សរ៍ ២៥ គ្រិស្តសតវត្សរ៍ទី ២០ ជាពុទ្ធបូជនីយដ្ឋានសម្រាប់ពុទ្ធបូជនីយេសក៍នានាគោរពបូជា និងកុដិលំនៅព្រះសង្ឃសព្វថ្ងៃនេះ ។

## អំពីទ្រង់បរិនិព្វាន

លំដាប់ពីទ្រង់សំដែងព្រះធម្មចក្កមក, ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាច់ចរប្រកាសសាសនាប្រោសវេនេយ្យសត្វ ដោយទ្រង់ប្រព្រឹត្តពុទ្ធកិច្ច ៥ យ៉ាង គឺ ១- ពេលព្រឹកទ្រង់ត្រាច់បិណ្ឌបាត, ២- ពេលរសៀលទ្រង់សំ-ដែងធម៌ប្រោសចតុព្វិធពុទ្ធបរិស័ទ, ៣- ពេលព្រលប់ទ្រង់ប្រទានឱវាទពួកភិក្ខុ, ៤- ពេលអធ្រាត្រទ្រង់ដោះបញ្ហានៃទេវតា, ៥- ពេលបែកបច្ចូសទ្រង់ប្រមើលមើលឧបនិស្ស័យសត្វដែលគួរប្រោស ឬមិនគួរប្រោសនៅក្នុងមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌាអស់វេលា ៤៥ ឆ្នាំ គឺចាប់ផ្តើមប្រកាសពីព្រះជន្ម ៣៥ រហូតដល់ព្រះជន្ម ៨០ ត្រាតែមានពុទ្ធបរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា គ្រប់គ្រាន់ អាចទ្រទ្រង់អាចផ្សាយព្រះពុទ្ធ-សាសនាជំនួសព្រះអង្គតមកបាន ទើបទ្រង់ស្តេចយាងទៅចូលព្រះនិព្វាន នៅថ្ងៃអង្គារ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ មុនពុទ្ធសករាជ ១ ថ្ងៃ ក្រោមដើមសាលព្រឹក្សទាំងគូ នៅខាងលិចក្រុងកុសិនារា គឺកុសិនគរៈ ឬកសៀ ដែលឋិតនៅចម្ងាយ ៩ គីឡូម៉ែត្រពីក្រុងគោរក្ខបុរ នៅរដ្ឋឧត្តរប្រទេស នាប្រទេសឥណ្ឌាសម័យបច្ចុប្បន្ន ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com





ព្រះបរមសពនៃព្រះសម្មាសម្ពុទ្ធ ពុទ្ធបរិស័ទបានបូជាព្រះភ្លើង ក្នុងថ្ងៃពុធ ៨ កើត ខែពិសាខ ឆ្នាំម្សាញ់ នៅមកុដពន្ធនៈចេតិយ ឬអង្គារៈចេតិយ ខាងកើតក្រុងកុសិនគរៈ គឺរាមភារៈចេតិយសព្វថ្ងៃ ។ ក្រោយពេលបូជាគេបានបែងចែកព្រះបរមសារីរិកធាតុជា ៨ ចំណែក រវាងព្រះរាជា ៨ រដ្ឋ នាមធ្យមប្រទេសសម័យនោះ ។

ក្នុងសម័យពុទ្ធបរិនិព្វាន កុសិនគរៈជាទីក្រុងមានប្រាសាទព្រះស្តូបពុទ្ធបូជនីយដ្ឋានជាច្រើន, សម័យបច្ចុប្បន្នដោយហេតុគេបោះបង់ទីក្រុងចោល ពុទ្ធបូជនីយដ្ឋាននៅទីក្រុងនោះក៏បាក់បែកអស់ នៅមានតែមហាបរិនិព្វានស្តូប ១ នឹងព្រះវិហារ១ ដំកល់ព្រះពុទ្ធរូបបរិនិព្វាន ១ ព្រះអង្គធំ ៗ ទីទ្រង់បរិនិព្វានជាពុទ្ធបូជនីយដ្ឋានទី ៤ សម្រាប់ពុទ្ធបូជនីយេសក៏ធ្វើពុទ្ធបូជា ។

ឧត្តមប្រីជា ចាប-ពិន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# វគ្គទី ២

## ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ប្រទេសខ្មែរបានទទួលអរិយធម៌ឥណ្ឌាទុកជាមត៌ក តាំងពីបុរាណ-កាល, សាសនាព្រាហ្មណ៍ក្តី ពុទ្ធសាសនាក្តី ដែលបានមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ក៏ក្លាយទៅជាអរិយធម៌សម្រាប់ប្រទេស ប្រជាជនខ្មែរបានរក្សាអរិយធម៌នោះទុកជាប្រពៃណីដោយប្រពៃ តពូជពង្សរៀងរាបរហូតមកដល់បច្ចុប្បន្នកាល ។ ដើមឡើយ, បុព្វជនខ្មែរ ក៏ដូចជាបុព្វជននៃមនុស្សទាំងឡាយលើពិភពលោកសម័យមុនប្រវត្តិសាស្ត្រដែរ តែងតែគោរពលោកធាតុគឺ ទឹក ដី ភ្លើង ខ្យល់ អារក្ស ទេពារក្ស ព្រះធរណី ព្រះពាយ យកឈើព្រៃភ្នំក្រំថ្មជាទីពឹងទីរឭកសម្រាប់បង្ក្រាបភ័យតក់ស្លុត ដូចយើងបានឃើញការលៀងអារក្សជាទំនៀមយើងក្នុងកាលសព្វថ្ងៃនេះ សម (១)
នឹងពុទ្ធភាសិតថា :—

« មនុស្សទាំងឡាយច្រើន ដែលត្រូវភ័យគម្រាមហើយ តែងយកភ្នំ ព្រៃ អារាម ឈើ ចេតិយជាទីពឹងទីរឭក » ។

សម័យតមក ប្រជាជនខ្មែរស្រាលជ្រើសយកសាសនាតែមួយដែលខ្លួនយល់ឃើញថាជាសរណៈឧត្តម អាចបង្ក្រាបភ័យតក់ស្លុតបាន អាចសម្រេចសេចក្តីប្រាថ្នានឹងសេចក្តីសង្ឃឹមបានព្រមទាំងអាចបញ្ជាក់នូវសេចក្តីទុកចិត្តរបស់ខ្លួនទៅអនាគតបានផង (២) សមដូចពុទ្ធភាសិតថា :—

---

១-២- ធម្មបទ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



«អ្នកណា បានដល់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃ
ទុកជាទីពឹងទីរឭក បានឃើញច្បាស់នូវអរិយសច្ច
ទាំង៤ដោយប្រាជ្ញាប្រពៃ គឺទុក្ខសច្ច១
សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ចមាន
អង្គ ៨ ជាដំណើរទៅកាន់ការម្ងាប់ទុក្ខ១
នុះឯងជាសរណៈក្សេម នុះឯងជាសរណៈឧត្តម
អ្នកនោះ ទើបរួចចាកទុក្ខទាំងពួងបាន ព្រោះ
អាស្រ័យនូវសរណៈឧត្តមនេះ» ។

ពុទ្ធសាសនាបានទូន្មានអប់រំប្រជាជនខ្មែរ ហើយបង្រៀនឲ្យចេះប្រើជីវិតស៊ូយកឈ្នះនូវជំនឿកុតនិយមនៃបុព្វជន ត្រាតែរសព្រះធម៌ជ្រួតជ្រាបក្នុងសាច់ឈាមនឹងជីវិតចិត្តថ្លើមរៀងរាល់ថ្ងៃ ។ តាំងពីបានចូលមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ព្រះពុទ្ធសាសនាក៏បានតាំងនៅស៊ប់ឥតសាបសូន្យទៅក្នុងវេលាណាមួយឡើយ គ្រាន់តែមិនបានចេញឈ្មោះជាផ្លូវការ ឬមិនបានទទួលក្តីគ្រោសប្រោណពីរាជសំណាក់ ក្នុងកាលខ្លះប៉ុណ្ណោះ ហើយផ្សាយឥទ្ធិពលទៅលើសិល្បៈនិងអក្សរសាស្ត្រខ្មែរទៀត ។ ក្នុងសម័យអាប់ឱន ព្រះពុទ្ធសាសនាអាចជ្រកជ្រៀតនៅជាមួយសាសនាព្រាហ្មណ៍បាន ហើយបិតថេរចីរកាលនៅរហូតមក ដូចប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរបង្ហាញឲ្យឃើញស្រាប់ ។

ប្រភពផ្សាយពុទ្ធសាសនាចូលមកប្រទេសខ្មែរ – ក្រោយ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធបរិនិព្វានទៅប្រមាណជា ២១៨ឆ្នាំ មានព្រះរាជាមួយអង្គព្រះនាម ព្រះបាទធម្មាសោកមហារាជ បានឡើងសោយរាជ្យក្នុងព្រះរាជធានីបាតលិ-បុត្តនៃមគធរដ្ឋ ។ ព្រះរាជាអង្គនេះ ប្រកបដោយឫទ្ធានុភាពច្រើន ផ្សាយតេជានុភាពទៅពេញប្រទេសឥណ្ឌា ។ ទ្រង់បានចូលកាន់ពុទ្ធសាសនា ហើយបានជាព្រះរាជូបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ព.ស. ២៣៤ ។ លុះធ្វើតតិយសង្គាយនាហើយ ទ្រង់បានបញ្ជូនសមណទូតទៅកាន់បច្ចន្តប្ប-ទេសនានាផុតពីដែនដីមជ្ឈិមប្រទេសមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា ។ ការបញ្ជូនសមណទូតទៅប្រកាសពុទ្ធសាសនានៅប្រទេសនានាគ្រានេះ ឈ្មោះថាទ្រង់បានបើកទ្វារទាំងសកលលោក ហើយបំភ្លឺឲ្យប្រជានិករបាន ស្គាល់ពុទ្ធសាសនាតាំងពីកាលនោះមក ។ ក្នុងបច្ចុប្បន្នកាលនេះ ពិភពលោកទាំងមូលបានទទួលស្គាល់ពុទ្ធសាសនាហើយ នៅទ្វីបអឺរ៉ុបក្តី ទ្វីបអា-មេរិកក្តី ទ្វីបអាហ្វ្រិកក្តី ស្ទើរតែមិនមានទីចន្លោះ មានជនានុជនចូលកាន់សាសនាពុទ្ធគេនកាន់តែកើនច្រើនឡើងហើយ ឥឡូវនេះ មានទីឋានណាមួយដែលមិនស្គាល់ពុទ្ធសាសនា ? ឃើញថាបានលទ្ធផលសមតាមព្រះរាជបំណងព្រះអង្គមែន ។

យើងបានដឹងតាមប្រភពកោះសិរីលង្កាថា ក្រោយកាលធ្វើតតិយ-សង្គាយនា ព្រះមោគ្គលិបុត្តតិស្សត្ថេរបានបញ្ជូនព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរមកកាន់សុវណ្ណភូមិ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទធម្មាសោកមហារាជ ដូចសេចក្តីក្នុងគម្ពីរបឋមសមន្តប្បាសាទិកាចែងទុកថា :

---

១– ត្រង់ពាហិរនិទានវណ្ណនា, មហាវង្ស ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



« ធ្វើតតិយសង្គាយនារួចហើយ ព្រះមោគ្គលីបុត្ត-តិស្សត្ថេរត្រិះរិះថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃក្នុងទីឋានណាហ្ន៎? ព្រះមហាថេរត្រិះរិះហើយឃើញថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃក្នុងបច្ចន្តប្បទេសទាំងឡាយ ស្រេចហើយព្រះមហាថេរក៏បានបញ្ជូនភិក្ខុទាំងឡាយជាសមណទូតកាន់ទីនោះ ៗ »

| | អតីតនាម | បច្ចុប្បន្ននាម(១) | |
|---|---|---|---|
| ១–ព្រះមជ្ឈន្តិកត្ថេរ | ទៅ កស្មិរៈ គន្ធារៈ | កស្មិរៈ គន្ធារៈ | |
| ២–ព្រះមហាទេវត្ថេរ | ទៅ មហិសមណ្ឌល | ខេត្តម៉ៃសោរ | (Mysore) |
| ៣–ព្រះរក្ខិតត្ថេរ | ទៅ វនវាសីប្រទេស | ខាងឧត្តរទិសនៃខេត្តកន្នរៈ | (Kannara) |
| ៤–ព្រះយោនកធម្មរក្ខិតត្ថេរ | ទៅ អបរន្តប្បទេស | ខេត្តគុជរាត | (Gujrat) |
| ៥–ព្រះមហាធម្មរក្ខិតត្ថេរ | ទៅ មហារដ្ឋ | ខេត្តមរាថេ | (Marathe) |
| ៦–ព្រះមហារក្ខិតត្ថេរ | ទៅ យោនកប្បទេស | អាណាចក្រក្រិក | (ទិសពាយព្យឥណ្ឌា) |
| ៧–ព្រះមជ្ឈិមត្ថេរ | ទៅ ហិមវន្តប្បទេស | តំបន់ហិមាល័យខាងឧត្តរទិស | |
| ៨–ព្រះមហាមហិន្ទត្ថេរ | ទៅ តាម្ពបណ្ណិ | កោះសិរីលង្កា | |
| ៩–ព្រះសោណកត្ថេរឧត្តរត្ថេរ | ទៅ សុវណ្ណភូមិ | សុវណ្ណភូមិ | (អាស៊ីភាគអាគ្នេយ៍) |

ដទៃពីប្រភពកោះសិរីលង្កាដែលបានពោលមកនេះ មានសិលាចារឹកព្រះរាជប្រកាសនៃព្រះបាទធម្មាសោកមហារាជច្រើនកន្លែងទៀត ខ្លះនៅក្នុងប្រទេសឥណ្ឌា ខ្លះទៀតនៅក្រៅប្រទេសឥណ្ឌា ដែលទ្រង់ព្រះរាជបញ្ជាឲ្យដំកល់ទុកក្នុងទីឋាននានាដែលព្រះអង្គផ្សាយពុទ្ធសាសនាទៅដល់ៗ

១ - J. Filliozat, L'Inde classique, T. II, P. 499.- P. Bapat, 2500 years of Buddhism, P. 59. - L. Finot. Le Buddhisme, Edition de l'Institut Bouddhique, Phnom-Penh.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



(១)

ខ្ញុំដកស្រង់ព្រះរាជប្រកាសទាំងនោះចំពោះតែគោលៗខ្លះ យកមកទុកក្នុងទីនេះសម្រាប់ប្រដាប់ការបេះដូងរបស់យើង ព្រោះប្រកពទាំងនេះអ្នកប្រាជ្ញទាំងឡាយតែងអះអាងថាជាសេចក្ដីពិតគួរជឿបានដូចតទៅនេះ ៖

«ក្រោយរាជាភិសេក ទ្រង់បានធ្វើសង្គ្រាមមានជ័យនៅកលិង្គរដ្ឋ ចាប់ឈ្លើយបាន ១៥០.០០០ នាក់ សម្លាប់ចោលអស់ ១០០.០០០ នាក់ស្លាប់ក្នុងសមរភូមិច្រើនអនេកទៅទៀត (ព្រោះតែមានទមហន្តភ័យនៃសង្គ្រាមនេះហើយ) តមក, ទ្រង់មិនលះបង់ការប្រតិបត្តិធម៌និងការផ្សាយព្រះធម៌ឡើយ (ព្រះរាជប្រកាសលេខ ១៣) ៗ ជ័យព្រះអង្គគឺធម្មវិជ័យ (ព្រះរាជប្រកាសលេខ ៤) ធម្មវិជ័យនេះដែលទ្រង់ឈ្នះក្នុងទីនេះ និងទីឆ្ងាយទៅទៀតដល់ ៦០០ យោជន៍(ព្រះរាជប្រកាសលេខ ១៣) ៗ នៅក្នុងព្រះរាជអាណាចក្រព្រះអង្គនិងប្រទេសជិតខាង ព្រះរាជប្រកាសព្រះអង្គ (ព្រះរាជប្រកាសលេខ ១៣) បានប្រាប់ឈ្មោះទីឋានតទៅនេះគឺ យោន-កៈ ឬ យវនៈ, កម្ពោជៈ, បាណ្ឌ្យៈ, ចោលៈ, បេរៈ, បុលិណ្ឌៈ និងតាម្ពបណ្ណិ (កោះសិរីលង្កា) ។ល។ ឆ្ងាយទៅទៀត, ព្រះរាជប្រកាសព្រះអង្គមានប្រាប់នាមព្រះបាទអន្តិយកៈ ឬ អន្តិយោកៈ (ព្រះរាជប្រកាសលេខ ២) និងព្រះរាជា ៤ អង្គទៀតគឺ តុរមាយៈ ឬ តុរមេយៈ ១, ព្រះបាទអន្តិកិនិ ឬ អន្តិកិនៈ ១, ព្រះបាទមកៈ ឬ មកៈ ១, ព្រះបាទអលិកសុន្ទរៈ

---

១- J. Filliozat, L'Inde classique, T. I. P. 218-219, T. II. P. 499.- P. Bapat. 2500 years of Buddhism. P. 59.— L. Finot, Le Bouddhisme, Edition de l'Institut Bouddhique Phnom-Penh

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ឬ អលិកសុទរៈ, ឬអលិកសន្ទ្រ១, (ព្រះរាជប្រកាសលេខ ១៣) ឈ្មោះទីបាទទឹងនាមព្រះរាជាទាំងនេះសរសេរអក្សរប្លែក ៗ គ្នាខ្លះ ៗ អ្នកប្រាជ្ញបុរាណបានស្រាវជ្រាវគេឃើញថា :

១– ព្រះបាទអន្តិយកៈនោះគឺ ព្រះបាទអន្តិយោកុស Antiochus Ier Soter (២៨០-២៦១ មុនគ្រឹស្តសករាជ) ឬអន្តិយោកុសទី ២Antiochus II Theos (២៦១-២៤៦ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសស៊ីរី (Syrie) ។

២– ព្រះបាទតុរមេយៈ គឺព្រះបាទបុតូឡេម៉េ Ptolémée Philadelphe (២៨៥-២៤៧មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសអេហ្ស៊ីប(Egypte) ។

៣–ព្រះបាទអន្តកិនិ គឺព្រះបាទអន្តិគោន Autigone (២៧៨-២៣៩ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសក្រិក ម៉ាសេដ្វាន(Macedoine) ។

៤– ព្រះបាទមគៈ គឺព្រះបាទមគ័ស Magas (៣០០-២៥៨ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសស៊ីរែន (Cyrène) ជាប្រទេសចំណុះក្រិកឋិតនៅខាងលិចប្រទេសអេហ្ស៊ីប ទ្វីបអាហ្វ្រិក ។

៥– ព្រះបាទអលិកសុន្ទរៈ គឺព្រះបាទអាឡេកសង់ដ្រ៍ Alexandre (២៧២.២៥៨ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសអេពីរ (Epire) ឬអាឡេកសង់ដ្រ៍ (២៥២-២៤៤ មុនគ្រឹស្តសករាជ) ជាព្រះរាជានៃប្រទេសកោរិន្ធ (Corinthe). ។

ក្នុងព្រះរាជប្រកាសព្រះបាទធម្មាសោកមហារាជ មិនឃើញមានគត់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ត្រា ឈ្មោះសុវណ្ណភូមិក្នុងព្រះរាជប្រកាសព្រះអង្គដូចប្រកតកោះសិរីលង្កាទេ គ្រាន់តែមានសេចក្ដីបញ្ជាក់ថា ទ្រង់បានផ្សាយពុទ្ធសាសនាទៅគ្រប់ទិសានុទិស ។ ដោយស្នាព្រហស្តព្រះអង្គនឹងព្រះរាជាអង្គខ្លះទៀតដូចព្រះបាទកនិស្កៈជាដើម ព្រះពុទ្ធសាសនាផ្សាយទៅខាងបច្ចិមទិសដល់រាជអាណាចក្រក្រិក ខាងឧត្តរដល់ទ្វីបអាហ្វ្រិក ខាងអាស៊ីភាគកណ្ដាលដល់ប្រទេសចិន, ម៉ុងគោលី, កូរេ, ជប៉ុន, ខាងឧត្តរទិសដល់ប្រទេសទីបេត៍, ខាងទក្ខិណទិសដល់កោះសិរីលង្កា ហួសឆ្ងាយទៅទៀតដល់សុវណ្ណភូមិ ។

សេចក្ដីដូចបានពោលរៀបរាប់មកហើយប៉ុណ្ណេះ យើងជឿជាក់ថា ព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ ជាសមណទូតនាំពុទ្ធសាសនាមកដល់សុវណ្ណភូមិកាលពីពុទ្ធសតវត្សទី ៣ ពិតមែនហើយ ដូចសេចក្ដីដែលមានចែងទុកក្នុងប្រកតកោះសិរីលង្កាស្រាប់ តែពិបាកនឹងកំណត់ឲ្យទៀងទាត់ថា ដែនដីចន្លោះប្រទេសឥណ្ឌៀនឹងប្រទេសចិននេះ ទីឋានត្រង់ណាជាសុវណ្ណភូមិ ដែលព្រះថេរៈទាំងពីរអង្គមកតាំងមណ្ឌលផ្សាយពុទ្ធ-សាសនុះ ? នឹងថានៅប្រទេសភូមាក៏នៅមានការជជែកគ្នា នឹងថានៅប្រទេសសៀមក៏មិនសមហេតុផលគ្រប់គ្រាន់ ឬ នឹងថានៅប្រទេសណាក៏មិនប្រាកដដែរ ព្រោះជាហេតុការណ៍ដែលមានមកមុនប្រវត្តិកាលនៃប្រទេសទាំងឡាយដែលមានក្នុងភូមិភាគនេះទាំងអស់ទៅទៀត ។ បណ្ដាប្រទេសទាំងឡាយដែលកាន់ពុទ្ធសាសនាថេរវាទនៅក្នុងភូមិភាគនេះទាំងអស់ ប្រទេសនីមួយ ៗ ក៏បានទុករឿងព្រះថេរៈទាំងពីរអង្គនឹងសុវណ្ណ-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ភូមិនេះជាប្រពៃណីបុរាណរបស់ប្រទេសរៀងខ្លួន ហើយអះអាងគ្រប់គ្នាថា តាំងនៅក្នុងដែនដីតែរៀងខ្លួនទៀត ដូចសេចក្ដីដែលលោក ប៉. ឌុយប៉ុង សរសេរថាៈ(១)

«ប្រពៃណីប្រទេសភូមាទីងសិលាចារឹកពីគ្រឹស្តសតវត្សទី១៥ បានពោលអះអាងថា ព្រះបាទធម្មាសោកមហារាជបានបញ្ជូនសមណទូតមកកាន់ប្រទេសភូមា៣លើកពីពុទ្ធសតវត្សទី ៣ តែចំនួនទីងនាមសមណទូតមានតែពីរអង្គដូចប្រកពកោះសិរីលង្កាដែរ ។ ឯប្រវត្តិដែលនិយាយពីព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរនិមន្តមកកាន់សុវណ្ណភូមិនេះ ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទនៅអាស៊ីអាគ្នេយ៍បានដឹងទាំងអស់គ្នា ជាអាទ៍ដូចប្រទេសសៀមហ៊ានទាំងពោលថា ប្រវត្តិសោណត្ថេរនឹងឧត្តរត្ថេរនេះជាប្រវត្តិប្រទេសខ្លួន ហើយតាំងនៅក្នុងប្រទេសខ្លួនថែមទៀតផង; រឿងរ៉ាវព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរទាំងពីរអង្គនេះ មានការបរិច្ឆេទចំនេងជាមិនពិតត្រឹមត្រូវទេ តែគេក្រឡុកថាជាប្រពៃណីសមណទូតពុទ្ធ-សាសនាដែលមានមកដល់ឥណ្ឌូចិនបច្ចិមទិសភាគតាំងពីបុរាណកាល„ ។

រឿងរ៉ាវសុវណ្ណភូមិ ជារឿងដែលយើងគួរតែចង់ចេះដឹងណាស់ ហើយយើងគប្បីតែស្រាវជ្រាវរកឲ្យឃើញសម្រាប់ប្រដាប់ការចេះដឹង ព្រោះជារឿងដែលទាក់ទងនឹងប្រទេសយើងដោយចំពោះ ។

---

១ - P. Dupont, La propagation du Bouddhisme indien d'Extrême-Orient. P. 48—49 (Bulletin de la Société des Etudes indochinoises nouvelles séries. T. XVIII 1 et 2—1er et 2ème trimestre (1943)

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តទៅ, ខ្ញុំសូមឱកាសរៀបរាប់ពីដំណើរដើមទងសុវណ្ណភូមិបន្តិចសិន សម្រាប់ប្រដាប់ការបេះដឹងរបស់យើង សឹមនិយាយពីព្រះពុទ្ធសាសនា ដែលចូលមកកាន់ប្រទេសខ្មែរយើងជាលំដាប់ ព្រោះការបេះដឹងរឿងសុវណ្ណភូមិសព្វគ្រប់ជាហេតុនាំឲ្យយើងយល់ប្រស្នាព្រះពុទ្ធសាសនា ដែលមកប្រតិស្ឋានៈទៅប្រទេសយើងដោយបរិបូណ៌ ។

ដើមទងដែលនាំឲ្យជនជាតិឥណ្ឌាមកកាន់សុវណ្ណភូមិក្នុងកាលនោះ មិនមែនហេតុអ្វីដទៃទេ គឺហេតុតែត្រូវការរកមាសជាធំ បានជាកើតពាក្យថា "សុវណ្ណភូមិ" ឡើង ៗ មែនពិត, ជនជាតិឥណ្ឌាក៏ដូចជនជាតិអឺរ៉ុបដែរ ដែលចេញទៅរកមាសនៅទ្វីបអាហ្វ្រិកខាងត្បូងក្តី ឬទៅទ្វីបអាមេរិកាវដ្ឋកាលីហ្វូរនីក្តី មិនមែនដោយផ្លូវនយោបាយជាហេតុតែប៉ុណ្ណោះទេ គឺដោយមានបំណងរកមាសជាហេតុផង ។ ភូមិប្រទេសណាមានមាស ក៏តែងមានមនុស្សធ្វើដំណើរទៅកាន់ភូមិប្រទេសនោះ ហើយឲ្យឈ្មោះទីឋាននោះ បើជាភាគផែនដីថា សុវណ្ណភូមិ បើជាកោះថា សុវណ្ណទ្វីប ហេតុនេះហើយបានជាភូមិប្រទេសយើងនេះ មានសមញ្ញាថា សុវណ្ណភូមិ ឬ សុវណ្ណទ្វីប ឬ អែលដូរ៉ាដូ( Eldorado, Chersonèse d'or )តាំងពីកាលនោះមក, មិនមែនតែមាសទេ សូម្បីតែគ្រឿងទេសតាំងឡាយដូចក្រវាញ កប្ប៉ូរ ខ្លឹមចន្ទន៍ក្រស្នា ដូចជាដើម ក៏ជនជាតិឥណ្ឌាត្រូវការដែរ បានជាមានកើតឈ្មោះថា តក្កោលៈ "ផ្កាលក់ក្រវាញ" ឈ្មោះថា កប្បុរទ្វីប "កោះកប្ប៉ូរ" ឈ្មោះនារិកេលទ្វីបឬនាឡិ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

គេរទ្វីប «កោះដូង» ជាដើមឡើង ដូចលោកសឺដែសសរសេរទុកថា:(១) —

«ការទាក់ទងជនជាតិម៉េឌីតែរ៉ាណេ នឹងជនជាតិបូព៌ាដោយសង្គ្រាមព្រះបាទអាឡេកសង់ឌ្រឺមហារាជក្តី ការកើតអាណាចក្រព្រះបាទធម្មាសោកមហារាជ តមក ព្រះបាទកនិស្កនៅប្រទេសឥណ្ឌាក្តី ការកើតអាណាចក្រពងវង្សសេឡឺស៊ីដ (Séleucide) នឹងអាណាចក្ររ៉ូមាំង (Romain) នៅទ្វីបឌុរ៉ុបក្តី ទាំងអស់នេះកើតឡើងក៏ព្រោះតែ «ភោគទ្រព្យចើត» ដែលជនជាតិឡាតាំង នឹកចង់បានហើយស្តាយតាំងពីគ្រិស្តសតវត្សទី ១ ម្លេះ ៗ ពិតហើយ, គ្រឿងទេស, ខ្លឹមច័ន្ទក្រស្នា, ក្រវាញ, កប្បូរ សុទ្ធតែជាផលិតផលដោយបំពោះនៃប្រទេស ឬកោះដែលនៅក្រៅដែនដីទន្លេគង្គា ដូចមានឈ្មោះកំពង់ពីអតីតកាលថា តក្កោលៈ (Takkola) «ផ្សារលក់ក្រវាញ», ឈ្មោះកប្បូរទ្វីប «កោះកប្បូរ», ឈ្មោះនារិកេល ឬ គេរទ្វីប «កោះដូង» ព្រមទាំងមានកំពង់ដទៃទៀតច្រើនដែលមានភូមិនាមប្រហែលៗគ្នា ទាំងនេះសំដែងឲ្យឃើញថា អត្ថប្រយោជន៍នេះហើយដែលទាញជនជាតិឥណ្ឌាឲ្យទៅកាន់ទីនោះៗ» ។

នៅក្នុងពិភពលោកត្រង់ភូមិភាគយើងនេះ មានភូមិនាមជាសំស្ក្រឹតជាមាសដូចគ្នាច្រើនណាស់ដូចលោកស៊ីលវ៉ាំងឡេវីសរសេរថា(២) «ពាក្យកនកបុរីដែលប្រែថាបុរីមាស» ក្នុងទ្វីបាន្តរៈ សំដែងឲ្យឃើញថាមាស

---

១- G. Cœdès, Histoire ancienne des Etats hindouisés Extrême-Orient, P. 23-24. ២– Sylvain Lévi, Kouen-Louen et Dvîpântara, Bijdr; 88,1631 P. 627.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នេះនាំជនជាតិឥណ្ឌាមកកាន់សុវណ្ណភូមិនឹងឥណ្ឌូណេស៊ី មិនមែនមានតែឈ្មោះ សុវណ្ណភូមិ សុវណ្ណទ្វីប ជាភស្តុតាងប៉ុណ្ណោះទេ សូម្បីតែឈ្មោះទន្លេក៏មាននាមថា «មាស»ដែរ ដូចបញ្ជាក់ផែនទីប្តូលេម៉េស្រាប់ គឺប្រាកដជាមាសនេះឯងហើយ ដែលនាំជនជាតិឥណ្ឌាឲ្យទៅអែលដូរាដូ (Eldorado) នៅបូព៌ា» ។

មិនមែនតែជនជាតិឥណ្ឌាទេដែលស្គាល់សុវណ្ណភូមិ ប្តូលេម៉េអ្នកភូមិសាស្ត្រក្រិក គ្រិស្តសតវត្សទី ២, អ្នកនិពន្ធចិនច្រើននាក់មានកាំងថៃ (K'ang t'ai) គ្រិស្តសតវត្សទី ៣ ជាដើម ក៏បានស្គាល់សុវណ្ណភូមិនេះពិតណាស់បានជាមានពាក្យហៅថា គេរសោណេសឌ័រ (Chersonèse d'or) ប្រែថា «ផែនដីមាស», ហៅថា លិន-គិន (Lin Kin) ប្រែថា «ព្រំដែនមាស ឬកំពែងមាស» ។

ជនជាតិឥណ្ឌាអ្នកស្វះស្វែងមាស ធ្វើដំណើរដោយសំពៅសមុទ្រចេញពីកំពង់ធំ ៗ នៅឆ្នេរខាងទក្ខិណទិសភាគប្រទេសឥណ្ឌា ដូចកំពង់កមរៈនៅមាត់ទន្លេកវេរិ ១ កំពង់ប៉ូឌូកេ ១ កំពង់សោបត្មៈ ១ ឬតាមកំពង់ធំមួយទៀតនៅមាត់ទន្លេគង្គាឈ្មោះតាម្រលិប្ត សព្វថ្ងៃហៅ តាម-លុក (ជាកំពង់ដែលលោកចិន ហ្វា-ហ៊ានគ្រិស្តសតវត្សទី ៥ នឹងលោកចិន យី-ត្សីងគ្រិស្តសតវត្សទី ៧ ធ្វើដំណើរត្រឡប់ទៅប្រទេសចិនវិញ) ធ្លោះទៅកាន់កំពង់តូចធំនៅឯសុវណ្ណភូមិឬ គ្រីសេ (Chrysê) របស់ប្តូលេម៉េ ឬកិមលិន-គិនរបស់ចិន ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កំពង់ចាំងឡាយពីបុរាណកាលនៅកោះក្តី នៅក្នុមិភាគដែនដីធំក្តី នៃអាស៊ីភាគអាគ្នេយ៍ដែលគេបានចូលមកដល់ ហើយគេបានស្គាល់តាមគម្ពីរទិទ្ទេស ឬ តាមបញ្ជីកងផែនទីប្តូឡេមេ ឬ តាមឯកសារចិននោះ មានដូចខាងក្រោមនេះ :

១–នៅប៉ែគូប្រទេសភូមាមានកំពង់ ៣ គឺតក្កោលៈ ១តេនសេរិម១, វេសុគ្គ ១,

២– នៅជ្រោយម៉ាឡាយូមានកំពង់ ១ ឈ្មោះតាំព្រលិង្គ:

៣– នៅកោះសូមាត្រា មានកំពង់ ១ ឈ្មោះបក្កា

៤– នៅដែនដីមាសជាត្រីសេរបស់ក្រិក (chrysé des Grecs) ឬ នៅកំពែងមាសជាលិន-គិនរបស់ចិន ។

៥– កំពង់អុក អែវ ជាកំពង់ធំនៅមាត់សមុទ្រនៃប្រទេសកម្ពុជាពីបុរាណ ។

កំពង់ឈ្មោះតេនសេរិមទីងតក្កោលៈជាកំពង់បុរាណនៅនាទីឆ្នេរនៃសមុទ្រឥណ្ឌៀ ខាងក្រោមប៉ែគូប្រទេសមន (ភូមាសព្វថ្ងៃ) មានពាណិជ ដែងចេញចូលធ្វើជំនួញក្រញ៉ាញ ។ លោកសឺដែសសរសេរថា : (១)

«កំពង់តក្កោលនេះ មានបែងកងគម្ពីរមិលិន្ទបញ្ហាហើយថាតាំងនៅត្រង់ទីក្រុងតាកួប៉ា (Takuapa) ជាខាងលិចជ្រោយក្រា (Kra) ចិនហៅថា តៀវ-គីវ-លី (T'eou-Kiu-li) គឺកំពង់នេះហើយដែលពជទូត

១- G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient. P. 47,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រទេសនគរភ្នំ (អតីតកម្ពុជា) បានចុះសំពៅទៅកាន់ប្រទេសឥណ្ឌៀ ពីគ្រិស្តសតវត្សទី៣»;

(១)

«កំពង់តាំព្រលិង្គនេះ ចិនហៅថា តាន់-ម៉ុ-លៀវ (Tan-mei-Lieou) តាំងនៅក្នុងតម្បន់លីគោរ (Ligor) មានសិលាចារឹកសំស្ក្រឹតពីគ្រិស្តសតវត្សទី ៦ ។ តាមគម្ពីរនិទ្ទេសបាលីលោកហៅកំពង់នេះថា តាម្ពលិង្គៈ ជាក្រុងចាស់កើតក្នុងរវាងគ្រិស្តសតវត្សទី ២»;

(២)

កំពង់បង្កាជាកំពង់បុរាណមួយ លោកសឺដែសសរសេរថា:

«កោះស៊ូមាត្រា ដូចជាកោះជ្វាឬសេឡេប (Célebes) មានព្រះពុទ្ធរូបបុរាណរចនាបែបអមរាវតីមួយ នៅខាងលិចស្រុកប៉ាឡេមប៉ាំងលើទួលសេគុនតាំង ។ ឯកំពង់បង្កានៅទីងកោះមួយខាងកើតកោះស៊ូមាត្រា ទំនងជាកំពង់នេះហើយដែលមានសំពៅឥណ្ឌៀមកមុនគេ ហេតុដូច្នេះហើយបានជាមានឈ្មោះនិយាយក្នុងគម្ពីរនិទ្ទេសថា កំពង់វង្គៈ (Vanga)» ។

លោកសឺដែសសរសេរបន្ថែមទៀតថា:(៣)

« ពិតមែនហើយ , មានសិលាចារឹកជាភាសាម៉ាឡេស៊ីបុរាណ ៣ កន្លែងនៅកោះស៊ូមាត្រា (ពីរនៅស្រុកប៉ាឡេមប៉ាំង (Palembang) មួយទៀតនៅស្រុកការាំង ព្រហ៊ី (Karang-Brahi) ជាខាងលើស្ទឹងបា-តាំង-ហារី (Batang-hari) , មានសិលាចារឹកមួយទៀតនៅស្រុកកូតា-

១ - BEFEO. XVIII, 6 P. 17.— ២- G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient. P. 65. — ៣- G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient. P. 102.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កប៉ូរ (kota-kapur) នៅលើកោះបង្កា (Banka) ។ សិលាចារឹកទាំង ៤ នេះបញ្ជាក់ថា ក្នុង គ.ស. ៦៨៣-៦៨៦ ស្រុកប៉ាឡេមបាំងជារាជអាណាចក្រកាន់ពុទ្ធសាសនា រាជធានីឈ្មោះស្រីវិជ័យ លោកចិនយី-ត្សីង ( Yi-Tsing )ហៅថា ចេ-លី-ហ្វូ-ចេ (Che-li-Fo-che),, ។

នៅមានកំពង់មួយទៀតឈ្មោះក្នុងបច្ចុប្បន្នថា អុក-កែវ ជាកំពង់ពីអតីតនៅមាត់សមុទ្រប្រទេសខ្មែរបុរាណ ។ ខ្ញុំស្តាយណាស់ ព្រោះមិនបានស្គាល់អតីតនាមនៃកំពង់នេះ តែពិតជាកំពង់ធំមួយនៃប្រទេសនគរភ្នំ ។ កំពង់នេះនៅចន្លោះប្រទេសចិននឹងឥណ្ឌា សម្រាប់ការទាក់ទងជំនួញផ្លូវសមុទ្រទៅកាន់ប្រទេសឆ្ងាយ ៗ ដូចសេចក្តីដែលលោកម៉ាល្លេរេត៍សរសេរថា :(១)

" គេបានដឹងថាកំពង់ អុក-កែវ ជាក្រុងបុរាណនៅមាត់សមុទ្រនៃប្រទេសនគរភ្នំ (Founan) ខាងឈូងសមុទ្រសៀម ជាកំពង់សម្រាប់ធ្វើការទាក់ទងនៃជំនួញតាមផ្លូវសមុទ្រ ខាងអាស៊ីភាគអាគ្នេយ៍ ព្រមទាំងទៅប្រទេសឆ្ងាយ ៗ ទៅដល់កំពង់ឆ្នេរទក្ខិណទិសនៃប្រទេសឥណ្ឌា, កំពង់នៅមាត់ទន្លេគង្គា ឬក៏អាចទាក់ទងរហូតទៅដល់ប្រទេសអ៊ីរ៉ង់នឹងសមុទ្រមេឌីទែរ៉ាណេទៀតផង ,, ។

នៅកំពង់នេះ គេបានរកឃើញបុរាណវត្ថុដែលមានអាយុតាំងពីគ្រិស្ត

១-L. Malleret. Aperçu de la gliptique d'Oc-èo BEFEO. TXLIV (1947-1950) 1951- P. 189 .— Les fouilles d'Oc-èo (1944) BEFEO. T. XLV. 1951- P, 88

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សតវត្សទី១ម្ល៉េះ មានរូបអ្នកស្រុក ទេវរូប ពុទ្ធរូប និងរូបបយវត្ថុជាតិពើម៉ាំង ជាតិឥណ្ឌៀ អក្សរព្រាហ្មី គួរនឹងរាប់ថាជាកំពង់បូរាណ ដែលបានទទួល យកវប្បធម៌ឥណ្ឌៀ សាសនាព្រាហ្មណ៍ ពុទ្ធសាសនា តាំងពីកាលនោះ មក ។

យើងបានពវរកកំពង់បូរាណដែលអ្នកឥណ្ឌៀមករកមាសនៅភូមិភាគ នេះឃើញហើយ សមគួរល្មមនឹងបុះមតិសម្រេចថាទីឋានទាំងនេះហើយ ជាសុវណ្ណភូមិ ព្រោះការសន្មតនេះមិនឃ្លាតពីសេចក្តីពិតណាស់ណាទេ តែមិនត្រូវអស់ចិត្ត ដូចជាថាមិនត្រូវអស់សង្ស័យភ្លាម ៗ គួរតែទទូបរក តទៅទៀត ដើម្បីឲ្យការបេះដឹងប្រវត្តិនៃសុវណ្ណភូមិបានពិចិត្រពិស្តារ ទើប ខ្ញុំយល់ថា រឿងនេះត្រូវតែរកមើលតាមទស្សនៈអ្នកប្រាជ្ញថែមទៀត ឲ្យ បានសព្វមុខសព្វអន្ទើសម្រាប់ប្រដាប់ការបេះដឹងរបស់យើង ឲ្យបានពេញ បរិបូណ៌ ។

ពួកអ្នកប្រាជ្ញទាំងឡាយ ដែលខំរិះរកទីឋានសុវណ្ណភូមិតាមប្រកពនា នា តោះជាគម្ពីរមហានិទ្ទេសក្តី តោះជាបញ្ជីផែនទីប្តូឡេម៉េក្តី តោះជា សេចក្តីពយការណ៍អ្នកនិពន្ធចិនក្តី មិនហ៊ានបញ្ជាក់ឲ្យច្បាស់លាស់ជាក់ លាក់ទេ គ្រាន់តែដៅថ្កសន្និដ្ឋានថាប្រហែលជា ឬទំនងជាត្រង់នេះត្រង់នោះ ហើយ ។ អ្នកប្រាជ្ញឥណ្ឌៀក្នុងបច្ចុប្បន្ន សាស្ត្រាចារ្យ ប៉. បាប៉ុត (១) សរសេរថា «ព្រះបាទធម្មាសោកមហារាជបានបញ្ជូនសមណទូតទៅឆ្ងាយ

១ – P. Bapat, 2500 years of Buddhism, P. 59.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ហួសកោះសិរីលង្កាទៅទៀត  ទៅរហូតដល់សុវណ្ណភូមិ ដែនដីមាស ( ជ្រោយម៉ាឡាយូនិងកោះស៊ូមាត្រា ) = Suvarnabhumi the Land of Gold (Malay and Sumatra),, ហើយបន្ថែមសេចក្តីទៅទៀត (១)

បា « ប្រភពកោះសិរីលង្កាថា  ព្រះមោគ្គលិបុត្តតិស្សត្ថេរបានបញ្ជូនសមណទូតទៅសុវណ្ណភូមិ  ហើយថាសុវណ្ណភូមិនៅឯប្រទេសភូមា ៗ លោកថាការពោលនេះ  ពុំទាន់យកជាការគួរជឿជាក់បាននៅឡើយទេ បើនឹងថាសុវណ្ណភូមិនៅប្រទេសភូមាមិនបាច់ជជែកគ្នាក៏បានដែរ  តែបើកាលណាមានអ្នកខ្លះសន្មតថាសុវណ្ណភូមិនៅឯប្រទេសភូមាហើយ  គង់មានអ្នកខ្លះទៀតនិយាយផ្សេងទៅវិញ  អាចនឹងថា  សុវណ្ណភូមិនៅឯប្រទេសសៀម ឬនៅនឹងដែនដីអាស៊ីអាគ្នេយ៍ទាំងមូលក៏សឹងបានទៀតដែរ  ព្រោះថាបើលើកលែងកុំនិយាយរឿងព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរតាមប្រភពកោះសិរីលង្កានេះចេញហើយ  មិនមានភស្តុតាងអ្វីជាក់លាក់ល្មមនឹងពោលអះអាងថា ព្រះពុទ្ធសាសនារុងរឿងក្នុងប្រទេសភូមាមុនគ្រិស្តសតវត្សទី ៤ បានទេ  ថ្វីត្បិតតែប្រទេសភូមានឹងឥណ្ឌានៅជិតខាងគ្នានឹងថាទៅមករកគ្នាពុំទាន់បានមុនគ្រិស្តសករាជក៏សឹងថាបានដែរ  ព្រះពុទ្ធសាសនាប្រហែលជាមិនអាចចូលមកប្រទេសភូមា  មុនគ្រិស្តសតវត្សទី ៥ បានឡើយ;  តពីកាលនោះមក  ទើបពុទ្ធសាសនាថេរវាទចំរើនរុងរឿងក្នុងអាណាចក្រព្យូស  (Pyus) ដែលគេបានស្គាល់ថាជាអាណាខេត្តស្រី-

---

១- P. Bapat, 2500 years of Buddhism, p. 86-87.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក្សេត្រៈ ទីក្រុងនៅផិត (Prome) នឹងមានបុរាណដ្ឋានៈនៅម៉ាហ្សា (Mazu) សព្វថ្ងៃនេះ ” ។

ពាក្យដែលសាស្ត្រាចារ្យ ប៉.ប៉ុតថា សុវណ្ណភូមិ នៅ (ក្រោយម៉ាឡាយូ នឹងសុមាត្រា) ក្នុងវង់ក្រចកយ៉ាងនេះសមនឹងពាក្យលោកសីដែសដែរ ។ ក្នុងឧបលក្ខណៈសៀវភៅលោកមានសេចក្តីថា (១) « ភិក្ខុទិគនាគ ជាសិស្ស ព្រះមហាថេរអសង្គៈ បានសិក្សានៅមហាវិទ្យាល័យនាលន្ទាអស់រយៈវេលា ៣០ ឆ្នាំ ហើយបានទៅសុវណ្ណទ្វីបគឺ (កោះសុមាត្រា ឬ ម៉ាឡេស៊ី) ក្នុងវង់ក្រចក ហើយលោកបន្ថែមទៀតថា (២) «បើលើកលែងកុំនិយាយពីរឿងព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ ជាសមណទូតដែលព្រះបាទធម្មាសោក មហារាជបានបញ្ជូនទៅសុវណ្ណភូមិក្នុងពុទ្ធសតវត្សទី ៣ ហើយ មកសន្មត ថា សុវណ្ណភូមិនៅឯប្រទេសមនបុរាណនោះ មិនដឹងជាថានេះខុសឬត្រូវទេ ដោយចំពោះថានៅ ថាតុង (Thaton) ជាទីក្រុងសុធម្មវតី ឬ សុធម្មបុរៈ ពីបុរាណកាល នុះមិនឃើញមានបុរាណដ្ឋានអ្វីមួយជាសក្ខីភាពល្មមឲ្យស្គាល់បានថាមានវប្បធម៌ណៅ បានចូលមកទីនេះពីអតីតកាល មុនសន្ទឹក មាសចារឹកជាបាលីថា «យេ ធម្មា ហេតុបភវា ... ហើយដែលគេបានរកឃើញនៅម៉ាហ្សា (Maza) នឹងនៅម៉ោងគាន (Moung gan) ជាទីឋាន បុរាណនៅព្រោម (Prome) កាលគ្រិស្តសតវត្សទី ៤ នោះបានឡើយ ។

---

១- G. Cœdès. Histoire ancienne des Etats hindouisés d'Extrême-Orient renvoi N° 7 P. 105 et P. 116.– ២- G. Cœdès. Histoire anc. Etats hind. E. O. P. 20. – 2. S. Lévi. Ptolémée.... Loc. cit; P. 29 et suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សេចក្តីយល់អ្នកប្រាជ្ញទាំងពីរខាងលើនេះ ក៏មិនខុសនឹងពាក្យលោកស៊ីល្វាំងឡេវីដែរ (១) លោកថា «ប្រភពចិនមាននិយាយថា ព្រះបាទហ្វាន់-ចេ-ម៉ុន (ស្រីមារៈ ?) ជាព្រះរាជានគរភ្នំ ទ្រង់ទិវង្គតក្នុងឱកាសដែលទ្រង់លើកសេនាយុទ្ធការទៅច្បាំងប្រទេស គិន-លីន (Kin-lin) «ព្រំដែនមាស» ត្រូវនឹងពាក្យថាសុវណ្ណភូមិដូចប្រភពបាលី ឬ សុវណ្ណកុដ្យៈ ដូចប្រភពសំស្ក្រឹតដែលសន្មតថានៅ (ភាគក្រោមប្រទេសភូមា ឬ ជ្រោយម៉ាឡេស៊ី) ដែរ» ។

សមន្តបាសាទិកា ជាប្រភពបាលីកោះសិរីលង្កាក៏ថា សុវណ្ណភូមិ ជាកោះដែរ (២) ដូចមាននិទានដំណាលថា "កាលព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ និមន្តទៅដល់សុវណ្ណភូមិ ពួកអ្នកកោះស្មានថាលោកជាមិត្តនឹងអារក្សទឹក ព្រោះមានអារក្សទឹកតែងតែមកចាប់ទារកក្នុងរាជត្រកូលយកទៅបរិភោគជារឿយ ៗ ហើយក៏បបួលគ្នាយកអាវុធរត់ទៅប្រុងនឹងសម្លាប់លោក ៗ ព្រះមហាថេរមានថេរដីកាថា អាត្មាជាសមណៈអ្នកកាន់សីល ។ល។ កំពុងតែមានថេរដីកា អារក្សទឹកមកដល់ លោកសំដែងបាដិហារិយ៍ បន្ទាបអារក្សទឹកមិនឲ្យមកទៀត ហើយចាត់ការរក្សានៅជុំវិញកោះ (ថេរេហិ តេ យាវ អទស្សនំ តាវ បលាបេត្វា ទីបស្ស សមន្តតោ អារក្ខំ ឋបេសិ) តមក អ្នកកោះឲ្យឈ្មោះទារកក្នុងរាជត្រកូលថា "សោណុត្តរៈ» តាំង

---

១- G. H. Luce, countries neighbouring Burma. J. Burma Res. Soc, XIV. 1924, P. 47-151. – ២ បឋមសមន្តបាសាទិកា ពាហិរនិទានវណ្ណនា ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពីកាលនោះមក» ។

ប្រកតពកោះសិរីលង្កានេះថា សុវណ្ណភូមិ ជាកោះទៀតហើយ ប្រកប នឹងសេចក្ដីអានខែអ្នកប្រាជ្ញទាំង៣នាក់ខាងលើ ត្រូវគ្នា៣នាក់យ៉ាង នេះ ដូចជាថាមិនបាច់ប្រកែកទៀតទេ ។ សន្មតថាប្រាយជាសុវណ្ណភូមិ សមដែរ តែបើថាកោះជាសុវណ្ណភូមិដូចជានិស់ពិបាកស្ដាប់ដូចទំពាំនដែល ថា ភិក្ខុទិតនាគទៅកាន់សុវណ្ណទ្វីប ហើយដែលលោកសិដែសថា (កោះសុ មាត្រា ឬម៉ាឡេស៊ុ) ។ មួយទៀត កោះត្រង់ភូមិភាគនេះមានច្រើន ដូចកោះជ្វា សុមាត្រា បរណេអូ សេឡែប ជាដើម តើកោះណាទុកជា សុវណ្ណភូមិ ? ពិបាកនឹងកំណត់ឲ្យទៀងទាត់ទៀត ។

ចំណែកប្រកតចិន(១) ក៏មិនមាននិយាយពីសុវណ្ណភូមិថានៅត្រង់ ណាឲ្យច្បាស់លាស់ដែរ គ្រាន់តែថា «ព្រះបាទហ្វាន់-ចេ-ម៉ុន(ស្រីមារៈ?) ចុំងទ័វផ្ទគង់ពេលច្បាំងនឹងប្រទេសគិន-លិន «ព្រំដែនមាស», ថា «ពីប្រ- ទេសនគរភ្នំទៅដល់អាណាច័ក្រ គិន-លិន «ព្រំដែនមាស», ហើយថា ភូងអាណាច័ក្រគិន-លិននេះ ប្រជាជនគោរពព្រះពុទ្ធ មានស្រមណ៍ច្រើន ពាន់» ។ លោកកស្យបៈគ្រិស្ដសតវត្សទី ១៨ ជាអ្នកអធិប្បាយសៀវភៅ ជាស្នាដៃលោកចិនយ៉ី-ត្សីង បានថាថា «អាណាចក្រគិន-លិន នៅភូង គិន-ចៀវ(Kin-Tcheou) ដែលប្រែថាកោះមាសៈ= សុវណ្ណទ្វីប ហើយថា លោកចិនយ៉ី-ត្សីង បានប្រើពាក្យកោះមាសនេះដល់ទៅពីដង ដើម្បី

១- P. Pelliot, Le Founan P. 75-76

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ហៅកោះសុមាត្រាឬតម្បន់ប៉ាឡេមប៉ាំង[1] ។ លោកប្លាគដេន បានរំឭក[2] ឡើងថា «ជនជាតិម៉ាឡេស៍ហៅ កោះសុមាត្រា ថា ពូឡូវមាស (Pulau Mas) ប្រែថា «កោះមាស» ។

លោក ល. ព្រិក្ស[3], ត្រង់បទថា ពាណិជ្ជកម្មនឹងវិត្ថារកម្មឥណ្ឌា ពីបុរាណកាល, សរសេរថា «តាំងពីខាងដើមគ្រឹស្តសតវត្សម្ល៉េះឥណ្ឌា បានស្គាល់ឈ្មោះគេនស្រុកមទឹងជ្រោយម៉ាឡាយូថាជា «សុវណ្ណភូមិ» មកហើយ មានជាតកនិទាននិងគម្ពីរដីកាខាងសាសនាបានដំណាលថា មានអ្នកដំណើរបានមកស្វែងរកលោហធាតុវិសេសត្រង់តម្បន់នេះ គម្ពីរសំស្ក្រឹតហៅតម្បន់នេះថា «សុវណ្ណភូមិ» « Land of gold » ព្រមទាំងហៅថា សុវណ្ណទ្វីបកោះមាសឬជ្រោយមាស Island (or Peninsula) of gold» ។ ក្រោយពីខាងដើមគ្រិស្តសតវត្សមកមិនយូរប៉ុន្មាន អ្នកភូមិសាស្ត្រក្រិកបានដៅឈ្មោះនេះថា ដែនដីមាស «Chryse the gold» ( the «golden chersonese» or Peninsula ។ សព្វថ្ងៃនេះ មានភូមិមួយឈ្មោះ តា-កួ-ប៉ា នៅខាងត្បូងតម្បន់ក្រា (Kra) គេថាជាកំពង់បុរាណនៅឆ្នេរខាងលិចជ្រោយ ។ មានផ្សារបុរាណមួយឈ្មោះ តក្កោលៈ ដែលលោកប្តូឡេម៉េ បានដៅកាលពីពាក់កណ្តាលភាគទីពីរនៃគ្រិស្តសតវត្សមកហើយនោះ គឺទំនងជា តា-កួ-ប៉ា នេះឯងហើយ ។ នៅឆ្នេរខាងកើត

---

១- Chavannes, Religieux Eminents, P. 180-186.- ២- Blagden, L'Acte du 11è congrès international des Orientalistes, Extrême-Orient, P. 236.- ៣- Briggs, The ancient Khmer Empire, P. 16-17.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នៃជ្រោយ ម៉ាឡាយូ នេះ មានកំពង់ឈ្មោះ តាំព្រលិង្គៈមួយទៀត ។ មាន គមនាគមន៍ចូលកាត់ទៅវិញទៅមក រវាងកំពង់ទាំងពីរនេះតាំងពីបុរាណកាល ។ តាមកំពង់នឹងតាមគមនាគមន៍នេះ គេអាចធ្វើដំណើរហូតមកដល់ទន្លេមេណាម និង ទន្លេមេគង្គ បានជានៅឥណ្ឌូចិនមានរឿងព្រាហ្មណ៍ហ៊ុន-ទៀន បានភរិយាហើយបានសោយរាជ្យនៅប្រទេសនគរភ្នំ» ។

ការស្រាវជ្រាវរកសុវណ្ណភូមិ នៃអ្នកប្រាជ្ញដែលបានពោលមកនេះ ឃើញថា លោកចោះសំដៅត្រង់កោះសុមាត្រាឬជ្រោយម៉ាឡាយូសមតាមទំនងហេតុផលប្រភពបាលីនិងភូមិសាស្ត្រដែរហើយ គួរនឹងចុះមតិយល់ស្របតាមទស្សន របស់លោកមិនបាច់ប្រកែកទៀត តែទស្សនៈទាំងនេះ លោកមិនហ៊ានបញ្ជាក់សោះ នាំឲ្យយើងនៅតែមានសន្ទិះសង្ស័យមិនទាន់អស់ចិត្តនៅឡើយ ដូច្នេះរឿងសុវណ្ណភូមិក៏នៅតែជារឿងអាថ៌កំបាំងដដែល តែបើយើងទទូចជីកក្កិះកកាយទៅទៀត គួរតែឆ្ងល់ថា ប្រភពបាលីនេះមានសេចក្តីគួរឲ្យចាប់ពិរុទ្ធថា «ព្រះសោណកត្ថេរនឹងព្រះឧត្តរត្ថេរទៅសុវណ្ណ-ភូមិ» ហើយប្រភពដដែលនេះ ត្រង់ពាហិរនិទានវណ្ណនាថា «ព្រះថេរៈទាំងពីរអង្គទៅកាន់កោះ» ដូចជាមិនស្របគ្នា ត្រង់ពាក្យ «ភូមិ» និង «កោះ» នេះសោះ ។ គួរតែថា កោះជាសុវណ្ណទ្វីប ហើយដែនដីធំគួរថា សុវណ្ណ-ភូមិ ទើបមានហេតុផលល្មមស្តាប់បាន ព្រោះជ្រុងពិភពលោកត្រង់អាស៊ីភាគអាគ្នេយ៍នេះ មានទាំងកោះ មានទាំងភាគផែនដីធំ ។ ចុះបើកោះសុមាត្រា មានរូបបញ្ជាក់ក្នុងតួឯងថា ទ្វីបស្របទៅហើយ ថែមទាំងសមហេតុ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ផលផង យើងនឹងនៅទទូចទទែយល់ថា "កោះសុមាត្រា" ជាសុវណ្ណ-ភូមិទៀតក៏មិនសមដែរ បើថាជ្រោយ ម៉ាឡាយូ ទុកជាក់ថាជាសុវណ្ណភូមិ ក៏ដូចជាមានហេតុផលគួរជឿដែរ ហើយជនជាតិឥណ្ឌាពីអតីតកាលដែល តាំងនាមសុវណ្ណភូមិកាលនោះឡើង ក៏មិនគួរនឹងឆ្ងល់សល់វ៉ល់អ្វីសព្វបើ ពាក្យថាទ្វីប" នឹង "ភូមិ" នេះឡើយដែរ ។

យើងបានឃើញសុវណ្ណភូមិតាមទស្សនៈអ្នកប្រាជ្ញបុរាណហើយ តទៅ យើងត្រូវរកសុវណ្ណភូមិតាមបុរាណវត្ថុដែលជាវប្បធម៌ឥណ្ឌាក្នុងភូមិភាគនេះទៀត ។

ការផ្សាយពុទ្ធសាសនាទៅកាន់បច្ចន្តប្បទេសនេះ មាន២ផ្លូវគឺ: ផ្លូវគោក ១ ផ្លូវទឹក ១ ។ ផ្លូវគោក ពុទ្ធសាសនា ផ្សាយទៅតាមពួកពា-ណិជក្បួនរទេះដែលដើរលក់ដូរទៅតាមស្រុកតូចធំនិគមជនបទក្នុងប្រទេសឥណ្ឌាក្តី ក្រៅប្រទេសឥណ្ឌាក្តី, ផ្លូវទឹក តាមពួកពាណិជដើរសំពៅសមុទ្រ ដែលធ្វើដំណើរទៅលក់ដូរតាមកោះតូចធំ នៅក្នុងសមុទ្រសាគរឬដែនដីណាដែលទៅតាមជើងគោកមិនបាន ។ ទំនៀមពុទ្ធសាសនិកជន ទោះជាពាណិជជើងគោកក្តី ទោះជាពាណិជជើងទឹកក្តី ក្នុងពេលធ្វើដំណើរម្តង ៗ តែងតែនិមន្តភិក្ខុសង្ឃឬកសាងព្រះពុទ្ធរូបយកទៅជាមួយ ដើម្បីការពារភយន្តរាយតាមផ្លូវគន្តារផង ដើម្បីធ្វើសក្ការៈបូជាយកចំណែកកុ-សលតាមផ្លូវផង ។ សាសនាដទៃ ៗ ក៏មានទំនៀមដូចគ្នាដែរ ។ តែការផ្សាយពុទ្ធសាសនា ធ្វើតែក្នុងរដូវចេញវស្សាទេ រដូវក្នុងវស្សា ព្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ភិក្ខុសង្ឃត្រូវឈប់សម្រាកអស់ត្រីមាស ។ ចំពោះការមកសុវណ្ណភូមិ ក្រៅពីព្រះសោណកត្ថេរ និងព្រះឧត្តរត្ថេរ ជាសមណទូតដែលព្រះបាទធម្មាសោកមហារាជបានបញ្ជូនកាលពីពុទ្ធសតវត្សទី៣នោះ នៅមានពួកពាណិជសំពៅសមុទ្របាននាំព្រះភិក្ខុសង្ឃ ឬព្រះពុទ្ធរូបមកជាមួយទៀតដែរ ។ ពាណិជសំពៅធ្វើដំណើរចេញពីភូមិភាគទក្ខិណទិសនៃប្រទេសឥណ្ឌា (ទក្ខិណាបថ ឬ ដេក្កង់សព្វថ្ងៃនេះ) មកលក់ដូរនៅដែនដីអាស៊ីភាគអគ្នេយ៍តាំងមូលនេះ ជាកោះក្តី ជាដែនដីក្តី ដែលយើងហៅថាសុវណ្ណភូមិ. កាលមកដល់ហើយ ក៏ផ្សាយពុទ្ធសាសនាតាមទីឋាននានាដែលខ្លួនទៅដល់ បានជាទីឋាននោះៗ ដែលមានវប្បធម៌ឥណ្ឌាមកដល់ហើយ មានបុរាណវត្ថុ បុរាណដ្ឋាន បុរាណទេវរូប បុរាណសិលាចារឹកសព្វទីកន្លែង ដោយចំពោះព្រះពុទ្ធរូប «ទីបង្ករៈ= ព្រះពុទ្ធជាទីពឹង» ដែលពួកពាណិជសំពៅចូលចិត្តរាប់អាន ។ ហេតុដូច្នេះហើយបានជាទីឋានដែលនៅឆ្ងាយដាច់ស្រយាលពីប្រទេសឥណ្ឌានេះ មានវប្បធម៌ឥណ្ឌាតាំងពីសម័យព្រេងនាយជាសក្ខីភាពដេរដាសពាសពេញដែនដីច្រើនកន្លែង គួរកំណត់សំគាល់ថា អាស៊ីភាគអគ្នេយ៍តាំងមូលជាសុវណ្ណភូមិមានហេតុផលសមបរិបូណ៌ មិនមានបន្ទោះគួរឲ្យតក់បានទៀតឡើយ ។

ឯដែនដីនៅចន្លោះឥណ្ឌានិងចិននេះ ពីអតីតកាល មានតែប្រទេសចាម ខ្មែរ មន និងជ្វាម៉ាឡាយូទេ ។ ប្រទេសចាម ខ្មែរ មន តាំងនៅលើភាគដែនដីធំ ឯប្រទេសជ្វាម៉ាឡាយូតាំងនៅតាមកោះ ៗ ដែន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ដីទាំងនេះបានទទួលវប្បធម៌ឥណ្ឌាតាំងពីបុរាណកាល តែគេមិនអាចកំណត់សករាជឲ្យបានទៀងទាត់ទេ ។ លោកហ្វែរ៉ង់និយាយថា (១) «មានវប្បធម៌ឥណ្ឌាចូលមកប្រទេសក្រៅឥណ្ឌា ទីឥណ្ឌូណេស៊ីមុនគ្រឹស្តសករាជ» (២) តែលោកសឺដេសថា «និយាយត្រឹមតែមានជនជាតិឥណ្ឌាមកតាំងទីឋាននៅបរិបូណ៌ក្នុងគ្រិស្តសតវត្សទី២ និងទី៣ ហើយបានផលចំរើនរុងរឿងក្នុងគ្រិស្តសតវត្សទី៤ និងទី៥ប៉ុណ្ណឹងហើយ» ចំណែកលោកប៉ី.ឌុយប៉ុងថា (៣) «ពុទ្ធសាសនាជាសាសនាដែលប្រទេសទាំងនេះបានទទួលតាំងពីខាងដើមគ្រិស្តសតវត្សទី១ម៉្លេះ ហើយមានជ័យជំនះឈ្នះការភក្តិប្រែទាំងខាងផ្លូវនយោបាយ និងទាំងខាងផ្លូវឃោសនា ព្រមទាំងមានដំណើរតាំងនៅមាំមួន និងបិតថេរបេកាលជានិវត្តារកម្មនៃឥណ្ឌាដទៃទាំងអស់» ។ យោបល់លោកទាំង៣ខាងលើនេះមានហេតុមានផលគួរស្តាប់បាន យើងអាចផ្សំនិយាយថា ពុទ្ធសាសនាមកពីពុទ្ធសតវត្សទី៣ . ហើយរុងរឿងចាប់តាំងពីខាងដើមគ្រិស្តសតវត្សមក ។

វប្បធម៌ឥណ្ឌាខាងពុទ្ធសាសនាដែលមាននៅលើភូមិភាគនេះយើងអាចចែកជាមជ្ឈមណ្ឌលពុទ្ធសាសនា ៦ មណ្ឌលដូចតទៅនេះ ៖

១– បុព្វទិសាភាគ ប្រទេសចម្ប៉ា ជាដែនដីចាមពីអតីតកាល ប្រ

---

១ — G. Ferrand. J. Asiat. Juillet-Août 1919. P. 20. ២— G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient P. 22-23.— ៣- P. Dupont, la propagation du Bouddhisme Indien en Indochine occidentale (Bulletin de la Société des Etudes Indochinoises nouvelles séries, T. XVIII N· 1 et 2 1er et 2è trimestre, Saigon 1943).

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទេសនេះកាន់ពុទ្ធសាសនា(១) មាននិកាយពុទ្ធសាសនា ២ គឺអរិយសម្មតិនិកាយ និង សព្វាស្តិវាទនិកាយ ។ មានព្រះពុទ្ធរូប សំរិទ្ធមួយព្រះអង្គ(២) ល្អវិសេស ការរចនាបែបអមរាវតីនៅស្រុកដុងដឿង ( Dông-dung) ខេត្តក្វាងណាម (Quang-nam) ពីពុទ្ធសតវត្សទី ៣ ឬ ទី ៤ ។

២– បុព្វទិសមជ្ឈភាគ ប្រទេសនគរភ្នំ (Founan) ប្រទេសកម្ពុជាបច្ចុប្បន្ន ។ ប្រភពចិនថែងថា ព្រះបាទ ហ៊ុន-ទៀន ព្រះនាង លៀវ-យី=កៅណ្ឌិន្យ-នាគីសោមា=ព្រះថោងនាងនាគី ជាបឋមក្សត្រិយ ស្ថាបនាប្រទេសនេះឡើងពីគ្រិស្តសតវត្សទី១ ។ មានសិលាចារឹក(៣) ពុទ្ធសាសនាបរមបុរាណជាងគេបង្អស់នៅឥណ្ឌូចិន ជាព្រះរាជប្រកាសព្រះបាទ ហ្វាន់-ចេ-មុន(ស្រីមារៈ ? )ពីគ្រិស្តសតវត្សទី ២ឬទី៣, មានសិលាចារឹកបុរាណ ៤ និងពុទ្ធរូបច្រើនជាសក្ខីភាព ។

៣– បច្ឆិមទិសមជ្ឈភាគ ដែនដីមននិងខ្មែរ ប្រទេសសៀមសព្វថ្ងៃនេះ ។ មានចក្រចារថា យេ ធម្មា.....(៤) នៅបុរាណដ្ឋាននគរបឋម ការរចនាចក្រនេះមិនមែនមានមុនគ្រិស្តសតវត្សទី ៦ ទេ ។ មានព្រះពុទ្ធរូប

---

១ — G. Maspero. Royaume du Champa. Paris; Van Oest 1928. — ២- G. Cœdès. Histoire ancienne des Etats hindouisés Extrême-Orient. P 21-51. — ៣ — A. Bergaigne. Inscription de Vo-Canh XX (416) Notices et Extraits des manuscrits T. XXVII 1889 P. 196. — G. Cœdès Inscription de Vo-Canh BEFFO T. XV P.3 — ៤ — Référence dans R.S. Le May. Buddhistart in Siam, Cambridge Université Press 1938. — Sur les feuilles rècentes de la mission P. Dupont, cf. BEFEO XXXVII P. 688-689. — XXXIX P. 351-365; X L. P. 503-504.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

សំរិទ្ធិមួយអង្គ នៅបុរាណដ្ឋានពង់ទឹក[១] (Pong-Tük) ការរចនាបែបអមរា-វតីគ្រិស្តសតវត្សទី ៣ ឬទី ៤ ។ មានព្រះពុទ្ធរូបសំរិទ្ធិមួយអង្គទៀត ការរចនាបែបអមរាវតីដែរ គេរកឃើញនៅនគររាជសីមា, ព្រះពុទ្ធរូបទាំងនេះចេញពីសាលាក្នុងអង្គរបុរី ( ខេត្តតាកែវ ) ។

៤– បច្ចិមទិសភាគ ប្រទេសមន ប្រទេសភូមាសព្វថ្ងៃនេះ មាន សន្លឹកមាសច្រើនសន្លឹកចារថា យេ ធម្មា..., នៅម៉ាហ្សាទីងម៉ាងគាន ជិតក្រុងព្រោម (Prome) ពីគ្រិស្តសតវត្សទី ៥ ទីក្រុងថាទុង (Thaton) ជាក្រុងចាស់ឈ្មោះសុធម្មវតី ឬ សុធម្មបុរៈ ដែលលោកចិនហៅថា ស្រី-ក្សេត្រៈ កាលពីគ្រិស្តសតវត្សទី ៧ ។

៥– ជ្រោយម៉ាឡាយូ ប្រភពចិននិយាយថានៅទីនេះ[២]មានរដ្ឋតូច ៗ កាន់តាមវប្បធម៌ឥណ្ឌា តាំងតែពីគ្រិស្តសតវត្សទី ២ តែសិលា-ចារឹកក្នុងទីនេះមិនមានមុនគ្រិស្តសតវត្សទី ៤ ឡើយ ។

៦– ប្រជុំកោះ[៣] មានសិលាចារឹកច្រើនកន្លែង ។ សិលាចារឹក ព្រះបាទមូលវរ្ម័នក្នុងស្រុកកុតី (Kutei) នៅកោះប៊័រណេអូ ពីខាងដើម គ្រិស្តសតវត្សទី ៥ ។ សិលាចារឹកព្រះបាទបូណ៌វរ្ម័ន នៅបច្ចិមភាគ កោះជ្វាពីក្នុងរវាងគ្រិស្តសតវត្សទី ៥ ដែរ ។ មានព្រះពុទ្ធរូប "ទីបង្ករ:

---

១ – G. Cœdès, the excavations at P'ong-Tük, J. Siam, Soc. XXI P. 195-209 .– G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient P. 20. — ២ — G. Cœdès Histoire ancienne des Etats hindouisée d'Extrême-Orient P. 21. — ៣ — Ibid P. 21-22.

ព្រះពុទ្ធជាទីពឹង „ ច្រើនអង្គ ការរចនាបែបអមរាវតី, មួយអង្គរកឃើញនៅស្រុកសេមប៉ាគា (Sempaga) ក្នុងកោះសេឡេប (Célèbes) មួយអង្គទៀត រកឃើញនៅខាងត្បូងខេត្តជេមប៊ែរ (Jamber) ប្រទេសជ្វាខាងបុព្វ-ទិស, មួយអង្គទៀតរកឃើញនៅលើទួលសេគុនតាំង (Séguntang) នៅកោះប៉ាឡេមបាំង (សុមាត្រា) ចិនហៅកោះជ្វានេះថា យេ៉-ទាវ (Ye-Tiao = Yava duipa) ពី គ.ស. ១៣២ ។

យើងបានប្រមូលឯកសារខាងលើនេះមកត្រិះរិះមើលឃើញថា ទីឋានតាំងនេះមានពុទ្ធសាសនាផ្សាយមកដល់ហើយ បើយកសករាជមកធៀបគ្នាមើលទៀត ឃើញថាមិនមុនមិនក្រោយជាងគ្នាប៉ុន្មានទេ តែបើប្រសិនជាយកសិលាចារឹកពុទ្ធសាសនាសំស្ក្រឹត នៅវ៉ូកាញ់ ដែលបរមបូរាណជាងគេមកទុកជាមូលដ្ឋានវិញ នោះយើងនឹងអាចពោលបានថា ពុទ្ធសាសនាមកដល់ប្រទេសនគរភ្នំ (Founan) អតីតកម្ពុជាមុនជាងទីឋានសុវណ្ណភូមិឯទៀតទាំងអស់ ។

ខ្ញុំមានសេចក្ដីស្ដាយណាស់ ដោយមិនមានឯកសារបញ្ជាក់ប្រស្នាចាក់ស្រែះ ដែលមានអាយុរាប់ពាន់ឆ្នាំកន្លងមកហើយនេះឲ្យច្បាស់លាស់ ព្រោះដំណឹងដែលយើងបានដឹងតាមគម្ពីរមហាវង្ស ឬ បឋមសមន្តប្បាសាទិកា ជាប្រភពកោះសិរីលង្កានោះ មានសេចក្ដីត្រឹមតែថា "ព្រះមហាមោគ្គលិបុត្តតិស្សត្ថេរ បានបញ្ជូនព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ ទៅកាន់សុវណ្ណភូមិពីពុទ្ធសតវត្សទី ៣ ហើយថា ព្រះថេរៈទាំងពីរអង្គនេះនិមន្តមក

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គង់នៅទីនឹងកោះ បានប្រោសជនានុជនក្នុងកោះនោះឲ្យចូលកាន់ពុទ្ធសាសនា„ ប៉ុណ្ណឹងតែសព្វថ្ងៃនេះ យើងមិនមានភស្តុតាងគ្រប់គ្រាន់ថាកោះណាដែលព្រះថេរទាំង ២ អង្គនិមន្តមកគង់នៅ ហើយតាំងជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាក្នុងបឋមកាលនោះ ។

ហេតុដូចបានពោលមកនេះ យើងត្រូវតែយកកំពង់ពីអតីតកាលនៅតាមកោះតូចធំ តាមដែនដី ដែលមានពាណិជឥណ្ឌាបានចូលមករកមាសពីសម័យព្រេងនាយ ហើយបាននាំយកវប្បធម៌ឥណ្ឌាចូលមកសាបព្រោះ នឹងបុរាណវត្ថុ បុរាណដ្ឋាន បុរាណទេវរូប បុរាណសិលាចារឹកដែលមានដេរដាសពាសពេញ ព្រមទាំងប្រភពចិន ប្រភពបូរទ្បេម៉ីដែលមានដំណើរមកកាន់អាស៊ីអាគ្នេយ៍ ពីអតីតកាលមកជាសក្ខីភាពហើយរួមពោលថា ដែនដីអាស៊ីអាគ្នេយ៍ទាំងមូលនេះជា „សុវណ្ណភូមិ„ លែងប្រកែកតទៅទៀតបាន ។ ភូមិភាគទាំង ៦ កន្លែងដែលបានពោលមកហើយនេះ ជាមជ្ឈមណ្ឌលដែលព្រះថេរានុត្ថេរទាំងឡាយ មានព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរជាដើមបានសាបព្រោះពូជសម្មាទិដ្ឋិ គឺព្រះពុទ្ធសាសនាឲ្យចាក់ឫសគល់បណ្ដុះបណ្ដាលឲ្យកើតជាពូជការលូតលាស់ដុះដាលចំរើនឡើង ត្រាតែក្នុងបច្ចុប្បន្នកាលនេះ មានប្រជាជនរាប់លាននាក់ចូលកាន់សាសនាព្រះជិនស្រី „សាសនាឈ្នះទុក្ខក្នុងលោក„ ។

**សម័យនគរភ្នំ.–** ពុទ្ធសតវត្សទី៦ទៅទី១១ (ព.ស.៥៤៣-១០៩៣) គ្រិស្តសតវត្សទី១ទៅទី៦ (គ.ស.ទី១.៥៥០) បើយើងយក

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គម្ពីរបឋមសម្ពន្ធប្បសាទិកា ឬ គម្ពីរមហាវង្សជាប្រកតៈការះសិរីលង្កាមក ជាសក្ខីភាព យើងត្រូវនិយាយថា ព្រះពុទ្ធសាសនាបានចូលមកប្រទេសកម្ពុជាយើងតាំងពីពុទ្ធសតវត្សទី៣ (ព.ស.២៣៤) មុនគ្រិស្តសករាជ ៣០៩ ឆ្នាំ ព្រោះដែនដីកម្ពុជានេះតាំងនៅក្នុងមណ្ឌលសុវណ្ណភូមិខាងបូព៌ទិស ឬ អាស៊ីអាគ្នេយ៍ តែប្រកតឯកសារទាំងឡាយពុំបានកំណត់ឲ្យច្បាស់លាស់ថា ព្រះពុទ្ធសាសនាចូលមកក្នុងរដ្ឋកាលណា? ព្រះថេរៈអង្គណា ឬ លោកណាបាននាំមកប្រតិស្ឋានមុនដំបូង? ដំណើងនេះនៅក្នុងអាថិកំបាំងទាំងអស់ ព្រោះហេតុការណ៍ទាំងឡាយមិនថាតែក្នុងកម្ពុជាទេ សូម្បីក្នុងភូមិភាគដទៃ ដែលមាននៅក្នុងសុវណ្ណភូមិទាំងប៉ុន្មានកាលពីមុនគ្រិស្តសករាជ ក៏ច្រើនតែពុំសូវមានប្រវត្តិអ្វីជាពស្តុតាង ម្ល៉ោះហើយលោកទុកសម័យនេះថាជាសម័យមុនប្រវត្តិសាស្ត្រតែម្តង ។

កាលនោះ ប្រទេសកម្ពុជាយើងមានសមញ្ញាថា ប្រទេស «នគរភ្នំ» (១) ។ នាមាភិធេយ្យថា «នគរភ្នំ» នេះ ចិនហៅថា ហ្វូណន (Founan) រាជធានីហៅថា ទូមូ ត្រូវនឹងពាក្យខ្មែរបុរាណថា «ទមាក់=ទ្រមាក់ ប្រែថា «អ្នកបាញ់» ស្របនឹងសិលាចារឹកជាភាសាខ្មែរថា «កុរុងភ្នំ ឬ វ្រះភ្នំ» ជាសំស្ក្រឹតថា «បវ៌តភូបាល ប្រែថា «ស្តេចភ្នំ» រាជធានីថា «វ្យាធបុរៈ បុរីអ្នកបាញ់» ជាទីក្រុងតាំងនៅទីរួមតម្បន់បាភ្នំ (ទំនងជានៅក្នុងខ្សាច់សបច្ចុប្បន្ននេះឯង?) ព្រោះទីឋាននេះ មានបុរាណ-

១— G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient P. 43-44.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្ថាន ទីនបុរាណទេវរូបសម័យនគរភ្នំច្រើនណាស់ ព្រមទាំងមានសិលាចារឹកមួយ(១)នៅវត្តបក្រិត នៅទឹងជើងភ្នំពីគ្រិស្តសតវត្សទី១០ និយាយថាបានសាងទេវរូបព្រះឥសូរមួយហៅថា «អទ្រិវ្យាធបុរេស្វរ:» ដំកល់ក្នុងទីនេះផង ៗ ពង្សាវតារក្នុងសម័យព្រេងនាយ ទាំងប៉ុន្មានបាត់បង់អស់ទៅតាមកាលវេលា នៅមានសល់ខ្លះតែសិលាចារឹក៤កន្លែង នៅវ៉ូកាញ់(២), ខេត្តញ៉ាត្រាំង ១ (វៀតណាម) នៅអ្នកតាដំបងដែក(៣) ខេត្តតាកែវ ១ នៅប្រាសាទប្រាំល្វែង(៤) កូសាំងស៊ីន ១ នៅទន្លេបាទី(៥) ខេត្តតាកែវ ១ ៗ សិលាចារឹកទាំងនេះ ខ្លះនិយាយពីព្រះរាជាគោរពសាសនាព្រាហ្មណ៍ ខ្លះនិយាយពីព្រះរាជាគោរពពុទ្ធសាសនា ៗ ដទៃពីនេះ យើងមានប្រកពចិន(៦) ជាឯកសារដែលលោក ប៉. ប៉ែល្លីយោ បានប្រែចេញពីពង្សាវតារចិនទៀត ៗ ប្រកពចិននេះ មាននិយាយពីពង្សាវតាយើងខ្លះ យើងអាចយកមកទុកជាពន្លឺគ្រោលបំភ្លឺមើលពង្សាវតារនៃយើងកាលពីសម័យនគរភ្នំបានដឹងហេតុការណ៍ខ្លះដែរ ៗ

ចិននិយាយថា «ខ្មែរយើងបានកសាងខ្លួនជាប្រជាជាតិមួយ មានរូប

---

១- P. Dupont, La statuaire préankorienne ASCONA P. 17.
២- Barth-Bergaigne, ISCC, N· XX, 191. — L. Finot, BEFEO, XV, II, 3. — G. Cœdès, IHQ XVI, 484 suiv. — ៣- Id, JGIS IV, 117 suiv. — ៤ — Id, BEFEO, XXXI[1] P. 1 et suiv. — ៥- Ibid. P. 8. — ៦- P. Pelliot, Le Founan (tirage à part) — BEFEO, II P. 248 suiv. P. 671 suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កងកើតឡើងក្នុងពិភពលោកតាំងតែពីគ្រឹស្តសតវត្សទី ១ ,, ។ តែលោកហ្វែរ៉ង់ថា (១) « នៅប្រទេសនគរភ្នំនេះ មានជនជាតិឥណ្ឌៀបាននាំយកវប្បធម៌ខ្លួនមកផ្សាយ តាំងតែពីពុទ្ធសតវត្សទី ៣ គឺតាំងពីមុនគ្រឹស្តសករាជ ៣០០ ឆ្នាំ ម៉្លេះ ,, ។ មានប្រភពចិនខ្លះនិយាយថា មានការទាក់ទង (២) ប្រទេសខ្មែរ ទឹងចិនតាំងពីមុនគ្រឹស្តសករាជច្រើនឆ្នាំ តែដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រទុកជាផ្លូវការរាប់ពីគ្រឹស្តសតវត្សទី ៣ រៀងរហូតមក ។ រាជទូតចិនដែលមកប្រទេសយើងជាបឋមមុន គ.ស. ២៣១ បន្តិច ហើយមានពីគ.ស. ២៤៣ មករហូតដល់គ.ស. ៤៣៤ ។ លោកចែកជាសម័យដូចទៅនេះ ៖

១–សម័យមុនគ្រឹស្តសករាជ

២–សម័យសាន់-គួ-ចេ (San-Kuouo-Tche) គ.ស. ២២០-២៨០

៣–សម័យពង្សាវតារត្សិន (Tsin) គ.ស. ២៦៥-៤១៩

៤–សម័យពង្សាវតារស៊ុង (Song) គ.ស. ៤២០-៤៧៨

៥–សម័យពង្សាវតារត្សី (Tsi) ខាងត្បូងគ.ស. ៤៧៩-៥០១

៦–សម័យពង្សាវតារលាង (Leang) គ.ស. ៥០២-៥៥៦ ។ល។

សម័យសាន់ គួ-ចេ រជ្ជកាលព្រះចៅក្រុងចិនទាមវូ (Wou) គ.ស.

---

១- G. Ferrand, Le Kouen-Louen, J .A. P. 549. — ២- P. Pelliot, Le Founan, (cf. Legge chinese classics III. II 536-537) tirage à part P. 58-59.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



២២០-២៨០ បានបញ្ជូនកាំង-ថៃ (Kang-Thai) និងជូ-យីង (Tchou-Ying) ជាបឋមទូតមកកាន់ប្រទេសយើងនៅខាងដើមគ្រិស្តសតវត្សទី ៣ ។ ឯកសារទាំងនេះ យើងអាចចងក្រងជាពង្សាវតារយើង ឲ្យយើងដឹងពីពិស្ដារភាព ទ្រព្យសម្បត្តិប្រទេស វប្បធម៌ ប្រពៃណីប្រជាជន មុខរបររកទទួលទាន និងលំដាប់ពង្ស ព្រមទាំងព្រះនាមព្រះរាជាអង្គខ្លះក្នុងសម័យនោះបានខ្លះដែរ ។ បើយើងប្រមូលឯកសារទាំងនេះមករួមគ្នាជាសង្ខិតន័យ យើងនឹងអាចដឹងបានដូចតទៅនេះ ៖

« ព្រះរាជអាណាចក្រនគរភ្នំ តាំងនៅនឹងឆ្នេរឈូងសមុទ្រមួយធំ ខាងកើតទល់នឹងប្រទេសលិនយី (ប្រទេសចម្ប៉ា, ចម្ងាយពីប្រទេសលិនយីមក ១០០០ លី, ខាងលិចទៅទល់ប្រទេសឥណ្ឌា) នឹងអាណាចក្រគិន-លិន « ព្រំដែនមាស » ទំហំប្រទេសចំនួន ៣០០០លី ។ មានក្រុងច្រើនសុទ្ធសឹងពទ្ធជុំវិញដោយកំពែង, មានប្រាសាទរាជស្ថានប្រកបដោយជាន់ មានគេហដ្ឋាន ៗ លើដី មានព្រៃព្រឹក្សា, គ្រឿងទេសមានសត្វទឹក សត្វគោក បក្សី ក្ងោក បរបាត សេក៥ពណ៌, ក្នុងដីមានមាស, ស្ពាន់, សំណ ដែកៗ មិនមានអ្វីខ្វះខាតទេ មានសម្បត្តិប្រទេសដែលគេបានដោយក្រៅដូចមាស, ពេជ, និលចិន្ដា, គជជាដើម ។ មានដើមអំពៅ, ក្រទឹម, ក្រូចពោធិ៍សាត់, ដើមស្លា; ដើមដូង ។ ប្រជាជនសម្បុរខ្មៅ សក់រួញ ប្រជុំភូមិមួយមានអណ្ដូង១ គេស៊ីធ្វើស្រែចំការ, បេះត្បាញរវៃអម្បោះសូត្រ, បេះសិល្ប៍·ឆ្លាក់ត្បាច់របនា, ធ្វើចិញ្ចៀន,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

កងកណ្ដ, ខ្សែកណ្ដ, ខ្សែដៃ, កងជើង, មានពានប្រាក់ប្រើប្រាស់ យកមាសប្រាក់គជគ្រឿងក្រអូបបង់ពន្ធដារ, មានក្បួនតម្រា, មានមន្ទីរឯកសារ, អក្សរសរសេរតាមអក្សរឥណ្ឌា, ទំនៀមការកូនចៅប្ដុរបុណ្យខ្មោចដូចនៅប្រទេសលិនយីដែរ, ប្រជាជនកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ, កាន់ពុទ្ធសាសនា ចេះធ្វើទេវរូបពីសម្រឹទ្ធិពីឬ បើមុខពីរមានដៃបួន, បើមុខបួនមានដៃប្រាំបីដៃមួយៗកាន់គ្រឿងឧបករណ៍ផ្សេងៗ ឬកាន់ព្រះអាទិត្យព្រះចន្ទ ៗ ទំនៀមកាន់ទុកខ្មោច ត្រូវគោរពុកមាត់កោរសក់ ៗ ទំនៀមកប់ខ្មោចមាន៤យ៉ាងគឺ កប់ក្នុងដី ចោលក្នុងព្រៃស្មសានឲ្យសត្វស៊ី, ទម្លាក់ចោលក្នុងទឹក, ដុត ៗ មានពាណិជលក់ដូរគ្រឿងទេស, មាសប្រាក់, សំពត់ព្រែ ៗ មានពាណិជពីប្រទេសឆ្ងាយទៅមកលក់ដូរ ៗ ប្រទេសសមុទ្រពជ មាននាម៉ឺនខ្មែរទៅនៅត្រួតត្រា នាម៉ឺនច្រើនស្គាំទាំងអស់ឈ្មោះ គូអង់លូអង់ ៗ ប្រទេសនគរភ្នំនឹងលិនយីទាំងពីរនេះ មានការទាក់ទងគ្នាតាមផ្លូវជើងទឹកជើងគោក ហើយជួយគ្នាទៅវិញទៅមក ៗ ប្រទេសនគរភ្នំទាក់ទងរហូតទៅដល់ប្រទេសឥណ្ឌា ៗ មានពាណិជឥណ្ឌាម្នាក់ឈ្មោះ កៀ-សាំង-លី (Kia-Siang-Li) បានមកលក់ដូរដល់ប្រទេសនគរភ្នំ ប្រហែលជាក្នុងកណ្ដាលគ្រិស្ដសតវត្សទី ២ ហើយសរសើរថាប្រទេសយើងនេះចំរើនរុងរឿង ៗ

AngkorLink.com CambodiaBuddhist.org ABCCambodia.com



(១)
ហេតុនេះហើយបានជា ក្នុងរជ្ជកាលព្រះចៅក្រុងចិននាមវូ (wou) គ.ស. ២២២-២៨០ មាននិយាយថា ព្រះបាទហ្វាន់ចាន់ប្រទេសនគរភ្នំ បានបញ្ជូនរាជទូតជាក្សត្រមួយអង្គព្រះនាមសូ-វូ (Sou-Wou) ឲ្យទៅកាន់ប្រទេសឥណ្ឌា (ប្រហែលជាខាងចុងគ្រឹស្តសតវត្សទី២) ចុះសមុទ្រនៅកំពង់តៀវ-គីវ លីតីកំពង់តក្កោល: សព្វថ្ងៃនេះហៅថាតាកួបានៅជ្រោយម៉ាឡាយូ ដែលជាដែនដីខ្មែរខាងបច្ចិមទិសទល់សមុទ្រឥណ្ឌា, ដើរសំពៅសៀរតាមឈូងសមុទ្រកាត់ស្រុកជាច្រើន មួយឆ្នាំបានដល់ទន្លេឥណ្ឌា (ទន្លេគង្គា) ហើយធ្វើដំណើរតាមទូកទៅទៀត ចំនួន៧០០០លីបានដល់ទៅរាជធានីស្តេចឥណ្ឌា ។ លោកស៊ុ-ឡេវីយល់ថា ព្រះរាជានេះជាវង្សមុរុន្ទៈ ។ ព្រះរាជាអង្គនេះ ស្ញើចណាស់លាន់ព្រះឧស្ឋថា ឧហ្ន៍ នៅត្រើយសមុទ្រម្ខាងមានមនុស្សដែរតើ ហើយត្រាស់បង្គាប់ឲ្យនាំរាជទូតខ្មែរដើរមើលប្រទេសឥណ្ឌា ។ ដល់ពេលត្រឡប់វិញ ព្រះរាជាឥណ្ឌាបានបញ្ជូនរាជទូតព្រះអង្គម្នាក់ឈ្មោះចិន-សុងឲ្យមកជាមួយរាជទូតខ្មែរផង ព្រមទាំងនាំយកដង្វាយ មានសេះប្រទេសយូចេ៤ (សេះសិន្ធពដែលមាននៅតាមដងទន្លេសិន្ធុ) ជាដើមមកថ្វាយស្តេចខ្មែរ ។ ទាំងទៅទាំងមក៤ឆ្នាំបានដល់មកប្រទេសនគរភ្នំវិញ គឺកាលនោះហើយដែលស្តេចក្រុងចិនព្រះនាមវូបានបញ្ជូនកាំង-ថៃ (Kang-Thai) នឹង ជូ-យីង (Tchou-Ying) ជាបឋម

---

១- P. Pelliot , Le Founan (tirage à part) P. 80. — Le Founan loc-cit P. 292.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



រាជទូតចិនឲ្យមកប្រទេសនគរភ្នំ ក្នុងរជ្ជកាលព្រះបាទហ្វាន់-ស៊ុន ទំនងជាក្នុង គ.ស. ២២៥–២៣០ បានជួបរាជទូតឥណ្ឌៀ ចិន-សុន ហើយសាកសួរពីទំនៀមទំលាប់នឹងស្ថានភាពប្រទេសឥណ្ឌៀផង ។

ប្រភពចិន មានដំណាលពីព្រះរាជានៅប្រទេសនគរភ្នំច្រើនព្រះអង្គ ។ ព្រះរាជាមួយអង្គ ប្រហែលជាខាងចុងគ្រិស្តសតវត្សទី ២ ទ្រង់ព្រះនាមហ្វាន់ម៉ុន ឬ ហ្វាន់-ចេ-ម៉ុន (ស្រីមារៈ ?) ជាព្រះរាជាកាន់ពុទ្ធសាសនា មានកិត្យានុភាពល្បីល្បាញ ។ ប្រភពចិនរៀបរាប់ថា នៅនគរភ្នំមានព្រះរាជិនីជាស្ដេចសោយរាជ្យជាទំនៀម ព្រះរាជិនីមួយអង្គព្រះនាម លៀវ-យី (Feuille de saule) ព្រះរូបឆោមល្អល្អះដូចជាព្រះរាជកុមារ ហើយមានព្រាហ្មណ៍ម្នាក់ឈ្មោះ ហុន-ទៀន បានធ្នូសរមួយដែលទេពតាប្រទាន ក៏ចុះសំពៅមកកាន់ប្រទេសនគរភ្នំ ព្រះនាងលៀវ-យី លើករេហ៍ពលទៅច្បាំងតនឹងព្រាហ្មណ៍ហុន-ទៀននោះ តែខ្លបខ្លាចចេស្ដាក៏ព្រមទទួលយកជាស្វាមី ។ ព្រះបាទហុន-ទៀននឹងព្រះនាងលៀវ-យីនេះ ជាបឋមក្សត្រ ។ រឿងព្រះបាទហុន-ទៀននឹងព្រះនាងលៀវ-យី តាមឯកសារចិននេះ ឆ្លើយមកត្រូវគ្នានឹងសិលាចារឹកនៅមីសឺង(១) (Myson) ក្នុង គ.ស. ៦៥៨ និយាយថា ព្រះបាទកៅណ្ឌិន្យបានប្រតិស្ឋានលំពែង ដែលទ្រង់បានពីអស្វត្ថាម័នជាបុត្រទ្រោណៈ មកដំកល់ទុកនៅជាភវបុរៈ បានព្រះនាងនាគីសោមាជាអគ្គមហេសី ហើយតាំងជារាជវង្សដើមនៃប្រទេសនេះឡើង ។ សិលាចារឹកនៅ

១ – L. Finot, BEFEO IV, 119.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក័ន្តប្រឡំ ទើបគេទុកដាក់ថាជាសិលាចារឹកប្រទេសចម្ប៉ាទៅវិញ តែលោក ល្វីហ្វីណូត៍ពិចារណាឃើញថា ទីឋានស្រុកវ៉ូ-កាញ់នេះ កាលពីអតីតកាលមិនមែនជាដែនដីចម្ប៉ាទេ គឺជាសមុទ្ទរាជប្រទេសនគរភ្នំ ។ ភាគខាងលើសិលាចារឹករលុបរលាយអក្សរអស់ហើយ មិនអាចមើលសកពជបាន តែគេស្គាល់បានដោយតួអក្សរដែលចាស់បុរាណពេក ស្ទើរតែមុនអក្សរចារឹកផ្នែកខាងលើនេះខ្លះទៀតផង បានជាអ្នកប្រាជ្ញអក្សរបុរាណដូចលោកបារថ៍ (Barth) និងប៊ែរហ្គេញ (Bergaigne) ទាយថា អក្សរសិលាចារឹកវ៉ូ-កាញ់នេះ ទំនងជាក្នុងគ្រិស្តសតវត្សទី៣ មានតែឡើងទៅដល់ក្នុងគ្រិស្តសតវត្សទី២ទៀតផង ។ សេចក្តីក្នុងសិលាចារឹកនោះថា ព្រះរាជាវង្សស្រីមារៈបានត្រាស់បង្គាប់ឲ្យចារឹកទុក ដើម្បីជាអនុស្សាវរីយចំពោះព្រះបាទស្រីមារៈថា រាជកុលៈគឺបឋមវង្សជ្រះថ្លាចំពោះពុទ្ធសាសនា ដោយទ្រង់យល់ច្បាស់នូវគតាគតិដំណើរអន្ទោលស្លាប់កើតនៃសត្វលោកក្នុងវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តាករុណាដល់សព្វសត្វហើយទ្រង់ត្រាស់បង្គាប់ឲ្យបរិច្ចាគព្រះរាជទ្រព្យព្រះអង្គធ្វើជាទាន ទុកជាសាធារណៈប្រយោជន៍ ទីបំផុតទ្រង់ផ្តែផ្តាំទុកថា សូមព្រះរាជាសោយរាជ្យជាតំណតទៅអនាគតឲ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីជាប្រយោជន៍ធំដល់សត្វលោក ។ ខ្ញុំដកស្រង់ហើយប្រែសម្រួលសេចក្តីក្នុងសិលាចារឹកនេះទុកជូនលោកអ្នកទាំងឡាយអានដូចតទៅនេះ :—

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អត្ថបទ

...ប្រជានំ... ប្រថមវិជយ... ណ្ណិមស្យាម ។ អាជ្ញាបិតំ សទសិ រាជវរេណ...រាជគណ...រាគម្ភូតំ បិពទ្ធុ ក្រីមារ... រាជកុល...ជ...ន ក្រីមារ...លោ...ន កុលនន្ទនេន ។ អាជ្ញាបិតំ ស្វជន...ស...មខ្យៃ វាក្យំ ប្រជាហិតករំ ករណាវិរេណ ៕ លោកស្យាស្យ គតាគតិ វិ...ន សិង្ហាសនាទ្យាសីនេន បុត្រក្រាតរិ នាន្តរេក ស្វសមីករណាធនេន តុប្យេត្ថុ យតកិញ្ចិទ្ទផតំ សុ-វណ្ណិមបិ វា សស្វាវញ្ចផមំ កោផ្លាគារេ ...នំ ប្រិយហិតេ សរ្វៃ វិសម្ភុំ មយា តទេវំ មយានុជ្ញាតំ ភវៃស្យរបិ រាជភិរនុមន្តវ្យំ វិទិតមស្តុ ប មេ ភ្ជុត្យស្យ វិរស្យ... ។

## សេចក្តីប្រែសម្រួល

«...សេចក្តីករុណាចំពោះសព្វសត្វទាំងឡាយ...ប្រថមជ័យ.. ថ្ងៃពេញបុណ្ណមី (?) ព្រះវរាជាទ្រង់បានប្រកាសក្នុងរាជសភាថា «ចូរប្រជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូល ព្រះបាទ ... ជាវង្សនៃព្រះបាទស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះរាជបន្ទូលសូរសីហនាទជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាករណទាំងពីរដ៏ប្រសើរ ទ្រង់ប្រថាប់លើសិង្ហាសនៈ (ព្រះរាជបល្ល័ង្កស្វេតឆត្រ ?) ហើយទ្រង់ឈ្វេងយល់នូវ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គតាគតិ គឺការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់ថា «កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តី មិនមែនអ្នកកន្ទៀតទេ បានសម្រេចបំណងខ្លួនហើយ (បានសោយរាជ្យទៅ ? ) (ខ្ញុំសូមឲ្យយក) សម្បត្តិខ្ញុំទាំងអស់ ប្រាក់មាសសង្ហារិមត្ថិ អសង្ហារិមត្ថិ ទៅប្រើជាវត្ថុសម្រាប់ជាទីរកពយទឹង ជាប្រយោជន៍ដល់សត្វលោកទាំងឡាយ ។ នេះជាសេចក្តីបញ្ជារបស់ខ្ញុំ ។ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាមបញ្ជាខ្ញុំនេះ កុំបីខាន ។ ហើយបូរប្រឹក្សាជាមួយសេវកាមាត្យឈ្មោះវរ ... របស់ខ្ញុំ» ។

សិលាចារឹកនេះទុកជាសក្ខីភាពគឺជាឯកសារទៀងទាត់ បញ្ជាក់ថា ប្រទេសនគរក្តីកាន់ពុទ្ធសាសនា ។ គួរពុទ្ធសាសនិកជនទូទៅចងចាំនូវព្រះនាមព្រះរាជាអង្គនេះទុកជាអនុស្សាវរីយ៍ សម្រាប់បូជាបុព្វការីបុគ្គលដែលបានទទួលព្រះពុទ្ធសាសនាទុកជាអរិយធម៌ប្រទេសមក ដើម្បីឲ្យជនានុជនបានក្រេបផឹកនូវទឹកអម្រឹតគឺសេចក្តីសុខចំរើនក្សេមក្សាន្ត ឲ្យបានសមតាមព្រះរាជបំណង ដូចទ្រង់បានត្រាស់ទុកក្នុងសិលាចារឹកជាភស្តុតាងស្រាប់ ។

យើងបានស្រាវជ្រាវរកដំណឹងពុទ្ធសាសនាដែលចូលមកប្រតិស្ឋាននៅក្នុងប្រទេសយើង តាំងពីកាលពុទ្ធសតវត្សទី ៣ នោះ ឥឡូវនេះ យើងបានដឹងថា ក្នុងរជ្ជកាលព្រះបាទស្រីមារៈគ្រិស្តសតវត្សទី ២ ព្រះពុទ្ធសាសនាបានលូតលាស់ដុះដាលក្នុងប្រទេសយើងហើយ ដូចមានសេចក្តីប្រាកដក្នុងសិលាចារឹកជាព្រះរាជប្រកាសព្រះបាទស្រីមារៈនេះស្រាប់ តែកាលតមក ពុទ្ធសាសនាបាត់ដំណឹងច្រើនឆ្នាំទៀត នាំឲ្យយើងស្តាយក្រៃលែង ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក្នុងត្រីស្តសតវត្សទី៥ (គ.ស. ៤៧៩-៥០១) ពង្សាវតារចិនរាជវង្សត្សីខាងត្បូង[១] (Tsi méridionaux) មានដំណាលថា ព្រះរាជានៅនគរភ្នំកាន់ពុទ្ធសាសនា ។ ដំណឹងនេះនាំឲ្យយើងរីករាយពន់ពេក ។ ពង្សាវតារចិននេះចែងថា ព្រះរាជានគរភ្នំ ជារាជវង្ស កៅ-ចិន-ជូ (កៅណ្ឌិន្យ) ព្រះនាមចូ-យេ៉-ប៉ា-ម៉ូ (ជយវរ្ម័ន) គឺព្រះបាទកៅណ្ឌិន្យជយវរ្ម័ន ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១០២១ (គ.ស.៤៧៨)[២] កាលដើមទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ (ព្រះឥសូរ) តែតមក ទ្រង់កាន់ពុទ្ធសាសនាវិញ ។ ក្នុងរជ្ជកាលព្រះអង្គ យើងបានដឹងថា "ក្នុង ព.ស. ១០២៧ (គ.ស.៤៨៤) ទ្រង់បានបញ្ជូន ភិក្ខុណា-គា-សាីង គឺភិក្ខុសាក្យនាគសេនៈជាតិឥណ្ឌា ជាបេសកជនទៅកាន់រាជសំណាក់ព្រះចៅក្រុងចិន វូ-ទី ទ្រង់បានផ្ញើគ្រឿងបណ្ណាការទៅថ្វាយព្រះចៅក្រុងចិន គឺរូបនាគរាជមាស១ រូបដំរីធ្វើពីខ្លឹមចន្ទន៍ក្រស្នា១ ព្រះស្តូបពីរធ្វើពីភ្លុក សំពត់ពីរផាប់ ចានកែវពិទូរ្យ (?) ពីរ ថាសដាក់ស្លាធ្វើពីក្រាស១ ។ ភិក្ខុសាក្យនាគសេននេះទៅដល់រាជសំណាក់ព្រះចៅក្រុងចិនហើយ បានរៀបរាប់ពីស្ថានភាពនៅប្រទេសនគរភ្នំគ្រប់ប្រការ ថ្វាយព្រះពរព្រះចៅក្រុងចិនឲ្យទ្រង់ជ្រាប ។ ចំពោះសាសនា ភិក្ខុនាគសេនៈថ្វាយព្រះពរថា ប្រទេសនគរភ្នំកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ(ព្រះ

---

១ — P. Pelliot Le Founan, P. 66. — ២ — L. Briggs, the ancient Khmer Empire, P, 28.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ផ្សារ) ឯព្រះពុទ្ធសាសនាក៏ចំរើនរុងរឿងណាស់ដែរ មានសមណច្រើនក្រៃលែង ចំណែកការប្រតិបត្តិព្រះពុទ្ធវចនៈក៏រឹងរឹតតែប្រពៃណាស់ទៀត ។ កាលភិក្ខុនាគសេនៈត្រឡប់មកវិញ, ព្រះចៅក្រុងចិនបានសុំឲ្យលោកនាំគ្រឿងបណ្ណាការមកថ្វាយព្រះចៅនគរភ្នំវិញដែរ គឺសំពត់ព្រែផ្ទពណ៌បៃតង, ស្វាយ មានផ្កា ពណ៌ខៀវ, លឿងមួយមុខ១៤ផាប់ ។ ក្នុងព.ស. ១០៤៦ (គ.ស.៥០៣) ព្រះបាទកៅណ្ឌិន្យជយវរ្ម័នបានបញ្ជូនរាជទូតម្នាក់ទៅកាន់រាជសំណាក់ព្រះចៅក្រុងចិនទៀត ។ គ្រានេះ, ទ្រង់បានឲ្យនាំគ្រឿងបណ្ណាការសុទ្ធសឹងជាផលិតផល ប្រទេសទៅថ្វាយព្រះចៅក្រុងចិន គឺព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រនិងវត្ថុដទៃទៀតច្រើន ។

ទ្រង់បានបញ្ជូនភិក្ខុខ្មែរពីរអង្គ ទៅប្រែព្រះត្រៃបិដកនៅប្រទេសចិន ។ ព្រះថេរទាំងពីរអង្គនេះគង់នៅប្រទេសចិនក្នុងរវាងខាងចុងគ្រិស្តសតវត្សទី៥ និងខាងដើមគ្រិស្តសតវត្សទី ៦ ។ ព្រះថេរៈមួយអង្គនាមសេង-គា-ប៉ូ-ឡូ (១) គឺសង្ឃបាលោ កើតពីគ.ស. ៤៦០ លោកចេះភាសាច្រើនភាសា . ។ ព្រះចៅក្រុងចិននាម វូ ក្នុងរាជវង្សលាងគ.ស.៥០៦ សុំនិមន្តលោកឲ្យជួយប្រែព្រះត្រៃបិដក លោកធ្វើការអស់រយៈ ១៦ ឆ្នាំ នៅហ្វូណន-ក្វាង (Founan-Kouan) ប្រែថា «ការិយាល័យប្រទេសនគរភ្នំ» ។ ព្រះសង្ឃបាលត្ថេរនេះសុគតក្នុងឆ្នាំ ព.ស. ១០៦៧ (គ.ស.៥២៤) ។

---

១ — P. Pelliot, Le Founan (Nanjio Catalogue, appendice 11, N· 102 et N· 101) P. 93.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះថេរៈមួយអង្គទៀត[១] នាមថា ម៉ុន-តូ-ឡូ (Man-to-lo) មន្ទ្រៈឬ ម៉ុន-តូ-ឡូ-សេង (Man-to-lo-Sien) មន្ទ្រសេនៈ ។ លោកនិមន្តទៅដល់រាជសំណាក់ព្រះចៅក្រុងចិននាមវូ (រាជវង្សលាង) ក្នុងព.ស.១០៤៧ (គ.ស. ៥០៣) ហើយបានទទួលព្រះរាជានុញ្ញាតឲ្យចូលធ្វើការប្រែព្រះត្រៃបិដកជាមួយព្រះមហាសង្ឃបាលត្ថេរ ។ សេចក្ដីប្រែជាស្នាព្រះហស្តព្រះថេរទាំងពីរអង្គនេះ មានជាប់ព្រះនាមនៅក្នុងព្រះត្រៃបិដកចិនរហូតមកដល់បច្ចុប្បន្នកាល ។ កាលសម្ដេចព្រះឧបយុវរាជសីហនុវរ្ម័នស្ដេចយាងទៅប្រទេសចិនក្នុង គ.ស. ១៩៥៦ កាលនោះអធិបតីសមាគមពុទ្ធសាសនាចិនបានយកសេចក្ដីប្រែជាស្នាព្រះហស្ត នៃព្រះថេរៈទាំងពីរអង្គនេះមកថ្វាយសម្ដេច ទុកជាសក្ខីភាពនៃមិត្តភាពខ្មែរ-ចិន ដែលមានអាយុ ១៥០០ឆ្នាំមកហើយ ។

ដទៃពីប្រភពចិន យើងមានសិលាចារឹកពីកន្លែងទៀតពីសម័យនគរភ្នំខាងចុងគ្រិស្តសតវត្សទី៥ ថ្លែងពីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ។ សិលាចារឹកមួយនៅប្រាសាទ ៤ ល្វែង[២] ស្រុកទឹកខ្មៅ (ខេត្តព្រៃកប្បាស) រៀបរាប់ថា ព្រះរាជកុមារនាមគុណវរ្ម័នរាជបុត្រនៃព្រះរាជា «ព្រះចន្ទនៃរាជវង្សកៅណ្ឌិន្យ» ទ្រង់ត្រាស់បង្គាប់ឲ្យចារឹកទុកថា ទីនេះព្រះវរបិតាព្រះអង្គយកបានមកពី «ទីទឹកភក់» ហើយតែងតាំងទ្រង់ឲ្យត្រួតត្រា ។

---

១ — P. Pelliot, Le Founan (Nanjio, Catalogue, appendice II N· 102 et 101) P. 93. — ២- G. Cœdès, BEFEO. XXXI, P. 1 et suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

សិលាចារឹកមួយទៀតនៅអ្នកតាដំបង់ដែក[១] (ខេត្តតាកែវ) ថ្លែងពីព្រះអគ្គ-មហេសីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ននាមព្រះនាងកុលប្រភាវតី ទ្រង់មានប្រាថ្នាចេញចាកលោក ហើយទ្រង់បានកសាងទេវាល័យដំកល់បដិមា-ករព្រះវិស្ណុធ្វើពីមាសសុទ្ធ ព្រមទាំងលំនៅសម្រាប់ព្រាហ្មណ៍ទីងស្រះ ។ ព្រះនាងកុលប្រភាវតីអគ្គនេះ ជាព្រះរាជជននីរាជកុមារគុណវរ្ម័ន ។ ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នទ្រង់ទិវង្គតក្នុងព.ស. ១០៥៧ (គ.ស. ៥១៤) ។

ព្រះបាទរុទ្រវរ្ម័នទ្រង់ឡើងសោយរាជ្យតសន្តតិវង្សព្រះវរបិតាមក ។ ប្រភពចិនពង្សាវតាររាជវង្សលៀងនិយាយតមកទៀតថា ព្រះបាទលៀវ-តូ-បា-មូ គឺរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះស្នំ មិនមែនជាអគ្គមហេសីទេ ទ្រង់ធ្វើឃាតមកុដរាជកុមារ (ប្រហែលជារាជកុមារគុណវរ្ម័នជាព្រះរាជបុត្រព្រះអគ្គមហេសីព្រះនាងកុលប្រភាវតី ?) ហើយឡើងសោយរាជ្យក្នុង គ.ស. ៥១៤ គឺឆ្នាំដែលព្រះវរបិតាទ្រង់ទិវង្គត ។ លុះបានឡើងសោយរាជ្យហើយ ទ្រង់ក៏បញ្ជូនរាជទូតទៅកាន់សំណាក់ព្រះចៅក្រុងចិនច្រើនដង ៗ រាជទូតដែលទ្រង់បញ្ជូនក្នុងព.ស.១០៦២ (គ.ស. ៥១៩) បាននាំយកគ្រឿងបណ្ណាការព្រះអង្គ គឺបដិមាករនាងទេវី ?[២] (Image heureuse) ធ្វើពីខ្លឹមចន្ទន៍ឥណ្ឌៀ ស្លឹកពោធិព្រឹក្ស គជខ្យង គ្រឿងទេស គ្រឿងក្រអូបផ្សេង ៗ ច្រើនទៅថ្វាយព្រះចៅក្រុងចិន ។ រាជទូតដែលទ្រង់បញ្ជូនក្នុងព.ស. ១០៨២ (គ.ស. ៥៣៩) បាននាំគ្រឿងបណ្ណាការព្រះអង្គ

១ — G. Cœdès, JGIS IV, 117 suiv. — ២- P. Pelliot, Le Founan, tiroge à part P. 79.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គឺ សត្វមាសព្រមទាំងផលិតផលប្រទេសដទៃទៀត ។ រាជទូតនេះបានក្រាបទូលព្រះចៅក្រុងចិនថា នៅប្រទេសនគរភ្នំមានព្រះបរមសារីរិកធាតុ គឺព្រះកេសមួយសរសៃវែងចំនួន ៣ ម៉ែត្រ ។ ទ្រង់ជ្រាបដំណឹងប្រសើរនេះហើយ ព្រះចៅក្រុងចិនបញ្ជូនភិក្ខុវេ-យុន-ប៉ាវឲ្យតាមរាជទូតខ្មែរមកដណ្ដើមព្រះបរមសារីរិកធាតុនោះយកបាត់ហូតឥឡូវនេះទៅ ។

ប្រភពចិននេះ មានសេចក្ដីថ្លើយស្របនឹងសិលាចារឹកខ្មែរនៅប្រាសាទតាព្រហ្មទន្លេបាទីពីក្នុងពុទ្ធសតវត្សទី ១១ (គ្រិស្តសតវត្សទី៦) ថា ព្រះបាទរុទ្រវរ្ម័នជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជយវរ្ម័ននេះ ទ្រង់កាន់ពុទ្ធសាសនាដែរ ហើយគោរពព្រះបរមសារីរិកធាតុនៃអង្គព្រះសម្មាសម្ពុទ្ធ ដូចមានសេចក្ដីក្នុងសិលាចារឹកនោះថា (១) ៖

«ព្រះជិនស្រីទ្រង់ឈ្នះនូវសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា ទ្រង់ប្រកបដោយសម្បទាគ្រប់ប្រការ មានពោធិញ្ញាណឥតទើសទាល់សល់បំពាក់អ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មានព្រះយសដ៏ទូលំទូលាយ ឥតមានមោះមន្ទិលអ្វីឡើយ ហើយផ្សាយទូទៅគ្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វដែលលិចលង់ក្នុងវាលវដ្ដសង្សារគឺត្រៃភព ហើយបានដល់ត្រើយត្រាណឋានព្រះនិព្វានដ៏ឧត្ដមឥតអ្វីប្រៀបបានឡើយ ។ ព្រះស្រីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្ដល់ប្រយោជន៍ធំដល់សព្វសត្វទាំងឡាយ ក៏នៅតែផ្ដល់

១ – G. Cœdès, BEFEO. XXXI, P. 8 et suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រយោជន៍ដល់សព្វសត្វ លុះរហូតមកដល់ឥឡូវនេះ..... ។ អំពើជាព្រះរាជកុសលដែលទ្រង់ (ព្រះបាទស្រីធម្មរាជាវរ័ន) បានបំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះរាជករណីយកិច្ចប៉ុណ្ណោះទេ គឺទ្រង់បំពេញដើម្បីអនុគ្រោះដល់លោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ... ទ្រង់បានតាំងព្រះអង្គពេញជាឧបាសក ដែលឥតមានអំពើបាបលាមក...» ។

សេចក្តីប៉ុណ្ណោះនាំឲ្យយើងដឹងបានថា ក្នុងរជ្ជកាលព្រះបាទស្រីធម្មរាជាវរ័ន យើងមានព្រះបរមសារីរិកធាតុគឺព្រះកេសមួយសរសៃ សម្រាប់ជាទីសក្ការបូជា តែគួរអនិច្ចាយើងត្រូវខាតបង់លែងបានគោរពទៅ ដោយព្រះចៅក្រុងចិន (រាជវង្សស៊្រីខាងត្បូង) យកបាត់ទៅ ។ រឿងទំនៀមគោរពព្រះបរមសារីរិកធាតុនេះ នៅប្រទេសភូមាយើងបានដឹងថា ប្រពៃណីមាននិយាយថា តបុស្សៈនិងភល្លិកៈ ជាបឋមឧបាសកនោះជាជាតិមន បានព្រះកេសធាតុយកមកដំកល់ទុកក្នុងសិង្គុត្តរចេតិយ៍ ឬចេតិយ៍ស្វេតាគង ។ ចុះព្រះបរមសារីរិកធាតុរបស់យើង ដែលបែងទុកក្នុងសិលាចារឹកប្រាសាទតាព្រហ្ម ទន្ទេបាទីនេះ តើបានពីណាមក ? គួរទឹងឲ្យនឹកថា ព្រះបរម-សារីរិកធាតុនេះ ជាមរតករបស់តបុស្សៈនិងភល្លិកៈទុកឲ្យជាតិខ្មែរ ព្រោះជាសាច់សន្តានជាមួយគ្នា ។

ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ននិងព្រះបាទស្រីធម្មវរ្ម័ននេះ ព្រះពុទ្ធសាសនាចំរើនរុងរឿងណាស់ ។ ព្រះបាទស្រីធម្មវរ័ន ប្រហែលជាទ្រង់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទីវត្តក្នុងរាំងព.ស. ១០៨៣ (គ.ស. ៥៤០) ។

សម័យនគរភ្នំ ក្នុងរជ្ជកាលនៃព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ននិងព្រះបាទរុទ្រវរ្ម័ន កើតមានពុទ្ធរូបច្រើនអង្គ ធ្វើពីថ្ម, ពីសំរិទ្ធ ឬពីឈើ ជាការរចនាខ្មែរ បែបអមរាវតី, គុប្ត, គន្ធារៈ, មថុរា ឬអជន្តា ។ ភ្នំដា(១) នៅអង្គរបុរី ជាមជ្ឈមណ្ឌលនៃការកសាងបដិមាករ មានកេរ្តិ៍ឈ្មោះល្បីល្បាញ។ បដិមាករ ការរចនាបែបភ្នំដា ផ្សាយខ្ចរទៅពេញផែនដីនគរភ្នំ ទិសខាងកើតទៅដល់ភាគខាងត្បូងនៃវៀតណាមកណ្តាល ។ នៅមឿងថៃយ៉ា-(មឿងជយា, សៀមភាគក្រោម) មានរូបអវលោកិតេស្វរៈមួយ ការរចនាបែបភ្នំដា ។ លោកសឹដែសថា រូបនេះ មានការរចនាដូចហរិហរៈនៅអាស្រមមហាឬសី ។

ព្រះពុទ្ធរូបការរចនាបែបភ្នំដាចែកជា ២ មណ្ឌល(២)គឺៈ

១– នៅអង្គរបុរីនិងទីជិតខាង មានព្រះពុទ្ធរូបធ្វើពីថ្មចាស់ជាងគេបំផុតនៅអាស៊ីភាគអាគ្នេយ៍ ។

២– នៅត្រពាំងវែង ខាងត្បូងខេត្តព្រះត្រពាំង (ត្រាវិញ) ។

ព្រះពុទ្ធរូបថ្មនៅវត្តរលក(៣)ចាស់ជាងគេ ការរចនាខ្មែរ បែបគុប្តៈ ទ្រង់សណ្ឋិតឈរ រពព្រះហស្ត ស្រុកព្រៃកប្បាស (ខេត្តតាកែវ) ពុទ្ធសត-វត្សទី ១០(គ្រិស្តសតវត្សទី៥) ។ ព្រះពុទ្ធរូបថ្មនៅត្រឹងទៀង ទ្រង់សណ្ឋិត

---

១- P. Dupont, statuaires préankoriennes, P. 66-67. - ២- Ibid. P. 189 et suiv. — ៣- G. Groslier, in Etudes Asiatique, BEFEO. I, P. 304.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ឈរ រាព្រះហស្ត (ខេត្តលង់ហោ) ពុទ្ធសតវត្សទី ១០ ។ ព្រះពុទ្ធរូបឈើ (១) ទ្រង់សណ្ឋិតឈរ រាព្រះហស្តនៅទឹកខ្មៅ (ខេត្តព្រែកឫស្សី) ពុទ្ធសតវត្សរ៍ទី ១១ (គ្រិស្តសតវត្សរ៍ទី ៦) ។ ព្រះពុទ្ធរូបសំរិទ្ធ នៅវត្តបាណន់ (ខេត្តបាត់ដំបង), ព្រះពុទ្ធរូបនៅទួលព្រះធាតុ (ខេត្តកំពង់ស្ពឺ), ទ្រង់សណ្ឋិតឈរ រាព្រះហស្តដូចគ្នា ។ ព្រះពុទ្ធរូបនៅសីងថ (ខេត្តព្រះត្រពាំង) ព្រះពុទ្ធរូបនៅត្រពាំងវែង (ខេត្តព្រះត្រពាំង) ពីរអង្គនេះ គង់ខាត់សមាធិ ។ មានព្រះពុទ្ធរូបនៅវត្តអាចារ្យចាស់ (ខេត្តព្រះត្រពាំង) មានព្រះពុទ្ធរូបនៅកាប់សាំងហ្សាក់ (Cap Saint Jacques) (២) ។ ព្រះពុទ្ធរូប ៣អង្គ មានចារឹកពុទ្ធភាសិតថា យេ ធម្មា... ។ មួយអង្គនៅវត្តឈ្នះ ជិតអង្គរបុរី (ខេត្តតាកែវ), មួយអង្គនៅត្រពាំងវែង (ខេត្តព្រះត្រពាំង), មួយទៀតនៅទួលព្រះធាតុ (ខេត្តកំពង់ស្ពឺ) ។ ព្រះពុទ្ធរូបទាំងនេះ (៣) ជាការរចនាភ្នំដា អង្គរបុរី បែបអមរាវតី ដូចព្រះពុទ្ធរូបនៅដុងយឿង (វៀតណាមកណ្ដាល), នៅទួលសេគុនតាំង (សុមាត្រា), នៅជេម្បែរ (ជ្វា), នៅស៊ុកេនដេង (កោះសេឡេប) ។ ឯព្រះពុទ្ធរូបនៅនគររាជសី-មា នៅនគរបឋម (សៀម) ជាការរចនាភ្នំដា នៅអង្គរបុរីដែរ ។ នៅបុរាណដ្ឋាន (៤) អុក-កែវ សម័យនគរភ្នំ លោក ល.ម៉ាល្លេរេត៍ បានរកឃើញ

---

១- L. Malleret. Pour comprendre la sculpture Bouddhique et Brahmanique en Indochine. PL. III. — ២- P. Dupont. statuaires préankoriennes. P. 190. — ៣- Ibid. P. 22. — ៤- L. Malleret. Les fouilles d'Oc-Eô. BEFEO, XLV. P. 86.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះពុទ្ធរូបបុរាណធ្វើពីសំរិទ្ធច្រើនអង្គ ការរចនាបែបគន្ធារៈនិងអមរាវតី ។

សេចក្តីរៀបរាប់មកប៉ុណ្ណេះ សំដែងឲ្យឃើញថា ព្រះពុទ្ធសាសនាថេរវាទចំរើនរុងរឿងណាស់ក្នុងសម័យនគរភ្នំ ហើយមិនដែលសាបសូន្យទៅក្នុងសម័យណាមួយទេ មិនមែនដូចពាក្យលោកចិនយី-តឹង [(១)] (Yi Tsing) ដែលលោកសរសេរកាលលោកមកកាន់អាស៊ីអាគ្នេយ៍ ពី ព. ស. ១២១៤-១២៣៨ (គ.ស. ៦៧១-៦៩៥) ថា "នៅប្រទេសនគរភ្នំ ព្រះពុទ្ធសាសនាចំរើនរុងរឿងណាស់ ហើយផ្សាយទូទៅ តមកមានព្រះរាជាមួយព្រះអង្គមិនសព្វព្រះទ័យ ហើយទ្រង់បំផ្លាញចោលអស់ទៅហើយ ឥឡូវនេះ សូម្បីតែភិក្ខុមួយអង្គក៏មិនសល់នៅផង„ នោះទេ ។

សម័យចេនឡា.— ពុទ្ធសតវត្សរ៍ទី១១ ទៅទី១៤ (ព.ស. ១០៩៣-១៣៤៥) គ្រិស្តសតវត្សទី ៦ ទៅទី ៩ (គ.ស. ៥៥០ – ៨០២) ពង្សាវតារចិន (រាជវង្សតាំង) ខាងដើមពុទ្ធសតវត្សរ៍ទី ១១ (គ្រិស្តសតវត្សរ៍ទី ៦) និយាយថា នៅប្រទេសហ្វូណន មានការកើតប្រែនៅក្នុងប្រទេស ។ ប្រទេសចេនឡាលើកទ័ពមកវាយក្រុងទូមូ (To-Mou)= វ្យាធបុរៈ (បាភ្នំ) ហើយព្រះរាជាវ្យាធបុរៈ ចេញទៅគង់នៅក្រុងខាងត្បូង ឈ្មោះណា-ហ្វូ-ណា (Na-Fou-Na) នរវរនគរ (អង្គរបុរី ?) ។ ពង្សាវតារចិន (រាជវង្សស៊ួយ) និយាយថា មានក្សត្រប្រទេសចេនឡានាម ចេ-ទូ-សេ-នា. ចិត្រសេនា គឺព្រះបាទភវវរ្ម័នទី ១ មកដណ្តើមយកក្រុងភ្នំ

---

១— P.Pelliot, Le Founan, loc. cit., P.284.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

បាន ។ សម័យនេះ អ្នកប្រាជ្ញពង្សាវតារសន្មតឈ្មោះថា « សម័យចេនឡា » ។ មានព្រះរាជាសោយរាជ្យតសន្តតិវង្សមកគឺព្រះបាទភវវរ្ម័នទី ១ ចិត្រសេនា (ពាក់កណ្ដាលគ្រិស្តសតវត្សរ៍ទី ៦ ) មហេន្ទ្រវរ្ម័ន (ខាងចុងគ្រិស្តសតវត្សរ៍ទី ៦) ឦសានវរ្ម័ន ក្នុង គ.ស. ៦១៦-៦២៦, ភវវរ្ម័នទី ២ ក្នុង គ.ស. ៦៣៩, ជយវរ្ម័នទី ១ ក្នុង គ.ស. ៦៥៧-៦៨១ ។ ពុទ្ធសាសនាថេរវាទចំរើនរុងរឿងនៅឡើយ តែសម័យនេះ មានការប្រែប្រួលគួរឲ្យកត់សំគាល់ គឺមានពុទ្ធសាសនាលទ្ធិមហាយានចូលមកប្រទេសកម្ពុជាយើងមុនដំបូងនៅខាងដើមពុទ្ធសតវត្សរ៍ទី ១២ ។

ក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី ១ ព.ស. ១១៥៩-១១៦៩ (គ.ស. ៦១៦-៦២៦) មានសិលាចារឹកមួយ(១)នៅសម្បូណ៌ព្រៃគុក (ឦសានបុរៈ) ខេត្តកំពង់ធំ ក្នុងព.ស. ១១៦៩ (គ.ស. ៦២៦) បញ្ជាក់ថាមានព្រះពុទ្ធសាសនា ។ មានការគោរពនាគរាជមុចលិន្ទដែលប្រក់ព្រះពុទ្ធរូប ។ សិលាចារឹកនេះនិយាយពីព្រាហ្មណ៍ឈ្មោះ បសុបតិ ឆាវជា វិទ្យាវិសេសៈ ជាអ្នកប្រាជ្ញមានការចេះដឹងខ្ពង់ខ្ពស់ ចេះអធ្យ័ន គឺផ្លូវវិទ្យាខាងវេយ្យាករណ៍ ខាងវៃសេសិកៈ ខាងន្យាយៈ ខាងសមីក្ស (សាំខ្យា,) និងពុទ្ធសាសនា ។ ក្នុងសិលាចារឹកនៅក្នុបាកយណ៍ ក៏ឃើញមានព្រាហ្មណ៍ឈ្មោះ បសុបតិនេះដែរ ។ លោកសឺដែសសរសេរថា សិលាចារឹកនេះជាគ្រឿងសំគាល់ឲ្យដឹងថា មានសិលាចារឹកពុទ្ធសាសនាជាបឋមក្នុងសម័យចេនឡា ។

---

១ – L. Finot, BEFEO. XXVIII. P. 44 et suiv.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តែម៉ាទួនលិន(១) , តាមពង្សាវតារចិនរាជវង្ស ស៊ួយ ថា ក្នុងរាជ្យអង្គនេះ មានភិក្ខុ ភិក្ខុនី ច្រើនអង្គ ៗ សម័យនេះ មានសិលាចារឹកដែលនិយាយពីពុទ្ធសាសនាច្រើនទៀត ។

ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី២ ព.ស. ១១៨២ (គ.ស. ៦៣៩) មានសិលាចារឹក(២)មួយនៅភូមិខាវកំពង់ជិតអរញ្ញប្រទេស (សៀម) ថ្លែងពីឧបា-សកម្នាក់ឈ្មោះជា លីនាហ្វ បានសាងព្រះវិហារមួយឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ព្រមទាំងថ្វាយទ្រព្យសម្រាប់វិហារទាំងទាសាចាស់ក្មេង ចំនួន ៣២ នាក់រាប់ទាំងអ្នករក្សាចំការដូងស្លាច្រើនរយដើមផង ។

ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ១ ព.ស. ១២០០.១២២៤ (គ.ស. ៦៥៧.៦៨១) មានសិលាចារឹកពីរ(៣) មួយនៅវត្តព្រៃវៀរក្នុងព.ស. ១២០៦ (គ.ស.៦៦៤) ស្រុកកំពង់ត្របែកខេត្តព្រៃវែង (កាលដើមជាខេត្តបាភ្នំ) ចែងទុកថា មានភិក្ខុពីរអង្គជាបងប្អូនបង្កើតជាតិជាក្សត្រចេញទ្រង់បព្វជាហើយគង់នៅវត្តព្រៃវៀរនេះ ដូចសេចក្ដីក្នុងចារឹកនោះថា "ក្នុងដែនដីដែលទ្រង់គ្រប់គ្រងនេះ មានភិក្ខុពីរអង្គជាបងប្អូនបង្កើត ទាំងពីរអង្គ មានសីល ជាពហូសូត្រ សុភាព មានខន្តី មានខ្លួនទូន្មានហើយ មានករុណា មានសមាធិចិត្តជាអរិយទ្រព្យ មាននាមខាងដើមជារតនៈដូចគ្នា ហើយខាងចុង មួយជាភាណុ មួយទៀតជាសិង្ហៈ គឺភិក្ខុរតន-

១ — G. Cœdès, Etat hindouisés, P. 130. — ២- G. Cœdès, Inscription du Cambodge, Vol. V. P. 23. ៣ — A. Barth, Inscription du Cambodge, P. 60 et suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

កាណ្ឌ១ ភិក្ខុវតនសិង្ហ: ១ ។

វត្តព្រៃវៀរនេះ ជាវត្តមួយបរមបុរាណបិតថេរបីរកាលតាំងពីកាលនោះរហូតមកដល់សព្វថ្ងៃនេះ ។ អ្នកស្រុកជិតខាងវត្ត ចាំរឿងបុរាណត ៗ គ្នាមក និយាយបញ្ជាក់ថា វត្តនេះព្រះរាជាសម័យពីដើមបានថ្វាយចំពោះព្រះសង្ឃ ហើយប្រគល់ឲ្យភិក្ខុពីរអង្គជាតិជាក្សត្រជាបងប្អូនបង្កើតថែរក្សា ហើយហាមប្រាមមិនឲ្យជនណាមួយទៅបៀតបៀនវត្តនេះទេ ។ អ្នកស្រុកហាមប្រាមកូនចៅត ៗ គ្នាមក ឲ្យវៀរមិនឲ្យទៅកាប់ឈើព្រៃក្នុងវត្តនេះសោះ ហើយខ្ជាប់ត ៗ គ្នាមកដល់សព្វថ្ងៃនេះ បានជាវត្តនេះមានឈ្មោះថា «វត្តព្រៃវៀរ» រហូតមក ។

មួយទៀតនៅវត្តប្រាសាទស្រុកកំពង់ត្របែក ខេត្តព្រៃវែង (កាលដើមជាខេត្តបាភ្នំ) និយាយពីការថ្វាយទាសៈចំពោះពោធិសត្វ ៣ អង្គគឺ សស្តៈ១ មៃត្រេយៈ១ អវលោកិតេស្វរៈ១ ទាំង ៣ អង្គនេះ មានសមណស័ក្តិជា «ព្រះ កម្រតាង អញ» ។ សិលាចារឹកនេះជាខ្មែរ លោកអាយម៉ូនិញេរ ថា ក្នុងគ្រិស្តសតវត្សទី៦ឬទី៧ ។ មានសិលាចារឹកមួយទៀតនៅសៀមរាប ពីព.ស. ១៣៣៤ (គ.ស. ៧៩១) និយាយពីការកសាងរូបពោធិសត្វអវលោកិតេស្វរៈ ទុកដើម្បីគោរពបូជា បូជនីយដ្ឋាននេះ សព្វថ្ងៃហៅថា ប្រាសាទ «តាកៀម» ។

សេចក្តីនេះត្រូវស្របគ្នានឹងឯកសារចិនដែរ ។ តង្វៀវតារប្រទេសខ្មែរសម័យចេនឡា ពុទ្ធសតវត្សទី ១៣ (គ្រិស្តសតវត្សទី ៧, ក្នុងរជ្ជកាល

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះបាទគ្លៀសានវរ្ម័ន មានទៅក្នុងពង្សាវតារចិន រាជវង្សស៊ួយ លោកម៉ា-ទួន លិន(១)សរសេរប្រហែលពីពុទ្ធសតវត្សទី ១៩ (គ្រិស្តសតវត្សទី ១៣) ថា៖

« ព្រះរាជាប្រថាប់នៅក្នុងព្រះរាជធានីក្រុង គ្លៀ-ប៊ូ-ណា (គ្លៀសានបុរះ) ។ ក្រុងនេះ មានគ្រួសារជាង២០គ្រួសារ ។ នៅកណ្ដាលក្រុង មានប្រាសាទមួយដែលទ្រង់ប្រោសប្រទានទទួលរាជបរិពារ ។ ក្នុងរាជអាណាចក្រទាំងមូលមានទីក្រុង ៣០ ។ ក្រុងនីមួយ ១ មានទីលំនៅនៃគ្រួសារច្រើនណាស់ ហើយមានចៅហ្វាយខេត្តម្នាក់ត្រួតត្រា ។ ព្រះរាជាទ្រង់ចេញគាន់ទីសាលប្រជុំជាទទ្បារក ៣ ថ្ងៃម្ដងរៀងទៅ ទ្រង់ប្រថាប់លើព្រះទែនធ្វើពីខ្លឹមចន្ទន៍ក្រស្នា ៥ ប្រភេទ ដែលប្រដាប់ដោយរតនវត្ថុ ៧ ប្រការ លើព្រះទែនមានស្វេតឆត្រ ជងធ្វើពីឈើមានផ្កា មុខព្រះទែនប្រកបក្ដុកកាយផ្កាយមាស ខាងក្រោយមានវង់រស្មីមាស... ។ នៅជិតក្រុង មានភ្នំមួយឈ្មោះ លិង-គា-ប៉ូ-ប៉ូ គឺលិង្គបព៌ត ។ នៅលើកំពូលភ្នំនេះ មានទេវាល័យមួយដែលជាកន្លែងសម្រាប់មនុស្សធ្វើយញ្ញពិធី មានទាហានមួយពាន់នាក់នៅចាំរក្សា ។ នៅចេនឡា មានប្រជាជនច្រើនកាន់ពុទ្ធសាសនា ។ អ្នកស្រុកធ្វើស្រែចំការ ។ល។

ក្នុងសម័យចេនឡា យើងឃើញថា ព្រះពុទ្ធសាសនាលទ្ធិមហាយានរុងរឿង តែមិនសូវមានរូបពោធិសត្វលោកេស្វរៈទេ មានមួយនៅខេត្តក្រមួនស មួយទៀតនៅប្រាសាទតាកៀម (សៀមរាប) ។ ឯព្រះ

---

១.— G Cœdès. Histoire ancienne des Etats hindouisés d'Extrême-Orient. P.90 et suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធសាសនាថេរវាទក៏មិនមែនសាបសូន្យដែរ មិនមែនដូចសេចក្ដីដែលលោកចិនយី-ត្សីងពោលមកខាងលើនោះទេ ។ តាមពិត សាសនាព្រាហ្មណ៍ក្ដី ពុទ្ធសាសនាក្ដី នៅជាមួយគ្នាឋិតថេរចិរកាលរហូតតមក ។

**សម័យមហានគរ.-** ពុទ្ធសតវត្សទី ១៤ ទៅទី ២០ (ព.ស.១៣៤៥-១៩៧៥) គ្រិស្តសតវត្សទី ៩ ទៅទី១៥ (គ.ស. ៨០២. ១៤៣២) ព្រះបាទជ័យវរ្ម័នទី ២ ទ្រង់ឡើងសោយរាជ្យក្នុងព.ស. ១៣៤៥ (គ.ស. ៨០២) ទ្រង់រៀបពិធីតាំងព្រះរាជធានីនៅលើមហេន្ទ្របព៌តគឺភ្នំគូលេន ។ ព្រះស្ដែងអញសិវកៃវល្យៈក៏តាមស្ដេចទៅនៅក្នុងព្រះរាជធានីនោះដែរ ។ កាលនោះ ទ្រង់បានមន្ត្រីព្រាហ្មណ៍ម្នាក់ឈ្មោះហិរណ្យទាមៈ ឲ្យមកជួយរៀបរាប់ពិធីប្រកាសឯករាជ្យជាចក្រពត្រាធិរាជ ហើយលើកកិត្តិយសព្រះអង្គជាតួអង្គ «ទេវរាជ គឺព្រះហរិហរៈ» ឡើងមុនដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ។ ព្រះបាទជយវរ្ម័នទី ២ នេះ ជាអង្គព្រះមហាក្សត្រមួយប្រសើរក្រៃលែង ទ្រង់បានរួបរួមប្រទេសដែលបែកបាក់គ្នាជាពីរ ដែលចិនហៅចេនឡាលើក្រោម ឲ្យទៅជាប្រទេសមានឯកភាពតែមួយឡើងក្នុងពង្សាវតារខ្មែរ ។ ព្រះរាជាអង្គនេះ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ ទ្រង់មិនបានកាន់ពុទ្ធសាសនាទេ តែពុទ្ធសាសនាទាំងពីរនិកាយក៏នៅជាមួយគ្នាដូចដើម ។ តាំងពីពុទ្ធសតវត្សទី ១៥ (គ្រិស្តសតវត្សទី ១០) រៀងរហូតមក (១) យើងសង្កេតឃើញមានកេរថ្លៃកពីអតីត

---

១— G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient P, 153,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សម័យ គឺព្រះរាជានឹងមុខមន្ត្រីកាន់សាសនាមិនសូវស្រុបគ្នាទេ បើព្រះរាជាកាន់សាសនាព្រាហ្មណ៍ មុខមន្ត្រីកាន់ពុទ្ធសាសនា បើព្រះរាជាកាន់ពុទ្ធ-សាសនា មុខមន្ត្រីកាន់សាសនាព្រាហ្មណ៍វិញ ។

ព្រះបាទឥន្ទ្រវរ្ម័នទី ១ ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១៤២០ (គ.ស. ៨៧៧) ទ្រង់តាំងព្រះរាជធានីនៅតម្បន់លលួស ស្រុកសូត្រ-និគមសព្វថ្ងៃនេះ ប្រាសាទបាគងជាហរិហរាល័យគឺជាឋានព្រះហរិហរៈ ។ ព្រះរាជាអង្គនេះ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ តែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ។(១) ក្នុងរជ្ជកាលព្រះអង្គ មានសិលាចារឹកមួយពី ព.ស.១៤២៩ (គ.ស.៨៨៦) នៅបាទប៉ុនកេប្រាប់ថា មានមន្ត្រីម្នាក់ឈ្មោះសោមាទិត្យៈ បានកសាងព្រះពុទ្ធរូបមួយអង្គ ជាសាស្តាក្រៃលែងជាងសាស្តាទាំងឡាយ ហើយថ្វាយព្រះនាមថា «ត្រៃលោក្យនាថ» ដើម្បីជួយស្រោចស្រង់មនុស្សលោកឲ្យរួចផុតពីការកើតនិងស្លាប់ ។ មួយទៀត ក្នុងរជ្ជកាលព្រះអង្គនេះ គេសង្កេតឃើញពាក្យថ្មីថា “កម្ពុជៈ” ។ សិលាចារឹកប្រាសាទព្រះគោកាលពី គ.ស. ៨៧៩ បានប្រើពាក្យថា «កម្ពុជៈ» ឬ “កម្ពុជទេស” មុនដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រោះពីអតីតកាល មិនដែលឃើញមានចារឹកថា “កម្ពុជៈ” នេះទេ ហេតុនេះហើយបានជាក្នុងកាលតមក យើងហៅប្រទេសយើងថា «កម្ពុជា» ។

ព្រះបាទយសោវរ្ម័នទី១ ជាព្រះរាជបុត្រទ្រង់ឡើងសោយរាជ្យពី

១ — G Cœdès, BEFEO, XXII. P. 63,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ព.ស.១៤៣២ (គ.ស.៨៨៩) ហើយទ្រង់លើកព្រះរាជធានីទៅនៅទីក្រុងឈ្មោះ «យសោធរបុរៈ» គឺអង្គរធំសព្វថ្ងៃនេះ ។ ព្រះរាជាអង្គនេះ ទ្រង់ជាពុទ្ធសាសនិកមួយអង្គដ៏ប្រសើរ ទ្រង់បានទទួលស្គាល់ពុទ្ធសាសនាមហាយានជាផ្លូវការមុនដំបូងបង្អស់ក្នុងពង្សាវតារប្រទេសខ្មែរ តែទ្រង់ប្រោសប្រាណសាសនាព្រាហ្មណ៍ដូចពុទ្ធសាសនាដែរ ។ ក្នុងកាលនោះពុទ្ធសាសនានិងសាសនាព្រាហ្មណ៍មិនមានការបៀតបៀនគ្នាទេ ។ ទ្រង់បានកសាងព្រហ្មាស្រម វៃស្ណវាស្រម និងសៅគតាស្រម (អាស្រមថ្វាយព្រះសុគត) ច្រើនកន្លែង ។ សិលាចារឹក(១)នៅប្រាសាទទេពប្រណម្យថ្លែងពីការកសាងសៅគតាស្រមនេះ ។ សាសនាទាំងអស់មានសិទ្ធិនិងបុព្វសិទ្ធិដូចៗគ្នា ។ រជ្ជកាលតមក ព្រះរាជាច្រើនអង្គកាន់សាសនាព្រាហ្មណ៍ ។

ព្រះបាទរាជេន្ទ្រវរ្ម័ន (ឥន្ទ្រវរ្ម័នទី២) ទ្រង់ឡើងសោយរាជ្យក្នុង ព.ស.១៤៨៧(២) (គ. ស.៩៤៤) ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះឥសូរ តែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ហើយការកសាងវត្តអារាមខាងពុទ្ធសាសនាមានកាន់តែច្រើនឡើងៗ ហើយកាន់តែសរសៀរចូលមកជិតព្រះរាជធានីថែមទៀត ។ ក្នុងរជ្ជកាលព្រះអង្គ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្រារិមថនៈជាទេវានប្រិយៈ ចេះវិជ្ជាស្ថាបត្យកម្មដូចអង្គវិស្សុកម្មទេវបុត្រ ហើយជាមហាពុទ្ធសាសនិកមួយរូប បានកសាង

---

១— G. Cœdès. La stêle de tep Pranam J. A. Mais-Avril 1908. ២— Id. La stèle Prè-Rùp (Inscription du Cambodge I )

AngkorLink.com CambodiaBuddhist.org ABCCambodia.com



វិហារ៣កន្លែងនៅបាតជុំ(១) មួយថ្វាយព្រះសម្មាសម្ពុទ្ធ មួយថ្វាយព្រះវជ្របាណិ មួយទៀតថ្វាយព្រះនាងប្រាជ្ញាបារមិតា ។ ព្រះរាជាអង្គនេះ(២) ទ្រង់មិនកាន់ពុទ្ធសាសនាពិតមែន តែទ្រង់តែងតាំងលោកកវីន្ទ្រារិមថនៈជាពុទ្ធសាសនិកជាប្រធានរដ្ឋមន្ត្រី ហើយទ្រង់សរសើរជាពិសេស ព្រមទាំងទ្រង់រៀបរាប់ពីបដិមាករដែលទ្រង់បានប្រទានថែមទៀតគឺ ១- ព្រះពុទ្ធរូបព្រះពុទ្ធជិនស្រីនៅជយន្តប្រទេស (គ.ស.៩៤៦) ២- ព្រះពុទ្ធរូបព្រះលោកនាថនិងរូបនាងទេវីពីរអង្គនៅកុដីស្វរៈ, ៣- ព្រះពុទ្ធបដិមាករព្រះជិនស្រីនិងរូបទិព្វទេវីមួយ (ប្រាជ្ញាបារមិតា ?) ព្រមទាំងរូបវជ្របាណិនៅប្រាសាទមេបុណ្យ (គ.ស. ៩៦៣) ។ ក្នុងរាជ្យនេះ សេរីភាពក្នុងការកាន់សាសនាទូលាយណាស់ ហើយនាំសាសនាព្រាហ្មណ៍លទ្ធិព្រះឥស្វរនិងពុទ្ធសាសនាឲ្យរលាយចូលគ្នាជាប់រហូតមកដល់ឥឡូវនេះ ។

ព្រះបាទជ័យវរ្ម័នទី៥ ជាព្រះរាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័ន ឡើងសោយរាជ្យក្នុងព.ស.១៥១១(គ.ស.៩៦៨) ។ ក្នុងរាជ្យព្រះអង្គ មានព្រឹត្តិការណ៍ដូចរាជ្យព្រះវរបិតាដែរ គឺទ្រង់កាន់សាសនាព្រាហ្មណ៍ដូចព្រះវរបិតា តែព្រះរាជត្រកូលនិងមន្ត្រីជាន់ខ្ពស់កាន់ពុទ្ធសាសនា ។ ទ្រង់តែងតាំងកីរ្តិបណ្ឌិតជាប្រធានរដ្ឋមន្ត្រី ដូចព្រះវរបិតាដែលតែងតាំងកវីន្ទ្រារិមថនៈជាប្រធានរដ្ឋមន្ត្រីដូច្នោះដែរ ។ សិលាចារឹក(៣)នៅវត្តស្រី-

---

១.— Inscription de Bat Chum J. A. Septembre-Octobre 1908 (traduction rectifiée). — ២ .— L. Briggs, the ancient Khmer Empire, P. 131-133. ៣ — G. Cœdès, stèle de vat Sithor, Inscription du Cambodge vol., VI, P. 195)

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សន្ធរថែងថា ក្តីបណ្ឌិតជាពុទ្ធសាសនិកដ៏មុះមុត ដូចសេចក្តីក្នុងសិលា-ចារឹកនេះថា ៖

«នមស្ការព្រះពុទ្ធ ព្រះធម៌ ព្រះពោធិសត្វ, ព្រះពុទ្ធមានកាយ ៣ គឺ ធម៌កាយ សម្ភោគកាយ និងនិម៌ាណកាយ (គាថាទី ១ ទៅទី ៩) សរសើរបារមីព្រះបាទជ័យវរ្ម័នទី ៥ ពីឆ្នាំ ៨៩៩ សកៈ គឺ គ.ស. ៩៧៧ (គាថាទី ៩ ទៅទី ១៨) សរសើរក្តីបណ្ឌិតដោយចំពោះការកែប្រែពុទ្ធសាសនាជារបៀបថ្មី ៗ តទៅ មាននិយាយអំពីបដិសន្ធរណពុទ្ធ-រូបច្រើនអង្គ អំពីអាជ្ញាព្រះពជាចំពោះការប្រតិបត្តិពុទ្ធសាសនា ។ល។»

ក្នុងសិលាចារឹកនេះ ពួកអ្នកប្រាជ្ញយល់ថា «មានការលាយសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាចូលគ្នា មុនដំបូងបង្អស់នៅក្នុងពង្សាវតារប្រទេសខ្មែរ» ។ សិលាចារឹកមួយទៀតនៅភូមិបន្ទាយនាង និយាយពីមន្ត្រីឈ្មោះត្រិកុវនវជ្រៈសាងបដិមាករ «ប្រាជ្ញាបារមិតា ឬ ភគវតី» គឺធម្មមាតានៃព្រះពុទ្ធពីគ.ស. ៩៨១ ព្រមទាំងវត្ថុនានាដែលថ្វាយដល់ព្រះជគទីស្វរៈទៀតផង ។ មន្ត្រីម្នាក់ទៀតឈ្មោះសោមវជ្រៈ ត្រូវជាបងថ្លៃនៃមន្ត្រីត្រិកុវនវជ្រៈ បានថ្វាយបដិមាករលោកេស្វរៈក្នុង គ.ស. ៩៨២ ។ សិលាចារឹកនៅប្រាសាទប្រជាកថែងពីព្រះរត្នត្រ័យ គឺព្រះស្រីឃនៈ (ព្រះពុទ្ធ) ព្រះធម៌និងព្រះសង្ឃ ។

ព្រះបាទសូរ្យវរ្ម័នទី ១ ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១៥៤៥ (គ.ស. ១០០២) ។ ព្រះអង្គជាបឋមក្សត្រពុទ្ធសាសនិកដែលបានទទួល

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្គាលព្រះពុទ្ធសាសនាជាផ្លូវការក្នុងសម័យមហានគរ មិនមែនគ្រាន់តែ ទទួលស្គាល់ប៉ុណ្ណោះទេ ទ្រង់បានជាព្រះរាជសាសនូបត្ថម្ភក៍ដ៏ប្រសើរ ទៀតផង តែសង្ករបណ្ឌិតដែលជាមន្ត្រីព្រះអង្គកាន់សាសនាព្រាហ្មណ៍ លទ្ធិព្រះឥសូរ ។ ព្រះរាជាអង្គនេះ [១] ទំនងជាព្រះរាជវង្សខាងព្រះវរបិតា មានការទាក់ទងមកពីព្រះរាជានៅក្រុងតាំព្រលិង្គៈ (តាម្ពលិង្គៈ) នៅ ជ្រោយម៉ាឡាយូ ដែលកាលនោះនៅក្នុងអំណាចអាណាចក្រស្រីវិជ័យ (កោះសុមាត្រា) ខាងព្រះវរមាតាជាប់ទាក់ទងមកពីព្រះរាជវង្សសប្តទេវកុល ពីព្រះនាងប្រាណាជាអគ្គមហេសីនៃព្រះបាទរាជេន្ទ្រវរ្ម័នទី ២ និងជាព្រះ នាយិកានៃការិយាល័យរបស់ព្រះបាទជយវរ្ម័នទី ៥ ផង ។ ពុទ្ធសាសនា លទ្ធិមហាយាន បានផ្សាយឥទ្ធិពលចូលមកប្រទេសខ្មែរខ្លាំងក្នុងរាជ្យព្រះ អង្គ គម្ពីរដីកាក្តី គ្រូបាអាចារ្យក្តី សុទ្ធសឹងតែចេញមកពីតាំព្រលិង្គៈដែល ជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា បានជាទីឋាននេះមានសមញ្ញាថា «ស្រី ធម្មិករាជនគរ ក្រុងនៃស្តេចធម៌ដ៏មានសិរី» (នគរស្រីធម្មរាជនៅភាគខាង ក្រោមប្រទេសថៃសព្វថ្ងៃនេះ) ។ ក្នុងរជ្ជកាលព្រះអង្គ រាជអាណាចក្រ ខ្មែរធំទូលាយណាស់ ព្រោះបានរួមទាំងលពបុរីជាអាណាចក្រមនសម័យ ទ្វារាវតី ជាដែនដីដែលមនមកពីថាទុន (សុធម្មបុរៈ) និងប៉ែកព្រមទាំងមន នៅទន្លេមេណាមនិងទន្លេ ឥរាវឌី (ឥរាវតី?) ដែលបានកសាងជារាមញ្ញប្រទេសឡើង ។ ព្រះបាទសូរ្យវរ្ម័នជាព្រះរាជាមានព្រះប្រាជ្ញាឈ្លៀវឈ្លាស

១ — L. Briggs, the ancient khmer Empire, P. 145 suiv. et G. Cœdès. Histoire ancienne des Etats hindouisés d'Extrême Orient. P. 171 suiv.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ណាស់ ទ្រង់ប្រកបដោយខន្តីធម៌យ៉ាងខ្ពង់ខ្ពស់ ទ្រង់ជាពុទ្ធសាសនិក លទ្ធិមហាយាន តែចេះគោរពហើយប្រោសប្រោណពុទ្ធសាសនាថេរវាទ ព្រមទាំងសាសនាព្រាហ្មណ៍ដោយធម៌ថែមទៀត មិនឲ្យសាសនាទាំងនេះមានមោះហ្មងនឹងគ្នាបានឡើយ ។ សិលាចារឹកខ្មែរនៅលវបុរី (១) ពី គ.ស. ១០២២-១០២៥ ថែងទុកថា ភិក្ខុមហាយានក្តី ភិក្ខុថេរវាទក្តី នៅជាមួយគ្នាសុខក្សេមក្សាន្ត ឯពួកតាបសយោគី ក៏ប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍បានដោយសេរី មិនមានការសង្កត់សង្កិនគ្នាទៅវិញទៅមកឡើយ ។ អ្នកប្រាជ្ញខាងសិល្បសាស្ត្របានឃើញថា មានការកើតព្រះពុទ្ធរូបប្រក់នាគដំបូងក្នុងរជ្យព្រះអង្គ ដែលមិនធ្លាប់មានមកពីអតីតកាល ។ ពិតមែនតែទ្រង់ជាក្សត្រពុទ្ធសាសនិក តែទ្រង់នៅគោរព "ទេវរាជ" (២) តាមប្រពៃណីរាជសម្បត្តិដូចដើម ។ លុះទ្រង់ទីវង្គតទៅ គេថ្វាយព្រះបច្ឆាមរណនាមព្រះអង្គថា "ព្រះនិព្វានបទ" ។

ព្រះបាទសូរ្យវរ្ម័នទី ២ ឡើងសោយរាជ្យក្នុង ព.ស. ១៦៥៦ (គ.ស. ១១១៣) ។ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះវិស្ណុ ហើយប្រហែលទ្រង់ទីវង្គតក្នុង ព.ស. ១៦៩៣ (គ.ស. ១១៥០) ។ តមក ព្រះបាទធរណីន្ទ្រវរ្ម័នទី ២ ឡើងសោយរាជ្យក្នុង ព.ស. ១៦៥០ ព្រះនាងស្រីជយរាជចូឌាមណីជាព្រះអគ្គមហេសី មានព្រះរាជបុត្រមួយព្រះអង្គ

---

១- G. Cœdès, Rec. Insciption du Siam II. P. 21-31. — ២- P. Dupont et G. Cœdès, les stèles de stok koh Thom. — Phnom-Sandak et Pravihar BEFEO; LXIII, 1943, P. 121.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រកបដោយគុណសម្បត្តិគ្រប់ប្រការ ជាមកុដរាជកុមារ ទៅអនាគតគឺ ព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះបាទធរណីន្ទ្រវរ្ម័នទ្រង់កាន់ពុទ្ធសាសនាមុតមាំណាស់ ។ សិលាចារឹក(១) (គាថាទី ១៧) នៅប្រាសាទតាព្រហ្មសរសើរព្រះអង្គថា៖

ធ្វាក្យេន្ទុធ្វាសេនសុធាជនិតាត្តប្តិរ៍ ភិក្សុទ្វិជចិជិនសាតក្តតក្បិសារៈ।
សាពញ្ញឃ្យក្សុរក្តុតាយតនាទសាពក្តាយាទជស្រជិនបាទក្តានតិយៈ॥

«ទ្រង់ (ព្រះបាទធរណីន្ទ្រវរ្ម័នទី ២) សព្វព្រះរាជហឫទ័យខ្លាំងចំពោះទឹកអម្រឹតនៃសាសនាព្រះចន្ទពោល គឺព្រះសាក្យមុនី ទ្រង់បានប្រគល់សិទ្ធិដល់ភិក្ខុព្រាហ្មណ៍នឹងប្រជាជនព្រះអង្គដែលចង់បាន ទ្រង់មានព្រះរាជបំណងចង់យកសារធម៌ពីកាយដែលមិនមានសារៈ ពោលគឺអាយតនៈជាអសុត ហើយទ្រង់បង្អោនព្រះកាយក្រាបថ្វាយបង្គំដោយគោរព ចំពោះព្រះបាទនៃព្រះជិនស្រីគ្រប់កាលទាំងពួង ។ ១៧ ។

ព្រះបាទជ័យវរ្ម័នទី៧ ឡើងសោយរាជ្យក្នុង ព.ស. ១៧២៤ (គ.ស. ១១៨១) ។ ព្រះអង្គជាព្រះរាជាមានព្រះកិត្តិនាមល្បីល្បាញបំផុតក្នុងពង្សាវតារខ្មែរ ទ្រង់ជាពុទ្ធសាសនិកដើម គោរពពោធិសត្វលោកេស្វរៈនឹងព្រះប្រាជ្ញាបារមីតាតាមខ្សែព្រះវរបិតា ។ ប្រពៃណីគោរព(២) «ទេវរាជ» ពីបុរាណកាលគឺតាំងពី ព.ស. ១៣៤៥ (គ.ស. ៨០២) មក ព្រះអង្គ

---

១— G. Coedès, la stèle de Ta-Prom. (BEFEO; VI. P. 72).
២.— G. Coedès Inscription de Pra Khan BEFEO. XLI. P. 285.—

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ផ្លាស់គោរព «ពុទ្ធរាជ» វិញ ព្រោះទ្រង់សព្វព្រះរាជហឫទ័យចំពោះទឹកអម្រឹតនៃសាសនាព្រះបន្ទូលព្រះសាក្យមុនី ។ សម័យនេះ ពុទ្ធចក្រក្តី អាណាចក្រក្តីចំរើនរុងរឿងអស្ចារ្យ ។ ក្សត្រមួយអង្គៗ ជាអង្គទេពតាំងអស់ ពោះទីវង្គតទៅហើយក្តី ពោះមានព្រះជន្មនៅក្តី គឺសុទ្ធតែជាអង្គពោធិសត្វ អវលោកិតេស្វរៈ ឬព្រះប្រាជ្ញាបារមីតាដែលប្រកបដោយព្រហ្មវិហារធម៌ ។ ពិតមែនតែទ្រង់កាន់ពុទ្ធសាសនាមុតមាំ តែទ្រង់ប្រោសប្រាណសាសនាព្រាហ្មណ៍ដែរ ។ សាសនាព្រាហ្មណ៍មិនធុនថយទេ ។ ក្នុងរាជ្យព្រះអង្គ ទ្រង់បានតែងតាំងព្រាហ្មណ៍ម្នាក់ឈ្មោះហ្ឫកេតុះ វណ្ណៈជាភារទ្វាជះ ស្រុកកំណើតនៅនរបតិប្រទេសជាបុរោហិតព្រះអង្គ ងារជាជយមហាប្រធាន ។ សិលាចារឹកនៅអង្គរធំថែងថា(១) « នៅកម្ពុជប្រទេសមានអ្នកប្រាជ្ញចេះដឹងត្រៃវេទច្រើនណាស់ » ។ មានបដិមាករ ២ គេជឿថាជាបដិមាករព្រះបាទជ័យវរ្ម័នទី ៧ គឺព្រះអង្គមានព្រះវរកាយធំសក្តិសម ព្រះកេសបួង បដិមរូបបែបនេះ មាននៅតាមរូបចម្លាក់ប្រាសាទនៅអង្គរ ។ បដិមាករមួយនៅប្រាសាទអង្គរធំ(២) មួយទៀតនៅប្រាសាទពិមាយ(៣) (ប្រទេសសៀម) ហើយគេយកទៅដំកល់ទុកក្នុងពិពិធភណ្ឌស្ថានក្រុងបាងកក ។

ក្នុងរជ្ជកាលព្រះអង្គ ប្រាង្គប្រាសាទរាជដ្ឋានមានកំពូលខ្ពស់ត្រដួចត្រដឹមស្កឹមស្កៃ សុទ្ធសឹងលោកេស្វរៈសមន្តមុខ ព្រះនេត្របិទពាក់កណ្តាល

១.— L. Finot, Les inscriptions d'Angkor BEFEO., XXV, P.403.—
២.— G. Cœdès. Pour mieux comprendre d'Angkor .—
៣.— G. Cœdès, les collections archéologiques au Musée Nationale de Bangkok, XII, 18-19.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សំឡឹងចុះមកក្រោម ហើយព្រះភក្ត្រញញឹមស្រស់ប្រិមប្រិយ ហៅថា «ញញឹមបែបសិល្បៈអង្គរ» គន់មើលទៅឃើញហាក់បីដូចតួអង្គព្រះបាទជ័យវរ្ម័នទី ៧ ដែលជាតួអង្គព្រះពោធិសត្វអវលោកិតេស្វរៈ ហោះយាងចុះពីឋានសុខាវតីមកផ្ចាក់ផ្ចួមបីបមថែរក្សាប្រជាជនខ្មែរព្រមទាំងសត្វលោកឲ្យបានសេចក្តីសុខក្សេមក្សាន្តនិរទុក្ខនិរភ័យ ផុសផុលកើតប្រុងប្រាងដេរដាសពាសពេញព្រះរាជអាណាចក្រកម្ពុជា ។ ទ្រង់បានកសាងប្រាសាទបន្ទាយក្តី តាព្រហ្ម, ព្រះខាន់, បាយ័ន, មន្ទីរពេទ្យ (អារោគ្យសាលា) តាមថ្នល់ធំដែលទ្រង់កសាងពីមហានគរទៅពិមាយ (សៀម), ទៅប្រទេសចម្ប៉ា ។ ក្រៅព្រះរាជធានីនៅមហានគរ ទ្រង់សាងប្រាសាទវត្តនគរ (កំពង់ចាម), តាព្រហ្ម ទន្លេបាទី (តាកែវ) ប្រាសាទមួយនៅបន្ទាយឆ្មាថ្វាយព្រះស្រីន្ទ្រកុមារជាព្រះរាជបុត្រ និងទីឋានដទៃទៀតច្រើនអនេក ដើម្បីឲ្យសមតាមព្រះរាជបំណងថា «កសាងប្រទេសកម្ពុជាឲ្យក្លាយទៅជាឋានសួគ៌ (និងកសាងប្រជាជនខ្មែរឲ្យទៅជាទេវតា) ។

ទ្រង់សាងប្រាសាទតាព្រហ្មហើយឲ្យឈ្មោះថា «ព្រះរាជវិហារ» ពីព.ស. ១៧២៩ (គ.ស. ១១៨៦) ឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ដើម្បីដំកល់បដិមាករព្រះនាងជ័យរាជចូឌាមណី ជាព្រះវររាជមាតា ទុកជាអង្គព្រះប្រាជ្ញាបារមិតា គឺជាមាតាបង្កើតព្រះពុទ្ធ និងបដិមាករតួអង្គព្រះរាជគ្រូមួយទៀតឈ្មោះជយមង្គលថ៌ៈ (១) ។ សិលាចារឹកនៅប្រាសាទតាព្រហ្ម ជាស្នាព្រះ-

១.— G. Cœdès, la stèle de Ta Prom (BEFEO, VI P.44)

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ហស្តព្រះរាជបុត្រព្រះអង្គព្រះនាមសូរ្យកុមារទ្រង់តែងឡើង រៀបរាប់ពីការកសាងនឹងការទំនុកបំរុងវត្តនេះ ឋមដើមនមស្ការ សរសើរបារមីព្រះបាទជ័យវរ្ម័នទី ៧, បញ្ជីវត្ថុគ្រឿងឧបភោគបរិភោគ វត្ថុសម្រាប់ពុទ្ធបូជា ។ ខ្ញុំដកស្រង់សេចក្តីខ្លះមកទុកក្នុងទីនេះ ។

### នមស្ការព្រះរតនត្រ័យ

សម្ភារវិស្តរវិភាវិតធម្មកាយ សម្ភោគនិម៌ិតវបុគ៌តនិគ្គក: ।
យោគោបភោជិនជិនាត្មជទេហភាជាំវុទ្ធាយភូតករុណាយ នមោស្តុ តស្មៃ ॥
វន្ទេ និរុត្តរមនុត្តរពោធិមាគ៌ំ ភូតាថ៌ទឝ៌ននិរាវរណៃកទ្ឫឞ្ដិម៌ ।
(១)
ធម្មំត្រិលោកវិទិតាមរវន្ទ្យវន្ទ្យមន្តវិសត្រុទ្វិរបណ្ឌវិខណ្ឌខឌ្គម៌ ॥
សម្យគ្ធិមុក្តិបរិបន្ថិតយា វិមុក្តសង្គា បិ សន្តតគ្ឫហីតបរាថ៌សង្គ: ।
សង្ឃោ មានជិនគ្នាសនគ្នាសិតានុភាវិ សង្ឃ្យាភិសំហិតហិតប្រភវោវតាត្វ: ॥

« ព្រះពុទ្ធដ៏មានបុណ្យអង្គណា មានកាយចែកជា ៣ ចំណែក គឺធម៌កាយ ១ សម្ភោគកាយ ១ និម៌ានកាយ ១ ដែលជាផលកើតចេញមកពីសម្ភារៈគឺបុណ្យ យើងខ្ញុំនមស្ការចំពោះអង្គព្រះពុទ្ធនោះ ដែលជាចំណែកនៃរាងកាយព្រះជិនស្រីនឹងបុត្រនៃព្រះជិនស្រី ហើយកើតបាន

---

១– អន្តរ៍សត្រូ+ឋទ+អរិ គឺ កាមៈ, ក្រោធៈ, លោភៈ, មោហៈ, មទៈ, មាត្សាយ៌ (មច្ឆរិយៈ) ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជាសរណៈនៃសត្វលោក ។១។

« យើងខ្ញុំសូមក្រាបបង្គំចំពោះព្រះធម៌ដ៏ក្សេម ជាមាគ៌ានៃពោធិ-ញាណដ៏ប្រសើរ ជាទ្រឹស្តីឯកបើកឲ្យបានយល់ធម៌ពិត ដែលជាធម៌គឺពួកអមរក្នុងត្រៃភពគួរគោរពវន្ទា ទុកជាព្រះខាន់សម្រាប់កាប់បំផ្លាញនូវគុម្ពបន្ទាពោលគឺសឹកសត្រូវខាងក្នុង ៦ ប្រការ ។២។

« ដោយអានុភាពព្រះសង្ឃដែលមានប្រកបនៃប្រយោជន៍រួមគ្នា សូម្បីអង្គលោករួចស្រឡះហើយដោយប្រពៃ អំពីសឹកសត្រូវនៃវិមុត្តិ-ញាណ ប៉ុន្តែលោកនៅជាប់ពាក់ព័ន្ធនឹងប្រយោជន៍នៃជនដទៃ ដែលអង្គលោកបានប្រតិបត្តិ ។ មកហើយ អង្គលោកស្វាធ្យាយន៍អង្គលោកផងបង្រៀននូវជិនសាសនាដល់ជនដទៃទាំងឡាយផង សូមការពារនូវលោកអ្នកទាំងឡាយគ្រប់គ្នាកុំឃ្លាតឃ្លាឡើយហោង ។៣។

ព្រះសូរ្យកុមារជាព្រះរាជបុត្រសរសើរបារមីចំពោះអង្គព្រះបាទជយវរ្ម័នទី ៧ ជាអនេកប្បការតទៅទៀត ត្រង់គាថាទី ៣៥ និងទី ៣៦ ដែលនិយាយពីកសាងព្រះរាជវិហារ (ប្រាសាទតាព្រហ្ម) សម្រាប់ដំកល់បដិមាករព្រះនាងស្រីជយរាជចូឌាមណី ទ្រង់មានព្រះបន្ទូលថា៖

ទត្យាទិតា តេនក្ខុជាគ្រូហិតធាត្រ្យាំ បុរីរាជវិហារនាម្នី ।
រត្នោល្លសន្តី ស្វណ៌ី វិភូមិតាង្គី មុនីន្ទ្រមាតុ៌រណោនិយុក្តា ॥
ប្រាតិម្ពប្រ៊ីជយរាជចូឌាមណី មណីទេវ្យាតិតបុណ្យទេហាមី ।
តស្យាញ្ជនន្យា ជិនមាតុមូតិ៌ មូតិ៌ សមូតិ៌ឲ្យក្នុក្នាង្កវិថៈ ॥

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



«បុរីឈ្មោះរាជវិហារ (ប្រាសាទតាព្រហ្ម) នេះមានអគ្គស្ថិតស្ថានហើយ ដោយសុវណ្ណក្តីប្រុះផ្ទុះប្រាក់ដោយពេជ្រ ទ្រង់(ព្រះបាទជ័យវរ្ម័នទី៧)បាន កសាងនៅលើផែនដី ដែលព្រះអគ្គបង្ហាំងយកមកបានដោយព្រះហស្ត ព្រះអង្គ ដើម្បីដំកល់ទុកនូវមុនិន្ទ្រមាតា ។ ៣៥ ។

«ទ្រង់ដំកល់ទុកនូវបដិមាករនៃព្រះជននីព្រះអង្គ ព្រះនាមស្រីជ័យរាជ ចូឌាមណី ដែលមានព្រះកាយក្តីផ្ទេកដោយកែវមណី ទុកជាអគ្គបដិមាករ-នៃព្រះជិនមាតាក្នុងឆ្នាំ ១១០៨ សក.(១) ។ ៣៦ ។

តទៅ, សិលាចារឹកនេះ រៀបរាប់តាំបញ្ជីមុខវត្ថុអាហារភោជននិង គ្រឿងប្រដាប់សម្រាប់ទំនុកបំរុងវត្ត «ព្រះរាជវិហារ» នេះទៀត ។

នេះបញ្ជីគ្រឿងពុទ្ធបូជាពលថ្ងៃ ១ សម្រាប់បដិមាករ «ស្រីជ័យរាជ ចូឌាមណីនិងទេវរូបបរិវារ» គឺ: អង្ករ ២ ទ្រោណៈ, ២ ប្រស្ថៈ, ៧៣ខា-រិកា; ល្ង: ១១ ប្រស្ថៈ, ២ ទ្រោណៈ, ២ កុទុវៈ; សណ្តែកដី: ២ ទ្រោណៈ, ២ កុទុវៈ; សណ្តែកកជមាសៈ ១៤ ប្រស្ថៈ; ទឹកដោះខាប់: ១យជី, ៣កុទុវៈ; ទធិ ក្សីរ ទឹកឃ្មុំ: ៧ប្រស្ថៈ ក្នុងមួយមុខៗ; ទឹកភេសជ្ជៈ ផ្អែមៈ ១យជី, ២ប្រស្ថៈ, ២កុទុវៈ; ប្រេងល្ង: ៣ប្រស្ថៈ, ២កុទុវៈ; ប្រេងឥរុផលៈ ៣កុទុវៈ ។ មានគ្រឿងប្រដាប់ដទៃទៀត...... ។ ទេវពស្ត្រ (សំលៀកបំពាក់ទេវតា) ៤៦០គូ, ព្រៃចិនសម្រាប់គ្រប ការពារព្រះបាទទេវរូបកុំឲ្យមូសបៀតបៀន៤៥ ។ វត្ថុសម្រាប់បែកអ្នក

១) ១១០៨សកៈ+៧៨=១១៨៦គ.ស.+៥៤៣=១៧២៩ព.ស. ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នៅជាមួយសាស្ត្រាចារ្យទីងអ្នកទេសនា: អង្ករ១៤ថាំង, ១ទ្រោណៈ ៥ប្រស្ថៈ, រាល់ៗថ្ងៃ ។

នេះបញ្ជីវត្ថុដែលត្រូវប្រើក្នុងថ្ងៃបុណ្យមួយៗរាល់ឆ្នាំត្រូវប្រើះ អង្ករ ១.០១៥ថាំង; ល្ង៤០ថាំង; សណ្តែកដី២ថាំង៣ទ្រោណៈ; ទឹកដោះថាប់ ២៥យដិកៈ; ក្បូរ ទធិ មួយមុខៗ ៣១យដិកៈ; ទឹកឃ្មុំ១៩យដិកៈ; ទឹកភេសជ្ជៈផ្អែម (ទឹកលាយស្ករដូចស៊ីរ៉ូ ឬទឹកអំពៅ)១៩យដិកៈ; ប្រេងល្ង ២កុដុវៈ ១៥យដិកៈ; ទេវពស្ត្រ (គ្រឿងស្លៀកពាក់) ១៨៨១ គូ ។ បូករួមមួយឆ្នាំអង្ករ២៨.០៤០ថាំង, ១ទ្រោណៈ; ស្រូវ១១២.១៦១ថាំងៗ

យកអាករមកពីស្រុក :

អង្ករ ៤.០៩៣ថាំងកា ១ទ្រោណៈ ២កុដុវៈ; ល្ង ១៨៣ថាំង ២ទ្រោណៈ៦ប្រស្ថៈ; សណ្តែកដី២១០ថាំង ២ទ្រោណៈ១០ប្រស្ថៈ; ទឹកដោះថាប់៤០០យដិកៈ ៩ប្រស្ថៈ; ទធិ៧ប្រស្ថៈ៥០៧យដី ក្បូរ១ប្រស្ថៈ; ៥៨៦យដី:; ទឹកឃ្មុំ ៥ប្រស្ថៈ៥៣៨យដី; ទឹកភេសជ្ជៈផ្អែម៤៨០យដិកៈ; ប្រេងល្ង ១៣ ប្រស្ថៈ, ប្រេងគរុផល៥ប្រស្ថៈ ៥ យដី ។

យកអាករមកពីផ្ទះអ្នកតម្បាញ ពីស្រុក ពីផ្សារ . . . .

គ្រឿងស្លៀកពាក់ ចំនួន៤០.០៩៥សម្រាប់; សំណុះឃ្មុំ១៧ការៈ ១៨តុលា, ៥ យដី ៩ បណៈ; សំណ៥១ការៈ ១៣តុលា ១កដ្តិកា, សេះ១ ពាសី២ ដំរី២ ។

**ព្រះរាជទ្រព្យទីងទេយ្យទានពីអ្នកមានទ្រព្យនៅស្រុក ៣.១៤០ ស្រុក**

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សម្រាប់ឧបត្ថម្ភ គឺៈ

បុរស៤០០នាក់, អធិការ (មហាថេរ) ១៨អង្គ, អធិការរង (អនុថេរ) ២.៧៤០អង្គ, បរិចារិកៈ (អ្នកបំរើ) ២.២៣២នាក់, រួមទាំងបរិចារិកា៦១៥នាក់ ជានាដកិត្តី (ស្រីល្ខោន)ផង, បូករួមទាំងអស់ ១២.៦៤០នាក់ រាប់ទាំងអ្នកដែលដេកនៅក្នុងទីនេះផង, ស្ត្រីប្រុស ៦៦.៦២៥នាក់សម្រាប់បំរើទេវរូប, បូករួម ៧៩.២៦៥នាក់ ព្រមទាំងជាតិបូកាមទឹងចម្ប៉ា (ភូមាទឹងហាម).... ។ មាសរចនាជាស្លាប ចានជើង..... ២៨គារៈ, ៤តុលា, ២បាទៈ, ៥កដ្តីកា; ប្រាក់ៈ ២០គារៈ, ១៥តុលា, ២កដ្តីកា, ២បាទៈ, ៤បណៈ ពេជ្រ៣៥គ្រាប់, ផ្តិតពីរប្រដាប់ដោយគជខ្យង; គជខ្យង៤០.៦២០គ្រាប់; រតនត្បូងគ្រប់មុខ៤.៥៤០គ្រាប់.....; ស្ពាន់១២០គារៈ ១៣តុលា, ១កដ្តី, ៥បណៈ; ពែងសំណ២.៣៣៩គារៈ, ១៧តុលា; ខ្ទះមាសមួយ ២៤គារៈ; ចានស្ពាន់ ១តុលា, ៦១៥គារៈ; សំណ ១០កដ្តី, ៧តុលា, ១៥គារៈ; សំណសុទ្ធ ៤៣៧គារៈ កន្ទះតុលា; សំពត់ចិន ៩៦៧; កម្រាលសូត្រ៥១២; ខ្ទស់៥២៣.....; ប្រាសាទកំពូល (ព្រះស្តូបតូច?) ៣៩, ទីលំនៅធ្វើពីថ្ម៥៦៦, ទីលំនៅធ្វើពីឥដ្ឋ២៨៨, ស្រះ បឹង ទទឹង ៧៦ព្យាម បណ្ដោយ១.១៥០ព្យាម, ថ្មរៀបប្រការជុំវិញ២ ៧០២ព្យាម, ធម្មការី (ភិក្ខុសង្ឃ)៤ ៣៩អង្គ ទទួលភត្តរាល់ថ្ងៃក្នុងព្រះរាជមន្ទីរ, អ្នកនៅជាមួយគ្រូ (សិស្ស?) ៩៧០នាក់, បូករួម ១.៤០៩នាក់ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ធ្វើបុណ្យខែចេត្រ ពីថ្ងៃទី៨ទៅថ្ងៃពេញបូណ៌តាមប្រពៃណីព្រះជ័នស្រី: ធ្វើបុណ្យតាមប្រពៃណីព្រះភគវតី (ប្រាជ្ញាបារមិតា?) ថ្ងៃ១៤នឹង១៥កើត ហែប្រទក្សិណព្រះភគវ័ត (លោកេស្វរៈ?) ព្រះភគវតី (ប្រាជ្ញាបារមិតា?) ទេពតាវីរៈ, សក្តិនឹងទេវតាដទៃទៀត; ក្បួនហែ ទង់សុវណ្ណផ្កាលា, ខ្ទស់... តូរ្យតន្ត្រីពួស្សូរមុខគួឲ្យរំភើបចិត្ត; អ្នករាំស្រីប្រុស កុមាររៀនរាំ ឲ្យបានសុក្រឹតខាងការឲ្យពានខាងចរិយាល្អ, បូជាចំពោះព្រះគុរុ៣អង្គ ចំពោះទេពតា ១០០០ ចំពោះទេវតា ៦១៩ ដែលនៅទីនេះ; ទំនុកបំរុង អ្នកប្រាជ្ញ; ភិក្ខុ ព្រាហ្មណ៍ ...; គោកិក្យា៩១, កង៨៩, មាស៧បណៈ (ទម្ងន់រួម); សំលៀកបំពាក់សម្រាប់ទេពតា ទឹងគ្រឿងស្លៀកពាក់អ្នក ដទៃទៀត ១.១០៧ ប្រដាប់, អាវក្លៀង ៣, អាវរោមសត្វ ២, អាវតូច ២៩, ឈ្នួតក្បាល២០, តុក្កុក១, ប្រអប់ដាក់ទឹកអប់៨៨, ទូ១, ពែង ផឹកទឹក១០០០; សំណាស ២៦ គុលា; ជ័រស្រល់នឹងសណ្តែកខ្មៅជាមួយគ្នា ២ គុលា, ១៦កដ្តិកា; ទៀនក្រមួនធំ ១៦៥·៧៤៤ទៀន; ក្រមួន ១.២០០ ភារៈ, ៣២ គុលា; មូស្លា, កម្រងផ្កា ។

អង្ករសម្រាប់ចំអិនថ្វាយទេវរូប: ៦៣០ ខារី, ១៣ប្រស្ថៈ; បាយ: ១៦ប្រស្ថៈ; ល្ង៣ខារីកន្លះ, ១១ប្រស្ថៈកន្លះ; សណ្តែកដី ៣ ខារិកា, ១ទ្រោណៈ, ១ប្រស្ថៈកន្លះ; ទឹកដោះគោខាប់: ២យដី, ៥ប្រស្ថៈកន្លះ; ទធិ ២យដិកា, ១១ប្រស្ថៈ; ក្សីរៈ ៤ ប្រស្ថៈ; ទឹកឃ្មុំ ៧ យដី; ទឹក កេសជ្ជៈផ្អែម ២យដី, ១០ប្រស្ថៈ; កប៉ូរ ១បាទៈ ៣មាឞៈ, ៤ពិម្ព;

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តុរុស្ក(?)ៈ ១១បណៈ; ឈើក្រអូប (?) ៨បណៈ, ១បាទៈ ១មាឞៈ; ជាតិហិង្គុលៈ ៤ពិម្ពៈ; ចន្ទន៍ក្រឹស្នាៈ ២កដ្តី, ៣ បណៈ, ៣បាដកៈ; តៃលកៈ (ខ្លាញ់សត្វរញ៉ី? ឬជ័រឈើសម្រាប់ធ្វើទឹកអប់) ១បណៈ, ២មាឞៈ, ៦ពិម្ពៈ; ប្រេងល្ង១ប្រស្ថៈ, ២កុឌុវៈ; ខ្ទិស្ដុតៈ ២បាទៈ, ១០កដ្តី; វត្ថុទាំងនេះ តាំងពីគោកិកក្រាមក ត្រូវយកពីឃ្លាំងព្រះរាជទ្រព្យ ។

វត្ថុដែលត្រូវយកពីឃ្លាំងព្រះរាជទ្រព្យរាល់ឆ្នាំដូច្នេះ៖

អង្ករៈ ២ទ្រោណៈ, ៤៧០ខារី; ល្ងៈ ២៦ខារី, ) ១ទ្រោណៈ, ៤ប្រស្ថៈ; សណ្ដែកដីៈ ១ទ្រោណៈ, ១០ប្រស្ថៈ, ៣៧ខារិកា; ទឹកដោះខាប់ ២៦ឃដី, ៩ប្រស្ថៈ; ទធិ៤ប្រស្ថៈ, ១ឃដិកា, ក្សីរៈ ច្រើនជាងទធិ; ទឹកឃ្មុំៈ ៧ ប្រស្ថៈ, ៦១ឃដី; ទឹកកេសដ្ឋៈផ្អែមៈ, ១៦ឃដី, ១អាឍកៈ; ប្រេងល្ងៈ ១០ ប្រស្ថៈ; ៣ឃដី; ទេវពស្ត្រ (គ្រឿងស្លៀកពាក់) ២.៣៨៧គូសម្រាប់ទេវរូបទាំងគ្រឿងស្លៀកពាក់ដទៃទៀត; ក្រែទឹងអច្រើន ស្នែង២៤, ពូក២០, មុង៣៦; កម្រាលជើងចិនប្រកស្នោ ២០, កម្រាលជើងព្រៃចិន ២៨; ក្រមួន១ភារៈ, ១០តុលា; មរិចៈ ៥ ប្រស្ថៈ ៣ទ្រោណៈ, ២ ខារិកា; ចន្ទន៍ក្រឹស្នា ១ តុលា, ១២កដ្តី, ៣បាទកៈ; ជ័រស្រល់; ៣០ តុលា, ១៣កដ្តី; សណ្ដែកខ្មៅៈ ១២កដ្តី, ១៥តុលា; កប្បូរៈ ២កដ្តិកា, ៦បណៈ; តុរុស្កៈ (?) ១២បណៈ, ១កដ្តី; ឈើក្រអូប (?)ៈ ១០បណៈ; ជាតិហិង្គុលៈ ២កដ្តី ៥បណៈ; កងមាស១; គោកិកក្រា១, ប្រអប់មេ្យា ៣០ បណៈ; ប្រាក់ៈ ៣០ណាឞៈ; ស្ពាន់ៈ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



៧តុលា, ៤កដ្ឋិកា; សំណ: ៤តុលា; ហិបចិន ៩០០; អំបិល: ៣៤ខារី, ៣ទ្រោណ:; សំណខ្មៅ:៣០តុលា; សេះ១ គោញី កបិលាប្រដាប់តាក់តែងដោយគ្រឿងមាសព្រមទាំងកូនគោផង១; មាន មន្ទីរពេទ្យ (អរោគ្យសាលា) ១០២ នៅគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ។ ក្នុងមន្ទីរពេទ្យទាំងនេះ មានទេវរូប ៧៩៨ អង្គ ។ ត្រូវចំណាយអង្ករ: ១១៧.២០០ ខារីការសម្រាប់អ្នកជម្ងឺដែលដេកនៅក្នុងមន្ទីរពេទ្យ ។ ស្រុក ៨៣៨ ស្រុក បុរសស្រ្តី ៨១.៦៤០ នាក់សម្រាប់ប្រចាំការក្នុងមន្ទីរ ពេទ្យនេះ ។

នេះបញ្ជីដែលត្រូវចំណាយពល់ឆ្នាំពីឃ្លាំងព្រះរាជទ្រព្យ:

ទ្រព្យសម្បត្តិ, គោតិក្យា, គង: ១៦ បណ:, ២ បាទ:, ៣ មាឞ:, គ្រឿងស្លៀកពាក់សម្រាប់ទេវរូប ទីងដទៃទៀត ១.៦០០ សម្រាប់; ចន្ទន៍ក្រស្នា: ១៤ បណ:, ៦កដ្ឋិ, ១ តុលា; ជ័រស្រល់: ៧ តុលា, ៨ កដ្ឋី, ៤ បណ:; សណ្ដែកខ្មៅ ៦ តុលា, ១១ កដ្ឋិ, ១០ បណ:; ក្រមួន: ៦ តុលា, ៣ បណ:; ទឹកឃ្មុំ: ១១១ ឃដិកា, ២២ ប្រស្ថ:កុខះ; គេសដ្ឋៈផ្អែម: ១២ ឃដិកា, ១២ ប្រស្ថ:; ទធិ ១០ ឃដិ, ៩ប្រស្ថ:, ២ កុទុវ:; ល្ង: ២២ខារិកា, ១ ទ្រោ- ណ:; ជីបូ: ១៣ តុលា, ២ កដ្ដកា; ទាក់ទី, ជីប៉ូ, លំអង ឈើបុន្នាគ, គណិកា (?) មួយមុខៗ: ៧ បណ:, ១៣ កដ្ឋិកា, ជាតីផល (ផ្កាចន្ទន៍?) ៣.៤០២; គក្កោរ: (?) ជ័រណ៍ជាមួយគ្នា: ៩ កដ្ឋី,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



១៤បណៈ; ក្រវាញពីរប្រភេទៈ ៣ កដ្ឋី, ១ បណៈ, ២ បាទ, ៣ មាប; ស្កៈ ២ តុលា, ១៣ កដ្ឋី, ៨ បណៈ; ទន្ទឹង្សៈ (?) ២.៦៧០; សតបុស្សៈ ១តុលា, ៦កដ្ឋី, ១២បណៈ; ឆន្ទ (ដើមឈើ ?) ១២ តុលា, ១៦ កដ្ឋិកា ១៤បណៈ; កកោល (ដើមឈើ ?) ទឹងម្រេចស្មើគា ១៣ កដ្ឋី, ៧បណៈ, សវ្វែលិកា (ឈ្មោះក្រវាញមួយវែប): ១១តុលា ៣កដ្ឋី, ៧បណៈ; សប្តបណៈ (ឈ្មោះក្រវាញមួយវែបទៀត): ១១ តុលា, ៣ កដ្ឋី, ៧បណៈ; ប្រចីវល (ដើមឈើក្លិនក្រអូប) ១១ តុលា, ១៦ កដ្ឋិកា; គ្រាប់ស្ពៃៈ ១ទ្រោណៈ, ១២ប្រស្ថៈ; បថ្យាវបៈ? តាំងអស់ៈ ១១.៣៦០? ទារី? ១.០៦៨..; ក្រមួនទន់ធ្វើពីបុសឈើ១០មុខ, មួយមុខៗចំនួន ៤៨.០០០; ..; នឹងឱសថតែពេតផ្សេងៗទៀត ។ល។

រៀបរាប់ពីបុញ្ញកិរិយាវត្ថុដែលទ្រង់បំពេញដ៏សម្បើមអស្ចារ្យយ៉ាងនេះហើយ ទ្រង់ឧទ្ទិសព្រះរាជកុសលថ្វាយព្រះវរមាតាដោយគាថាដូច្នេះ

កុវិន្ទមាទិ សុក្កតាទ្យតិមាត្តមាតកត្ត្រាវ្យជាតីប្រណិធិរមេវមសៅក្ស្រិតីទ្រៈ។
ឯកិត្តុកែមិមក្កែតកិរិនាំកវវ្យួត្តារណាយកជតាំជនទីជិនភូមិ ។

"អំពើជាកុសលដែលទ្រង់ (ព្រះបាទជយវរ្ម័នទី ៧) បានបំពេញដោយប្រពៃចំពោះព្រះវររាជមាតាដោយភក្តីភាពយ៉ាងនេះហើយ ព្រះរាជាតាំងប្រណិធិថា «ដោយអំណាចបុញ្ញរាសីនេះ សូមព្រះវរជននីខ្ញុំដែលធ្លងរួចពាកមហាសាគរតឹកភពហើយ បានសម្រេចនូវភាពជាព្រះជិនស្រីកុំ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ឃ្លាតឡើយ ” ។ ១៤១ ។

ក្រោយសាងព្រះរាជវិហារមក ៩ ឆ្នាំក្នុង ព.ស. ១៧៣៤ (គ.ស. ១១៩១) ទ្រង់សាងមហាប្រាសាទមួយទៀតឈ្មោះប្រាសាទ “ជយស្រី” ឧទ្ទិសថ្វាយព្រះពុទ្ធសាសនា សព្វថ្ងៃហៅប្រាសាទព្រះខាន់ ដើម្បីដំកល់បដិមាករព្រះបាទធរណីន្ទ្រវរ្ម័ន ជាព្រះវររាជបិតាទុកជាអង្គពោធិសត្វលោកេស្វរៈហើយថ្វាយព្រះនាមថា “ជយវរមេស្វរៈ” ។ នៅទិសខាងកើតក្នុងវង់ប្រាសាទព្រះខាន់នេះ ទ្រង់បានសាងប្រាសាទមួយមានសមញ្ញាថា “រាជ្យស្រី” សព្វថ្ងៃហៅប្រាសាទ “នាគព័ន្ធ” នៅចំកណ្ដាលស្រះ ជាប្រាសាទតូចមួយមាននាគព័ន្ធពីក្រោមហើយមានស្រះ ៤ នៅគ្រប់ទិស ។ ស្រះនីមួយ ៗ មានទវារសម្រាប់បង្ហូរទឹកលាងបាបចេញពីស្រះកណ្ដាលដែលជាតួប្រាសាទនាគព័ន្ធ ។ ប្រាសាទ “រាជ្យស្រី” នេះ ជាកំពង់បុណ្យសម្រាប់លាងបាប ទាញយកលំអពីស្រះទាំង ៤ ទិស សាងដំណាងអនោតត្តស្រះនៅភ្នំព្រះសុមេរុរាជ (ភ្នំហិមាលយា) ដែលនិយាយថាមានកំពង់ ៤ ហូរចុះទៅកាន់ទិសទាំង ៤ តាមប្រវេណីប្រទេសឥណ្ឌា] ហើយទ្រង់បានសាងបដិមរូបព្រះអង្គទុកជាអង្គព្រះពុទ្ធគ្រូពេទ្យនាម “ព្រះភៃសជ្យគុរុ វៃទូរ្យប្រភា” ដំកល់ទុកក្នុងប្រាសាទនេះផង សម្រាប់ជួយសង្គ្រោះសត្វលោកដែលមានជម្ងឺ ។ រូបសេះមួយដែលមានបង្កោមមនុស្សតោងី ក៏ជាបដិមរូបព្រះអង្គដែរ មានន័យថា “ព្រះអង្គដឹកជញ្ជូនសត្វលោកពីមហាសាគរ គឺវាលវដ្តសង្សារត្រែកតទៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

កាន់ទីក្រោមក្បាន្តគឺព្រះនិព្វាន ” ។ រឿងទាំងនេះ ដូចសិលាចារឹកនៅ (១) ប្រាសាទព្រះខាន់ដែលចារឹកថា : ៖

សុរុចិរវិចិតាយា ភូមហិប្យាស្រមស្តប្រភូតសុភូតកេតក្រុំជយក្រុំតវ៍យាំមី។
ចបលកនកមាលារញ្ជិតា យាំក្រ័យា ពរវិរចិតជយតដាកាទគិមេបោរវនីន្រ្ទះ॥
អម្ភោជកាតាញ្ជិតក្ចាតកុម្ភប្រាសាទភាសារុណិតាម្ពុកត្ចះ។
វិក្រាជតេ ភាគិរភាវិតស្យរក្តប្រហ្រទស្យាភូត៌មុទ្ធហំ យះ॥
យាស្យាន្តរេ តីថិដវៃលកពក្ចខា តាកិពម៌ បុលិនំបពទ្ធិ មី។
សំស្យ គិទាំ ក្យាលិតបាបបង្កំ វហិត្រកូតន្តរណំ ភវាវ្ធេះ॥

“ទ្រង់ (ព្រះបាទជយវរ្ម័នទី៧) បានសាងស្រះជយស្រី: (នាគព័ ទុកដូចកញ្ចក់ក្លុំដោយកែវឧបលនឹងកម្រងផ្កាមាសទុកក្នុងប្រាសាទជ័យស្រី (ព្រះខាន់) ប្រាកដដូចក្នុងព្រះកេសាដែលប្អូនដោយសិល្បៈយ៉ាងប្រពៃ នៃព្រះអគ្គមហេសី ដែលគាត់តែងវិចិត្រមុខគួរឲ្យកោកយ ។១៦៨។

“ស្រះជយស្រីនេះ មានទឹកថ្លាយង់យល់ដី ដុះស្រមោលនៃពន្លឺ ប្រាសាទមាសនឹងពណ៌ផ្កាឈូកក្រហម ពោលពន្លឺក្លីប្រាលឆ្អិនឆ្អៅ ប្រាកដដូចជាស្រះឈាមដែលព្រះបាទភាគីរៈ (ស្តេចនៃចម្ប៉ា) ធ្វើឲ្យហូរហាច (ក្នុងច្បាំង) ។១៦៩។

---

១.— G. Cœdès, La Stèle de Pra Khan (BEFEO., XLI, P. 282).

AngkorLink.com CambodiaBuddhist.org ABCCambodia.com



«នៅកណ្ដាលស្រះរាជ្យស្រីនេះ មានកំពង់បុណ្យសម្រាប់លាងបាបមួយ ទាញយកលំអស្រស់មកពីស្រះ (គ្រប់ទិសទាំង៤) ជាកំពង់បុណ្យសម្រាប់លាងផុតគឺបាបនៃជនណាដែលបានចូលទៅ ជាសំពៅកេត្រាដឹកជញ្ជូនសត្វលោក កាត់ឆ្លងសមុទ្រមហាសាគរឲ្យចេញចាកត្រៃភព (ទៅកាន់អមតមហានិព្វាន) ។១៧០។

ទ្រង់បានសាងប្រាសាទច្រើនកន្លែងទៀត សម្រាប់ដំកល់ព្រះពុទ្ធ[1] បដិមាករនាម «ព្រះជយពុទ្ធមហានាថ» ដើម្បីដោះទុក្ខសត្វលោក ។ គេបានរកឃើញព្រះពុទ្ធរូបបែបនេះ នៅលពបុរី សុព័ណ្ណបុរី រាជបុរី ពេជ្របុរី មឿងសិង្ហ (ក្នុងដីសៀមសព្វថ្ងៃនេះ) ។

សិលាចារឹកនៅប្រាសាទព្រះខាន់ មានចំនួនដូចសិលាចារឹកនៅប្រាសាទតាព្រហ្មដែរ ខុសគ្នាបន្តិចបន្តួច តែជាស្នាព្រះហស្ដព្រះរាជបុត្រព្រះអង្គមួយអង្គផ្សេងទៀតព្រះនាម “ព្រះវីរកុមារ” ។ ព្រះវររាជមាតាព្រះវីរកុមារនេះព្រះនាមព្រះនាង “រាជេន្ទ្រទេវី” ជាអគ្គមហេសីទី១ ។ សិលាចារឹកនេះ[2] បទដើមនមស្ការព្រះរតនត្រ័យដូចសិលាចារឹកនៅប្រាសាទតាព្រហ្ម រៀបរាប់ពីព្រះរាជវង្ស សរសើរបារមីព្រះបាទជយវរ្ម័នទី៧ ហើយរៀបរាប់ពីបញ្ជីតអាហារភោជន ដែលត្រូវប្រើប្រាស់ក្នុងវត្តព្រះខាន់នេះ ។ ខ្ញុំដកស្រង់សេចក្ដីខ្លះមកទុកក្នុងទីនេះ ។ ត្រង់កសាងប្រាសាទ

---

១— G. Cœdès, Histoire ancienne des Etats hindouisés d'Extrême-Orient P.227.— ២— G. Cœdès, La Stèle du Pra Khan (BEFEO., XLI, P.255).

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះខាន់ សិលាចារឹកនេះចែងទុកថា ៖

យត្រទ្វិឌ្រុធិរជាម្ពុជយស្រិយំ យោ ជគ្រាហ យុធិ ប្រាប្យ តត្របុរីក្តា ខ្យាមា

ហេមាម្ភោជផលវិញ្ចិតភូមិភាគា ទ្ឫ្គាធុនាបិ រុចិរៃវ យា វិភាតិ ॥

«ព្រះរាជាអង្គណា (ព្រះបាទជយវរ្ម័នទី៧) ច្បាំងមានជ័យក្នុងសង្គ្រាម ត្រង់ទីឋានណា ព្រះរាជាអង្គនោះ កសាងបុរីមាននាមថា «ជ័យស្រី» ត្រង់ទីឋានដែលឈាមនៃសត្រូវដក់នៅនោះ ជាភូមិភាគមានរតនវត្ថុទឹង ផ្កាឈូកមាសចាំងរស្មីធ្វើដីឲ្យមានពណ៌ក្រហមភ្លឺប្រាលរន្ទាលរហូតមកដល់កាលឥឡូវនេះ ប្រាកដហាក់ដូចគេយកឈាមនៃសត្រូវទៅលាប ។៣២។

ទ្រង់បានកសាងបដិមាករព្រះវររាជបិតាជាតួអង្គពោធិសត្វលោកេស្វរៈ ថ្វាយព្រះនាមថា «ជយវរមេស្វរៈ» ដំកល់ទុកក្នុងប្រាសាទជ័យស្រីនេះ ក្នុងព.ស.១៧៣៤ (គ.ស.១១៩១) ព្រមទាំងបានកសាងព្រះពុទ្ធរូបដទៃទៀតច្រើនអនេក ហើយទំនុកបំរុងដោយបច្ច័យ ៤ ច្រើនអនេកអនន្តទៀត ។

នេះបញ្ជីវត្ថុដែលថ្វាយដល់ទេវរូបរាល់ថ្ងៃ មានពោធិសត្វលោកេស្វរៈជាដើមនៅវត្តព្រះខាន់គឺ ៖

អង្ករៈ ៧៥ ខារិកា, កន្ទះទ្រោណៈ ; ល្ងៈ ១ ខារិកា, ៥ ប្រស្ថៈ, ២ កុឌុវៈ ; សណ្តែករាជមាសៈ ២ ទ្រោណៈ, ៤ ប្រស្ថៈ, ២កុឌុវៈ ; ទឹកដោះខាប់ៈ ១ឃដិកា, ១៣ ប្រស្ថៈ ; ទធិៈ ១ឃដិកា,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



១៤ ប្រស្ថៈ, ២ កុឌុវៈ; ក្សីរៈ ២៩ ប្រស្ថៈ, ២ កុឌុវៈ; ទឹកឃ្មុំៈ ២១ ប្រស្ថៈ; ទឹកកេសជ្ជៈផ្អែមៈ ១៩ ប្រស្ថៈ; ប្រេងល្ងៈ ៦ ប្រស្ថៈ, ៣ កុឌុវៈ; ប្រេងផ្លែឈើៈ ២ ប្រស្ថៈ, ២កុឌុវៈ ព្រមទាំងគ្រឿងប្រដាប់បូជា ។ បន្ទាប់ផ្លែឈើមិនកប់ក្នុងទីនេះទេ ។ សំពត់សាក្វាតសនឹងក្រហម ៦៤៥ ផាប់សម្រាប់សំលៀកបំពាក់ទេវតា ព្រមទាំងសម្រាប់គ្រែដេក នឹងកម្រាល; សំពត់ព្រែចិនស្តើងសម្រាប់ការពារសត្វល្អិតដែលកេមព្រះបាទទេវរូបដូចលោកកេស្វរៈនឹងទេវតាដទៃទៀតជាដើម ។

បញ្ជីចំណាយសម្រាប់បុគ្គលិក សាស្ត្រាចារ្យ, និស្សិតៈ

អង្ករៈ ២២ ខារី, ២ ទ្រោណៈ, ១៤ ប្រស្ថៈ ។ បំនួនអង្ករនេះរួមទាំងអង្ករសម្រាប់សេវាទេវតាផង គល់ថ្ងៃឡើងដល់ៈ ៩៧ ខារី, ៣ ទ្រោណៈ, ៦ ប្រស្ថៈ ។

នេះបញ្ជីសម្រាប់ថ្ងៃបុណ្យទី ៥, ទី ៨, ទី ១២, ទី ១៤, ទី ១៥ កល់បក្ស, បុណ្យចូលឆ្នាំ (សង្ក្រាន្ត) ព្រមទាំងថ្ងៃបុណ្យ ១៨ ផង ។ បើបូករួមមុខចំណាយទាំងនេះជាមួយគ្នាក្នុងមួយឆ្នាំ ។ នឹងមានចំនួនដូចនេះៈ

អង្ករធុនល្អៈ ៥.៣៨៦ ខារី, ១០ ប្រស្ថៈ; ល្ងៈ ៧៤ ខារិកា, ៣ ទ្រោណៈ, ២ កុឌុវៈ; សណ្តែកកដមាសៈ ៧៥ ខារិកា, ២ ទ្រោណៈ, ១៣ ប្រស្ថៈ, ២ កុឌុវៈ; ទឹកដោះខាប់ៈ ៧៥ ឃដិកា, ៩ ប្រស្ថៈ; ទធិៈ ៦៨ ឃដិកា, ១ អាឍកៈ, ២ កុឌុវៈ; ក្សីរៈ ៧៩ ឃដិកា, ៧ ប្រស្ថៈ, ២ កុឌុវៈ; ទឹកឃ្មុំៈ ៧៥ ឃដិកា, ១ ប្រស្ថៈ; ទឹកកេសជ្ជៈផ្អែមៈ ៦០

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



យជិកា, ៤ ប្រស្ថ:, ២ កុឌុវ: ; ប្រេងល្ង : ៥៣ យជិកា, ១០ ប្រស្ថ:; ប្រេងផ្លែឈើសម្រាប់ពិធីបូជាទេវតា: ១៣ យជិកា, ៤ ប្រស្ថ: ។ បើបូករួមចំណែកសម្រាប់សេវាទេពតាមួយឆ្នាំ ។ ផង ត្រូវប្រើវត្ថុទាំងនេះជាទ្វេគុណ ។

នេះបញ្ជីវត្ថុជាអាករបានមកពីស្រុក :

ស្រូវ: ១៤៦.៨៩១ ខារី; អង្ករដែលបានមកពីស្រាខ្ន, ពីខែមាឃ, ពីផ្គុរ, និងទីផ្សេង ៗ ទៀត : ៧.៨៤៨ ខារី; ល្ង : ៤៣៣ ខារី; សណ្តែកពជមាស ៤២២ ខារី, ៣ ព្រោណ: ; ទឹកដោះខាប់: ៥៤៥ យជិកា, ៧ ប្រស្ថ:កន្លះ; ទធិ: ៧៧៨ យជី, ១០ ប្រស្ថ:; ក្សីរ: ៦៣៩, ៦ ប្រស្ថ:; ទឹកឃ្មុំ: ៤៥៤ យជិកា, ៥ ប្រស្ថ:; ទឹកកេសជ្ជ:ផ្អែម: ៤៥១ យជិកា, ៥ ប្រស្ថ:; ប្រេងល្ង: ៣១៥ យជី, ៣ ប្រស្ថ:; ប្រេងឈើ: ១១៩ យជី, ៨ ប្រស្ថ: ; គ្រឿងស្លៀកពាក់សម្រាប់ទេវតា និងគ្រឿងស្លៀកពាក់ដទៃទៀត ២២.៦៨២ គូ; តុរុស្ក: ១ តុលា, ៩២ បណ: ; ជ័រស្រល់ : ១ ភារ:, ២ តុលា, ១៣ កដ្តិកា; ឈើក្រឹស្ណា ១ ភារ:, ៣ តុលា, ១៣ កដ្តិកា; ក្រមួន: ១០០ ភារ:, ២ តុលា, ១១ កដ្តិកាកន្លះ; ពពែ ៤២៣, ព្រាប ៣៦០, មានក្ងោកនិងព្រាបហរិតាលជាច្រើនទៀត; ព្រះពជាទិងអ្នកមានទ្រព្យនៅស្រុកបានបូជា : ៥.៣២៤ ស្រុក ; បុរសស្ត្រីបូករួម : ៩៧.៨៤០ នាក់ ក្នុងចំនួននេះ មានជនជាប្រមុខ ៤៤៤ នាក់; សេវក:៤០០៦; បរិចារិកា: ២,២៩៨ នាក់ រួមទាំងស្រីល្ខោន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



១០០០ នាក់ផង; មានអ្នកធ្វើពិធីបូជា : ៤៧.៤៣៦ នាក់ទៀត ។

នេះបញ្ជីវត្ថុដែលត្រូវយកពីឃ្លាំងព្រះរាជទ្រព្យរាល់ឆ្នាំ ៖

អង្ករ: ១.៣២៨ខារី, ២ទ្រោណ:; សណ្ដែកពពជមាស:៥៧ខារី, ៣ទ្រោណ:; ល្ង: ២៩ខារិកា, ៣ទ្រោណ:, ៤ប្រស្ថ:; ទឹកដោះខាប់ ២៣ឃដិកា, ៦ប្រស្ថ:; ទធិ៣០ឃដិកា, ៩ប្រស្ថ:, ២កុឌវ:; ក្សីរ: ៣១ឃដី, ៦ប្រស្ថ:; ទឹកឃ្មុំ: ៣៨៦ឃដី, ៦ប្រស្ថ:, ២កុឌវ:; ទឹកកេសជ្ជ:ផ្អែម១៦ឃដិកា, ៦ប្រស្ថ:, ២កុឌវ;; ប្រេងល្ង: ៦ឃដិកា, ៤ប្រស្ថ ; សំលៀកបំពាក់ទេវតានឹងដទៃទៀត៣.៧១២គូ; ត្រែ១១៣; មុងព្រែចិន៣២៣; ពូក២២; ពូកចិនធ្វើពីស្លៅ២៣; ម្រេច: ១ខារិកា, ១២ប្រស្ថ:; ក្រមួន: ២ភារ:, ២តុលា, ១១កដ្ដិកាកន្លះ; អំបិល៤ខារី, ១០ទ្រោណ:; ចន្ទន៍ក្រឹស្នា: ១ភារ:, ៥តុលា; ជ័រស្រល់: ១ភារ:, ៣តុលា ..., ឈើក្រឹស្ណ: ១ភារ:, ៦តុលា; កប៉ូរ ៣កដ្ដី..., មាឞ: ....., ៦កដ្ដិកា, ១០បណ:; ចេសស្ពូត្រ: ៣កដ្ដី..., កងទឹងគោភិក្សាមាស: ២មាឞ:, ៣បាទ:, ១២...; ប្រអប់, ប៉ាន់បំពួយ.... ៨បណ:, ៣បាទ:...., ៨ពិម្ពក:; ចានស្ពាន់: ១តុលា ..., កដ្ដិកា....; ....៥កដ្ដិកា, ២តុលា, ៥បណ:; ប្រអប់ចិន៥២០; គោញីក្រហមប្រផេស មានក្របកជើងនឹងស្នែងទំពាំមាសនឹងសំពត់គ្រប១; សេះពណ៌៤, ដំរី៤, ទាសី២, ក្របីញី២ វត្ថុប៉ុណ្ណោះត្រូវព្រះរាជប្រទាន ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



វត្ថុជាវិការៈនៃមាសៈ ប្រាសាទ ២៥៣ (ស្តូប?) ទីនវត្ថុផ្សេង ៗ ទៀត ៗ បានដើង (ជាវិការនៃមាស) នឹងគ្រឿងប្រដាប់ (ជាវិការនៃមាស) ដទៃទៀត : ១៨.១៦០ ៗ ចំនួនមាសសម្រាប់កសាងគ្រឿងប្រដាប់ : ៣០០ការៈ, ១២តុលា, ៣កដ្ឋិកា, ១៤បណៈ, ១បាទៈ, ២មាឋៈ, ២ពិម្ពកៈ; ប្រាក់ : ១៣៧ការៈ, ២កដ្ឋិកា; រតន : ៣៥.៨៣៧គ្រាប់ គឺពេជ្រ, កែវពៃទូរ្យ, មុក្តា; គជ១១២.៣០០គ្រាប់; ស្ពាន់ : ៧៣ការៈ, ១តុលា, ៣កដ្ឋី; សម្រឹទ្ធ : ១៦.០១០ការៈ, ២តុលា, ១កដ្ឋី, ១០បណៈ; តានមាស២០០ការៈ, ៣តុលា, ៣កដ្ឋី; សំណ : ៩០០ការៈ, ២តុលា, ៥កដ្ឋីៈ; សំណស្ពុទ្ធ : ៩២៤ការៈ; ដែក : ៤៦០ការៈ, ៤តុលា, ៣កដ្ឋី; ស្តូបមានជាន់ទាំងអស់: ១០២; សំណាន់ច្នូ៤៨៥ក្រុម, ប្រាការថ្មបាយក្រៀមៈ ២.២៣៨ព្យាម, ៥កន្លៃង; ២.០៧៥ព្យាម . . . . ; . . . ផ្លូវថ្មបាយក្រៀមគ្រប់កន្លៃង; បន្ទប់ទាំងអស់, ៤៣៩; អធ្យាប័កៈ (សាស្ត្រាចារ្យ)១នាក់, ឧបាធ្យាប័ក (សាស្ត្រាចារ្យរង) ១៥នាក់ . . . . ; ធម្មចារីគបស័លធម្មការណកយោគី . . . . ទាំងអស់នេះចំនួន៣០៨នាក់ ៗ ចំណែកព្រាហ្មណ៍កាន់សាសនាព្រះឥសូរមាន ៣៩ . . . . ៗ បូករួមចំនួនមនុស្សដែលនៅខាងក្នុងរាប់ពាន់ . . . . . ៗ

ព្រះបាទជយវរ្ម័នទី ៧ បានកសាងព្រះសុគតស្រីវិសក្តិ ហើយដម្កល់ទុកក្នុងទីនេះ ៗ ទ្រង់បានកសាងព្រះសុគតស្រីពជបតីស្វរៈ, ជយមង្គលាចិ-ឋ្ញាមណី ដម្កល់ទុកក្នុងស្រុកសិកជា ៗ ទ្រង់បានដម្កល់ទុកព្រះរតន-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ត្រ័យ នៅស្រីជយន្តបុរៈ, វន្សបពិត, មហិលបុរៈ, ស្រីជយរាជធានី, ស្រី-ជយន្តនគរី, ជយសិង្ហវតី, ស្រីជយវីរវតី, លវោទយបុរៈ, ស្វណ៌បុរៈ, សម្ពុកបដ្ដនៈ, ជយរាជបុរី, ស្រីជយសិង្ហបុរី, ស្រីជយវជ្របុរី, ស្រី-ជយស្តម្ភបុរី, ស្រីជយរាជគិរី, ស្រីជយវីរបុរី, ស្រីជយវជ្រវតី, ស្រីជយ-កីត្តិបុរី, ស្រីជយក្សេមបុរី, ស្រីវិជយាទិត្យបុរី, ស្រីជយសិង្ហគ្រាម, មធ្យម-គ្រាមកៈ, សមរេន្ទ្រគ្រាម, ស្រីជយបុរី, វិហារោត្តរកៈ, បូរ៉ាភាស, និងក្នុងទេវាល័យ ២៣ ទៀត ។ ទ្រង់កសាងព្រះជយពុទ្ធមហានាថនឹងមន្ទីរស្រង់ (ស្ពានៈ) ១០ នៅឆ្នេរស្រះយសោធរៈ ។ ទ្រង់បានកសាងសាលាសំណាក់ តាមថ្នល់ពីក្រុងយសោធរបុរៈទៅរាជធានីចម្ប៉ា ៥៧ សាលា ។ ពីក្រុងយសោធរបុរ ទៅពិមាយ ១៧ សាលា ។ ពីក្រុងយសោធរបុរៈទៅក្រុងជយវតី តទៅជយសិង្ហវតី តទៅជយវីរវតី តទៅជយរាជគិរីតាមថ្នល់ ១៤ សាលា ។ សាលា ១ នៅក្រុងស្រីសូរ្យបពិត, ១ នៅក្រុងស្រីវិជយាទិត្យបុរៈ, ១ នៅក្រុងកល្យាណសិទ្ធិកៈ, រួមទាំងអស់ ១២១ សាលា ។

បញ្ជីរាយនាមព្រះពុទ្ធរូបធ្វើពីមាសប្រាក់សំរិទ្ធច្រើនអង្គ....... បូករួមព្រមទាំងព្រះយមព្រះកាលផង នៅគ្រប់ខេត្តចំនួន ២០.៤០០អង្គ ។ ចំណែកភោជនាហារគ្រឿងបូជាទេវតា និងគ្រឿងទំនុកបំរុងបុគ្គលិកដែលនៅជាមួយអធ្យាប័ក និងសិស្សគ្រូទាំងអស់ដូច្នេះ :

ស្រូវ: ១៨៣.១៩០ ខារិកា; អង្ករ: ៤:៥៣៣ ខារិកា; សណ្ដែក

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



រាជមាសៈ ២.៩២៣ ខារី; លូៈ ២.៥៤៥ ខារី; ទឹកដោះខាប់ៈ ១.៦៦៤ យជី, ១០ ប្រស្ថៈ, ២កុឌុវៈ; ទធិនឹងក្សីរៈ ១.៧៦៦ យជី, ៣ប្រស្ថៈមួយមុខៗ; ទឹកឃ្មុំនឹងទឹកភេសជ្ជៈផ្អែមៈ ១.៦៩៣ យជី, ៦ប្រស្ថៈមួយមុខៗ; ប្រេងល្ងៈ ៩១៤ យជី ២ប្រស្ថៈ; ប្រេងផ្លែឈើៈ ២៣៦ យជី, ៤ប្រស្ថៈកន្លះ; ជ័រស្រល់ៈ ២ការៈ, ៥តុលា, ២កដ្ដិកា, ១០បណៈ; ឈើក្រឹស្ណៈ មានទម្ងន់ដូចគ្នា; ចន្ទន៍ក្រឹស្នាៈ ១ការៈ, ១តុលា, ១កដ្ដី, ១៨បណៈ; កប្បិរៈ ១តុលា, ១កដ្ដី កន្លះ, ៥បណៈ; ឈើតរុស្កៈ ៤តុលា, ១៤កដ្ដិកា, ៣បណៈ; ក្រមួនៈ ៣.២០០ការៈ, ៣កដ្ដី, ១០បណ ; គ្រឿងស្លៀកពាក់សម្រាប់ទេវតា ៧៥.៤២៥ ប្រដាប់.....; គ្រៃៈ ១.៦៦៦ ។ ព្រះរាជាព្រះរាជទានជាមួយអ្នកមានសទ្ធាដទៃទៀត ៨.១៧៦ ស្រុក ។ មានបុរសស្រីជាទាសទាសី ២០៨.៥៣២ នាក់, បណ្ដាជនទាំងនេះ អភិរក្ស ៩២៣ នាក់, កម្មករ ៦.៤៦៥ នាក់, ស្រី ៤.៣៣២ នាក់ រួមទាំងស្រីលោន ១.៦២២ នាក់ផង ។

មាសសម្រាប់រចនាជាប្រាសាទ (ស្តូប?) នឹងវត្ថុផ្សេង ៗ ទៀត ដូចបានដើមមូល នឹងគ្រឿងប្រើប្រាស់ៈ ១៣៨ ការៈ, ១២ កដ្ដិកា; ប្រាក់ៈ ១២១ ការៈ, ១២កដ្ដិកា, ១១ បណៈ; ស្ពាន់ៈ ៣២៣ ការៈ, ១ តុលា, ១ កដ្ដិកា, ៥ បណៈ; សម្រឹទ្ធៈ ៥.៣៦០ ការៈ, ២ តុលា: ២ កដ្ដី; តានមាសៈ ២០០ ការៈ, ១ កដ្ដី, ១៦ បណៈ; សំណៈ ១៤ ការៈ, ២ តុលា, ៤ កដ្ដិកា; សំណសុទ្ធៈ ១.២០០

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ការៈ, ៥ តុលា; ដែក: ២.០០០ ការៈ, ៧ តុលា, ៦ កដ្ដី; រតនវត្ថុ ពេជ្រដៃកវៃពទូរ្យ ទទឹម: ៤៧.៣២៨ គ្រាប់; គជ: ១៦៩.៤២២ គ្រាប់; ប្រាសាទ (ស្តូប?) ៥១៤; ក្រុមសំណង់តូច ២.០៦៦; ប្រាការ (កំពែង) ៤៦.៤៩០ ព្យាម; ជុំវិញអាងទឹក ២៤.៦២៨ ព្យាម; ជុំវិញស្រះមានស្រះជយតដាកៈជាដើម: ៩៣.៥០៧ ព្យាម; បន្ទប់: ១.៥១២; បុរសទៅជាមួយនិស្សិតៈ ២.៩៨៩ នាក់ ។

ក្នុងខែផល្គុណរាល់ឆ្នាំ ព្រះពុទ្ធរូបទាំងឡាយដូចមានកយព្រះនាមខាងក្រោមត្រូវដង្ហែមកដំកល់ក្នុងទីនេះ (ប្រាសាទព្រះខាន់) គឺៈព្រះមុនិន្ទ្រៈ (ខាងកើត) ១ អង្គ; ព្រះស្រីជយរាជចូឌាមណី ១ អង្គ; ព្រះជយពុទ្ធមហានាថ ២៥អង្គនៅ ២៥ ប្រទេស; ព្រះសុគតស្រីវីរសក្តិ ១អង្គ; ព្រះសុគតពិមាយ១អង្គ; ព្រះកម្រទេស្វរៈ ១ អង្គ; ព្រះចម្បេស្វរៈ១អង្គ; ព្រះប្ញថុសៃលេស្វរៈ ១ អង្គ រួម ១២២ ព្រះអង្គ ព្រមទាំងទេវតាជាបរិវារផង ។

គ្រឿងប្រដាប់ទំនុកបំរុងទេពតាទាំងឡាយនេះដែលត្រូវយកពីឃ្លាំងព្រះរាជទ្រព្យក្នុងឱកាសបុណ្យខែផល្គុណនេះ :

មាសៈ ៤ បលៈ, ២ កដ្ដី; ប្រាក់ៈ ១៤ កដ្ដី; សំណសៈ ៤ តុលា; គ្រឿងប្រដាប់ស្លៀកពាក់ទេវតា ២៥៩ គូ; អង្ករៈ ១០០ ខារិកា; គ្រឿងក្រអូប: ១៤៣ ប្រអប់; ទឹកដោះខាប់, ទឹកឃ្មុំ, ទឹកភេសជ្ជៈ ផ្អែមៈ ១ ឃដ្ដី, ១០ ប្រស្ថៈ ក្នុងមួយមុខៗ; ក្រមួនឃ្មុំៈ ១ តុលា, ៥ កដ្ដីកា; ជ័រស្រស់, ឈើក្រឹស្ណៈ ៥តុលា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក្នុងមួយមុខ ៗ ; ទធិទឹងក្បែរ: ១ យដិកា , ១០ ប្រស្ថ:ក្នុងមួយមុខ ៗ ។

ព្រាហ្មណ៍ទាំងឡាយ មានព្រាហ្មណ៍ឈ្មោះស្រីសូរ្យភដ្ដជាដើម , ព្រះរាជាវៃទជវ: ( ជ្វា ), ព្រះរាជាវៃទយវន: ( យួន ) ព្រះរាជាទាំងពីរអង្គនៃចាម , ស្ដេចយាងមកធ្វើពិធីស្នាន: ពិធីស្រង់ (ព្រះឧទក:) ព្រះពុទ្ធរូបដោយកក្តីពល់ ៗ ថ្ងៃ ។

ក្នុងការទេបត្តអព្រះវិហារ « ជ័យស្រី » នេះ មានបុរសស្ត្រីរួមទាំងជនជាតិ ចាម យួន បុកាម (ប្បគាន= ភូមា) និងរួន[១] (Rvan) ផងមានចំនួន ៣០៦.៣៧២ នាក់ ស្រុកចំនួន ១៣.៥០០ ស្រុក, អង្ករជាគ្រឿងពុទ្ធបូជា ៤០០.១២៦ ខារី ។ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានបំពេញមហាកុសលខ្ទង់សង្វាយព្រះពុទ្ធសាសនាដ៏អស្ចារ្យក្រៃលែង មិនខុនថយជាងព្រះបាទធម្មាសោកមហារាជប្រាកដដូច្នេះហើយ ព្រះរាជបុត្រស្រីវីរកុមារត្រាស់សរសើរព្រះអង្គទុកក្នុងគាថា ១៦៧ ថា «សព្វបើព្រាននៃព្រឈ្មោះអជិតេទ្រ្ទ: គ្រាន់តែបានថ្វាយភ្ការមួយបន្ទះ ម្ដេចទៅកើតបានភាពជាធំឈ្មោះ «កៃរព៌សុរ: » ក្នុងឋានសួគ៌ទៅហើយ ចំណង់បើព្រះរាជាអង្គនេះ ដែលបានបូជាដោយអើពើចំពោះព្រះពុទ្ធ ចំពោះទេវតា ចំពោះព្រាហ្មណ៍ ចំពោះតាបស ដោយកត្រាសន: ដោយប្រាសាទមាសកែវមណីនឹងភ្នុកប្រាកដយ៉ាងនេះ (នឹងបានផលានិសង្សដល់ម្ល៉ាទៅទៀត?) ។

---

១– ជនជាតិ រួន នេះ មិនដឹងប្រាកដជាជាតិអ្វី, លោកសឺដែសយល់ថា ប្រហែលជាជាតិ « ភមញ្ញ តីមន ឬ ប៉េគូន » ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទីបំផុត ព្រះរាជកុមារបានបញ្ចប់សេចក្ដីថា ៖

ក្ត្វា ប្រក្កមស្ក្កានរ្យមិតានរ្យជស្រមថាយ សោវទិបតិទិចិណា សុភា ជាមិ ។
កុរ្វំស្តិមានិកុត្តលានិ បត្តប្រក្កូមកក្ក្យា វិក្ខុមតតិ ប្រទិជី វកាយេ ៕
បុណ្យរម៉ែកិរ្កយាវណ្ណនុកាភិ ប្រជាកិច្ចិសរៃវិរិនិហត្យ សុខ្យ: ។
វេជីបភនធិតតាំកជតាំ ភវាខ្វេត្ដារណាយជគតាញ្ញនកោ មទីយ: ៕

« លុះបានបំពេញកុសលដ៏ច្រើនរាប់មិនអស់រាល់ថ្ងៃ ជាប្រយោជន៍ដល់សត្វលោកយ៉ាងនេះហើយ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់បានបំពេញព្រះរាជកុសលថ្វាយព្រះវររាជបិតា (ព្រះបាទធរណីន្ទ្រវរ្ម័ន) ដោយកក្ដីភាពយ៉ាងវិសេសវិសាលថែមទៀត ហើយទ្រង់តាំងប្រណិធានទូលព្រះរាជកុសលថ្វាយថា ។១៧១។

"សូមអំណាចបុញ្ញរាសីដ៏ច្រើន ដែលផ្សាយចេញទៅតាមរស្មីប្រាជ្ញា (ទ្រង់ទុបត្តម្ភគ្រូសិស្សក្នុងការសិក្សា) នឹងព្រះអាទិត្យ (ទ្រង់កសាងកំពូលប្រាសាទទិព្វមាសក្ដីប្រាលរន្ទាល) កំចាត់បង់នូវមោហន្ធការដែលបិទបាំង (នូវបុញ្ញរាសីដែលព្រះវរបិតាខ្ញុំបានបំពេញ តាំងពីរប្រការខាងលើនេះ) រាល់ថ្ងៃ ហើយសូមព្រះវររាជបិតាខ្ញុំបានសម្រេចពោធិញាណដែលជនដទៃពុំទាន់បាន ដើម្បីនឹងចម្លងសត្វលោកឲ្យឆ្លងចាកមហាសាគរគឺត្រៃភព (ទៅកាន់ត្រើយត្រាណអមតមហានិព្វានកុំបីខាន) ។១៧២។

ដទៃពីនេះ ព្រះបាទជយវរ្ម័នទ្រង់បានកសាងថ្នល់ធំពីមហានគរទៅប្រទេសចម្ប៉ា (វៀតណាម) ដល់ក្រុងផានរាង (បាណ្ឌុរង្គ:) ឬក្រុងវិជ័យ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ខែត្របិញឌិញ (Binh-dinh) ទៅក្រុងពិមាយ (សៀម) ៗ តាមថ្នល់ធំនេះ ទ្រង់បានសាង « សាលាសំណាក់មានភ្លើង » ១២១ សាលា, មួយ ៗបំផាយពីគ្នា ប្រហែល ១៥ គីឡូម៉ែត្រ, ពីមហានគរទៅដល់ចម្ប៉ា មាន ៥៧ សាលា, ពីមហានគរទៅពិមាយ ១៧ សាលា, ទីឯនដទៃពីនេះ ៤៦ សាលា, នៅក្នុងដីស្រុក ព្រមទាំងមន្ទីរពេទ្យ ១០២ (អរោគ្យ-សាលា) ផង ៗ មានសិលាចារឹកមួយ ៗ នៅគ្រប់មន្ទីរពេទ្យ ៗ សិលា-ចារឹកនេះ (១) រៀបរាប់ពីការឧបត្ថម្ភក្នុងមន្ទីរពេទ្យមានគ្រូពេទ្យ មានគិលានុ-បដ្ឋាក គិលានុបដ្ឋាយិកា ៗលៗ ក្រោមអធិបតីភាពព្រះសុគត គឺគ្រូពេទ្យឈ្មោះ « ភៃសជ្យគុរុ វៃឌូរ្យប្រភា » និងបុត្រព្រះជិនស្រីពីរព្រះអង្គទៀតគឺ សូរ្យវៃរោចនៈនិងចន្ទ្រវៃរោចនៈ ៗ ជនវណ្ណៈទាំង ៤ ទៅព្យាបាលរោគនៅមន្ទីរពេទ្យបានដូចគ្នា ៗ បុគ្គលិកធ្វើការមានៈ គ្រូពេទ្យ ២ នាក់ គ្រូពេទ្យរង ៣ នាក់ៈ ប្រុស ១, ស្រី ២ (មន្ត្រីសុខាភិបាល); និធិបាល (អ្នករក្សាឃ្លាំង) ២ នាក់; បាចកៈ (អ្នកគ្រួ) ២ នាក់; យជ្ញហារី (អ្នកបូជា) ២ នាក់; អរោគ្យសាលាសំរៀន (គិលានុបដ្ឋាក) ១៤ នាក់, ស្រី ៨ នាក់ ពីរនាក់សម្រាប់បុកអង្ករ ៗ ក្រៅពីនេះ រៀបរាប់ពីអាហារភោជននិងភេសជ្ជៈកែរោគ ៗ

កិច្ចការទាំងនេះ សំដែងឲ្យឃើញថា ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ប្រកបដោយព្រះមហាករុណាទិគុណដ៏ធំក្រៃលែង ដូចសិលាចារឹកនេះ

---

១ — L.Finot, Insrciption sanskrite de Say-Fong. BEFEO., III, P.18.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពោលបញ្ជាក់ថា :

ពុទ្ធ្យា ស្វគ៌ិកល្បាំ ប្ឫថ្វីំ    មគ្នាម្ពរណោ ទូបិតាមិ ។
មត៌្យាណាមមរត្វាយ    យោ ទិក្តទូបជាមតមិ ‖១០‖
បុម្យំ ក្ឫតី ក្ឫតីក្ឫត្យ    ប៊ូណាគ្នំ យោកពេទ ឬមិ ។
កលៃទ្យាបិតិត្យា ទ្រិ    ភគ្នំ ត្រិយុគទោបគៈ ‖១១‖
ជិត្វាទ្យៈគោបតិ ឬបំ    ស្វៃរំ ត្រិកុវទាគ្គណោ ។
ជម្ឫកេ ទិននទ្ធីរំ    ឬហោ យតិបុក្ឫលិក្ឫតៈ ‖១២‖
ទេហិនាទ្ធេហពេះគាយ- (ន្ទ ស្វោក្ខ)គោ ភុជគ្គភម ។
ពគ្រុទ្ធៈទំ ហិ ក្ឫត្តណាំ    ទុៈខំ ទុៈខន្តុ នាគ្នន: ‖១៣‖

“ ទ្រង់ (ព្រះបាទជ័យវរ្ម័នទី៧) ជ្រាបថា ផែនដីព្រះអង្គដែលទ្រង់បានកសាងឲ្យក្លាយទៅជាឋានសួគ៌ដោយព្រះប្រាជ្ញា ត្រូវមរណៈប្រទូស្ត ហើយ ទ្រង់ដឹកនាំឲ្យយកទឹកអម្រឹតជាភេសជ្ជៈ ដើម្បីញុំាងសត្វដែលត្រូវតែស្លាប់ កុំឲ្យស្លាប់ទៀត (គឺឲ្យបានអមតមហានិញ្វន) ។ ១០ ។

“ ទ្រង់បានកសាងកលិយុគនេះ ឲ្យបានជាយុគផ្កាកែដូចកាលក្ឫតយុគ, ទ្រង់បានតជើងគោ (គឺសុចរិតធម៌) ដែលបាក់ឲ្យមានអង្គបរិបូណ៌គ្រប់អង្គទាំង៤ឡើងវិញ (ព្រោះជើងគោគឺសុចរិតធម៌ទាំង៣នេះ ត្រូវទោសក្នុងយុគទាំង៣គឺ ក្ឫតយុគ, ត្រិតយុគ ទ្វាបរយុគប្រទូស្ត ឲ្យបាក់ហើយ) ពជពេទ្យក្នុងអតីតកាលរក្សាពុំបាន ។ ១១ ។

“គោជ័យ (គឺសុចរិតធម៌) ព្រះអង្គ ដែលទ្រង់កសាងឲ្យមានអង្គ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គ្រប់ទាំង៤ឡើងវិញហើយ ឈ្នះនូវគេ (គឺទុច្ចរិតធម៌) នៃអរិន្ទកដដទៃទាំងអស់ ហើយឋិតនៅលើលានគឺត្រៃភព បើកបាក់យ៉ាងធំ បន្លឺនូវសីហនាទដ៏ខ្លាំង (ថា: សុចរិត!!! សន្តិភាព!!!) ។១២។

«ទ្រង់ខ្លោចផ្សារក្រៃលែង ចំពោះរោគនៃជនអ្នកមានរាងកាយ (ប្រជាជនព្រះអង្គ) ជាងព្រះអាពាធផ្ទាល់ព្រះអង្គ ព្រោះថា ទុក្ខរាស្ត្រជាទុក្ខនៃអ្នកគ្រប់គ្រង (គឺព្រះរាជា) ទាំងឡាយ ពុំមែនចំពោះទុក្ខផ្ទាល់ព្រះវរកាយព្រះអង្គឡើយ ។១៣។

ទីបំផុត ទ្រង់តាំងចិត្តប្រកបដោយមេត្តាដ៏ជ្រាលជ្រៅ ហើយទ្រង់តាំងប្រណិធិថា «សូមឲ្យខ្ញុំបានចម្លងសព្វសត្វទាំងអស់ដែលលិចលង់នៅក្នុងសាគរវាលវដ្តសង្សារគឺត្រៃភពនេះ (ទៅដាក់ដល់ត្រើយត្រាណអមតមហានិព្វាន) ដោយតេជកុសលដែលខ្ញុំបានសាងនេះកុំបីខានឡើយ» ។

ក្នុងបច្ឆិមវ័យកាល ព្រះអង្គទ្រង់សាងប្រាសាទបាយ័ន(១) ឧទ្ទិសថ្វាយព្រះពុទ្ធសាសនានៅចំកណ្តាលព្រះមហានគរ លើកដំកើងព្រះកិត្តិយស ដើម្បីដឹកល់ព្រះបដិមាករព្រះអង្គដែលទុកជាតួអង្គ «ពុទ្ធរាជ» ជំនួសអង្គ «ទេវរាជ» (លិង្គមាស) ពីបុរាណកាល មិនតែប៉ុណ្ណោះទេ សូម្បីពោធិសត្វលោកេស្វរៈសមន្តមុខដែលនៅគ្រប់កំពូលប្រាង្គប្រាង បែរព្រះភក្ត្រញញឹមទៅគ្រប់ទិសទាំង៤ ក៏ទុកជាតួអង្គទ្រង់ដែរ ។ សិលាចារឹកនៅប្រាសាទ

១- G. Cœdès, Histoire ancienne des Etats hindousés d'Extrême-Orient, P.226-227.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បាយ័នថ្លែងបញ្ជាក់ថា ប្រាសាទនេះ ជាមជ្ឈមណ្ឌលការគោរពសកលទេពបូជានៃព្រះរាជវង្សានុវង្សទាំងនានាខេត្តខណ្ឌដែនសីមានៃប្រទេសគឺព្រះមហានគរដែលមានប្រាការ ១២គ.ម. ជុំវិញ មានភ្នំជាមជ្ឈមណ្ឌលទុកជាតួសកលលោកសន្និវាស ឯប្រាសាទបាយ័នទុកជាតួព្រះរាជអាណាចក្រ (ប្រាង្គកណ្ដាលខ្ពស់ជារាជធានី ប្រាង្គនៅជុំវិញជានានាខេត្ត) ជាសញ្ញាលក្ខណៈការទាក់ទងមនុស្សលោកនឹងទេវលោកនៅនាឋានក្រោមនេះ ។

ក្នុងរជ្ជកាលព្រះអង្គ មានព្រឹត្តិការណ៍មួយបំប្លែក គួរកត់សំគាល់ គឺទ្រង់បានបញ្ជូនព្រះរាជបុត្រទៅសិក្សាវិជ្ជាព្រះពុទ្ធសាសនា ហើយបព្វជានៅវត្តមហាវិហារនាកោះសិរីលង្កា ។ តាមពង្សាវតារភូមា(១) និយាយថា “មានសាមណេរមនមួយអង្គឈ្មោះ ឆបតៈ អាយុ២០ឆ្នាំ ចេញទៅរៀននៅកោះសិរីលង្កា ១០ ឆ្នាំ ហើយត្រឡប់មកកាន់ប្រទេសភូមាវិញ ពី ព.ស. ១.៧៣៣ ជាមួយនឹងភិក្ខុឯទៀត ៤ អង្គ មួយអង្គនាមតាមលិន្ទៈ ជាព្រះរាជបុត្រនៃព្រះមហាក្សត្រប្រទេសកម្ពុជា” ។ ភិក្ខុ តាមលិន្ទនេះ ប្រាកដជាព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ ហើយ ។ សេចក្ដីមានប៉ុណ្ណេះ ជាដើមដែលនាំឲ្យអ្នកប្រាជ្ញពង្សាវតារចុះសេចក្ដីយល់ថាៈ “ភិក្ខុតាមលិន្ទៈ ជាព្រះរាជបុត្រនៃព្រះបាទជ័យវរ្ម័នទី ៧ នេះហើយ ដែលនាំពុទ្ធសាសនាថេរវាទលង្កាវង្សចូលមកផ្សាយក្នុងប្រទេសកម្ពុជាមុនដំបូងបង្អស់ក្នុងពង្សាវតារខ្មែរ” ។ តែសេចក្ដីនេះ ខ្ញុំយល់ថា ពុទ្ធសាសនាថេរវាទគឺ សាសនា-

---

១ – បុលវង្សៈ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រាហ្មណ៍ក្តី ពុទ្ធសាសនាលទ្ធិមហាយានដែលចូលមកជំនាន់ក្រោយក្តី តាំងតែពីបានមកប្រតិស្ឋាននៅលើទឹកដីកម្ពុជាហើយ មិនសាបសូន្យបាត់បង់ទៅក្នុងកាលណាមួយទេ នៅជាមួយគ្នារៀងរហូតមក ឯកិច្ចតាមលទ្ធិ: ដែលអ្នកប្រាជ្ញទាំងឡាយយល់ថា « ទើបនឹងនាំពុទ្ធសាសនាថេរវាទមកបណ្តុះបណ្តាលនេះ » គ្រាន់តែជាការទាក់ទងផ្លាស់ប្តូរវប្បធម៌មួយចំណែកតាមប្រពៃណីពុទ្ធសាសនាតែប៉ុណ្ណោះទេ ដូចជាព្រឹត្តិការណ៍ដែលមានក្នុងបច្ចុប្បន្នកាលនេះដែរ ។

ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ទៅ ព្រះរាជាសោយរាជ្យជាតំណព្រះវង្សត្រឡប់មកកាន់សាសនាព្រាហ្មណ៍វិញ សាសនាព្រាហ្មណ៍រុងរឿងចុងក្រោយបំផុតម្តងទៀត ។ ឯពុទ្ធសាសនាថេរវាទ ដែលមិនសូវលេចឮឈ្មោះបោះសម្លេងនឹងគេមកអស់កាលយូរហើយនោះ ក៏ចំរើនខ្លាំងណាស់ដែរក្នុងសម័យនេះ ។ លោក ចៀវ-តា-កួន(១) ជារាជទូតព្រះចៅក្រុងចិន ដែលបានមកកាន់មហានគរនៃប្រទេសខ្មែរក្នុងព.ស. ១៨៣៩ (គ.ស. ១២៩៦) បានធ្វើសេចក្តីរាយការណ៍ទុកមកដូច្នេះថា « ឃើញមានភិក្ខុកោរព្រះកេស ប្រដាប់ត្រៃចីវរពណ៌លឿង គ្រងចីវរឆៀងស្មាឆ្វេង នៅស្មាស្តាំទំនេរ ដើរជើងទទេ វិហារប្រក់ក្បឿង ក្នុងវិហារមានរូបតែមួយគឺព្រះ= ព្រះពុទ្ធរូបសក្យមុនី ព្រះពុទ្ធរូបនៅក្នុងវិហារធ្វើពីសម្រឹទ្ធ មិនមានជួងស្គរទេ ឆាន់ត្រីសាច់ មិនឆាន់សុរាទេ ឆាន់មួយថ្ងៃ

១.— P.Pelliot, Mémoires sur les coutumes du Cambodge (Oeuvres Posthumes) P. 14.—

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តែម្តង ក្នុងវត្តអារាមមិនមានផ្ទះបាយទេ ភិក្ខុសាមណេរទទួលបិណ្ឌបាត សូត្រធម៌ គម្ពីរដីកាដាក់ស្លឹករឹត ព្រះរាជាទ្រង់ពិគ្រោះកិច្ចការធំៗ នឹងភិក្ខុសង្ឃ មិនមានភិក្ខុនីទេ» ។ សេចក្តីរាយការណ៍លោក ចៅ-តា-កួន នេះ សំដែងឲ្យឃើញច្បាស់ថា ពុទ្ធសាសនាថេរវាទលូតលាស់ដុះដាល ចំរើនបរិបូណ៌ក្រៃលែង ហើយបានទទួលស្គាល់ពីព្រះរាជា នឹងមុខមន្ត្រី រហូតដល់ប្រជាជនទូទៅ ។

ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ នេះ ប្រទេសខ្មែរចំរើនរុងរឿង ដល់ថ្នាក់ខ្ពស់ផុត សមដូចសេចក្តីរាយការណ៍ លោកចៅ-តា-កួន ថា «កាំង-ប៊ូ-ចេ គឺកម្ពុជាចំរើនរុងរឿងណាស់, មហានគរ (យសោធរបុរៈក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧) គឺអង្គរធំសព្វថ្ងៃនេះ មានគូទឹកជុំវិញ មានប្រាការ, មានគោបុរៈ ៥ មានស្ពានបង្កាន់នាគ មានប្រាសាទមាស (បាយ័ន) ជាមជ្ឈមណ្ឌលមហានគរ, មានប្រាសាទស្ពាន់ (បាពួន), មួយលីទៅខាងជើង ជាព្រះរាជវាំង ។ ខាងក្រៅប្រាការ នៅខាងត្បូងមាន ប្រាសាទលូបាន់ (ភ្នំបាខែង), ចេតិយលូបាន់ (អង្គរវត្ត) ។ល។»

ព្រះបាទស្រីន្ទ្រវរ្ម័ន ឡើងសោយរាជ្យនៅក្រុងយសោធរបុរៈក្នុង ព.ស. ១៨៣៩ (គ.ស. ១១៩៦) ។ ព្រះអង្គទ្រង់ជ្រះថ្លាក្នុងបវរពុទ្ធសាសនាប្រសើរមួយអង្គដែរ បានថ្វាយគ្រាមមួយសម្រាប់កសាងវត្តអារាមទុំស្បថ្វាយព្រះពុទ្ធសាសនា ក្រោយមកចំនងជាទ្រង់ដាក់រាជ្យថ្វាយព្រះរាជបុត្រហើយចេញសាងអភិនិស្ក្រមណ៍ ។ ក្នុងរាជ្យព្រះអង្គ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កើតមានសិលាចារឹក(១) បាលីមុនដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនាថេរវាទនៅប្រទេសកម្ពុជា ។ ខ្ញុំស្រង់យកតាំងអស់មកទុកក្នុងទីនេះជាអនុស្សាវរីយ៍ដល់ពុទ្ធសាសនិកជនទូទៅ ។

## សេចក្ដីបម្ទង

វិសុទ្ធមវិសុទ្ធានំ    សុទ្ធិសម្បាបកញ្ចនំ ।
ធម្មញ្ចារិយសង្ឃញ្ច    សុគតំ សិរសា នមេ ॥ ១ ॥
សិរិសិរិន្ទវម្មាខ្យ—    ភូបេ សោ គុណភូសណោ ।
យសោធរបុរេ អាសិ    មន្តលិន្ទុយមិន្ទុនា ॥ ២ ॥
ន ភត្តិយមចន្ទម្ហិ    អស្សិនីតារកាទិកេ ।
រវិវារម្ហិ តតិយេ    យាមេ,តីតេ ទ្វិបាទកេ ॥ ៣ ॥
សិរិសិរិន្ទមោលិស្ស    មហាថេរស្ស ធីមតោ ।
សិរិសិរិន្ទវតន—    តាមមេតមតា មុតា ॥ ៤ ॥
សិរិមោលិនីរតន—    លក្ខី នាម ឧបាសិកា ।
សទ្ធាទិគុណសម្បន្នា    ពជាលង្ការបាលកា ॥ ៥ ॥
បេសិតា តេន តាវេត្វា    វិហារមិធ សា បុន ।
បរិខញ្ច តជាកញ្ច    ខនាបេត្តី តតោ បរំ ॥ ៦ ॥
បន្តិយមចន្ទម្ហិ    ភូបាធិបតិបេសិតា ।

១.— G. Cœdès, La plus ancienne inscription en Pali du Cambodge. Etudes Cambodgiennes (extrait BEFEO., XXXVI) P.14.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធបេណ្ណាបាបេត្វា  ពាសិតាសាទិកេ អទា ॥៧॥
វិកុលត្តលគាមញ្ច  ទំពាមវ្ហេគាមកំ ।
តាលីសត្តលគាមញ្ច  ទព្វគ្គគាមកញ្ចិមេ ॥៨॥
ពាន្ទេន្ទា ខេត្តសីមាយោ  សមន្តតទិសាសុ ច ।
ពុទ្ធប្បជាយ ហាពាសិ  ភូបាធិបតិ ធម្មិកោ ॥៩॥
សិរិសិរិន្ទវគន–  គាមខេត្តានមន្តរេ ।
អដ្ឋបន្ទីទិ ខេត្តានិ  យាជកានមពាបយិ ॥១០॥

## សេចក្តីប្រែ

« ខ្ញុំសូមនមស្ការចំពោះព្រះជិនស្រីដ៏បរិសុទ្ធ ដែលផ្តល់នូវសេចក្តីបរិសុទ្ធិដល់ជនមិនបរិសុទ្ធទាំងឡាយផង ចំពោះព្រះធម៌ផង ចំពោះព្រះសង្ឃផង ដោយចេសិរសោគីត្បូង អស់កាលមិនដាច់ ។១។

« ព្រះរាជាអង្គនេះ ប្រដាប់ព្រះអង្គដោយគុណសម្បត្តិ (គ្រប់ប្រការ) ទ្រង់ព្រះនាមព្រះបាទសិរិសិរិន្ទវម្ម: បានឡើងសោយរាជ្យក្នុងយសោធរបុរៈ ក្នុងឆ្នាំឥន្ទ (១), យមៈ (២), ឥន្ទ (១), មង្គល (៨) = ១២១៨[១] សកៈ ។២។

« ក្នុងឆ្នាំ ចន្ទ (១), យមៈ (២), អគ្គិ (៣), នភៈ (០) = ១២៣០[២] សកៈ ប្រកបដោយអស្សទីនក្ខត្តឫក រវិវារៈ ២ បាទ

---

១– ១២១៨ សកៈ+៧៨=១២៩៦គ.ស.+៥៤៣ — ១៨៣៩ ព.ស.–

២– ១២៣០សកៈ+៧៨ — ១៣០៨គ.ស. + ៥៤៣ — ១៨៥១ ព.ស. ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក្រោយយាមទី ៣ កន្លងហើយ ។ ៣ ។

« ព្រះរាជាបានថ្វាយសិរិសិរិទ្ធិរតនគ្រាមនេះ ចំពោះព្រះមហាថេរជាអ្នកប្រាជ្ញ ព្រះនាមសិរិសិរិទ្ធិមោលិ ដោយសេចក្តីគោរព ។ ៤ ។

« ព្រះនាងឧបាសិកាព្រះនាមសិរិមោលិនីលក្ខី មានគុណធម៌មានសទ្ធាជាដើម ជាអ្នករក្សានូវព្រះរាជាលង្ការ ។ ៥ ។

« ព្រះនាងឧបាសិកាអគ្គនេះ គឺព្រះរាជាអគ្គនោះត្រាស់បង្គាប់ឲ្យចាត់ចែងកសាងព្រះវិហារនៅសិរិសិរិទ្ធិរតនគ្រាមនេះ ព្រមទាំងឲ្យជីកគូនិងស្រះថែមទៀត ។ ៦ ។

« ក្នុងឆ្នាំ ចន្ទ[១] (១), យមៈ (២), អគ្គិ (៣), ចន្ទ (១) ព្រះនាងឧបាសិកាអគ្គនេះ បានដំកល់ព្រះពុទ្ធរូបមួយអង្គតាមព្រះរាជបញ្ញា ព្រមទាំងថ្វាយវត្ថុទាំងឡាយមានទាសាទាសីជាដើម ។ ៧ ។

« គ្រាមទាំងឡាយនេះគឺ វកុលត្តគ្រាម ១, គ្រាមឈ្មោះទំទាំ១, កាលីសត្តលគ្រាម ១, នទ្យគ្គគ្រាម ១ ។ ៨ ។

«ព្រះភូបាធិបតីប្រកបដោយធម៌ ទ្រង់ត្រាស់ឲ្យបង់ខេត្តសីមា (ឲ្យគូផែនទី) ជុំវិញគ្រប់ទិស ហើយថ្វាយជាពុទ្ធបូជា ។៩។

«នៅក្នុងសិរិសិរិទ្ធិរតនគ្រាមនេះ ទ្រង់មានព្រះរាជបញ្ញាឲ្យចែកខេត្តទាំងឡាយ៨ទៀតដល់យាជកៈ (ភិក្ខុអ្នកបូជា)ទាំងឡាយ ។១០។

---

១– ១២៣១ ស.ក. +៧៨ – ១៣០៩ គ.ស. ៥៤៣ — ១៨៥២ ព.ស,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ចំណេរចីរកាលតមក ពុទ្ធសាសនាថេរវាទឡើងកាន់តែចំរើនរុងរឿងពេញទី មិនមែនចំរើននៅតែក្នុងប្រទេសខ្មែរទេ ពុទ្ធសាសនាប្រទេសខ្មែរបានផ្សាយចូលទៅក្នុងប្រទេសលាវទៀត ហើយលូតលាស់ដុះដាលចំរើនដូចយើងបានឃើញនៅប្រទេសលាវសព្វថ្ងៃនេះស្រាប់ ៗ សេចក្ដីរុងរឿងនៃពុទ្ធសាសនានឹងសិល្បវិជ្ជាការនានានៅប្រទេសលាវ សុទ្ធតែកើតចេញមកពីឥទ្ធិរស្មីនៃវប្បធម៌ខ្មែរពីបូរាណ តាំងអស់ ៗ

សេចក្ដីត្រង់នេះ លោកសឺដែសសរសេរទុកថា[1] ព្រះចៅក្រុងលាវព្រះនាម ព្រះយ៉ា ខាំផុង ទ្រង់ព្រះពិរោធចំពោះព្រះរាជបុត្រព្រះនាម ផី-ហ្វា "ទេវ-តាឋានសួគ៌" ហើយទ្រង់បំបរបង់ចេញពីប្រទេស ។ ក្នុងគ្រិស្ដសករាជ ១.៣១៦ ព្រះរាជកុមារ ផី-ហ្វា អង្គនេះ ទ្រង់បាននាំព្រះរាជឱរសព្រះអង្គព្រះនាម ហ្វា-ង៉ុម (Fa-Ngum) មួយព្រះអង្គ មកគង់នៅប្រទេសកម្ពុជា នៅក្នុងរជ្ជកាលព្រះបាទជយវម៌បរមេស្វរៈ ដែលទ្រង់ប្រថាប់នៅរាជធានីយសោធរក្នុងគ្រិស្ដសករាជ ១៣២៧ តែព្រះនាមថា ជយវម៌បរមេស្វរៈ នេះ លោកព្រិគ្ស យល់ផ្សេងហើយសរសេរថា[2] ក្នុងប្រវត្តិសាស្ត្រលាវ គេថានៅក្នុងរាជ្យព្រះបាទបរមេចខមរាជ ដូច្នេះវិញ ឃើញថាព្រះនាមនេះ ហាក់ដូចជាព្រះនាមព្រះរាជាមួយអង្គផ្សេងទៀត មិនមែនអង្គព្រះបាទ

១- G. Cœdès, Histoire ancienne des États hindouisés d'Extrême-Orient, P.P 288 289
២-L. Briggs. The ancient khmer Empire, P.P. 254.255—

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ជយវម៌្មបរមេស្វរ: ដូចក្នុងសិលាចារឹកទេ ៗ លោកសឺដែសសរសេរទៀតថា ព្រះរាជកុមារ ហ្វា-ង៉ុម អង្គនេះ កាលទ្រង់ប្រថាប់នៅក្នុងរាជធានីខ្មែរនោះ ទ្រង់នៅជាព្រះយោវនៅឡើយ ហើយទ្រង់បានទទួលការសិក្សាយ៉ាងខ្ពង់ខ្ពស់នៅក្នុងរាជសំណាក់ខ្មែរ ។ តាមលាវនុប្បវត្តិលាវនិយាយថា ព្រះរាជកុមារ ហ្វា-ង៉ុម ទ្រង់បានទៅសិក្សាចំណេះវិជ្ជាក្នុងសំណាក់ព្រះមហាថេរខ្មែរមួយអង្គ មានឋានៈខ្ពង់ខ្ពស់ជា មហា ផះ សម៉ន ចៅ= "មហាព្រះសមណ:" លុះទ្រង់បានព្រះជន្ម១៦វស្សាហើយ ព្រះមហាក្សត្រិយ៍ខ្មែរ ទ្រង់សព្វព្រះរាជហឫទ័យណាស់ ទ្រង់ព្រះមេត្តាប្រោសលើកព្រះរាជធីតាព្រះអង្គព្រះនាម កែវ ឬ យ៉ត-កែវ= "កំពូលកែវ=ពេជ្រ" ឬក៏ កែវ-ល៉ត-ហ្វា = "ពេជ្រឋានសួគ៌" អភិសេក ប្រទានជាព្រះអគ្គជាយា ។

ក្នុងគ្រិស្តសករាជ ១៣៤០-១៣៥០ ព្រះមហាក្សត្រិយ៍ខ្មែរ ទ្រង់បានជួយឧបត្ថម្ភព្រះរាជកុមារ ហ្វា-ង៉ុម ដោយរៀបចំពលសកលយោធា ហើយឲ្យលើកទៅវាយដណ្តើមយករាជបល្ល័ង្ក ជាប្រពៃណីព្រះវរបិតាព្រះអង្គមកវិញ ។ ការយាត្រាសែនទ្រុទុកាពទៅនេះ មានជោគជ័យមហាប្រសើរណាស់ ហើយទ្រង់បានប្រាប្តអភិសេកជាព្រះមហាក្សត្រិយ៍លាវ ព្រះនាមថា ព្រះយ៉ា ហ្វា-ង៉ុម ក្នុងគ្រិស្តសករាជ ១៣៥៣ តមកទ្រង់ខ្នាននាមព្រះរាជធានីថា ល៉ាន ឆាង "ដំរីមួយលាន" (សតនាគនហុត) ពាក្យថា "ល៉ាន"(១) នេះគឺ លាន ប្រែថា ទីកន្ទ្រង ឬ លាន ឬ ក្រោលដំរី (?) កាលនោះនៅពុំទាន់បាននាមថា "លួងព្រះបាង" នៅឡើយទេ ។

លោកសឺដែសសរសេរតទៅទៀតថា មានសិលាចារឹកសៀមមួយនៅសុខោ-

១-G. Cœdès. A propos des anciens noms de Luong-Prabang. BEFEO. T. XVIII P.10

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទ័យ ក្នុងបច្ឆាកាលនៃគ្រិស្តសករាជ ១៣៨៩ និយាយថា មានរាជាណាចក្រមួយ ជាប្រទេសជិតខាង នៅទិសខាងកើតតាមដងទន្លេមេគង្គ គឺរាជាណាចក្រនៃព្រះយ៉ា ហ្វា-ង៉ូម នេះឯង ។ ព្រឹត្តិកាលព្រះយ៉ា ហ្វា-ង៉ូម អង្គនេះ មានការសំខាន់ណាស់ មិនមែនដោយសារតែទ្រង់បានកសាងប្រជាជាតិមួយ ឲ្យចូលមកក្នុងវង់នយោបាយ សារវ័ន្តដ៏ក្រៃលែង ក្នុងអាស៊ីអាគ្នេយ៍តែប៉ុណ្ណឹងទេ មានផលប្រសើរមួយទៀត ដែលបំភ្លេចចោលមិនបាន ដោយទ្រង់បាននាំយកវប្បធម៌ខ្មែរ គឺពុទ្ធសាសនាខ្មែរ សិល្បៈខ្មែរ ប្រពៃណីខ្មែរ ទៅកាន់ភាគលើនៃទន្លេមេគង្គទៀតផង ។ កាលនោះ ព្រះយ៉ា ហ្វា-ង៉ូម បានសុំព្រះរាជានុញ្ញាតព្រះមហាក្សត្រិយ៍ខ្មែរ និមន្តព្រះមហាសមណៈជាគ្រូព្រះអង្គ គណៈសង្ឃខ្មែរ សិល្បិនខ្មែរច្រើននាក់ ព្រមទាំងគម្ពីរដីកាពុទ្ធសាសនាយកទៅប្រតិស្ឋានទុកក្នុងប្រទេសលាវ ។ ដើម្បីនឹងឲ្យកើតសិរីសួស្តីជ័យមង្គលប្រសើរច្រើនដល់ប្រទេសនឹងប្រជាជនព្រះអង្គ ទ្រង់បានសុំព្រះរាជានុញ្ញាតព្រះមហាក្សត្រិយ៍ខ្មែរ និមន្តព្រះពុទ្ធបដិមាសក្តិសិទ្ធមួយអង្គដែលមានកិត្តិនាមល្បីល្បាញ យកទៅប្រតិស្ឋានទុកជាមង្គល ឬ កិត្តិយសព្រះរាជធានី លានឆាង ថែមទៀត ។ ព្រះពុទ្ធរូបអង្គនេះ គេមិនបានស្គាល់ព្រះនាមពិតទេ តែស្មានមើលទៅប្រហែលជា ព្រះពុទ្ធរូបព្រះនាម „ជយពុទ្ធមហានាថ„ ដែលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់សព្វព្រះរាជហឫទ័យ ព្រោះព្រះពុទ្ធរូប "ជយពុទ្ធមហានាថ" ទាំងអស់មានចំនួន ២៨ អង្គ ។ យើងបានដឹងថា ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានបង្កើតប្រពៃណីស្រង់ព្រះ "ពិធីស្នានៈ" ក្នុងខែផល្គុន ។ ក្នុងមួយឆ្នាំៗ ទ្រង់និមន្តព្រះពុទ្ធរូបទាំង ២៨ ព្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

អង្គនេះ ដែលប្រតិស្ឋានទុកក្នុងបុរីធំៗក្នុងព្រះរាជាណាចក្រតាំងមូល មកកាន់វត្តជ័យស្រី (ព្រះខាន់) ដើម្បីធ្វើពិធីស្នានៈ ក្នុងពិធីនេះ ទ្រង់បានអញ្ជើញព្រះរាជាគ្រប់ប្រទេសមករួមក្នុងពិធីនេះផង គឺព្រះរាជាយវនៈ="យួន", ព្រះរាជាចាម, ព្រះរាជាជវៈ = "ជ្វា" លុះធ្វើរួចហើយ ទើបនិមន្តទៅប្រតិស្ឋានទុកតាមទីដើមវិញ ដើម្បីឲ្យកើតសិរីសួស្តីជ័យមង្គលត្រជាក់ត្រជុំពេញប្រទេស ៗ ពិធីស្នានៈនេះហើយ តមកកើតជាប្រពៃណី «ស្រង់ព្រះ» ពេញប្រទេសខ្មែរ ៗ នេះជាអរិយធម៌ប្រទេសខ្មែរប្រសើរមួយ ហើយផ្សាយឥទ្ធិពលទៅលើប្រទេសជិតខាងផង ៗ ប្រហែលជាដោយអរិយធម៌ប្រសើរនេះហើយ បានជាព្រះយ៉ា ហ្វា-ង៉ូម ទ្រង់និមន្តព្រះពុទ្ធរូបជ័យពុទ្ធមហានាថមួយព្រះអង្គទៅប្រតិស្ឋាននៅព្រះរាជធានីនៃប្រទេសព្រះអង្គ លុះបានទៅប្រតិស្ឋាននៅព្រះរាជធានី លាន៉ឆាង ហើយ ព្រះពុទ្ធបដិមាអង្គនេះ ក៏បានខ្នានព្រះនាមទៅជា «ព្រះបាង» វិញ អាស្រ័យដោយសព្វអ្នកនគរ គឺអ្នកនេះខ្លះអ្នកនោះខ្លះ បានយកសន្លឹកមាសទៅបិតអង្គនៃព្រះពុទ្ធរូបនោះ បិតពាល់តែអង្គព្រះពុទ្ធរូបពោរពេញទៅដោយមាស ៗ ឯព្រះរាជធានី លាន៉ឆាង តាំងតែពីបាន «ព្រះបាង» ទុកជាជ័យមង្គលហើយ ក៏បាននាមភិធេយ្យថ្មីថា «រាជធានីលួងព្រះបាង»វិញ តាំងពីកាលនោះមកហូតដល់បច្ចុប្បន្នកាលនេះ ៗ

ពង្សាវតារខ្មែរ បានចាត់ទុកប្រវត្តិនេះទុកជាកិត្តិយសដ៏ខ្ពង់ខ្ពស់នៃមហាក្សត្រិយ៍ខ្មែរ[១] គណៈសង្ឃខ្មែរ ប្រជាជនខ្មែរ ដែលបានទុកជាស្នាដៃដ៏ប្រសើរបំភ្លេចពុំបាន ដោយបានផ្សាយពុទ្ធសាសនាជាសាសនាពន្លឺព្រះចន្ទ្រ ជាសាសនាទឹកអម្រឹត

១-Paul-Lévy, les traces de l'Introduction du Bouddhisme à Luong Prabang. BEFEO. T.XL (1940) P. 411 suiv.

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រមទាំងវិជ្ជាការ សិល្បៈប្រពៃណីខ្មែរចូលទៅកាន់ប្រទេសលាវ ឲ្យប្រទេសលាវបាន កើតទៅជាប្រជាជាតិមួយ ប្រកបដោយអរិយធម៌ទំនៀមទំលាប់ប្រសើរខ្ពង់ខ្ពស់ ។ សព្វថ្ងៃនេះ ពុទ្ធសាសនា ជាសាសនារដ្ឋលាវ ប្រជាជនលាវជាពុទ្ធសាសនិក ប្រទេសលាវមានវត្តអារាមដេរដាសពាសពេញ មានសម្តេចព្រះសង្ឃនាយក ពជាគណៈ ឋានានុក្រម ភិក្ខុសាមណេរ ជាស្រែបុណ្យគ្រប់ទីកន្លែង ដូច្នេះ ប្រពៃណីលាវ គឺប្រពៃណីពុទ្ធសាសនានៅប្រទេសខ្មែរយើង ។

នៅក្នុងបច្ចុប្បន្នកាលនេះ ព្រះមហាក្សត្រិយ៍ខ្មែរនឹងព្រះមហាក្សត្រិយ៍លាវមាន សម្ពន្ធមេត្រីយ៉ាងជិតស្និទ្ធល្អ មិនដែលមានការបោះបង់គ្នាក្នុងកាលណាមួយឡើយ ។ ប្រទេសខ្មែរយើង តែងបានជួយទំនុកបំរុងប្រទេសលាវរៀងរហូតមក ដោយបាន និមន្តព្រះសង្ឃខ្មែរឲ្យទៅជួយក្នុងការសិក្សាពុទ្ធសាសនានៅប្រទេសលាវ ឯនិស្សិត លាវជាសមណៈ ឬ ជាគ្រហស្ថ ក៏បានមកនៅសិក្សាក្នុងប្រទេសខ្មែរក្រោមការឧបត្ថម្ភ ព្រះមហាក្សត្រិយ៍ខ្មែរយើង ខ្មែរយើងរាប់អានដូចជាបងប្អូនបង្កើត ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តពីរជ្ជកាលព្រះបាទស្រីសូរ្យោទ័យមក រវាងពាក់កណ្ដាលពុទ្ធសត-វត្សទី១៩ (គ្រិស្តសតវត្សទី១៤) ប្រទេសកម្ពុជាមានគ្រោះថ្នាក់ធំ ចុះរោយរៀវបន្តិចម្ដងៗទៀងមក ដោយសារចម្បាំងរាំងជលមិនមានដាច់ សិលា-ចារឹកតំណាលពីរាជវង្សតាមកមិនសូវមាន ពង្សាវតារពីបុរាណទាំងប៉ុន្មានដែលមានមកហើយ ក៏អន្តរធានបាត់បង់ទៅវិញតាមកាលវេលា រហូតមកដល់រជ្ជកាលព្រះបាទពញាយ៉ាត ពាក់កណ្ដាលពុទ្ធសតវត្សទី២០ (រវាងព.ស. ១៩៧៥ គ.ស.១៤៣១) (១) ។ ព្រះបាទពញាយ៉ាតអង្គនេះលះបង់មហានគរមកគង់នៅបាសាន (ស្រីសន្ធរ) ហើយតមកតាំងនៅក្រុងចតុមុខ (ក្រុងភ្នំពេញ) សព្វថ្ងៃនេះ ។

**សម័យបច្ចុប្បន្ន**.— ពុទ្ធសតវត្សទី២០ទៅទី២៥ (ព.ស.១៩៧៥-២៥០០) គ្រិស្តសតវត្សទី១៥ទៅទី២០ (គ.ស.១៤៣១-១៩៥៧) ក្រោយសម័យមហានគរមក ព្រះពុទ្ធសាសនាថេរវាទប្រតិស្ឋានលើផែនដីខ្មែរជាប់សឹងឥតប្រែប្រួល ចាក់ឫសគល់មាំជាស្ថាពររៀងរហូតមកដល់បច្ចុប្បន្នកាលនេះ ឯសាសនាព្រាហ្មណ៍នឹងពុទ្ធសាសនាមហាយានមិនសូវមានសាវ័កក៏សាបសូន្យបន្តិចម្ដងៗរហូតដល់អវសាន បាត់ឈ្មោះបោះសម្ងំសូន្យឈឹង នៅសល់តែបុរាណដ្ឋានជាតំណែលដេរដាសពាសពេញប្រទេស ។

---

១- G. Coedès. Histoire ancienne des Etats hindouisés d'Extrême-Orient. P. 307.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះពុទ្ធសាសនាថេរវាទឡើងកាន់សេចក្ដីចំរើន យកវត្តសាសនាព្រាហ្មណ៍មកធ្វើជាវត្តពុទ្ធសាសនាវិញ បាត់សិវលិង្គនៅលើស្ថានខ-ក្រោណិទៅ លេចឃើញព្រះពុទ្ធរូបដំកល់នៅលើស្ថានក្រោណិជំនួសវិញ ៗ មានវត្តច្រើនណាស់ដែលតាំងនៅលើកន្លែងវត្តសាសនាព្រាហ្មណ៍ ឈ្មោះនៅជាឈ្មោះវត្តសាសនាព្រាហ្មណ៍ថា អង្គ, តាំង, ក្រាំង, រលាំង, បា ដូចជា អង្គព្រះលិង្គ, តាំងគោក, ក្រាំងស្វាយ, រលាំងកែន, បាឆាយដដែល តែតួវត្តសព្វថ្ងៃជាពុទ្ធសាសនា ៗ វត្តណាមួយដែលតាំងនៅលើវត្តសាសនាព្រាហ្មណ៍ វត្តនោះមិនមែននៅសល់តែឈ្មោះទេ នៅមានសល់តាំងស្នាមដំណែលសាសនាព្រាហ្មណ៍ គឺបាទកៃលាសជាទីលំនៅព្រះឥសូរទៀតផង ៗ ឯទំនៀមប្រពៃណីឬពិធីផ្សេងៗ ដែលលាយឡំដោយលទ្ធិសាសនាព្រាហ្មណ៍និងពុទ្ធសាសនាមហាយាន ក៏កើតទៅជាទំនៀមប្រពៃណីស្រុកទេសជាប់រហូតមកដល់សព្វថ្ងៃនេះ ៗ ក្នុងព្រះបរមរាជវាំង ព្រះរាជពិធីផ្សេងៗ ដែលមានមកពីបុរាណកាលចំនួន ២.០០០ ឆ្នាំមកហើយ ក៏នៅមានតាមប្រពៃណីដើមដដែល ៗ សព្វថ្ងៃនេះ មើលទៅឃើញតែវត្តអារាម កុដិវិហារសាលាធំហើយដោយកំពូលគាងឃ្វាយប្រុងប្រាង ភិក្ខុសាមណេរគ្រងចីពរពណ៌លឿង សព្វទីកន្លែងពាសពេញព្រះរាជអាណាចក្រ បានជាកើតមានពាក្យអ្នកបរទេសខ្លះគេហៅប្រទេសយើងថា «ប្រទេសភិក្ខុសង្ឃ» ៗ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធសាសនានិងប្រជាជនខ្មែរ.— ក្នុងសម័យអាប់ឲន ប្រជាជនខ្មែរទាំងប្រទេសបានជួបប្រទះសេចក្តីទុក្ខវេទនាខ្លាំងបំផុត ថមថយកម្លាំងទីងសាំងសេចក្តីចំរើនដូចសម័យព្រេងនាយពុំបាន តែទោះបីធ្លាក់ចុះដុនដាបប៉ុណ្ណឹងក៏ដោយ ប្រជាជនខ្មែរដែលបានស្គាល់រសជាតិព្រះធម៌ថ្លៃវិសេសហើយ នូវសាសនានេះជាប់នឹងខ្លួនតកតមក ស៊ូស្លាប់មិនព្រមលះបង់ចោល ។ បុណ្យទទួលព្រះបរមសារីរិកធាតុនៃព្រះអរហន្តធាតុព្រះសារីបុត្តនិងព្រះមហាមោគ្គល្លានពីខែតុលា ព.ស. ២៤៩៤ ជាពស្តុតាងឲ្យឃើញច្បាស់ថា ប្រជាជនខ្មែរទាំងប្រទេសមានចិត្តភក្តីចំពោះព្រះពុទ្ធសាសនាស្រាប់ហើយ ។ ពុទ្ធសាសនាថេរវាទដែលធ្លាប់មានមកពីសម័យព្រេងនាយស្រាប់ហើយ ក៏ជ្រួតជ្រាបរហ័សចូលទៅដល់ចិត្តថ្លើមប្រជាជនគ្រប់ជាន់គ្រប់ថ្នាក់ ហើយធ្លាក់ជាប់មិនមានឥទ្ធិពលអ្វីមួយមកគាស់រំលើងបានឡើយ ។ អស់លោកអ្នកនាំប្រទេសខ្មែរ ព្រះមហាក្សត្រ មន្ត្រីតូចធំ ដែលបានយល់តម្លៃពុទ្ធសាសនាថាមានផលប្រយោជន៍ មានហេតុផលគ្រប់គ្រាន់ល្មមនាំខ្លួនទៅកាន់សេចក្តីសុខក្សេមក្សាន្តបាន ក៏ព្រមលះបង់សាសនាដទៃចោលអស់ទៅ ជ្រើសសម្រាំងយកតែពុទ្ធសាសនាថេរវាទមួយប៉ុណ្ណោះ ទុកជាសម្បត្តិវប្បធម៌ប្រចាំប្រទេសខ្មែររហូតដល់មកបច្ចុប្បន្នកាលនេះ ។ ក្នុងសម័យអាប់ឲន ប្រជាជនខ្មែរបានពុទ្ធសាសនានេះហើយជាសរណៈដ៏ឧត្តមខ្ពង់ខ្ពស់ជួយសម្រាលលំហែសេចក្តីទុក្ខ ដោយជឿកម្ម

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ផលច្បាស់លាស់ថា «ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់» ហើយទូន្មានប្រដៅប្រៀនកូនចៅនៅឯក្រោយឲ្យខំកសាងសេចក្ដីល្អ ដើម្បីកសាងអនាគតឲ្យបានរុងរឿងដូចសម័យព្រេងនាយវិញ ទោះជាលំបាកយ៉ាងណា ក៏ពេញចិត្តរួមសុខទុក្ខជាមួយពុទ្ធសាសនា ពាល់តែកើតទៅជាសុភាសិតប្រចាំជាតិថា « ស៊ូស្លាប់ទៅតាប់ រស់ធម៌កុំបីបង់ » ។

ពុទ្ធសាសនានឹងវដ្ដ.– ដោយចិត្តខ្មែរជាធម៌បែបនេះហើយ បានជាប្រជាជនខ្មែរមិនចូលចិត្តប្រើកម្លាំងអាវុធ ពេញចិត្តនាំប្រទេសខ្លួនទៅដោយសន្តិវិធី ហើយតាំងនៅក្នុងអព្យាក្រឹតភាព ស្រឡាញ់មនុស្សជាតិគ្រប់សាសន៍គ្រប់ភាសាក្នុងសកលលោកមិនរើសមុខ ទុកមនុស្សលោកជាកល្យាណមិត្តសម្រាប់ដើរទៅកាន់ផ្លូវឆ្ងាយគន្តារ រួមសុខរួមទុក្ខជាមួយគ្នា ដ្បិតបានជាកើតមកហើយ ចង់រួមរស់នៅជាមួយគ្នាដោយក្សេមក្សាន្តរហូតតទៅ ដើម្បីសាងក្ដីសុខក្ដីចំរើនដល់មនុស្សលោក ។ ប្រជា-ជនខ្មែរតាំងប្រទេសប្រកាសខ្លួនជាអព្យាក្រឹតយ៉ាងឧឡារិក ចំពោះសកលលោក មិនថាលោកខាងនេះឬលោកខាងនោះទេ នេះឯងហើយជាសក្ខីភាពឲ្យសកលលោកស្គាល់ចិត្តខ្មែរថាខ្មែរ «ចិត្តធម៌» ។ តែប្រវត្តិសាស្ត្រខ្មែរបានប្រាប់ថា ខ្មែរមិនមែនចិត្តធម៌ស្លាប់ស្លូតនោះទេ ខ្មែរមានសតិ-សម្បជញ្ញៈ មានគំនិតរស់រវើក បេះគស៊ូ ព្រមយកជីវិតខ្លួនជាពលី ដើម្បីបូជាមាតុប្រទេស បូជាជាតិ សាសនា មហាក្សត្រខ្លួនរហូតមក ។

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពុទ្ធសាសនានិងយុវជនខ្មែរ ៖ ប្រជាជនខ្មែរអប់រំកូនចៅតាមប្រពៃណីបុរាណ គឺឲ្យកូនចៅទៅរៀននៅវត្ត ។ កូនខ្មែរទោះជាព្រះរាជបុត្រក្តី បុត្រមន្ត្រីក្តី កូនចៅប្រជានុរាស្ត្រក្តី ទាំងអស់ទៅរៀននៅវត្ត យកវត្តជាសាលារៀន វត្តមួយ ៗ ត្រូវបង្រៀនមុខវិជ្ជាបានគ្រប់យ៉ាង បង្រៀនអក្សរ នព្វន្ត ការរចនា ការស្ថាបនា ច្បាប់សីលធម៌ និងធម៌កាថិពុទ្ធសាសនា ៗ កូនខ្មែរដែលបានរៀនសូត្រចេះដឹងគួរសមហើយ ត្រូវបួសជាសាមណេរជាភិក្ខុ កើតទៅជាទំនៀមថា កូនប្រុសអាយុ ១២ ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា អាយុ ២១ ឆ្នាំ ត្រូវបួសជាភិក្ខុ សងគុណបិតា, បួសហើយត្រូវរៀនសូត្រវិជ្ជាខ្ពង់ខ្ពស់តទៅទៀត រៀនបាលី រៀនធម៌កាថិពុទ្ធវចនៈ ។ល។ កូនចៅខ្មែរ, បើបានបួសជាសាមណេរ ជាភិក្ខុហើយ សឹកមកវិញ ទើបគេរាប់ថាជាមនុស្សពេញអង្គ. សឹកមកវិញភ្លាម គេឲ្យនាមថា បណ្ឌិត ប្រែថា អ្នកប្រាជ្ញ គេលែងហៅ អា មីង ដូចពីដើមហើយ ៗ បើមិនបានបួសទេ គេហៅ អា មីង មួយជាតិ ហើយគេមិនរាប់ជាត្រីមុខទេ ៗ បើបានបួសហើយ តែខ្ជិលរៀនសូត្រទៀត ច្បាប់ក្រមខ្មែរបន្ទោសថា «កំជិលអៀនប្រៀន បួសហើយមិនរៀន បន្ទោសថាខ្លៅ» ៗ អាស្រ័យដោយការអប់រំប្រសើរនេះហើយ ទើបបានជាប្រជាជនខ្មែរមានចរិយាសុភាពរាបសាសួតត្រង់ ចិត្តថ្លើមល្អ មិនសូវចេះបៀតបៀនគ្នាទេ ៗ សព្វថ្ងៃនេះ កូនប្រុសពុំសូវបានបួសជាភិក្ខុជាសាមណេរដូចជំនាន់មុនទេ ព្រោះមានសាលាកើតនៅក្រៅវត្តច្រើន តែ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពោះម្តេចម្តា ព្រះរាជវង្សាភិបាលក៏ព្យាយាមបង្កើតសាលានៅតាមវត្តដូចបុរាណកាលវិញជាបំផុត ។ សូម្បីមានសាលារៀននៅក្រៅវត្ត តែមានសិស្សច្រើនគ្នាណាស់ដែលពឹងពាក់អាស្រ័យនៅតាមវត្តអារាម ជាឱកាសល្អបានសេពគប់ព្រះសង្ឃ ។ ឯយុវជនដែលអាស្រ័យនៅផ្ទះ ក៏តែងមានឱកាសចូលទៅវត្តអារាម បានធ្វើបុណ្យតាមប្រពៃណីពុទ្ធសាសនា បានភ្ជាប់និស្ស័យខ្លួននឹងពុទ្ធសាសនា ចេះខ្លាចបាប ចេះចង់បានបុណ្យ ចេះយល់ព្រះពុទ្ធសាសនា ហើយប្រកាសខ្លួនជាពុទ្ធសាសនិក ព្រោះហេតុតែបានទទួលពន្លឺព្រះពុទ្ធសាសនាតាំងពីកុមារមក ។

**ពុទ្ធសាសនានឹងសង្គមខ្មែរ.–** បុណ្យទានខាងពុទ្ធសាសនាក្តី បុណ្យប្រពៃណីប្រទេសក្តី ប្រជាជនខ្មែរតែងប្រមូលគ្នាទៅធ្វើនៅតាមវត្តអារាម ។ ការប្រមូលគ្នាទៅវត្តនេះមានប្រយោជន៍ណាស់ ព្រោះជាឱកាសល្អនាំឲ្យបានស្គាល់គ្នា ឲ្យរាប់អានគ្នា ឲ្យបានប្រាស្រ័យទៅគ្នានឹងគ្នា ឲ្យយោគយល់គ្នា ឲ្យចេះរួបរួមគ្នា ដើម្បីបំពេញកុសល ឬសម្រេចកិច្ចការសង្គមអ្វីមួយ ។ ការសមាទានសីលជាកិច្ចការសង្គមមួយដ៏ប្រសើរ ព្រោះបានដុសខាត់សង្គមឲ្យស្អាតបរិសុទ្ធ ឲ្យមានចរិយាប្រសើរ មានសីលធម៌ខ្ពស់ ។ ឯការបំពេញទានថ្វាយសង្ឃ ក៏ជាការសង្គមមួយប្រសើរទៀត ព្រោះជាការជម្រះសេចក្តីកំណាញ់គិតតែប្រយោជន៍ផ្ទាល់ខ្លួន នឹងជាការបង្ហាត់ខ្លួនឲ្យចេះធ្វើចិត្តធូរទូលាយ ចេះគិតផ្តល់ប្រយោជន៍នឹងសេចក្តីសុខនៃគ្នាទៅវិញទៅមក មិនតែប៉ុណ្ណោះទេ ការប្រមូលគ្នាទៅវត្តជាឱកាសមួយប្រសើរដោយឡែកទៀត ព្រោះអាចយកពេលជួបគ្នានេះសម្រាប់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជជែកគ្នា ពិគ្រោះគ្នា ពិភាក្សាគ្នា អំពីកិច្ចការសង្គមជាប្រក្រតីថែមទៀតផង ។ ហេតុដូច្នេះ ប្រស្នាអ្វីមួយជាកិច្ចការសង្គមដែលបានប្រឹក្សាគ្នានៅវត្តអារាម តែងតែជាប់លាយដោយគំនិតពុទ្ធសាសនាជាសទ្ធម្មនាំឲ្យកើតសេចក្ដីសុខក្សេមក្សាន្តជាដរាប ។

ចាស់ទុំបរមបុរាណខ្មែរបានបង្កើតបុណ្យទំនៀមច្រើន ដើម្បីអប់រំនិស្ស័យសង្គមឲ្យជាប់នឹងពុទ្ធសាសនា ដូចបុណ្យកាន់បិណ្ឌ បុណ្យស្រង់ព្រះ បុណ្យស្រោចស្រពមាតាបិតាចាស់ទុំ បុណ្យបំបួសនាគ បុណ្យកឋិនទាន ជាដើម ។ ឯបុណ្យខ្មោច ពិធីរៀបមង្គលកូនប្រុសស្រីជាស្វាមីភរិយា បុណ្យចូលឆ្នាំ ។ល។ ក៏ចាស់ទុំបញ្ចូលលទ្ធិពុទ្ធសាសនាជាមង្គលទាំងអស់ ។ ដោយជាតិយើងចូលចិត្តធ្វើបុណ្យដូច្នេះហើយ បានជាមានពាក្យអ្នកបរទេសខ្លះពោលទោសយើងថា «ខ្មែរបានជាក្រ មកពីធ្វើបុណ្យច្រើនពេក» ។ ជនជាតិខ្មែរពេញចិត្តធ្វើបុណ្យយ៉ាងនេះ មកពីយល់ថា «ក្រក៏ក្រចុះ ឲ្យតែមានល្អ គឺមានអរិយទ្រព្យ» ។

បុណ្យសំខាន់មួយទៀតសម្រាប់អប់រំចរិយាសង្គមឲ្យវិសេសវិសាល គឺបុណ្យទេសនាទសជាតិ ។ ការទេសនាទសជាតិ គឺសំដែងពីចរិយាព្រះបរមពោធិសត្វដែលព្រះអង្គខំប្រឹងប្រតិបត្តិក្នុងអតីតជាតិឲ្យបានត្រាស់ដឹងធម៌ឲ្យប្រជាជនស្ដាប់ ហើយឲ្យយកជាគតិទុកជាពន្លឺក្នុងជីវិតខ្លួនគ្រប់ ៗ គ្នា សម្រាប់ប្រតិបត្តិយកសេចក្ដីសុខនៅនាលោកនេះនិងបរលោក ។ អាស្រ័យដោយការអប់រំដ៏ប្រសើរនេះ ប្រជាជនខ្មែរបានចេះដឹងពុទ្ធ-ចរិយា ដែលព្រះបរមពោធិសត្វកាលព្រះអង្គបានបំពេញទសបារមី ហើយ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រព្រឹត្តតាមពុទ្ធចរិយា យកពុទ្ធចរិយានេះជាគតិប្រចាំជីវិត ដើម្បីទូន្មានខ្លួនឲ្យប្រព្រឹត្តល្អ ឲ្យមានសីលធម៌ខ្ពង់ខ្ពស់ ឲ្យមានចិត្តតាំងនៅក្នុងធម៌ ។

ពុទ្ធសាសនាយុកាល២៥០០វស្សា.— ព្រះពុទ្ធសាសនាគ្រប់ជា ២៥០០ វស្សាហើយ ប្រជាជនខ្មែរទាំងប្រទេសបានរៀបចំធ្វើបុណ្យរំលឹកពុទ្ធសាសនាគម្រប់ ២៥០០ វស្សានេះយ៉ាងឧឡារិក ដូចប្រជាជនរួមសាសនានៃប្រទេសនានាដែរ ។ ដោយហេតុអ្វី? ហើយព្រោះហេតុអ្វីបានជាប្រជាជនពុទ្ធសាសនិកសកលលោក ធ្វើបុណ្យរំលឹកឆ្នាំនេះទុកជាបុណ្យយ៉ាងធំមួយក្នុងព្រះពុទ្ធសាសនា? នេះជាប្រស្នាគួរជញ្ជឹងគិត ។

ចំណែកប្រជាជនខ្មែរតែងរង់ចាំនូវអតិលក្ខិតសម័យនេះយូរយារណាស់ហើយដោយសោមនស្សជាបំផុត ព្រោះចាស់ទុំរមែងដាស់តឿនប្រដៅកូនចៅទុកតៗគ្នាថា «តាចាស់ហើយ ។ វាអើយ ! ខំធ្វើបុណ្យទានរក្សាសីលទៅ ឲ្យបានទាន់សាសនា២៥០០វស្សានឹងគេ» ប្រដៅកូនចៅហើយ ក៏ខំប្រព្រឹត្តធ្វើល្អខ្លួនឯងផង ព្រោះខ្លួនដល់វ័យចាស់ជរាណាស់ទៅហើយ ក្រែងពុំបានទាន់ពេលវេលាដ៏ប្រសើរនេះនឹងគេ ព្រោះទំនៀមចាត់ទុកថាជាអភ័ព្វមួយយ៉ាងធំក្រៃលែង ។ អាស្រ័យដោយហេតុនេះហើយ បានជាប្រជាជនខ្មែរទាំងក្មេងទាំងចាស់ទន្ទឹងរង់ចាំឱកាសនេះណាស់ ព្រោះក្នុងទំនាយនានាដែលអាចារ្យជាន់ដើមបានព្យាករទុកមកនោះមានសេចក្តីបញ្ជាក់ថា លុះជិតដល់២៥០០វស្សាហើយ ប្រទេសខ្មែរនឹងកើតកលិយុគវឹកវរខ្លាំងណាស់ រហូតដល់សាសនាគ្រប់បរិបូណ៌ជា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



២៥០០វស្សា ទើបព្រះបាទធម្មិកមកលើកពុទ្ធសាសនា បានសេចក្តីសុខសប្បាយត្រេកក្សាន្តទូទៅទាំងប្រទេស ឥតមានទុក្ខសោកពេកភ័យអ្វីមួយបៀតបៀនឡើយ ប្រទេសកម្ពុជាទឹងសម្បូណ៌សប្បាយ ហាក់បីដូចជាឋានសួគ៌ ។

ទំនាយទាំងនេះកើតក្នុងពេលរងទុក្ខវេទនានៃពង្សាវតារខ្មែរ បានធ្វើចិត្តខេមរជនគ្រប់រូបឲ្យមានសេចក្តីសង្ឃឹមជានិច្ច មិនឲ្យលះបង់សេចក្តីប្រឹងប្រែង ឲ្យបេះអត់ធ្មត់តស៊ូចំពោះទុក្ខលំបាកគ្រប់ប្រការ ហើយឲ្យស្មុះស្ម័គ្រទៅរកអនាគតដ៏រុងរោចន៍ ពុំមែនឲ្យដេកចាំព្រេងសំណាងដោយទឹកស្រមៃរេរាយដល់ជោគវាសនាដ៏ថ្លៃថ្លានោះទេ គឺត្រូវឲ្យខិតខំព្យាយាមកសាងអនាគតនោះ ឲ្យកើតជារូបរាងប្រាកដជាក់ច្បាស់ឡើង ព្រោះពុទ្ធសាសនាជាសាសនាហាមវន្ត មិនមែនឲ្យដេកចាំវាសនាទេ ។ រូបរាងកាយឬ ទ្រព្យសម្បត្តិយើង ជាវត្ថុអាចធ្លាក់ទៅក្នុងទាសភាពបាន តែចិត្តគំនិតធ្លាក់ទៅពុំបានទេ តែងតែអណ្តែតខ្ពស់ផុតពីទាសភាពជាដរាប ទឹកចិត្តបែបនេះ បានសំដែងឲ្យឃើញជាក់ច្បាស់ក្នុងពង្សាវតារខ្មែរច្រើនលើកច្រើនគ្រាណាស់មកហើយ ។ ទឹកចិត្តប្រសើរនេះហើយដែលអាចញុំាងប្រជាជននៃប្រទេសនីមួយ ៗ ឲ្យមានខ្លឹមសារ មិនឲ្យសាបសូន្យទៅតាមកាលវិបត្តិឡើយ ។

បើពិនិត្យមើលទៅតាមទំនាយនិងតាមស្ថានការណ៍ក្នុងសកលលោកបច្ចុប្បន្ន ក៏យើងឃើញថា ទំនាយខ្មែរនេះ ហាក់ដូចជាមិនឃ្លាតពីសេចក្តីពិតប៉ុន្មានទេ ប្រទេសខ្មែរបានចំរុងចំរើនក្នុងពេលនេះមែន ឯពុទ្ធសាសនា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទៀត ក៏ជ្រួតជ្រាបពេញទាំងប្រទេសខ្លាំងជាងសម័យមុន ដោយការផ្សាយព្រះបរមពុទ្ធវាទពេញទំហឹងតាមការទេសនា ការបង្រៀនធម្មវិន័យ ការបង្រៀនភាសាបាលី ការផ្សាយសៀវភៅធម៌របស់ពុទ្ធសាសនបណ្ឌិត្យ និងការបង្កើតពុទ្ធិកមហាវិទ្យាល័យ ។

បើពោលតាមវង់ការនានាប្រទេសវិញ យើងឃើញថាទំនាយរបស់ខ្មែរក៏មានទំនងស្របគ្នានឹងទំនាយនៃប្រទេសពុទ្ធសាសនានានាក្នុងសកលលោកដែរ បានជាមានការធ្វើបុណ្យរំលឹកពុទ្ធសាសនាគម្រប់ ២៥០០វស្សាដូចគ្នា ។ ឯស្ថានការណ៍ក្នុងសកលលោក យើងសង្កេតឃើញមានការប្រែប្រួលច្រើន គឺប្រែពីសភាពតឹងតែង ទៅរកសភាពធូរស្រាល មិនសូវនាំឲ្យកើតភ្ញាក់ផ្អើលពីការកំហែងសង្គ្រាមថ្មីនិងផលអាក្រក់ទាំងឡាយនៃសង្គ្រាមនេះពេក ។ យើងសង្កេតឃើញមួយទៀតថា វិវឌ្ឍនភាពខាងសម្ភារនិយមក្នុងយុគបរមាណូ ពុំអាចនឹងបន្ថយនូវស្ថានការណ៍តឹងតែងអន្តរជាតិបានដោយងាយទេ គឺមានតែពិនាំឲ្យកើតបារម្ភតក់ស្លុតរន្ធត់ចំពោះអាវុធថ្មីនេះវិញទេ បានជាប្រទេសទាំងឡាយបបួលគ្នាត្រិះរិះរកមធ្យោបាយស្វែងរកសន្តិភាពខាងចិត្តនិយមវិញ ហើយកំពុងរិះរករូបមន្តថ្មីមួយ ដើម្បីរួបរួមគ្នាជាមិត្តភក្តិ ជួយគ្នាទៅវិញទៅមក ឲ្យរួចផុតទុក្ខវេទនា ឲ្យរួចផុតពីការព្យាបាទគ្នា «រូបមន្តថ្មីនេះពិតប្រាកដជាស្វាក្ខាតធម៌នៃព្រះពុទ្ធសាសនាឥតសង្ស័យឡើយ» ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ធម្មក្នុងព្យាករណ៍ទាំងឡាយពុំ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មែនជាតួបុគ្គលមានបុណ្យណាមួយចុះមករៀបចំប្រទេសនានាក្នុងសកលលោកឲ្យបានសុខសប្បាយឲ្យបានសាន្តត្រាណនោះទេ គឺជានិមិត្តរូបនៃការស្រុះស្រួលគ្នាក្នុងលោក ដោយការគោរពធម៌ ដើម្បីសន្តិសុខ និងការរួមចិត្តគំនិតមូលតែមួយ ដើម្បីធ្វើបុណ្យគោរពពុទ្ធសាសនាយុកាលគម្រប់ ២៥០០វស្សា រំលឹកដល់ពាក្យឱវាទនៃព្រះបរមគ្រូដែលជាអាវុធដ៏មុតថ្លា អាចកាប់ផ្តារនូវមហាមោហន្ធការក្នុងលោក ចំណាយបង់នូវអំពើបៀតបៀន កំរោលឃោរឃៅ នូវឥស្សាឈ្នានីសសាហាវយង់ឃ្នង នូវអំពើចងពៀរព្យាបាទគំនុំគុំកួនដែលជាគំនរភ្លើងអសន្តិសុខ ឲ្យប្រែក្លាយសភាពអសុរទៅជាសភាពសិវដ្ឋាន ហើយផ្សាយប្រគល់នូវសន្តិសុខដែលជាទឹកអម្រឹតទិព្វវិសេសស្រោចស្រពប្រជាជនសកលលោកឥតរើសមុខ រើសពូជពង្សរើសពណ៌សម្បុរឡើយ ។ បរិយាកាសប្រពៃដែលបានអប់រំប្រជាករកាលពី ២៥០០ ឆ្នាំកន្លងមកហើយនោះ ក៏ដូចជាមករួមកម្លាំងគ្នាកើតឡើងចំក្នុងពេលនេះ មួងនេះពុំមែនមានខេត្តខណ្ឌត្រឹមតែព្រំប្រទល់មជ្ឈប្រទេសប៉ុណ្ណោះទេ អាចរាតត្បាតសន្ធឹងផ្សព្វផ្សាយទូទៅគ្រប់ទ្វីបក្នុងភូគោលដុំពិភពលោក ដែលមានពុទ្ធបរិស័ទចំនួនប្រមាណ ៥ រយលាននាក់ កំពុងសោមនស្សរីករាយគោរពបូជាព្រះសម្មាសម្ពុទ្ធ ផ្សាយនូវមេត្តាធម៌គ្រប់ទិសដំបន់ ត្រូវការចក្តុមគតិតែមួយគឺ « សន្តិសុខ » តែប៉ុណ្ណោះ ។

ប្រជាជនខ្មែរទុកជាមានភ័ព្វប្រសើរណាស់ ដោយបានទទួលពន្លឺពុទ្ធសាសនាតាំងពីបុព្វកាលរៀងមក ហើយខំថែរក្សាទុកមិនឲ្យបាត់បង់ទៅវិញ ពន្លឺនេះរុងរឿងចិញ្ចាចចាំងក្នុងបច្ចុប្បន្នកាលនេះ ជាគំរូមួយឲ្យ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សកលលោកមើល ទុកដូចជាព្រះពុទ្ធសាសនាមានជីវិតនៅរស់រវើកក្នុងផែនដីខ្មែរ ហាក់ដូចសម័យពុទ្ធកាល ។ ប្រទេសខ្មែរដែលបានរក្សាព្រះពុទ្ធសាសនាទុកមកដោយប្រពៃដូច្នេះ ទុកជាបានរក្សាទុកនូវទឹកអម្រឹតទិព្វវិសេស សម្រាប់ជួយរំលត់ភ្លើងទុក្ខសកលលោកឲ្យរលត់ ហើយឲ្យបានសេចក្ដីសុខពិត ឈ្មោះថាបានបូជាដោយពិសេសចំពោះអង្គព្រះសម្មា-សម្ពុទ្ធបរមគ្រូដោយបដិបត្តិបូជាដ៏ខ្ពង់ខ្ពស់ ។

ចំណែកភិក្ខុសាមណេរនៅប្រទេសខ្មែរ ខិតខំទ្រទ្រង់ធុរៈទាំងពីរក្នុងពុទ្ធសាសនាព្រមទាំងផ្សាយពុទ្ធសាសនាឲ្យបានជ្រួតជ្រាបទូទៅឥតកំណត់កាលវេលាឡើយ មានបំណងតែមួយចង់ឲ្យតែសាសនាព្រះសម្មាសម្ពុទ្ធឋិតថេរចេរកាលអង្វែងតទៅ តែងតែនមស្ការគុណព្រះរតនត្រ័យរាល់ទិវា-រាត្រីស្វាធ្យាយពុទ្ធភាសិតោវាទ រួចហើយសូត្ររំលឹកពុទ្ធសាសនាថា ៖

« សូមគោរពរំលឹកដល់កាលដែលព្រះសក្យមុនីសព្វញ្ញុពុទ្ធ ព្រះអង្គចូលនិព្វានទៅដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយអនុរាធ-នក្ខត្តឫក្ស នាយាមអង្គារ ថ្ងៃអង្គារ ១៥ កើតខែពិសាខ គម្ហរជូវឆ្នាំម្សាញ់ ក្រោមបន្ទោះមែកសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារាក្នុងបច្ចូសសម័យ ។ រាប់ចាប់ដើមតាំងពីថ្ងៃ ខែ ឆ្នាំនោះមកដល់ថ្ងៃចន្ទ ១៥ កើតខែពិសាខឆ្នាំរកានព្វស័កនេះ ពុទ្ធសករាជកន្លងទៅបាន ២៥០០ ឆ្នាំហើយ ។

សូត្ររំលឹកពុទ្ធសាសនាដោយជ្រះថ្លា ព្រោះបានទ្រទ្រង់ធុរៈក្នុងពុទ្ធសាសនាឲ្យគង់វង់ឋិតថេរចិរកាលអង្វែងមួយថ្ងៃហើយមួយថ្ងៃទៀត

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជាប់ជានិច្ចមិនដាច់ផ្ទះរួចហើយ ក៏ស្វាធ្យាយបច្ឆិមពុទ្ធវចនៈបញ្ចប់ថា៖

«ម្នាលអានន្ទ! ធម៌ក្តី វិន័យក្តីដែលតថាគតបានទេសនាហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ធម៌និងវិន័យនោះ ឥតអំពីតថាគតទៅ នឹងជាគ្រូអាចារ្យនៃអ្នកទាំងឡាយ;

«អ្នកណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី បើបានប្រតិបត្តិធម៌សមគួរដល់ធម៌ហើយ អ្នកនោះឈ្មោះថាបានធ្វើសក្ការគោរព រាប់អាន-បូជាតថាគត ដោយការបូជាដ៏ខ្ពង់ខ្ពស់;

«ម្នាលភិក្ខុទាំងឡាយ! ឥឡូវនេះ តថាគតដាស់តឿនអ្នកទាំង-ឡាយរាល់គ្នាថា «សំខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរបំពេញកិច្ចទាំងពួងរបស់អ្នកឲ្យបានពេញបរិបូណ៌ដោយសេចក្តីមិនប្រមាទចុះ» ។

ក្នុងអភិលក្ខិតសម័យ ២៥០០ នេះ ខ្ញុំសូមទូនកាយវាចា ចិត្តក្រាបថ្វាយបង្គំចំពោះព្រះសោណកត្ថេរ ព្រះឧត្តរត្ថេរ ដែលបាននាំព្រះពុទ្ធសាសនាមកប្រតិស្ឋាននៅក្នុងដែនដីសុវណ្ណ-ភូមិនេះ ចំពោះព្រះមហាថេរានុត្ថេរៈទាំងឡាយ ដែលបានខំប្រឹងរក្សាព្រះពុទ្ធសាសនាទុកមកដោយសេចក្តីគោរព ។

សូមព្រះពុទ្ធសាសនា " សាសនាទឹកអម្រឹត „ រីកធំទូលំទូលាយផ្លូតផ្លាបផ្សប់ផ្សាយទូទៅពេញសកលលោក ញុំាងលោចសន្និវាសនេះឲ្យបានត្រជាក់ត្រជុំក្សេមក្សាន្តជានិច្ចនិរន្តរ អស់កាលជាអង្វែងតទៅហោង ។

ប. ៗ.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com



ព្រះចេតិយពុទ្ធគយា នៅទីពោធិព្រឹក្ស ក្នុងរដ្ឋពិហារ ប្រទេសឥណ្ឌា

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# វគ្គទី ៣

## សិល្បៈពុទ្ធសាសនា

## អំពីពាក្យថា “សិល្បៈ”

ពាក្យថា “សិល្បៈ” ជាពាក្យដែលយើងធ្លាប់និយាយមកជាយសិបសាំដែរហើយ, ប៉ុន្តែវេលានេះ ជាពេលចាំបាច់ក្នុងការសំដែងអំពីសិល្បៈ ដែលជាប់ទាក់ទងក្នុងផ្លូវពុទ្ធសាសនាដូចសេចក្ដីបរិយាយតទៅនេះ ៖

សិល្បៈជាភាសាសំស្ក្រឹត, សិប្បៈជាភាសាបាលី ប្រែជាភាសាខ្មែរថា “ការឈ្លាសវៃដោយដៃ, ការប៉ិនប្រសប់, ជំនាងដ៏ថ្នឹក, ហត្ថកម្មដ៏ស្ទាត់ជំនាញ” ។

សិល្បៈជាឈ្មោះវិជ្ជាបច្ចេកទេស ដែលប្រកបដោយហត្ថកម្មទាំងដៃឆ្លៀវឆ្លាសដោយអំណាចនៃការហាត់រៀន, ការអប់រំរឿយៗ គឺថា វិជ្ជាកម្មណាដែលគេបានព្យាយាមសិក្សាធ្វើដោយផ្ទាល់ដៃ ដរាបដល់ថ្នឹកចាំស្ទាត់ប្រាកដហាក់ដូចជាចម្លាក់ជាប់នៅក្នុងចិត្តឥតគាន់ច្រឡំឥតភ្លេច, វិជ្ជាកម្មនោះឈ្មោះថា សិល្បៈទាំងអស់ ។

ពាក្យថា “សិល្បៈ” បើប្រែតាមធាតុថា “វិជ្ជាកម្មដែលគួរសិក្សា, ដែលគួរសេពគប់, ដែលគួរចូលចិត្ត” ដូចបាលីវិគ្រោះថា “អត្តនោ ហិ-តមាសីសន្តេហិ សេវិយតេតិ សិប្បំ វិជ្ជាកម្មណា ដែលបុគ្គលអ្នកប៉ុនប៉ងនូវប្រយោជន៍ដើម្បីខ្លួនគួរសេពគប់ វិជ្ជាកម្មនោះ ហៅថា សិប្បៈ (សិល្បៈ)”

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មួយទៀតថា «សិក្ខិតព្វន្តិ សិប្បំ វិជ្ជាកម្មដែលគប្បីរៀន (សិល្បៈ)» ។

សិល្បៈ បើចែកតាមលក្ខណៈ (គ្រឿងសំគាល់) មាន៣ យ៉ាង ដូចសេចក្ដីរៀបរាប់ព្រមទាំងអធិប្បាយតទៅនេះ

លក្ខណៈនៃសិល្បៈ (ហៅតាមបាលីថាសិប្បៈ) មាន ៣ យ៉ាង គឺ

១. អភិធេយ្យសិប្បៈ សិល្បៈដោយឈ្មោះ;

២. ហេតុសិប្បៈ សិល្បៈកើតអំពីហេតុ;

៣. ផលសិប្បៈ សិល្បៈកើតអំពីផល ។

## អធិប្បាយលក្ខណៈសិល្បៈ

១. អភិធេយ្យសិប្បៈ សិល្បៈដោយឈ្មោះ ។

សិល្បៈនេះ លោកអ្នកប្រាជ្ញសំដែងតាមឈ្មោះនៃវិជ្ជាកម្មដែលមានមកតាំងពីបុរាណកាល សឹងមាន ក្នុងគម្ពីរអដ្ឋកថា ។ ខាងខុទ្ទកនិកាយ ត្រង់ឧទ្ទេសគ្គបាលឈ្មោះសិល្បៈធំៗ ហៅថា «មហាសិប្បៈ» មាន ១៤ យ៉ាងគឺ

១) ហត្ថិសិប្បៈ សិល្បៈក្នុងការបង្ហាត់ដំរី;

២) អស្សសិប្បៈ សិល្បៈក្នុងការបង្ហាត់សេះ;

៣) រថសិប្បៈ សិល្បៈក្នុងការធ្វើរទេះ បររទេះ;

៤) ធនុសិប្បៈ សិល្បៈក្នុងការបាញ់ធ្នូ;

៥) ថរុសិប្បៈ សិល្បៈក្នុងការធ្វើគ្រឿងអាវុធមានដាវជាដើម;

៦) មុទ្ធាសិប្បៈ សិល្បៈក្នុងការរាប់គាញ់គ្នេរដោយដៃទទេ;

៧) គណនាសិប្បៈ សិល្បៈក្នុងការគិតតាមលេខគណិតសាស្ត្រ;

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

៨) សន្ធានសិប្បៈ: សិល្បៈក្នុងការពិចារណា ដោយប្រាជ្ញាក្នុងឧបទេស គឺនយោបាយ;

៩) លេខាសិប្បៈ: សិល្បៈក្នុងការសរសេររៀបចំអក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ;

១០) កាវេយ្យសិប្បៈ: សិល្បៈក្នុងកាព្យឃ្លោង;

១១) លោកាយតសិប្បៈ: សិល្បៈក្នុងផ្លូវលោកមានវិជ្ជាពេទ្យ, វិជ្ជាផ្សំធាតុជាដើម;

១២) ខត្តិវិជ្ជាសិប្បៈ: សិល្បៈក្នុងវិជ្ជានីតិធម្មសាស្ត្រ, យុទ្ធសាស្ត្រ ។

ទិសៀតក្នុងសាលាទិសាបាមោក្ខ ក្រុងតក្កសិលាក្នុងសម័យបុរាណគេតែងយកសិល្បៈទាំង ១២ យ៉ាងនេះ ទៅដាក់ក្នុងកម្មវិធីសម្រាប់បង្រៀន ។

សិប្បសាធារណៈដោយឡែកទៀតមាន ៩ យ៉ាង គឺ

១) ទារុសិប្បៈ: សិល្បៈ ក្នុងការកសាងដោយគ្រឿងឈើមានការសង់ផ្ទះជាដើម ;

២) សុធាសិប្បៈ: សិល្បៈក្នុងការកសាង ដោយគ្រឿងកំបោរបាយអ, ឥដ្ឋ ;

៣) លោហធាតុសិប្បៈ: សិល្បៈក្នុងការរំលាយ សិតសូនគ្រឿងលោហធាតុ ;

៤) វត្ថសិប្បៈ: សិល្បៈក្នុងការធ្វើសំពត់;

៥) ចិត្តកម្មសិប្បៈ: សិល្បៈក្នុងការគូររូបផ្សេងៗ;

AngkorLink.com CambodiaBuddhist.org ABCCambodia.com



៦) ចម្មសិប្ប: សិល្ប:ក្នុងការសម្ងាប់ស្បែក;

៧) មណិការសិប្ប: សិល្ប:ក្នុងការស្វែងរកពេជ្រ ច្នៃពេជ្រ ;

៨) ឧឡុការសិប្ប: សិល្ប:ក្នុងការត្បាញផែង ត្បាញកន្ទេល ;

៩) ឧហាបិតសិប្ប: សិល្ប:ក្នុងការកាត់កោរសក់ ។

សិល្ប: មានឈ្មោះ ៧ យ៉ាងទៀត គឺ

១) វេឧសិប្ប: សិល្ប:ក្នុងការជ្រលក់សំពត់;

២) ឆេទឧសិប្ប: សិល្ប:ក្នុងការកាត់សំពត់អាវ, ស្បង់ចីពរ;

៣) សិព្វឧសិប្ប: សិល្ប:ក្នុងការដេរប៉ាក់ ;

៤) រចឧសិប្ប: សិល្ប:ក្នុងការគូរក្បាច់ក្បូរ ;

៥) កុម្ភការសិប្ប: សិល្ប:ក្នុងការធ្វើក្អម ឆ្នាំង ឬភាជន:ពិសេសណាមួយ ;

៦) សុវណ្ណការសិប្ប: សិល្ប:ក្នុងការធ្វើមាស ;

៧) នាដកសិប្ប: សិល្ប:ក្នុងរបាំ ។

ក្នុងគម្ពីរមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រថា «វិជ្ជាណាមួយ ដែលគេរៀនហាត់ស្ទាត់បានចចង្រៃកអស្ចារ្យ គួរឲ្យអ្នកផងកោតសរសើរ សូម្បីតែវិជ្ជាផ្ចាត់ផ្ចុំគ្រួស ក៏លោកហៅថា សាឡិតសិប្ប: ឬសក្ខរសិប្ប: ដែរ»។

២) ហេតុសិប្ប: សិល្ប:កើតអំពីហេតុ ។

សិល្ប:ទាំងអស់ ដែលជាប់ដោយហត្ថកម្ម សុទ្ធតែកើតឡើងអា-ស្រ័យហេតុ គឺថាមានហេតុជាប្រភព (ជាដែនកើត)នៃសិល្ប: ។ ពាក្យ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជា «ហេតុ» បានដល់ដំណើរឬការណ៍អ្វីមួយ ដែលកើតមុនដំបូងបង្អស់ ដូចយ៉ាងអារម្មណ៍ណាមួយ ដែលមាននៅក្នុងគំនិតរបស់មនុស្ស ឬជា គួ មនោសញ្ចេតនា ដែលអាចឆាករ ត្រិះរិះរកការងារ ឬរកវត្ថុសម្ភារៈ សម្រាប់ប្រើប្រាស់ លុះត្រិះរិះគិតឃើញជាក់ច្បាស់ហើយ ឈ្មោះថា មនោសញ្ចេតនា បានប្រមូលគំនិតនោះទុកឲ្យឋិតនៅមូលក្នុងចិត្តស៊ប់ស្ងួន ល្អហើយ ៗ លំដាប់ពីនោះមក យោនិសោមនសិការៈ ការកំណត់ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញារបស់មនុស្ស ក៏រមែងកើតឡើង ដោយមានមនោសញ្ចេតនា ជាហេតុ លុះយោនិសោមនសិការៈ មានកម្លាំងឡើងដោយរួមជាមួយនឹងវីរិយៈ ក៏អាចបបួលដឹកនាំឲ្យចុះដៃចាប់ធ្វើនូវវត្ថុសម្ភារៈ ដែលកំណត់ទុកនោះ តាមស្នាមគំនូសរបស់គំនិត ដែលគិតឃើញពីមុនដរាបដល់ចុះដៃចាប់ធ្វើឲ្យកើតបានដូចបំណងឬមិនទាន់បានដូចបំណងប៉ុន្តែការងារនោះរបេះតែជួយបំភ្លឺបន្តិចៗជាលំដាប់ ឈ្មោះថាមានសិល្បៈជួយពង្រីកគំនិតឲ្យកាន់តែយល់ស្គាល់ដំណើរការណ៍នោះៗ ដោយមានយោនិសោមនសិការៈជាហេតុ ៗ

វត្ថុៗទាំងអស់ មានចេតិយប្រាង្គប្រាសាទជាដើម ដែលកើតឡើងនោះបើល្អក្តី អាក្រក់ក្តី សុទ្ធតែកើតមកពីហត្ថកម្ម (ការងារដែលធ្វើដោយដៃ) ៗ រូបវត្ថុដែលល្អ មកពីហត្ថកម្មស្ទាត់ជំនាញ, រូបវត្ថុដែលមិនល្អមកពីហត្ថកម្មមិនទាន់ស្ទាត់ជំនាញ ៗ ដំណើរនេះបើពោលដោយរួមរួម គឺសិល្បៈទាំងអស់ សុទ្ធតែកើតមកអំពីហេតុ មានមនោគតិ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



(ដំណើររបស់គំនិត) ជាដំបូងបង្អស់ ដែលឲ្យកំណើតដល់សិល្បៈ ឬទឹង ថាសិល្បៈគ្រប់យ៉ាងក្នុងលោកនេះ កើតមកអំពីមនោគតិរបស់មនុស្សដូច្នេះវិញក៏បាន ។ មនោគតិដែលគេបានអប់រំញឹកញយនេះឯងជាមូលហេតុនាំឲ្យកើតសិល្បៈ ដោយមិនហួសអំពីវិស័យគំនិតមនុស្សឡើយ ព្រោះថា មនោគតិរបស់មនុស្សអ្នកមានសមត្ថភាពមិនចេះនៅស្ងៀម ឈរទ្រឹងនៅដដែលទេ ចេះតែមានការវិវត្តន៍ (ការសើរើពរែក) នូវអព្ភុតវត្ថុ (វត្ថុដែលមិនទាន់កើតមាន) ជារឿយៗជួនកាលក៏ធ្លាប់បានសម្រេចដូចបំណង ជួនកាលក៏យូរ អស់មួយតំណអាយុក៏មាន ពីរបីតំណអាយុក៏មាន ។

សម័យជាលំដាប់តមក ពួកសិប្បវ័ន្ត (អ្នកមានសិល្បៈ) ក៏អាចរៀបចំនិពន្ធក្បួនតម្រា ចងជាច្បាប់ទុកបន្តមកទៀត ដើម្បីឲ្យងាយក្នុងការរចនាវត្ថុផ្សេងៗ ដល់មនុស្សជាន់ក្រោយ ៗ ក្បួនតម្រា ដែលពួកសិប្បវ័ន្តបាននិពន្ធទុកមកនោះ ហៅថា សិល្បសាស្ត្រ ប្រែថា គម្ពីរដែលនិយាយអំពីសិល្បៈ ដកបមក ៗ ពួកអ្នកមានវិជ្ជាបច្ចេកទេស ពីដើមដំបូងបង្អស់នោះហត់នឿយក្នុងការប្រើគំនិតពិចារណាពរែកក្រៃពេកណាស់ ទម្រាំនឹងកើតបានជារូបសិល្បៈ, ជារូបសិល្បសាស្ត្រឡើង ។

អ្នកបច្ចេកទេសជាន់ក្រោយ ដែលចុះស្នាមក្នុងការសិក្សាតាមលំអានសិល្បសាស្ត្រ ដែលគេបាននិពន្ធទុកមកហើយនោះ មិនសូវលំបាកហត់នឿយ ដោយមធ្យោបាយក្នុងមនោគតិប៉ុន្មានទេ ព្រោះហេតុមានក្បួនតម្រា, មានកម្មវិធី, មានរូបមន្ត, មានកម្មសិក្សារបស់បុព្វបុរសស្រាប់ៗ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



វិជ្ជាបច្ចេកទេសរបស់មនុស្សដែលបានសិក្សាតាមក្បួនតម្រា កំរេះតែប្រ-គបដោយវឌ្ឍនភាពមានបដិសម្ភិទា (បែកគំនិតប្រាជ្ញា) រីកផ្សាយទូលាយកាន់តែចំរើនឡើងតមកទៀត ៗ សិល្បៈទាំងអស់ដែលកើតមានឡើងដោយអ្នកនិពន្ធ ក៏ព្រោះតែគំនិតពីរេករបស់មនុស្ស ជាបុព្វបុរសជាដើមហេតុ ៗ ករណីនេះ សិល្បៈគ្រប់យ៉ាងទើបឈ្មោះថា កើតមកអំពីហេតុ ៗ

៣- ផលសិប្បៈ សិល្ប កើតអំពីផល ៗ

សិល្បៈដែលសង្គ្រោះថា កើតអំពីផលនោះសំដៅយករូបវត្ថុផ្សេងៗមានចេតិយឬព្រះពុទ្ធរូបជាដើម ដែលបុព្វបុរស បានសាងទុកមកហើយដោយហេតុឲ្យយើងបានឃើញជំនាងស្នាដៃស្ទាត់ជំនាញឬមិនស្ទាត់ជំនាញជារូបមានបែបភាពទ្រង់ទ្រាយ, មានក្បាច់របនា តាមជំនាន់តាមសម័យជូនផលដល់យើង ដើម្បីឲ្យយើងឃើញបែបយ៉ាងរបស់វប្បធម៌នៃបុព្វបុរសតាមសម័យនោះ ៗ ៗ ពាក្យថា « ផល » ប្រែថា កំរៃ, ផ្លែឈើ, សេចក្តីចំរើន, សេចក្តីរុងរឿង, សេចក្តីសម្រេចដូចបំណង, លាភ, យស, រង្វាន់ ៗ

ត្រង់ដែលថា សិល្បៈ កើតអំពីផលនោះ សំដៅយកការហាត់រៀនកន្លងផ្លូវសិល្បៈរបស់មនុស្សដែលសម្លឹងឃើញផលដែលត្រូវបាន, ការហាត់រៀននោះក៏រេះតែខំតស៊ូមិនខ្លាចខ្វបស័គ្គណាមួយ ដោយមានបំណងចំពោះផលជាទិសស្ទន៍, មួយទៀតសិល្បៈនេះរាប់ថាជាផ្លូវអាជីវៈមួយដ៏ប្រសើរដែលនាំឲ្យមនុស្សមានជីវភាពខ្ពង់ខ្ពស់ ឧទាហរណ៍ ដូចសិល្បៈខាងការ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



រចនាព្រះពុទ្ធរូប, ស្តូប, ចេតិយ, ប្រាង្គ, ប្រាសាទ, វិហារ, សាលា, គំនូរ និងការរចនាផ្សេងៗ របស់បុព្វបុរសដែលវិវត្តមកដល់យើងសព្វថ្ងៃឲ្យយើងបានឃើញជាភស្តុតាងយ៉ាងជាក់ស្តែង ។ សិល្បៈរបស់យើងជាន់ក្រោយឈ្មោះថា កើតមកអំពីផលរបស់សិល្បៈនៃបុព្វបុរសដែលបានផ្តល់ទស្សនៈឲ្យយើង ។ រូបភាពទាំងអស់ដែលបុព្វបុរសខ្មែរសាងឡើងដោយថ្មក្តី ដោយបាយអឥដ្ឋក្តី ឈ្មោះថាជារូបសិល្បៈស្ថាពរមានមកយូរហើយ ដើម្បីជានិទស្សន៍ បង្ហាញយើងជាន់ក្រោយ ។

## អំពីព្រះពុទ្ធរូប

ព្រះពុទ្ធរូប បើតាមអ្នកប្រាជ្ញប្រវត្តិសាស្ត្រត្រាច់រង្គាត់ស្រាវជ្រាវរកបុរាណវត្ថុក្នុងប្រទេសផ្សេងៗ មានប្រទេសឥណ្ឌាជាដើម គេឃើញព្រះពុទ្ធរូបច្រើនបែប ប៉ុន្តែបើទុកជាយ៉ាងណា ក៏ព្រះពុទ្ធរូបនោះៗ ប្លែកពីរូបមនុស្សធម្មតាដែលអាចឲ្យអ្នកផងឃើញហើយ គួរឲ្យស្គាល់បានភ្លាមថាជារូបព្រះពុទ្ធ ។ មួយទៀត ព្រះពុទ្ធរូបដែលគេឆ្លាក់ថ្មក្តី ខ្លឹមឈើក្តី គេតែងតម្រូវចិត្តនៃពុទ្ធសាសនិកជនផង ឲ្យត្រូវតាមមហាបុរិសលក្ខណៈនៃព្រះសម្មាសម្ពុទ្ធផង ។ ប៉ុន្តែពួកអ្នកសិប្បវ័ន្ត ដែលកសាងព្រះពុទ្ធរូបនោះទោះបីអំពីថ្មក្តី ខ្លឹមឈើក្តី ឬគំនូរក្តី ច្រើនតែធ្វើទៅតាមបែបភាពទ្រង់ទ្រាយមុខមាត់ របស់ជាតិខ្លួនឯងជាដរាប មិនសូវខុសអំពីមុខមាត់របស់ជាតិខ្លួនបានឡើយ ដែលនាំឲ្យយើងស្គាល់ថា ជាការរចនារបស់ជាតិនេះ ជាតិនោះជាប្រាកដ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បើតាមសេចក្តីរាយការណ៍របស់អ្នកប្រាជ្ញ ដែលស្វែងរកបុរាណវត្ថុឃើញថា ព្រះពុទ្ធរូបទើបតែនឹងកើតមានឡើងក្នុងកាលខាងក្រោយ ដែលពុទ្ធសករាជកន្លងទៅបានជាង ៤០០ ឆ្នាំហើយពុំមែនកើតឡើង ក្នុងកាលព្រះអង្គគង់ព្រះជន្មនៅឡើយនោះទេ ។ ព្រះពុទ្ធរូបដែលកើតមុនដំបូងបង្អស់ នៅក្នុងប្រទេសគន្ធារៈ ដោយព្រះបាទកនិស្កៈ ជាក្សត្រមួយព្រះអង្គ ជាជាតិក្រិក ជាប់ពូជវង្សមកអំពីព្រះបាទអាឡេកសង់ដ្រ៍ ដែលមានឥទ្ធិពលពង្រីកអាណាចក្រចូលមកក្នុងប្រទេសឥណ្ឌា ក្នុងកាលពុទ្ធសតវត្សរ៍ទី ៤ ។ បន្ទាប់មកពួកសិប្បករ ជាតិក្រិកខ្លះ ជាតិឥណ្ឌាខ្លះ ចេះតែកសាងព្រះពុទ្ធរូប ដោយការឆ្លាក់ថ្មក៏មាន ខ្ចឹមឈើក៏មានតៗគ្នា តាំងពីកាលនោះមក ។

## ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប

១– ព្រះពុទ្ធរូបសមាធិ គង់ពត់ព្រះភ្លៅមានព្រះហស្តស្តាំផ្ងារលើព្រះហស្តឆ្វេង តម្រែតលើព្រះភ្លៅ ហៅថា វិតក្កមុទ្រា ។

២– ព្រះពុទ្ធរូបមារវិជ័យ (កាលផ្ចាញ់មារ) គង់ពត់ព្រះភ្លៅដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំផ្កាប់លើព្រះឩរុ (ភ្លៅ) បង្អុលចុះទៅផែនដី, ព្រះហស្តឆ្វេងផ្ងារដាក់លើព្រះឩរុ ហៅថា ភូមិស្បើសមុទ្រា ។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរនៅជញ្ជាំងវិហារ ឬលើផ្ទាំងសំពត់ ឃើញសុទ្ធតែមានរូបពួកពលមារពធិកជ កាន់អាវុធពល់ដៃ ។

៣– ព្រះពុទ្ធរូបសំដែងធម្មចក្រ គង់ពត់ព្រះភ្លៅមានព្រះហស្តស្តាំ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក្តោបម្រាមធ្វើជាវង់មូលដូចជារូបកង់រទេះ, ព្រះហស្តឆ្វេងធ្វើអាការដូចព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរុក៏មានហៅថា ធម្មចក្រមុទ្រា ។ ព្រះពុទ្ធ-រូបថែបនេះ កាលបើគេគូរ តែងតែមានរូបបញ្ចវគ្គិយភិក្ខុ កំពុងអង្គុយគោរព ស្តាប់ធម្មចក្កប្បវត្តនសូត្រ ដែលជាបឋមទេសនា ។

៤– ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ប្រោសសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មាន គង់ពត់ព្រះភ្លៅក៏មាន ព្រះហស្តស្តាំលាចេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះហៅថា អភយមុទ្រា ។

៥– ព្រះពុទ្ធរូបប្រទានពរ មានព្រះហស្តទាំងពីរសំយុងចុះ បែរបាតព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្លៅក៏មាន ទ្រង់ឈរក៏មាន ជាដំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំដោយត្រូវការចង់ជួបចង់ឃើញក្តី ក្រាបទូលសួរធម៌អាថ៌ចំពោះព្រះអង្គក្តី ហៅថា វរមុទ្រា ។

៦– ព្រះពុទ្ធរូបទ្រង់ឈរឧបបាត្រ ជាតំណាងកាលដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត ហៅថា បាត្រាទានមុទ្រា ។

៧– ព្រះពុទ្ធរូបទ្រង់ផ្ទុំ ជាតំណាងកាលដែលព្រះអង្គផ្ទុំផ្អៀងព្រះកាយទៅខាងស្តាំ ព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំដោយទ្រង់ផ្ទុំធម្មតាក្តី ផ្ទុំលើមញ្ចាសនៈជាអនុដ្ឋានសញ្ញាទ្រង់បរិនិព្វានក្តី ហៅថា សយន-មុទ្រា ។

៨– ព្រះពុទ្ធរូបនាគប្រក់ ជាតំណាងកាលព្រះអង្គគង់នៅក្នុងស្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មុចលិន្ទ ដែលក្នុងពេលនោះមានភ្លៀងបង្អុរខ្លាំង មាននាគរាជមកពេនព័ទ្ធព្រះអង្គបើកពពារគ្របបាំងលើព្រះអង្គដើម្បីការពារភ្លៀង ។

ពាក្យថា «មុទ្រា» នេះជាពាក្យសំស្ក្រឹត, បាលីថា «មុទ្ទា», ប្រែជាខ្មែរថា «គ្រឿងសំគាល់, បែបយ៉ាង, អាការ, កាយវិការ, ត្រា, សញ្ញា » ។

ព្រះពុទ្ធរូបទាំង៨បែបនេះ ជារូបដែលគេយកថ្ម មកឆ្លាក់ក៏មាន យកចម្លាក់ពុម្ពលាយស៊ីម៉ងត៍នឹងខ្សាច់បោះពុម្ពក៏មាន ឥឡូវនេះគេច្រើនតែបោះពុម្ព ។ ព្រះពុទ្ធរូបដែលមានគ្រឿងសំគាល់ផ្សេងៗគ្នានេះ ជាបែបសិល្បៈនៃបុព្វបុរសជាតិខ្មែរ ជាពុទ្ធសាសនិកខាងនិកាយថេរវាទ ដែលគួរគោរពគួរជឿបានដោយពិត ព្រោះជារូបដែលកសាងត្រូវតាមគោលរឿងពុទ្ធប្បវត្តិ ។ ព្រះពុទ្ធរូបទាំង ៨ បែបនេះនៅប្រទេសខ្មែរយើង គេមិនគ្រាន់តែរចនាដោយឆ្លាក់ឈើថ្ម ឬបោះពុម្ពដោយស៊ីម៉ង់ទេ ឃើញគេគូរនៅជញ្ជាំងវិហារក៏មាន គូរលើផ្ទាំងសំពត់ក៏មាន លើផ្ទៃកញ្ចក់ក៏មាន គឺគេគូរតាមរឿងពុទ្ធប្បវត្តិ ឬទសជាតក៍, មានរូបមួយបែបទៀតដែលអ្នកស្រុកហៅថាព្រះពុទ្ធរូបទ្រង់គ្រឿង ប៉ុន្តែតាមពិតរូបនេះ ពុំមែនជាព្រះពុទ្ធរូបទេ គឺជារូបស្តេចចក្រ ឬ ជារូបព្រះមេត្តេយ្យពោធិសត្វ មានទ្រង់មកុដ, សង្វារ, ខ្សែស្មារងនឹងចិញ្ចៀនដូចរូបស្តេចទ្រង់មកុដ ឬរូបស្រីល្ខោន ។

ព្រះពុទ្ធរូបនាគប្រក់ នៅប្រទេសឥណ្ឌា មិនដែលឃើញមានទេ មានតែក្នុងប្រទេសខ្មែរ ដែលកើតឡើងដោយសិល្បៈខ្មែរក្នុងសម័យខាងក្រោយកសាងតាមរឿងពុទ្ធប្បវត្តិ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អំពីស្តូប-ចេតិយ

ស្តូបជាគារវត្ថុ ជាទីបញ្ចុះសព ឬអដ្ឋិធាតុរបស់បុគ្គល មានមាតាបិតាជាដើម ដែលគេគួរគោរព ។ រូបភាពស្តូបមានពងមូលខាងក្រោមរីកធំ ត្រសាកខាងលើវៀវស្រួចដូចអកកំបោរក៏មាន, មានពងពាលដូចផ្តិលផ្កាប់ក៏មាន, ដែលគេកសាង ដោយពូនដីជាពំនូកក៏មាន កសាងដោយឥដ្ឋ ដោយថ្មក៏មាន, ស្តូបគ្រប់បែបច្រើនតែមិនសូវមានក្បាច់របនាទេ ច្រើនតែលាតរលីងជុំវិញ ។ ពាក្យថា «ស្តូបៈ» ជាភាសាសំស្ក្រឹត បាលីថា «ថូប» គឺគោលជាគ្រឿងចំណាំទីកន្លែងអដ្ឋិធាតុសម្រាប់គោរពបូជា ។

ចេតិយជាឈ្មោះគារវត្ថុដូចស្តូបដែរ ។ ពាក្យថា «ចេតិយ» ប្រែថា ទីដែលគួរគោរព គួរបូជា ។ ចេតិយមានទំហំកំពស់ធំខ្ពស់ជាងស្តូប តាំងតួពងរៅច្រើនតែប្រកបក្បាច់របនាផ្សេង ៗ គ្នា, គេកសាងដោយឥដ្ឋ-ថ្មក៏មាន ដោយស៊ីម៉ង់ត៍ក៏មាន ។ ចេតិយប្រដាប់ដោយកំពូលវៀវស្រួចក៏មាន ដាក់ឆត្រតួតធ្វើដោយស្ពាន់ត្រង់កំពូលក៏មាន, កំពូលមានមុខ ៤ ដូចជាមនុស្សដែលគេច្រើនហៅថា «មុខព្រហ្ម» ក៏មាន ។ ចេតិយដែលធ្វើជាកំពូលមុខព្រហ្មនេះ ដោយភ្ជាប់ជាប់ទាក់ទងនឹងសាសនាព្រាហ្មណ៍ ដោយហេតុសាសនាព្រាហ្មណ៍តែងគោរពនមស្ការចំពោះព្រះព្រហ្មដែលបិតនៅឯឋានព្រហ្ម ដោយហេតុថា ព្រះព្រហ្មមានធម៌ ៤ ប្រការគឺ មេត្តា ករុណា មុទិតា ឧបេក្ខា ។ មួយទៀត ខាងអ្នកកាន់ពុទ្ធសាសនាមហាយានថា រូបដែលមានមុខ ៤ នេះ ជារូបព្រះពោធិសត្វ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com



ព្រះពុទ្ធរូបថ្មនាគប្រក់ នៅប្រាសាទបាយ័ន អង្គរធំ
ជាសិល្បៈខ្មែរភាគ ព.ស.១៧៥០ គ.ស ១២០៨

AngkorLink.com CambodiaBuddhist.org ABCCambodia.com



អវលោកិតេស្វរៈ ដែលគេសាងទុកគោរពនមស្ការនោះ សុទ្ធតែមានមុខ ៤ សម្លឹងចុះក្រោម ដើម្បីសំគាល់ថា លោកតែងប្រមើលសុខទុក្ខមនុស្សលោក ទាំងនាមរបស់អវលោកិតេស្វរៈ គេតែងហៅថា សមន្តមុខៈ ប្រែថា "មានមុខជុំវិញ" ។

នៅប្រទេសកម្ពុជាយើង រូបភាពចេតិយមានច្រើនបែបណាស់ ឥតដូចគ្នាទេ ប្លែកទៅតាមស្នាដៃរបស់ពួកសិល្បករដែលអាចធ្វើបាន ដើម្បីបញ្ចុះអដ្ឋិធាតុរបស់អ្នកមានគុណ ឲ្យសមគួរដល់កិត្តិយសរបស់គេអ្នកមានភោគសម្បត្តិ ឬឲ្យសមរម្យដល់តម្លៃគុណនៃលោកអ្នកមានគុណ មានមាតាបិតាជាដើម ។ រូបរាងទ្រង់ទ្រាយទំហំកំពស់ចេតិយទាំងអស់បើទុកជាច្រើនបែប ដោយជំនាញសិល្បករយ៉ាងណាក៏ដោយ គង់រួមចូលក្នុងប្រភេទចេតិយ ៤ យ៉ាងប៉ុណ្ណោះ ។

## អំពីចេតិយ ៤ ប្រភេទ

១. ធាតុចេត្តិយ ចេតិយសម្រាប់បញ្ចុះព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ, ឬសារីរិកធាតុនៃព្រះបច្ចេកពុទ្ធ, ព្រះអរហន្តទីងស្តេចចក្រពត្រ; ប៉ុន្តែបើពោលតាមសម័យនិយម សូម្បីចេតិយដែលបញ្ចុះអដ្ឋិ-ធាតុសាមញ្ញជន ក៏គេហៅថា ធាតុចេតិយ បានដែរ ។

២. ធម្មចេតិយ ចេតិយសម្រាប់តំកល់ព្រះធម្មក្ខន្ធ (ព្រះត្រៃបិដក) ឬហៅ ធម្មមន្ទីរ សម្រាប់ទុកគម្ពីរដិកាក៏បាន ។

៣. បរិភោគចេតិយ ចេតិយសម្រាប់បញ្ចុះគ្រឿងបរិក្ខាររបស់ព្រះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

សម្មាសម្ពុទ្ធ មានវត្ថុតទួបផ្ដះ ទីផងម្ហូបក្រកជាដើម ។

៤. ឧទ្ទេសិកចេតិយ ចេតិយដែលគេសាងចំពោះព្រះសម្មាសម្ពុទ្ធ ដើម្បីនមស្ការគោរពបូជាសូម្បីព្រះពុទ្ធរូបក៏រាប់ជាឧទ្ទេសិកចេតិយដែរ ។

បើតាមមហាបរិនិព្វានសូត្រ ក្នុងកាលដែលព្រះសម្ពុទ្ធទ្រង់ព្រះអាពាធ ទ្រង់សំដែងចំពោះពួកភិក្ខុមានព្រះអានន្ទជាប្រធានថា « ចត្តារោ មេ ភិក្ខវេ ថូបារហបុគ្គលា សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ អរហា ចក្កវត្តិ រាជា ប្រែថា ម្នាលភិក្ខុទាំងឡាយបុគ្គល ៤ ពួកនេះគឺ ព្រះសម្មាសម្ពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះអរហន្ត ១ ស្ដេចចក្រពត្រ ១ គួរដល់ការបញ្ចុះកន្ទុកក្នុងស្តូប» ។

បុគ្គល ៤ ពួក ខាងលើនេះ ជាបុគ្គលជាន់ខ្ពស់បំផុត ជាទីគោរពសក្ការបូជារបស់ពុទ្ធបរិស័ទ, រាជបរិស័ទដោយពិត ។ យើងជាពុទ្ធបរិស័ទសម័យជាន់ក្រោយ មិនអាចនឹងស្វែងរកព្រះអដ្ឋិធាតុបុគ្គល ជាន់ខ្ពស់នោះមកបញ្ចុះកន្ទុកចេតិយ បានដោយងាយឡើយ មានតែព្រះអដ្ឋិធាតុនៃព្រះមហាក្សត្រិយ៍, អដ្ឋិធាតុមាតាបិតា, គ្រូអាចារ្យនឹងវដ្ឋបរសប៉ុណ្ណោះទុកជាទីគោរពបូជា របស់យើងដែរហើយ ។

ចេតិយ បើតាមប្រវត្តិការណ៍ក្នុងគម្ពីរព្រះពុទ្ធសាសនាថាជាវត្ថុស័ក្តិសិទ្ធិមួយ ដែលគេសាងទុកជាទីគោរពបូជា មានមកតាំងពីព្រេងព្រឹទ្ធមុនសម័យពុទ្ធកាល ដែលមានឈ្មោះថា បាវាឡចេតិយ សារន្ទទចេតិយ ជាដើម ។

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អំពីប្រាង្គ - ប្រាសាទ

ពាក្យថា "ប្រាង្គ" ជាពាក្យសំស្ក្រឹត រាប់ថាជាគារវត្ថុដែលមានទ្រង់ទ្រាយដូចប្រាសាទដែរ ប៉ុន្តែមានទំហំ កំពស់ តូចតាមជាងប្រាសាទ ហើយច្រើនតែមានរាង ៤ ជ្រុងខ្ពស់ប្រឡោ មានកំពូលខ្ពស់ គេកសាងលើទីលានខ្ពស់មួយថ្នាក់ឬពីរបីថ្នាក់ ។ ពាក្យថា "ប្រាង្គ" ប្រែថា "សេនាសនៈ មានតួរាងប្រាកដស្មើដោយប្រាសាទ "ឬថា" មានគម្រោងដូចប្រាសាទ "ប្រាង្គនេះគេតែងធ្វើដោយឥដ្ឋ ឬថ្ម" មានក្បាច់របនា, សម្រាប់បញ្ចុះ សម្រាប់ដំកល់អដ្ឋិធាតុដូចចេតិយដែរ ។

ពាក្យថា "ប្រាសាទ" ជាពាក្យសំស្ក្រឹតដែរ បាលីថា "បាសាទ" ប្រែថា "គ្រឹះស្ថានជាទីញុំាងចិត្តឲ្យជ្រះថ្លា, គ្រឹះស្ថានគួរឲ្យសប្បាយ" ។ ប្រាសាទ គឺផ្ទះដែលធំទូលាយខ្ពស់មានកំពូលក្ដី ឥតកំពូលក្ដី មានរចនាក្បាច់ក្បូរក្ដី មិនមានក្ដី ដែលល្អប្លែកអស្ចារ្យ គួរឲ្យកោតសរសើរ ដូចយ៉ាងប្រាសាទអង្គរធំ, ប្រាសាទបាយ័ន, ប្រាសាទអង្គរតូចជាដើម ។ ប្រទេសកម្ពុជាយើងមានប្រាសាទអង្គរ ជាគ្រឿងបង្ហាញនូវសិល្បៈរបស់វិស្វករខ្មែរសម័យបុរាណដល់ជនបរទេស ។ ប្រាសាទអង្គរទុកជាគោលចារឹកនៃប្រទេសកម្ពុជា ឬជា មុទ្រាមួយដ៏ធំបំផុតរបស់ជាតិខ្មែរ រាប់ថាជាផលនៃសិល្បៈរបស់បុព្វបុរសខ្មែរ ។ ប្រជាជនច្រើនប្រទេសដែលបានមកមើលប្រាសាទអង្គរ ច្រើនតែលាន់មាត់ស្ញើចសរសើរសិល្បៈរបស់បុព្វបុរសយើង ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



តាមអ្នកប្រាជ្ញបរទេសខាងបុរាណវត្ថុ ដែលបានស្គាល់ប្រវត្តិការណ៍អង្គរ ឃើញថា វិស្វករអ្នកកសាងប្រាសាទអង្គរ ជាមនុស្សបច្ចេកទេសដោយសិល្បៈយ៉ាងឯកក្នុងលោក ៗ ប្រាសាទអង្គរទុកជានិមិត្តរូបមួយដ៏អស្ចារ្យដែលជាស្នាដៃរបស់សិល្បករនៃជាតិខ្មែរសម័យបុរាណ ពុំមែនជនបរទេស ឬ ទេវបុត្តណាមួយ មកសាងប្រាសាទអង្គរទេ ៗ

## អំពី វិហារ-សាលា-គំនូរ

វិហារ ប្រែថា «លំនៅ, ទីជ្រកកោន, ទីនៅអាស្រ័យ» ៗ ពាក្យថា «វិហារ» នេះបានដល់សេនាសនៈគ្រប់យ៉ាងតាំងកុដិ សាលាធំតូច ឬ ទីវត្តតាំងមូលរបស់បព្វជិតពុទ្ធសាសនិក ប៉ុន្តែខ្មែរយើងច្រើនហៅតាមទម្លាប់ចំពោះតែ ឧបោសថាគារ (រោងឧបោសថ) ដែលមានព័ទ្ធសីមាថាជាវិហារ ៗ បែបភាពទ្រង់ទ្រាយនិងការរចនារបស់វិហារនៅប្រទេសយើង ហាក់ដូចជាចេញមកអំពីសិល្បៈរបស់ជាងតែម្នាក់ ដោយហេតុឃើញវិហារគ្រប់ស្រុកខេត្តស្រដៀងគ្នា គឺមានពង, មានរបៀង, មាននាគ, មានជហ្វាដង្កា, មានហោជាង មានក្បាច់រចនា ប្រហែលៗគ្នា ៗ វិហារដែលកសាងក្នុងសម័យមុនច្រើនតែធ្វើដោយឈើ ឥឡូវនេះច្រើនតែកសាងដោយគ្រឿងបេតុងអារម៉េឬដោយឥដ្ឋ ៗ ព្រះពុទ្ធរូបស្តូប ចេតិយជាដើមនេះ រាប់ថាជាគោលចារឹកនៃព្រះពុទ្ធសាសនា; ជាវត្ថុស្ថាពរនៃប្រទេសកជាមុតទៅ ៗ

សាលា ច្រើនសំដៅយកសេនាសនៈសម្រាប់ប្រើប្រាស់តាមកាល

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

វេលា មិនមែនជាកន្លែងសម្រាប់ដេកនៅប្រក្រតីទេ ដូចឧបដ្ឋានសាលា
កុដិវត្តសម្រាប់ពុទ្ធបរិស័ទប្រើប្រាស់តាមកាលម្តងៗ, សិក្ខាសាលាសម្រាប់
តែចូលរៀនប៉ុណ្ណោះជាដើម ពុំមែនសម្រាប់ដេកនៅឡើយ ។ ឧបដ្ឋាន-
សាលាគ្រប់វត្ត ក៏មានបែបភាពប្រហែល ៗ គ្នាដែរ ។

គំនូររូបព្រះសម្មាសម្ពុទ្ធតាមរឿងបឋមសម្ពោធិ ឬ ទសជាតក៍ក្នុងប្រទេស
យើងដែលជាងគំនូរបានគូរនៅលើក្រដាស, លើផ្ទាំងសំពត់ឬគូរនៅជញ្ជាំង
វិហារ សុទ្ធតែកប់ថាជាសិល្បៈដែលទាក់ទងលើព្រះពុទ្ធសាសនាទាំងអស់ ។

សិល្បៈគ្រប់យ៉ាងរបស់ជនជាតិខ្មែរ ដែលកើតមានឡើងច្រើនតែយក
បែបតាមគម្ពីរព្រះពុទ្ធសាសនា ដោយបានសិក្សារៀនសូត្រ បានដឹងរឿង
ដឹងប្រវត្តិការណ៍ក្នុងផ្លូវព្រះពុទ្ធសាសនា ហើយអាចប្រដិដ្ឋយករឿងនោះៗ
មកគូរជារូបភាព ឲ្យឃើញប្រាកដឡើង ដោយយកព្រះពុទ្ធសាសនា ជា
ទ្រឹស្តីសូម្បីព្រះឥន្ទ្រ, ព្រះព្រហ្ម, ទេវតា, នរក, ប្រេត, យក្ស ដែលមិនបាប់
បានឃើញសោះ ក៏អាចគូរកើត ទោះបីគំនូររូបនោះៗ ដូចមែនក្តី មិន
ដូចក្តី ឲ្យតែគួរសន្និដ្ឋានយកបានក៏ចេះតែគូរតៗ តាមគ្នាមក ទុកជាអ្នក
សិល្បៈណាមួយ ក៏មិនអាចចាប់កំហុសគំនូរទាំងនោះបាន ដោយហេតុ
គ្មានរូបព្រះឥន្ទ្រ ព្រះព្រហ្ម មានជីវិតរស់មែនយកមកផ្ទៀងកើតឡើយ ។

ព្រះពុទ្ធរូប ស្តូបចេតិយ ប្រាង្គ ប្រាសាទ វិហារ សាលា គំនូរដែល
មានមកហើយនោះឈ្មោះថាជា រូបភាពនៃសិល្បៈ ឬជាលទ្ធផលរបស់
សិល្បៈនៃបុព្វបុរសខ្មែរអ្នកគោរពព្រះពុទ្ធសាសនា ឬជាការកសាងវត្ថុទាំង

AngkorLink.com CambodiaBuddhist.org ABCCambodia.com



អស់មានព្រះពុទ្ធរូប ស្តូប ចេតិយ ជាដើមនេះ ទុកជាទត្តុមតតិនៃពុទ្ធបរិស័ទក្នុងសម័យបុរាណ ដើម្បីឲ្យយើងជាន់ក្រោយឃើញសិល្បៈនៃបុព្វបុរស ហើយយើងក៏អាចចម្លងយកបែបសិល្បៈនោះៗ តមកទៀត ។

## ប្រយោជន៍នៃពុទ្ធសាសនា

ខេមរជនក្នុងប្រទេសកម្ពុជា បានទទួលផល អំពីព្រះពុទ្ធសាសនា ជាច្រើនយ៉ាង ដូចសេចក្តីដែលត្រូវសំដែងតទៅនេះ

១– ព្រះពុទ្ធសាសនា ទុកដូចជាគ្រឹះស្ថាន ឬមហាមន្ទីរជាទីកើតនៃសិល្បៈ, អក្សរវិជ្ជា, វិទ្យាសាស្ត្រ នឹងសីលធម៌ គឺប្រពៃណីដ៏ល្អ ។ ព្រះពុទ្ធសាសនាមានអត្ថបទល្អៗ ច្រើនណាស់សម្រាប់ប្រតិបត្តិដើម្បីរលត់ទុក្ខ នាំមកនូវសេចក្តីសុខ, ជាសាសនាបំភ្លឺប្រយោជន៍ តាំងអំពីបច្ចុប្បន្នដល់បរលោក ជាសាសនាឲ្យសិទ្ធិបរិបូណ៌ដល់សត្វលោកគឺមនុស្សនឹងតិរច្ឆាន, ព្រះពុទ្ធសាសនាទុកដូចជាដួងប្រទីបមួយដ៏ធំក្នុងលោក សម្រាប់គ្រោលបំភ្លឺឲ្យមនុស្សលោកឃើញសិល្បៈ, ឃើញផ្លូវប្រតិបត្តិ, ដើរកាត់តម្រង់ទៅរកសន្តិសុខចំរើនទាំងបច្ចុប្បន្ននឹងបរលោក ជាសាសនាលូកពារកឃើញមគ្គផលនិព្វានបាន ។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ជាច្រើនយ៉ាង ដូចយ៉ាងសេចក្តីចំរើន ឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធសាសនាជាដំបូង សូម្បីវេជ្ជសាស្ត្រ នឹងវិទ្យាសាស្ត្រ ដែលរាប់ថាជាវិជ្ជាសម័យថ្មី ក៏កើតមកអំពីអ្នកប្រាជ្ញដែលចម្លងផ្តិតយករបៀបអំពីព្រះពុទ្ធសាសនាខ្លះមិនខាន បើមិនច្រើនក៏តិចៗ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គ្រប់ប្រទេសទាំងអស់ ច្រើនតែទទួលដឹងថា សេចក្តីចំរើនក្នុងសិល្បៈវិទ្យាបានទទួលកំណើតអំពីសាសនា ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា "ព្រះពុទ្ធសាសនាជាសាសនានាំសេចក្តីចំរើនមកប្រគល់ឲ្យប្រទេសជប៉ុន, ព្រះពុទ្ធសាសនាបានបើកទ្វារប្រទេសជប៉ុនដោយទ្រឹស្តីមុនដំបូងបង្អស់ ឲ្យប្រទេសជប៉ុនឈមមុខទៅរកសេចក្តីចំរើន ព្រោះហេតុនោះ យើងជាជាតិជប៉ុននៅចុងបូព៌ាប្រទេស គួរណាស់តែសើរើ សិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរព មិនត្រូវធ្វេសប្រហែស" ។

២– ព្រះពុទ្ធសាសនា ជាអណ្តូងសម្រាប់កើតនៃការសិក្សា ទោះបីការសិក្សានោះពុំបានធំទូលាយ ដោយមិនទាន់បានអនុវត្ត ក៏អាចចិញ្ចឹមសិល្បៈក្នុងផ្លូវវប្បធម៌របស់ជាតិខ្មែរ ឲ្យមានជីវិតជាប់ពូជជារមិនដាច់ ។ ប្រទេសកម្ពុជារបស់យើង ដែលមានការចេះដឹងក្នុងលទ្ធិសាសនាក្តី ក្នុងសិល្បៈណាមួយក្តី ផ្លូវអក្សរសាស្ត្រក្តី សុទ្ធតែកើតអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជាដំបូង សូម្បីវិជ្ជាពេទ្យ ក៏ច្រើនតែកើតមកអំពីបព្វជិតពុទ្ធសាសនិក ទោះបីមានវិន័យ ហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជម្ងឺក៏ហាមបានដោយក្រណាស់ ដោយហេតុបព្វជិតមើលជម្ងឺឲ្យទេ មិនបាច់យកថ្លៃ ។

៣– វត្តអារាម ជាកន្លែងប្រជុំប្រជាជន ដើម្បីសន្ទនាពីធម៌អាថ៌ឬពីព្រឹត្តិការណ៍នានាតាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះៗ ។ វត្តអារាម

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទុកជារោងរៀនហត្ថកម្មមួយ ក្នុងផ្លូវសិល្បៈ មានរៀនការជាងឈើការត សាងវិហារ សាលាជាដើមៗ ពូជជាតិនៃសេចក្ដីចំរើនរបស់យើង ដែលមានឈ្មោះជាប់មក ជាប្រទេសមានអក្សរសាស្ត្រ, មានបុរាណវត្ថុជាគ្រឿងបង្ហាញសិល្បៈឲ្យឃើញជាកេរ្តិ៍ដំណែល, មានប្រជាជាតិជាម្ចាស់ប្រទេស, មានមហាក្សត្រសោយរាជ្យ ក៏ដោយអំណាចគុណភាពនៃព្រះពុទ្ធសាសនាជួយទ្រទ្រង់ ឬថាព្រះពុទ្ធសាសនា ជាឃ្លាំងទុកដាក់នូវសិល្បៈព្រមទាំងអក្សរសាស្ត្ររបស់ជាតិ ឲ្យមានជីវិតរស់នៅរហូតមក, រួមសេចក្ដីថា "ព្រះពុទ្ធសាសនានាំមកនូវប្រយោជន៍យ៉ាងធំ ឲ្យប្រទេសកម្ពុជាយើង" ។

៤ - ប្រទេសកម្ពុជាយើង ក៏យើងអាចបានឃើញជាក់ច្បាស់ហើយ គឺថា កាលដែលប្រទេសយើងមិនទាន់មានសាលារៀនអក្សរសាស្ត្រក្នុង ក្នុងផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯង ជាសាលារៀន, កាលដែលផ្លូវការមិនទាន់មានមន្ទីរពេទ្យព្យាបាលគេនៅឡើយ មានតែវត្តអារាមជាមន្ទីរពេទ្យសម្រាប់មើលជម្ងឺនៃប្រជាជន, មិនត្រឹមតែមើលជម្ងឺកាយប៉ុណ្ណោះទេ, អាចពិនិត្យមើលជម្ងឺចិត្តផងទៀត ព្រោះថាការកើតទុក្ខព្រួយបារម្ភក្នុងផ្លូវចិត្តនេះ ចាត់ជារោគមួយយ៉ាងធំណាស់ វត្តអារាមនៃព្រះពុទ្ធសាសនា ឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ - ចិត្ត ដែលមានទុក្ខឲ្យធូរស្រាលក៏មាន ឲ្យជាសះស្បើយទៅក៏មាន ។

៥ — ក្រុងភ្នំពេញជារាជធានីនៃប្រទេសកម្ពុជាយើងមានវត្តអារាមធំៗ គឺវត្តឧណ្ណាលោម, វត្តលង្កា, វត្តសារាវ័ន, វត្តបទុមវតី ជាដើម ជាវត្ត

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទទួលបន្ទុកនៃពួកភិក្ខុ-សាមណេរ និងកុមារតូចធំបានច្រើនណាស់ ។ វត្តនីមួយៗ មានភិក្ខុសាមណេរ និងកុមារ ដែលស្វះពន្វះចេញអំពីស្រុក-ខែត្រផ្សេងៗ មកនៅបញ្ចុះជ្រំជាមួយគ្នា ដើម្បីសិក្សារៀនសូត្រ យកបំណេះវិជ្ជា ព្រោះថា ក្រុងភ្នំពេញជាទីប្រជុំធំសម្បូណ៌ដោយការសិក្សាជាងទីឯទៀត ។ ពួកភិក្ខុដែលមកនៅក្នុងវត្តទាំងនោះ បានយូរឆ្នាំ ទាំងមានសមត្ថភាពគ្រាន់បើ ហើយបានធ្វើជាមេកុដិ អាចទទួលបញ្ចឹមភិក្ខុ-សាមណេរនិងកុមារឲ្យនៅរៀនសូត្រផង ទាល់តែសម្រេចការសិក្សា ។ ពួកកុមារដែលមកនៅអាស្រ័យជ្រកកោន ក្នុងវត្តជាមួយនឹងព្រះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចំការ ដែលក្រទ័លទ្រព្យសម្បត្តិ, គួរឲ្យអាណោជអធម្ម អាណិតអាសូរពួកកុមារកំសត់ទាំងនេះពន់ពេក បើកុំតែមានវត្តព្រះពុទ្ធសាសនា ប្រហែលជា មិនបានទទួលស្មើការសិក្សា ដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្ដីថា «កូនអ្នកក្រីក្រធនធានរស់នៅដោយសារបាយវត្ត» ខំទ្រាំទ្រនៅបំពេញការសិក្សាទាំងរហេមរហាម ទាល់តែសម្រេចផលនៃការសិក្សាបានឡើងឋានៈទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់តាមសមគួរដល់សមត្ថភាពរបស់ខ្លួន, ចំណែកខាងឯកូនអស់លោកឥស្សរជន ឬកូនគហបតី មិនត្រូវការមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្ដីសង្គ្រោះ អំពីបព្វជិតពុទ្ធ-សាសនិកក្នុងឆ្នាំនីមួយ ៗ បានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំៗ មានកុមារចំនួន ៣០០ ឬ ៤០០ នាក់ ។ ចំនួនពួកកុមារទាំងប៉ុណ្ណោះ បើជា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ពលរដ្ឋកិបាលទទួលយកទៅចិញ្ចឹមវិញ  អស់ប្រាក់បវិកាជាតិ  មិនមែនតិចទេ ។ កុមារទាំងនេះ ឈ្មោះថា រស់នៅដោយអាស្រ័យទីងម្លប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមម្លប់ទង់ព្រះពុទ្ធសាសនា ខំប្រឹងប្រែងសិក្សាទាល់តែបានទទួលលទ្ធផល  នៃការសិក្សារបស់ខ្លួន ។ ករណីនេះឃើញថា ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាយើង មានប្រយោជន៍ដ៏ធំទូលាយ  អាចជួយសង្គ្រោះទំនុកបំរុងដល់ប្រទេសជាតិបាន គឺថា វត្តនៃព្រះពុទ្ធសាសនា  ទុកដូចជាកន្លែងឧបត្ថម្ភអាហារូបករណ៍មួយដ៏ប្រសើរដល់អ្នកក្រីក្រ, អាចចិញ្ចឹមមនុស្សក្រទ័ល ដែលមិនមានលំនៅជ្រកកោននិងអាហារបរិភោគ ។ វត្តរបស់ព្រះពុទ្ធសាសនា ឈ្មោះថាបានជួយសម្រាលភារៈនៃពលរដ្ឋកិបាល ឲ្យធូរស្រាលបានច្រើនណាស់ ។

៦– បព្វជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុកមានលោកចៅអធិការគ្រូសូត្រជាដើម ដែលភ្ញាក់ខ្លួនក្នុងការសិក្សាធម្មវិន័យហើយ បានចុះស្នាមក្នុងផ្លូវសិក្សាតាមសម័យនិយម ។ ការសិក្សាច្បាប់ព្រះពុទ្ធសាសនា របស់បព្វជិតពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមានប្រាជ្ញាស្មារតីបរិបូណ៌ នាំឲ្យភ្លឺក្នុងផ្លូវធម៌ផង ផ្លូវលោកផង គឺថា ការសិក្សានោះជួយឲ្យបព្វជិតនោះមានឧត្តមគតិនិងសមត្ថភាព ទាំងពួកឧបាសកជើងវត្តក៏អាចដឹកនាំចិត្ត ឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បំរើព្រះពុទ្ធសាសនាផង បំរើប្រទេសជាតិផង ។ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រ ដែលកើតមានព្រោងព្រាតក្នុងស្រុក-ខេត្តផ្សេង ៗ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មានខែត្រកណ្ដាល តាកែវ-ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនា ជាដើមអាទិ៍ គឺថា សាលាសិក្សាទាំងនោះកើតឡើងបានដោយសារស្នាដៃរបស់ព្រះសង្ឃមានចៅអធិការ ឬ គ្រូសូត្រជាដើមណែនាំពួកគ្រហស្ថដើរវត្តឲ្យកសាងដោយឥតមើលបំណាំរាជរដ្ឋាភិបាលឡើយ លុះកសាងហើយជូនប្រគល់សាលាសិក្សានោះដល់រាជរដ្ឋាភិបាល ដើម្បីឲ្យរាជការចាត់ចែងរកគ្រូបង្រៀនតាមផ្លូវការតទៅ ដែលអាចគាំពាររាជរដ្ឋាភិបាល ជួយកម្លាំងហិរញ្ញវត្ថុដល់រាជរដ្ឋាភិបាលឲ្យចំណេញថវិកាជាតិបានច្រើនណាស់ ។

ដំណើរនេះសឲ្យឃើញថា « ព្រះពុទ្ធសាសនា កាលបើបុគ្គលណាបានអប់រំសិក្សាល្អហើយ អាចនាំឲ្យធ្លុះបំភ្លឺឃើញសារប្រយោជន៍ ក្នុងផ្លូវធម៌បានផង ផ្លូវលោកបានផង » ។ ព្រះពុទ្ធសាសនាឈ្មោះថាជាសាសនាជួយពលរដ្ឋប្រទេសកម្ពុជា ឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្ដីល្អអាចជួយសាងវប្បធម៌និងសាមគ្គីធម៌របស់ជាតិ ឲ្យកើតមានឡើង ។

៧– អក្សរសាស្ត្រខ្មែរ សម្រាប់ប្រទេសយើង បើកុំតែមានវត្តអារាមនៃពុទ្ធសាសនិក ប្រហែលជាសាបសូន្យអស់ទៅហើយ ព្រោះហេតុនោះ វត្តអារាមឈ្មោះថាជាកន្លែងសម្រាប់រក្សាទុកនូវសិល្បសាស្ត្រចិញ្ចឹមអក្សរសាស្ត្ររបស់ជាតិទុកឲ្យរស់នៅ ។ អក្សរសាស្ត្រនេះទុកជាពន្លឺរស្មីរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រហើយ ជាតិក៏អាប់ឱន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សាបសូន្យទៅជាលំដាប់ ដោយហេតុនេះពុទ្ធសាសនានៅប្រទេសយើង ឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវអក្សរសាស្ត្រជាតិ ។

បព្វជិតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈ គឺរៀនគម្ពីរបាលីព្រះត្រៃបិដក ចេះចាំយល់ស័ព្ទភាសាបាលី អាចប្រែពីបាលីមកជាភាសាខ្មែរបានដោយងាយ បានបោះពុម្ពផ្សាយចេញជាសៀវភៅធំ-តូចគរគោក សូមអញ្ជើញមើលក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបណ្ណាគារឯទៀតៗ នឹងឃើញសៀវភៅខ្មែរជោរជាសកប់មិនឈ្មុះ ។ សៀវភៅអក្សរខ្មែរផ្សាយផ្នែកពុទ្ធសាសនា ចេញព្រោងព្រាតទាំងនេះ ច្រើនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា ៗ ប្រទេសកម្ពុជាដែលមានវឌ្ឍនធម៌ ខាងផ្លូវសិល្បសាស្ត្រ, អក្សរសាស្ត្រ កំពុងរើបៗទៅរកផ្លូវចំរើនរុងរឿងមកនេះ ដោយកម្លាំងស្នៃព្រះពុទ្ធសាសនាជាប្រាកដ ।।

ព្រះឧបាលិវង្ស ស្បូរ - ហាយ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រះស្តូបធម្មេយ នៅក្រុងសារនាថ ប្រទេសឥណ្ឌា ត្រង់ទីព្រះសម្ពុទ្ធទ្រង់សំដែងព្រះធម្មចក្រ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

# វគ្គទី ៤

## វប្បធម៌ពុទ្ធសាសនា

អ្វីជាវប្បធម៌ ? អ្វីជាពុទ្ធសាសនា ?

— សភាពសព្វយ៉ាងដែលតាំងឡើងក្នុងភូមិប្រទេស ដោយអំពើផ្សេងៗ មានការគាស់ពនក្ខកេស់ សាបព្រោះបណ្ដុះដាំផ្សាំបំពេញជាដើម ឬក្នុងកាយប្រទេស ដោយការសិក្សាអប់រំបណ្ដុះនិស្ស័យសន្តាន, នេះជាវប្បធម៌ ។

— ធម៌វិន័យដែលព្រះពុទ្ធទ្រង់សំដែង ទ្រង់បញ្ញត្តទុកប្រោសសត្វ-លោកហៅថា ពុទ្ធសាសនា ។ ពុទ្ធសាសនាជាវប្បធម៌កើតអំពីព្រះពុទ្ធ ។ ព្រះពុទ្ធ កាលដែលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់ទេសនាប្រោសសត្វទូទៅ ហៅថា ទ្រង់បានសាបព្រោះបណ្ដុះដាំផ្សាំវប្បធម៌ព្រះពុទ្ធក្នុងពិភពលោក ។

## វប្បធម៌ឥណ្ឌៀសម័យបុរាណ
## និងសម័យពុទ្ធកាល

ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះសម្ភពនឹងទ្រង់ត្រាស់ដឹងនៅប្រទេសឥណ្ឌៀភាគខាងជើងដែលក្នុងសម័យនោះគេទុកជាមជ្ឈិមប្រទេស ។ សម័យនោះឥណ្ឌៀភាគខាងជើងមានអារ្យធម៌ខ្ពស់ជាងភាគខាងត្បូង ដោយមានវប្បធម៌ខាងបច្ចេកទេសនឹងខាងរដ្ឋប្បសាសនោបាយ ព្រមទាំងខន្តី

AngkorLink.com CambodiaBuddhist.org ABCCambodia.com



និងវីរិយៈសំខាន់ជាង ។ ឥណ្ឌាភាគខាងជើងមានឥទ្ធិពលក្លាខ្លាំងអាចទម្លាក់ឋានៈឥណ្ឌាភាគខាងត្បូងឲ្យថោកទាបដូចឋាននរក សូម្បីតែក្នុងឥណ្ឌាភាគខាងជើងជាមួយគ្នាក៏បែងឋានៈប្រជាជនជា ៤ ត្រកូល គឺត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលវៃស្យៈ (ឈ្មួញ) ត្រកូលសូទ្រៈ (អ្នកងារ) ។ បណ្តាត្រកូលទាំង ៤ នេះ ត្រកូលក្សត្រនឹងត្រកូលព្រាហ្មណ៍ជាត្រកូលឧត្តមដោយមានវប្បធម៌ជាន់ខ្ពស់ ត្រកូលវៃស្យៈជាត្រកូលបន្ទាប់បន្សំ ដោយមានវប្បធម៌ថ្នាក់កណ្តាល, ត្រកូលសូទ្រៈជាត្រកូលទាបជាងគេបង្អស់ដោយមានវប្បធម៌ថោកទាបបំផុត; កាលបើមានវប្បធម៌ផ្សេងគ្នាតាមឋានៈត្រកូលដូច្នេះ អារ្យធម៌សេចក្តីចម្រើនរុងរឿងដោយអាកប្ប-កិរិយាទាំងឡាយ មានសម្លៀកបំពាក់នឹងសីលធម៌ ចរិយាជាដើមក៏ផ្សេងគ្នាទៅតាមនោះ ។ ដល់ព្រះពុទ្ធជាម្ចាស់បានត្រាស់មកទ្រង់ផ្សាយអនុត្តរ-ធម៌ ទ្រង់ទម្លាយឋានៈចំពោះជនដែលមកពីត្រកូលទាំង ៤ នោះ ទោះបីត្រកូលណាក៏ដោយឲ្យតែចូលបួសក្នុងធម្មវិន័យរបស់ព្រះអង្គ ទ្រង់ទុកដាក់ឋានៈជាស្មើគ្នាទាំងអស់ឲ្យគោរពដល់គ្នានឹងគ្នាតែតាមវស្សាចាស់ខ្ចី និងការចេះដឹងតិចច្រើនប៉ុណ្ណោះហើយនឹងទ្រង់អប់រំនិស្ស័យពុទ្ធបរិស័ទ ដោយនាយកធម៌នានា មាន ទាន សីល ភាវនា ឬសីល សមាធិ បញ្ញាជាដើមរហូតដល់មគ្គផលនិព្វានជាទីបំផុត ។ ដូច្នេះឈ្មោះថា ព្រះពុទ្ធជាម្ចាស់ទ្រង់បានសាបព្រោះបណ្តុះដាំផ្សាំពូជវប្បធម៌ពុទ្ធសាសនា ទុកក្នុងប្រទេសឥណ្ឌា ជាមជ្ឈិមប្រទេសដែលជាជាតិភូមិរបស់ព្រះអង្គ ក្នុងសម័យពុទ្ធ-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កាល ៗ លុះព្រះអង្គបរិនិព្វានទៅ ទើបវប្បធម៌នោះសាយភាយចេញទៅកាន់ប្រទេសនានាជាបច្ចន្តប្រទេស ដរាបដល់ទូទៅទាំងពិភពលោកដូចឃើញប្រាកដក្នុងសម័យបច្ចុប្បន្ននេះ ៗ

## វប្បធម៌ពុទ្ធសាសនាផ្សាយមកកាន់សុវណ្ណភូមិ

បច្ចន្តប្រទេសទាំងពួងក្នុងទ្វីបសុវណ្ណភូមិ បានទទួលយកវប្ប-ធម៌ពុទ្ធសាសនាមកសាបព្រោះបណ្ដោះដាំនៅសម័យក្រោយពុទ្ធកាលគឺក្នុង-សតវត្សទី ៣ នៃពុទ្ធសករាជ នារជ្ជកាលអសោកមហារាជ ដោយព្រះមោគ្គលីបុត្តតិស្សត្ថេរជាសង្ឃប្រមុខបានចាត់ព្រះថេរៈ ២ រូបគឺព្រះសោណ-កត្ថេរ ១ ឧត្តរត្ថេរ ១ ឲ្យជាសមណទូតនាំវប្បធម៌ពុទ្ធសាសនាមកផ្សាយដល់សុវណ្ណភូមិដែលតាមប្រភពខ្លះថាតាំងនៅក្នុងអាណាចក្រភូមា ដែលមានអរហន្តសីមានិងសិលាចារឹកជាភស្តុតាងនៅរហូតដល់សម័យបច្ចុប្បន្ន-នេះ ៗ

ឯប្រទេសកម្ពុជាយើង បើតាមសិលាចារឹកក្នុងចេតិយផ្លូននានានៅសតវត្សទី ៨ នៃ ព.ស. សម័យនគរភ្នំ (ហ្វូណន់) ប្រាកដថាមានពុទ្ធសាសនាមកចាក់ឫសលូតលាស់ពាសពេញអាណាខេត្រទៅហើយ ៗ កាលបើដូច្នេះ អាចសន្និដ្ឋានថា ប្រទេសកម្ពុជាបានទទួលវប្បធម៌ពុទ្ធសាសនាតាំងពីមុនសម័យនោះទៅទៀត គឺថាប្រហែលតាំងពីសតវត្សទី ៣ ឬ ទី ៤ នៃព.ស. ដំណាល ឬ បន្ទាប់គ្នានឹងប្រទេសភូមានោះដែរ ព្រោះទំរាំនឹងកើតបានជាសិលាចារឹកបែបនេះ ក៏អាស្រ័យមានជនានុជន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជឿគោរពកាន់មកមុនយូរក្រែលដែរហើយ តាំងសម័យនោះ នៅឧបទ្វីបសុវណ្ណភូមិយើង មានប្រជាជាតិតែ ៣ ផង គឺភាគខាងលិចប្រជាជាតិមន, ភាគខាងកើតប្រជាជាតិចាម, ភាគកណ្តាលប្រជាជាតិខ្មែរ ។ ដូច្នេះឃើញថាប្រជាជាតិទាំង ៣ អាចផ្សាយ ឬ អាចចម្លងវប្បធម៌ទៅវិញទៅមកបានដោយងាយ, ហើយបើនឹកដល់រឿងមួយទៀតថាជាតិខ្មែរនឹងជាតិមនមានអម្បូរភាសាជាមួយគ្នា ដែលហៅថាភាសាមន-ខ្មែរ ប្រាកដមកដល់សព្វថ្ងៃនេះ ក៏នៅតែឃើញថាសមណាស់ទៅទៀត ។ ព្រោះហេតុការណ៍ទាំងអស់នៅអាចសន្និដ្ឋានថា វប្បធម៌ពុទ្ធសាសនាខាងថេរវាទ ដែលជាគូនឹងអាចរិយវាទ បានមកចាក់ឫសផុះដាលក្នុងប្រទេសយើង តាំងពីមុនសម័យនគរភ្នំ ។ ជាតិខ្មែរដែលធ្លាប់តែកាន់សាសនាព្រាហ្មណ៍មកពីមុនៗក៏បែរត្រឡប់មកគោរពកាន់ពុទ្ធសាសនាតាំងព្រះមហាក្សត្រ តាំងអាណាប្រជារាស្ត្រ កាន់តែច្រើនឡើងច្រើនឡើង ។ លុះចូលមកដល់សម័យចេនឡាគឺពីសតវត្សទី ១១ ទៅទី ១៤ នៃព.ស. ក្នុងវេលានេះវប្បធម៌ពុទ្ធសាសនាខាងអាចរិយវាទ ក៏បានផ្សាយចូលមកដល់ទៀត បានចាក់ឫសលូតលាស់ឡើងជាគូនឹងសាសនាព្រាហ្មណ៍ ដោយមានឥទ្ធិពលផ្សាយចូលកាន់ព្រះពជសំណាក់ក្នុងរជ្ជកាលខ្លះៗផង ដរាបមកដល់សម័យអង្គរ គឺពីសតវត្សទី ១៤ ទៅទី ២០ នៃ. ព. ស. ក្នុងវេលានេះ រជ្ជកាលខ្លះក៏នៅតែមានឥទ្ធិពលយ៉ាងអស្ចារ្យ មានព្រះមហាក្សត្រគោរពគប់អានថ្វាយព្រះអង្គជាពុទ្ធសាសនិក ដូចព្រះបាទជ័យវរ្ម័នទី៧ ដែលមានព្រះកិត្តិនាមល្បី

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ល្បាញ មានព្រះរាជអាណាខេត្រដ៏ធំទូលាយ ក្នុងសតវត្សទី ១៨ នៃ-ព.ស. ។ ក្នុងរជ្ជកាលព្រះអង្គទ្រង់បានសាងចេតិយស្ថានសំខាន់ៗ មានប្រាសាទ តាព្រហ្ម ព្រះខ័ន និងបាយ័នជាដើម ដែលទុកជាវប្បធម៌ខាងការរចនានៃព្រះពុទ្ធសាសនាលទ្ធិអាចារ្យវាទ ទាំងបានសាងមន្ទីរពេទ្យ ស្ពាន ថ្នល់ សាលាសំណាក់ជាសពាសក្នុងព្រះរាជអាណាចក្រ ។ តាមសិលាចារឹកក្នុងបុរាណស្ថានទាំងឡាយ បំភ្លឺឲ្យឃើញថាព្រះអង្គជាបណ្ឌិតឯកមួយ ទាំងខាងសាសនោបាយ ទាំងខាងនយោបាយ ។ ទាំងព្រះនាងជយាទេវី អគ្គមហេសីព្រះអង្គក៏ជាសាស្ត្រាចារ្យខាងព្រះពុទ្ធសាសនា ។

## មូលហេតុព្រះត្រៃបិដកស្លឹករឹត

វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ តាំងពីព្រះពុទ្ធជាម្ចាស់គង់ព្រះជន្មទាន់នៅដរាបមក លោកអ្នកបំរើព្រះពុទ្ធសាសនាទាំងឡាយគ្រាន់តែរៀនសូត្រឲ្យចេះចាំ ហើយបង្ហាត់បង្រៀននិងប្រជុំសង្គាយនាដោតក្រងធម្មវិន័យជាបិដក ៣ (ព្រះត្រៃបិដក) និងផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវ រួចចាំទុកត ៗ គ្នាមកដោយការស្វាធ្យាយលើកពុទ្ធវចនៈឡើងកាន់ចិត្តទាំងអស់ ឥតមានចារឹកដាក់ស្លឹករឹតឬដាក់ផ្ទាំងសិលា ដូចដែលយើងធ្លាប់បានឃើញនៅប្រទេសយើងនិងប្រទេសភូមាជាដើមទេ ។ សូម្បីវប្បធម៌ពុទ្ធសាសនាហូរចូលមកតាក់ឬសក្នុងប្រទេសខ្មែរ លូតលាស់ឋិតនៅដរាបទល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ហើយអត្ថបទព្រះត្រៃបិដកស្លឹករឹតនេះ ក៏មិនប្រាកដថាមាននៅឡើយ ។ ឃើញមានតែអត្ថបទបន្តិចបន្តួចដែលចារឹកនៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ផ្ទាំងថ្មដូចក្នុងសម័យអសោកមហារាជដែរ ។ លុះមកដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ទើបមានរឿងដំណាលថា ព្រះអង្គបានបញ្ជូនព្រះរាជបុត្រឲ្យទៅបួសរៀននៅកោះសេរីលង្កា នៅសតវត្សទី ១៨ នៃព.ស. ហើយវិលមកប្រទេសវិញក្នុងសតវត្សដដែល ។ ក្នុងព្រះដំណើរបំពេញបេសកកម្មនៃព្រះថេរៈជាព្រះរាជបុត្រនេះ គង់មានកុលបុត្រខ្មែរច្រើនរូបតាមហែជាសហការី ហើយគង់មាននាំព្រះត្រៃបិដកសឹករិត នឹងបករណ៍ឯទៀតច្រើនមកកាន់ប្រទេសខ្លួននៅវេលាត្រឡប់វិញ ។

## វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ

វប្បធម៌ខាងអក្សរសាស្ត្រពុទ្ធសាសនា ទុកជាគ្រឿងរចនាពិសេសមួយ តាំងឡើងដោយសារព្រះពុទ្ធនិងព្រះអនុពុទ្ធលោកអ្នកបំរើព្រះពុទ្ធសាសនា ។ ព្រះពុទ្ធជាអម្ចាស់យើងដោយព្រះអង្គទ្រង់បានស្ដេចចេញទៅសាងអភិនិស្ក្រមប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ព្រះវស្សា ហើយបានត្រាស់ដឹងជាព្រះពុទ្ធនៅដែនមគធៈផង និងដោយព្រះអង្គត្រូវសំដែងធម៌ប្រោសវេនេយ្យសត្វក្នុងដែននេះជាមុនផង ទើបទ្រង់យកភាសាអ្នកដែននេះដែលហៅថា មគធភាសា មកប្រើប្រកាសធម្មវិន័យដែលទ្រង់បានត្រាស់ដឹង គឺសំដែងធម៌បញ្ញត្តវិន័យដោយភាសានេះទាំងអស់ ។

ពីដើមមកមគធភាសា សម្រាប់ប្រើការតាមធម្មតាស្រុក មិនទាន់រាប់ថាជាតន្តិភាសា ដូចភាសាសំស្ក្រឹតទេ លុះព្រះពុទ្ធទ្រង់យកមកប្រើក្នុងការផ្សាយព្រះពុទ្ធសាសនា ក៏បានទទួលការរចនាក្លាយទៅជាតន្តិភាសា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



(ភាសាមានរបៀប) ប្រកបដោយលិង្គ វចនៈ វិភត្តិ កាល បទ បច្ច័យជាដើមយ៉ាងបរិបូណ៌ ហើយផ្ទុកដោយច្បាប់ធម្មវិន័យ មានអត្ថរសដ៏ជ្រាលជ្រៅ ៗ មកគឺភាសា មានពាក្យហៅម្យ៉ាងទៀតថា បាលីភាសា ជាភាសាសម្រាប់ប្រកាសធម្មវិន័យពុទ្ធសាសនានេះ ដល់មកក្នុងបឋមសង្គីតិកាល ព្រះសង្គីតិការកៈទាំងឡាយ បានចាត់ការរួបរួមទៅជាព្រះបិដក៣ ដោយយកបាលីដទៃៗ មានបាលីនិទានជាដើមមកបញ្ចូលផ្សំផង ៗ បាលីដើមដែលបានឡើងកាន់សង្គាយនាទាំងនេះ ចាត់ជាបករណ៍មួយឈ្មោះថាមូលប្បករណ៍ (គម្ពីរដើម) ឬហៅថាបាលីដដែលក៏បាន ៗ បករណ៍ជាអត្ថវណ្ណនា (សម្រាប់ពណ៌នាសេចក្តី) នៃបាលីនេះហៅថា អដ្ឋកថា ៗ បករណ៍ជាអត្ថវណ្ណនានៃបករណ៍ទាំងពីរ គឺបាលី និងអដ្ឋកថា ហៅថាដីកា ៗ បករណ៍ក្រៅពីនេះ មានវិសុទ្ធិមគ្គ និងមង្គលត្ថទីបនីជាដើម ហៅថា តព្វិនិមុត្ត ឬបករណវិសេស ៗ

ឯព្រះបករណ៍ទាំងឡាយមានអដ្ឋកថាជាដើម កើតឡើងជាលំដាប់តាំងពីអរហន្តសម័យ ហើយច្រើនតែជាបាលីភាសា ៗ ទោះមានបករណ៍ខ្លះតាំងនៅជាភាសាដទៃ ក៏ពួកពុទ្ធសាវ័កទាំងឡាយ នាំគ្នាប្រែមកជាបាលីភាសាវិញ ដូចរឿងព្រះពុទ្ធឃោសាចារ្យអ្នកស្រុកមគធៈបាននិមន្តទៅលង្កាទ្វីបប្រែអដ្ឋកថាចេញពីសីហឡភាសាមកជាបាលីភាសា នៅពុទ្ធសតវត្សទី ១០ គឺធ្វើភាសាដែលកត់អដ្ឋកថានោះឲ្យទៅជាបាលីភាសា ស្របទៅតាមភាសាដែលកត់មូលប្បករណ៍ ដើម្បីឲ្យផ្សាយទៅកាន់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រទេសនានាបានដោយស្រួល ។

មួយទៀត បាលីភាសានេះ នឹងហៅថា ពុទ្ធភាសា ក៏បាន ព្រោះជាភាសាបច្ចេកទេសមួយក្នុងចំណោមមគធភាសា ហើយកើតឡើងដោយការទេសនារបស់ព្រះពុទ្ធ ។ កាលខ្ញុំ (អ្នកសរសេររឿងនេះ) ទៅបំពេញបេសកកម្មក្នុងឆដ្ឋសង្គាយនានៅប្រទេសភូមា ខ្ញុំបានឮថេរវាចាព្រះសង្គីតិការកៈខ្លះថា យើងបានស្គាល់គ្នាដកពេកដល់ទុកចិត្តស្និទ្ធស្នាល ដោយសារយើងបានចេះពុទ្ធភាសា ដូចអ្នកស្គាល់ជំខ្សែពេទ្យ ដោយសារចេះភាសាពេទ្យ ។

សព្វថ្ងៃអ្នកស្រុកភូមាក្ដី ឥណ្ឌៀក្ដី កាលប្រាថ្នាឲ្យយល់អត្ថរសជ្រាលជ្រៅនៃបាលីពុទ្ធភាសា គេតែងទៅនៅសិក្សាអប់រំ នៅប្រទេសសេរីលង្កា ដូចព្រះរាជបុត្រស្ដេចខ្មែរពីសម័យបុរាណដែរ គេជឿថាប្រទេសនេះ បានសិក្សាហាត់រៀនក្នុងអត្ថបទបាលីពុទ្ធភាសា តមកអំពីអ្នកប្រាជ្ញទាំងឡាយ មានព្រះមហាមហិន្ទត្ថេរអគ្គអរហន្តជាដើមដែលជាអ្នកស្រុកមគធៈ (ជម្ពូទ្វីប) ហើយបានសង្គាយនាធម្មវិន័យរក្សាទុកដរាបមក ។ សូម្បីប្រទេសភូមា ដែលបានចារឹកព្រះត្រៃបិដកមួយចប់ ចុះក្នុងសិលាកែវចំនួន ៧២៩ ផ្ទាំង នៅដើមពុទ្ធសតវត្សទី ២៥ នេះ ក៏ដោយសារបានចម្លងគម្ពីរស្លឹករឹតពីប្រទេសសេរីលង្កាដែរ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# ព្រឹត្តិការណ៍វប្បធម៌ពុទ្ធសាសនានៅកម្ពុជរដ្ឋ

ខ្ញុំបានពណ៌នាមកហើយថា វប្បធម៌ពុទ្ធសាសនាបានមកចាក់ឫសចាក់គល់ក្នុងប្រទេសខ្មែរតាំងពីសម័យនគរភ្នំ(ហ្វូណន)ឬមុននេះទៅទៀត, តែវប្បធម៌នេះតែងមានវប្បធម៌សាសនាព្រាហ្មណ៍ ដែលមានមកជាយូរដែរ ហើយនោះជាគូប្រឆាំងឬជាឧបសគ្គ ព្រោះក្នុងរជ្ជកាលតៗមក មានព្រះមហាក្សត្រច្រើនព្រះអង្គ ឬមន្ត្រីធំៗ ជាព្រាហ្មណិក (កាន់សាសនាព្រាហ្មណ៍) ហើយព្រះអង្គខ្លះទៀត បានតាំងព្រះអង្គជាគូប្រឆាំងឬជាសត្រូវនឹងវប្បធម៌ខាងពុទ្ធសាសនាទាល់តែមានប្រភពខ្លះថា ក្នុងកាលខ្លះ ព្រះពុទ្ធ-សាសនាសាបសូន្យពីប្រទេសខ្មែរទៅហើយក៏មាន ដូចក្នុងរជ្ជកាលតមកពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ សម័យអង្គរ មានមហាក្សត្រអង្គខ្លះជាព្រាហ្មណិកលើកតម្កើងវប្បធម៌ព្រាហ្មណ៍ បំបាត់វប្បធម៌ពុទ្ធសាសនា ដូចមានវប្បធម៌ខាងការរចនារបស់ព្រាហ្មណ៍ នៅប្រាសាទបាយ័នឋិតនៅមកដល់សព្វថ្ងៃជាឧទាហរណ៍ស្រាប់ ។

ដំណើរខាងលើនេះ ធ្វើឲ្យយើងរឹតតែជ្រះថ្លាចំពោះគុណានុភាពព្រះពុទ្ធសាសនាថែមឡើងទៀត ព្រោះព្រះពុទ្ធសាសនាជាសាសនាស្លូតសុភាព ទោះក្នុងរជ្ជកាលណាក៏ដោយ តាំងពីសម័យនគរភ្នំដល់ផុតសម័យអង្គរព្រះមហាក្សត្រជាពុទ្ធសាសនិកទាំងឡាយ មិនដែលតាំងព្រះអង្គជាគូសត្រូវនឹងសាសនាដទៃដល់ម្ដងទេ បើខ្លាំងណាស់គ្រាន់តែមិនគោរពគប់អានថ្វាយព្រះអង្គជាសាសនូបត្ថម្ភកប៉ុណ្ណោះ ឧទាហរណ៍ដូច

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រាសាទនគរវត្តដែលធ្លាប់ធ្លាក់នៅក្នុងកណ្ដាប់ព្រះហស្តព្រះមហាក្សត្រជាពុទ្ធសាសនិក ឃើញគង់រូបនៅតាមដើមគ្រប់គ្រឿងរចនាផ្សេងៗ ទាំងអស់ ។ ដោយវប្បធម៌ពុទ្ធសាសនាស្លូតសុភាពបែបនេះ ហើយមានការផ្សព្វផ្សាយទៅកាន់វេនេយ្យសត្វ បើកសិទ្ធិឲ្យប្រើវិចារណញ្ញាណដេញដោលឥតមានការបង្ខិតបង្ខំ ក៏ទៅជាមានអានុភាពអាចចាក់ឬសដុះដាលក្នុងសន្ដានប្រជាជនជាសពាសពេញទាំងដែន ទោះបីមានព្រះមហាក្សត្រ ឬមន្ត្រីធំៗជាគូសត្រូវយ៉ាងណាក៏ដោយ បើខ្មាំងណាស់គ្រាន់តែប្រជាជនពុំអាចបញ្ចេញមុខប្រកាសខ្លួនថាជាពុទ្ធសាសនិកប៉ុណ្ណោះ ឧទាហរណ៍ដូចរដ្ឋបុរសសំខាន់ៗទាំងឡាយរបស់ប្រទេសឥណ្ឌា] មានលោកគន្ធី លោករាជេន្ទ្រប្រាសាទនឹងលោកនេរូជាដើម បើទុកជាលោកទាំងនេះ ពុំបានប្រកាសខ្លួនថាជាពុទ្ធសាសនិក ក៏អាចឃើញថាវប្បធម៌ខាងពុទ្ធសាសនាចាក់ឬសជ្រួតជ្រាបយ៉ាងជ្រាលជ្រៅ ក្នុងសន្ដានរបស់លោកទាំងនេះស្រេចទៅហើយ ព្រោះក្នុងសម័យមុនព្រះពុទ្ធត្រាស់ គ្មាននរណាអាចពោលធម៌អាចិប្រកបដោយហេតុផល ហើយមានសន្ដានស្រឡាញ់ភាតរភាពនឹងសមភាពតាមរបបលទ្ធិប្រជាធិបតេយ្យដូច្នេះទេ ។ នឹងថាព្រះពុទ្ធជាមូលនិទានការទៅខាងលទ្ធិនេះក៏បាន ព្រោះព្រះអង្គប្រកបដោយព្រះមហាករុណា មានព្រះអធ្យាស្រ័យដ៏ធំទូលាយគ្មានទីបំផុត ។ ព្រះពុទ្ធសាសនាកើតក្រោយសាសនាព្រាហ្មណ៍ តែមានវប្បធម៌ខាងទស្សនវិជ្ជាប្រកបដោយអត្ថរសដ៏ជ្រាលជ្រៅក្រៃលែង ផុតវិស័យលទ្ធិព្រាហ្មណ៍ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សាសនាគ្រិស្តនិងសាសនាមហាម័ត្ត ព្រោះបើមានដើមកំណើតនៅទ្វីបអាស៊ី ដូចព្រះពុទ្ធសាសនាដែរ ហើយកើតក្រោយព្រះពុទ្ធសាសនាផង ក៏មិនឃើញមានអត្តសញ្ញាណពិសេសជាងព្រះពុទ្ធសាសនាឡើយ ឃើញគ្រាន់បើតែត្រង់បបួលនិងបង្ខំគេឲ្យជឿព្រះអាទិទេព ដូចពួកព្រាហ្មណ៍បបួលគេឲ្យជឿគោរពគោតខ្លាចព្រះព្រហ្ម ព្រះឥសូរ និងព្រះនារាយណ៍ ៗ ហេតុនេះ ឃើញថា វប្បធម៌ពុទ្ធសាសនាជាកំពូលខាងទស្សនវិជ្ជានៅទ្វីបអាស៊ី ៗ បំណែកទ្វីបដទៃដែលទើបតែបម្លងយកវប្បធម៌ទៅពីទ្វីបអាស៊ីក្រោយពុទ្ធកាល ដូចទ្វីបអាមេរិកបានទទួលវប្បធម៌ពីទ្វីបអឺរ៉ុបនោះ មិនបានចាត់ជាបញ្ហាត្រូវដោះស្រាយក្នុងទីនេះទេ ៗ រួមសេចក្តីទៅអាចឃើញថា ព្រះពុទ្ធជាកំពូលអ្នកប្រាជ្ញក្នុងការរាវរកហេតុផល ទាំងខាងរូបសាស្ត្រទាំងខាងចិត្តសាស្ត្រ ៗ

## វប្បធម៌ពុទ្ធសាសនាសម័យក្រោយអង្គរ

ដោយវប្បធម៌ពុទ្ធសាសនាបានចាក់ឫសក្នុងសន្តានជនជាតិខ្មែរតាំងពីបុរាណកាលមក លុះដល់សម័យអង្គរ គឺរយៈវេលាពុទ្ធសតវត្សទី ២០ ដល់ទី ២៥នេះ ទោះមានហេតុការណ៍ចលាចលជាញឹកញយ ដោយពួកជនបរទេសចូលលុកលុយស្រុករឹបជាន់ បំផ្លិចបំផ្លាញជីវិត និងភោគសម្បត្តិជាដើមយ៉ាងណា ក៏ប្រជាជនខ្មែរនៅតែព្យាយាមអោបពទាំងត្រដាបត្រដួសនូវព្រះពុទ្ធសាសនាមិនបោះបង់សោះឡើយ គឺនៅតែនាំគ្នាចូលបួសជាភិក្ខុសាមណេរ ថ្វាយខ្លួនជាឧបាសកឧបាសិកា និងសាងវត្តអាវាស

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សម្រាប់ព្រះសង្ឃគ្រប់ឃុំខែត្រនៃព្រះរាជអាណាចក្រ ។ សូម្បីកន្លែងណាធ្លាប់ជាវត្តអារាមរបស់សាសនាព្រាហ្មណ៍ ក៏ប្រែទៅជារបស់ព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។ ម្ល៉ោះហើយវប្បធម៌ព្រាហ្មណ៍ ដោយគ្មានអ្នកគោរពគប់អានក៏សាបសូន្យអស់ទៅ នៅសល់តែគ្រឿងរបនានឹងការទំនៀមទម្លាប់បន្តិចបន្តួចក្នុងពិធីខ្លះៗ មានព្រះរាជពិធីអភិសេកជាដើមប៉ុណ្ណោះ ។ អាស្រ័យជនជាតិខ្មែរភាគច្រើនជាពុទ្ធសាសនិក នឹងមានព្រះមហាក្សត្រជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ទើបប្រទេសខ្មែរក៏ជាប្រទេសពុទ្ធសាសនិកពេញទីហើយទទួលស្គាល់តាមរដ្ឋធម្មនុញ្ញនូវព្រះពុទ្ធសាសនាថាជាសាសនារបស់រដ្ឋថែមទៀត ។

ក្នុងសម័យបច្ចុប្បន្ន នាពុទ្ធសតវត្សទី ២៥ នេះ ប្រទេសខ្មែរមានភ័ព្វសំណាងលើសលុបជាងសតវត្សមុនៗ ដែលមានបន្ទាប់មកពីសម័យអង្គរ ព្រោះបានឯករាជ្យមានអធិបតេយ្យបរិបូណ៌ទាំងខាងក្នុងទាំងខាងក្រៅ ហើយមានទីបណ្ដុះវប្បធម៌ខាងពុទ្ធសាសនា គឺកើតមានសាលារៀនធម្មវិន័យ សាលាពុទ្ធិកបឋមសិក្សា សាលាពុទ្ធិកវិទ្យាល័យ សាលាពុទ្ធិកមហាវិទ្យាល័យ ពុទ្ធសាសនបណ្ឌិត្យ ក្រុមជំនុំព្រះត្រៃបិដក សមាគមមិត្តពុទ្ធិកវិទ្យាល័យនឹងពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋព្រមទាំងមានព្រះសង្ឃបានបំពេញគន្ថធុរៈ រៀនប្រឡងជាប់ថ្នាក់ជាអ្នកធម្មវិទូ ជាមហាបធានវិជ្ជា នឹងជាមហាឧត្តមវិជ្ជាច្រើនពាន់រូប ហើយបញ្ជូនព្រះមហាឧត្តមវិជ្ជាច្រើនរូបឲ្យទៅសិក្សាអប់រំបំពេញវិជ្ជា ក្នុង

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ប្រទេសផ្សេងៗមានប្រទេសឥណ្ឌា និងភូមាជាដើម ។

ដំណើរការខាងលើនេះនាំឲ្យប្រទេសខ្មែរមានកម្លាំងល្មមពេញចិត្តធ្វើបុណ្យសម្ពោធលើកស្ទួយព្រះពុទ្ធសាសនា ដែលមានអាយុគំរប់ ២៥០០ វស្សានេះផង និងនាំឲ្យមានការសង្ឃឹមថា វប្បធម៌ពុទ្ធសាសនាទាំងខាងទ្រឹស្តី ទាំងខាងប្រតិបត្តិ រឹងរឹតតែចាក់ឫសដុះលូតលាស់ចំរើនធំទូលាយទូទៅក្នុងពិភពលោកផង ។

## វប្បធម៌ពុទ្ធសាសនាខាងទ្រឹស្តី

ជនជាតិខ្មែរ ធ្លាប់យល់ឃើញតាមព្រះពុទ្ធសាសនាថា ការថ្លៃថ្នូរថោកទាបបរិសុទ្ធនិងមិនបរិសុទ្ធ កើតមកអំពីខ្លួន មានខ្លួនជាទីសម្ភព មិនមែនកើតដោយស្នាដៃទេវតាណាឡើយ ។ សូម្បីព្រះពុទ្ធជាគ្រូដើម ក៏បានទទួលការថ្លៃថ្នូរ បរិសុទ្ធ ព្រោះអំពើដែលជាសំណាងរបស់ព្រះអង្គដែរ ។ កាលទ្រង់បំពេញពុទ្ធកិច្ច ទ្រង់គ្រាន់តែប្រាប់ផ្លូវនៃសេចក្តីថ្លៃថ្នូរបរិសុទ្ធ ទ្រង់មិនអាចប្រទានសេចក្តីថ្លៃថ្នូរបរិសុទ្ធដល់គេដែលមិនធ្វើដំណើរតាមផ្លូវនោះផងបានទេ ។ កាលមានវប្បធម៌ខាងទ្រឹស្តីដូច្នេះ ទោះជនជាតិខ្មែរធ្វើការអ្វីដែលទាក់ទិនដោយពិធីបន់ស្រន់ ក៏ធ្វើគ្រាន់តែជាទំនៀមទម្លាប់ជាប់តមកពីព្រាហ្មណសម័យប៉ុណ្ណោះ មិនមែនជឿថា ទោះបីគ្មានអំពើសមហេតុផល ក៏អាចថ្លៃថ្នូរបរិសុទ្ធបានទេ ។ ទានសីលនិងភាវនាចាត់ជាអំពើដែលសមហេតុផលនៃសេចក្តីថ្លៃថ្នូរបរិសុទ្ធ ។ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ដែលបានទទួលសេចក្តីថ្លៃថ្នូរបរិសុទ្ធ ក៏

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ព្រោះតែអំពើនេះទាំងអស់ ៗ ពុទ្ធការកធម៌ ១០ ប្រការមានទានជាដើម មានឧបេក្ខាជាអវសាន ដែលហៅថា ទសបារមី ក៏សង្គ្រោះចូលក្នុងអំពើនេះដែរ ៗ

## វប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ

ដោយសារទ្រឹស្តីមានដើមដូចបានពោលមកហើយនេះ ជនជាតិខ្មែរក៏មានសទ្ធាជ្រះថ្លា ក្នុងទានសីលនឹងភាវនាផង ក្នុងបុគ្គលដែលជាអ្នកទានសីលភាវនាផង ៗ ដោយសារសទ្ធាជ្រះថ្លានេះ ទើបខំបំពេញទានសីលនឹងភាវនាធ្វើខ្លួនឲ្យទៅជាអ្នកទានអ្នកសីលនឹងជាអ្នកភាវនា ៗ ករណីយកិច្ចក្នុងជីវិតរបស់ជនជាតិខ្មែរ តែងមានអំពើគឺទានសីលនឹងភាវនានេះជាទីជ្រះថ្លា នឹងជាទីកក់ក្តៅដរាបអស់អាយុសង្ខារ ព្រោះឃើញថាមានតែអំពើនេះទេ ដែលអាចសាងខ្លួនឲ្យទៅជាមនុស្សល្អ ត្រូវតាមព្រះពុទ្ធសាសនា ហើយសមគួរដល់ខ្លួនដែលកើតហើយត្រូវចាស់ស្លាប់ ៗ

## អ្នកទាន

អ្នកទានជាតិខ្មែរ តែងធ្វើទានដោយអនុគ្រោះផង ដោយបូជាផង, ជនខ្វះខាតគួរគេធ្វើទានដោយអនុគ្រោះ, ជនមិនខ្វះខាតទេ តែមានគុណធម៌ល្អ គួរគេធ្វើទានដោយបូជា, បើខ្វះខាតផង មានគុណធម៌ល្អផង គួរគេធ្វើទានដោយអនុគ្រោះផង ដោយបូជាផងៗ ដូច្នេះដើម្បីឲ្យបានផលានិសង្សច្រើនសមគួរដល់ទានដែលមានគុណ អាចកំចាត់មច្ឆរិយៈ ចិត្តចង្អៀតហើយធ្វើចិត្តឲ្យទូលាយ ជនជាតិខ្មែរទើបនិយមធ្វើទានដល់ពួកបព្វជិតក្នុងពុទ្ធ-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សាសនា ជាងពួកជនឯទៀត ដរាបដល់ក្មេងគិតមាតាបិតាក៏មាន មកពីឃើញថាពួកនេះតែងមានការខ្វះខាតគួរអនុគ្រោះផង មានគុណគួរបូជាផង ការធ្វើទានដល់ពួកនេះ ជាមធ្យោបាយពង្រីកសេចក្ដីសុខចំរើនឲ្យរីកធំទូទៅដល់សព្វសត្វឥតរើសមុខ ព្រោះពួកនេះជាអ្នកបំរើពុទ្ធសាសនាដោយផ្ទាល់ មានប្រពៃណីធ្វើទានតាំងពីបុរាណកាល ទោះបីស្រុកទេសធ្លាក់ក្នុងវិបត្តិធំៗ ខ្វះអ្នកប្រាជ្ញខ្វះគម្ពីរក្បួនខ្នាត ដូចក្នុងសម័យខ្លះមានសម័យក្រុងលង្វែកជាដើម ជនជាតិខ្មែរក៏នៅតែរក្សាប្រពៃណីធ្វើទានដរាប ៗ បុណ្យថ្លងវាលុកចេតិយ និមន្តព្រះសង្ឃស្រង់ទឹកចូលឆ្នាំ បុណ្យចូលវស្សា បុណ្យភ្ជុំបិណ្ឌ បុណ្យចេញវស្សា បុណ្យមាឃបូជា និងបុណ្យពិសាខបូជាជាដើម សុទ្ធតែមានការធ្វើសក្ការៈគោរពកោតអានបូជាព្រះរតនត្រ័យដោយអាមិសបូជានិងបដិបត្តិបូជាជាប្រពៃណីទាំងអស់ ៗ ហេតុនេះបានជាវប្បធម៌ព្រះពុទ្ធសាសនា មិនរលើងឬសសាបសូន្យទៅពីប្រទេសខ្មែរឡើយ ទោះប្រទេសនេះមានការកើតប្រែបចលាចលឬមានជាតិសាសន៍ដទៃនាំសាសនាជាគូប្រឆាំងមកផ្សាយយ៉ាងណាក៏ដោយ ៗ

## អ្នកសីល

អ្នកសីលជាតិខ្មែរ ដែលមានប្រាជ្ញាតែងរក្សាសីលមាននិច្ចសីលជាដើម្បីវៀរចាកការបៀតបៀនជនដទៃផង ដើម្បីផ្ដាច់កង្វល់អាក្រក់ដោយកាយវាចាដែលជាហេតុក្ដៅក្រហាយចិត្តផង ដើម្បីរម្ងាប់ពៀរវេរា និងសាងសេចក្ដីកក់ក្ដៅក្នុងចិត្តគ្នាក្នុងលោកផង ព្រោះជនទ្រុស្តសីលគ្មាន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

អកយពានទេ ប្រែសេចក្ដីថា ជាអ្នកឲ្យតែសេចក្ដីភ័យបារម្ភ ឲ្យតែសេចក្ដីមិនទុកចិត្តដល់គ្នានឹងគ្នា ។ អ្នកសីលមិនអាចដើរឧបាយបំបាត់ទ្រព្យសង្ឃ ទ្រព្យរាជការ ទ្រព្យឯកជន ឬទទួលសំណូកយកទៅចិញ្ចឹមខ្លួន ចិញ្ចឹមគ្រួសារ ឬធ្វើបុណ្យពានអ្វី ១ ឡើយ ។ ហេតុនេះអ្នកសីលអាចជាទីកក់ក្ដៅទុកចិត្តនឹងជាទីពឹងរបស់រដ្ឋទៀតផង ។ រដ្ឋបើមានអ្នកសីលជាពលរដ្ឋច្រើននឹងពុំអាចធ្លាក់ខ្លួនទៅជាបាវព្រាវរបស់រដ្ឋណាដោយងាយ ៗ ទេ ។ ដូច្នេះទើបរដ្ឋខ្លះខំអប់រំពលរដ្ឋឲ្យមានសីលធម៌តាំងពីក្មេង ៗ រហូតដល់ទៅបំបាត់មិនឲ្យបើកស្រាក្នុងស្រុក ទឹងមិនឲ្យស្រាអាកៀនចូលស្រុកទៀតផង ដូចគ្រួសារដែលមានសីលធម៌ល្អមិនចង់ឲ្យមានល្បែងស៊ីសងឡើងផ្ទះ ព្រោះខ្លាចមានការខូចអាក្រក់ដល់កូនចៅ ។ អ្នកប្រាជ្ញទាំងឡាយតែងឃើញអំពើទ្រុស្ដសីល ឬល្បែងស៊ីសងថាជាភ័យរបស់លោកសន្និវាស ទើបមានហរិទុតប្បៈខ្ពើមខ្លាចអំពើទាំងនេះ ដូចគេខ្ពើមខ្លាចពស់អសិរពិសដែលពេនត្រាំក្នុងលាមក ។ កាលបើលោកសន្និវាសមានសីលធម៌ល្អ លោកសន្និវាសនឹងមិនមានការបៀតបៀនគ្នា ។ អាស្រ័យការមិនបៀតបៀន សេចក្ដីសុខក៏មានឡើង សមនឹងពុទ្ធ ៗ ពានថា

សុខំ លោកេ ការមិនបៀតបៀនគ្នាជាសុខក្នុងលោក ។

រធ្លាប់ជាអ្នកមានសីលធម៌បែបនេះមកតាំងពីបុរាណកាល តែ

ទច្រើនជាងមនុស្សទ្រុស្ដសីលទេ ។ តទៅគួរណាស់តែរដ្ឋ

អប់រំពលរដ្ឋឲ្យទៅជាអ្នកសីលមានភាគច្រើនឡើងដើម្បីជាទី

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អ្នកភាវនា

អ្នកភាវនាជាតិខ្មែរ តែងមានការចំរើនភាវនា និងការនមស្ការ(ថ្វាយបង្គំព្រះ) ជាប្រពៃណីតាំងពីបុរាណកាល ។ ក្រៅពីចំរើនភាវនាក្នុងបូជនីយដ្ឋានមានព្រះបដិមាឃរៈ (ព្រះវិហារ) ជាដើម តែងភាវនានៅទីកុដិនិងនៅគេហស្ថានដែលហៅថា ធ្វើវត្តព្រឹកនិងវត្តល្ងាច ។ នៅកុដិព្រះសង្ឃ និងផ្ទះឧបាសកតែងមានតុតាំងដំកល់ព្រះពុទ្ធរូបព្រមទាំងគ្រឿងសក្ការបូជាដែលហៅថា គ្រែព្រះធម៌ ជាទីគោរពនមស្ការនិងជាទីចំរើនភាវនា ។ ឯការចំរើនភាវនានោះ គេតែងមានការចំរើនចតុរក្ខ-កម្មដ្ឋានជាគោល គឺ

ក) ចម្រើនភាវនារំលឹកពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ដើម្បីបណ្តុះចិត្តសទ្ធាជ្រះថ្លាក្នុងព្រះគុណទាំងនោះ មិនឲ្យចិត្តរញ្ញកចយ ឬរសាយចេញពីកុសលធម៌ ។

ខ) ចម្រើនព្រហ្មវិហារគឺភាវនាផ្សាយមេត្តាដល់សត្វទូទៅ ដោយតាំងចិត្តឲ្យបានកប់ប្រទះតែនូវសេចក្តីសុខចំរើនគ្រប់គ្នា, ផ្សាយករុណាដោយប្រាថ្នាឲ្យបានរួចដោះចាកទុក្ខគ្រប់ប្រាណ ផ្សាយមុទិតាដោយប្រាថ្នាមិនឲ្យប្រាសព្រាត់ចាកសេចក្តីសុខ ដែលបានហើយទាំងអស់គ្នា, ផ្សាយឧបេក្ខាដោយគិតថាសត្វទាំងអស់គ្នាតែងមានកម្មជារបស់ខ្លួន គឺថាបើខ្លួនធ្វើល្អនឹងទទួលផលល្អ ធ្វើអាក្រក់នឹងទទួលផលអាក្រក់ ដើម្បីកំចាត់បង់ចិត្តព្យាបាទ ចិត្តវិបដិសារីនិងចិត្តឫស្យាឈ្នានីសគ្នាជាដើម ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គ) ចំរើនអសុភភាវនាពិចារណារាងកាយដែលជាទីប្រជុំធាតុ ៤ ឲ្យឃើញថាពោរពេញដោយអាការៈស្មោកគ្រោកមិនស្អាត មានសក់រោមក្រចក ធ្មេញ ស្បែកជាដើម ។

ឃ) ចំរើនមរណស្សតិភាវនា នឹកពិចារណាសេចក្ដីស្លាប់ដែលត្រូវមានដល់ខ្លួនដោយទៀងទាត់ តែមិនប្រាកដថាមានមកដល់ថ្ងៃណា ព្រោះជីវិតមិនទៀង ដើម្បីបណ្ដុះចិត្តសង្វេគ ហើយប្រញាប់ចាប់ធ្វើការដែលមានខ្លឹមសារ ឲ្យសមគួរដល់ខ្លួនដែលមានសេចក្ដីស្លាប់ចាំស្កាត់ពីខាងមុខ ។

ការចំរើនភាវនាដែលរៀបរាប់មកនេះ ជាពិធីសាងសេចក្ដីស្ងប់ សុខក្សេមក្នុងចិត្ត ហើយអាចញុំាងចិត្តជាពានជាសីល ឲ្យតែតែមានជំហររឹងប៉ឹងទឹងឲ្យមានផលានិសង្សច្រើនទៀតផង ។ ហេតុនេះទើបលោកអ្នកខ្លះ អាចលះកន្លល់ផ្សេង ៗ ទៅសម្ងំចំរើនសមថកម្មដ្ឋានក្នុងទីស្ងាត់ ដើម្បីឲ្យបានផលានិសង្សនេះផង ដើម្បីឲ្យបានសម្រេចឈានចិត្តដែលជាទីតាំងនៃវិបស្សនាកម្មដ្ឋានផង ។ ឯវិបស្សនាភាវនាក៏ជាករណីយកិច្ចត្រូវធ្វើបន្ទាប់មកពីការចំរើនចតុរារក្ខកម្មដ្ឋាន ដែលហៅថាសមថភាវនានោះដែរ ។ ហេតុនោះ កាលបានភាវនារំលឹកគុណព្រះរតនត្រ័យផ្សាយមេត្តា ចំរើនអសុភនឹងរំលឹកសេចក្ដីស្លាប់រួចហើយ តែងភាវនាវិបស្សនាកម្មដ្ឋានពិចារណាអត្តភាពទាំងមូលឲ្យឃើញថាគ្រាន់តែជានាមរូប ឬគ្រាន់តែជាខន្ធ ៥ ជាដើមប៉ុណ្ណោះ មិនមែនជាសត្វបុគ្គលគេយើងទេ ហើយលើកសភាពធម៌ទាំងនេះឡើងកាន់ត្រៃលក្ខណ៍ ភាវនាបញ្ជាក់ឲ្យឃើញថាមិន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទៀត ព្រោះកើតហើយរលត់ទៅនឹងប្រែក្លាយទៅជាសភាពផ្សេងៗ , ជាទុក្ខព្រោះក្តៅដោយភ្លើងកិលេសនឹងភ្លើងទុក្ខគ្រប់រយៈកើតរលត់ នឹងប្រែក្លាយ, ជាអនត្តាមិនមែនខ្លួន ព្រោះមិនទៅក្នុងអំណាច ដើម្បីរលាយនូវឧបាទានមានសេចក្តីប្រកាន់តាមលោកសន្មតថា ជារបស់យើង ថាជាយើង នឹងថាជាខ្លួនប្រាណរបស់យើង ដែលជាហេតុឆេះក្តៅ ឲ្យអស់សូន្យទៅពីខន្ធសន្តានហើយ បាននូវព្រះនិព្វានគ្មានឆេះដោយភ្លើងទុក្ខនឹងភ្លើងកិលេសឡើយ ។ សមនឹងពុទ្ធភាសិតថា:

សីលេន វីតិក្កមន្តំ បរិយុដ្ឋំ សមាធិនា
បញ្ញាយ អនុសយំ ឆិន្ទំ បត្តោ និព្វានមុត្តមំ ។

(អ្នកប្រាជ្ញ) តែងលះកិលេស (រាគៈទោសៈមោហៈ) ថ្នាក់វីតិក្កមៈ ដោយសីល ថ្នាក់បរិយុដ្ឋានដោយសមាធិ, ថ្នាក់អនុស័យ ដោយបញ្ញា ទើបបានសម្រេចព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

ជនជាតិខ្មែរ ទាំងបព្វជិតទាំងគ្រហស្ថ ច្រើនតែបានភាវនាអប់រំចិត្ត ដោយសមថៈនឹងវិបស្សនា តាំងពីបុរាណកាល ដូចពណ៌នាមកនេះ ។

ដូច្នេះហៅថា វប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ ។

ព្រះញាណាវីរិយៈ វ៉ាណា-សា ឌុំ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# វគ្គទី៥

## សទ្ធម្មប្បជ្ជោត

ថ្ងៃនេះជាថ្ងៃ បុណ្ណមី ខែពិសាខ ឆ្នាំរកា គំរប់ ២៥០០ វស្សានៃពុទ្ធសាសនា ដែលជាកាលកម្របាន ដែលពុទ្ធសាសនិកជនអ្នកត្រូវការសន្តិភាពមានភ័ព្វបានជួប ត្រូវនឹងខណៈ ៤:

ក) ពុទ្ធសាសនុប្បាទក្ខណៈ ខណៈកើតមានពុទ្ធសាសនា;

ខ) បដិរូបទេសុប្បត្តិក្ខណៈ ខណៈកើតក្នុងប្រទេសសមគួរ;

គ) សម្មាទិដ្ឋិប្បដិលទ្ធក្ខណៈ ខណៈបានបំពោះនូវទិដ្ឋិល្អ;

ឃ) ឆន្នាយតនាវេកល្លក្ខណៈ ខណៈមិនខ្វះខាតអាយតនៈ៦;

ហើយបានបំពេញកុសលធម៌ គឺទាន សីល ភាវនា ជាមាគ៌ានៃសន្តិភាពឥតអាមិស ។

ដើម្បីតម្រូវកាលនេះ, ពុទ្ធសាសនបណ្ឌិត្យបានរៀបរៀង «សទ្ធម្មប្បជ្ជោត» (ពន្លឺដ៏រុងរឿងគឺព្រះសទ្ធម្ម) ជា ៥ ផ្នែក គឺ

១- សទ្ធម្មុប្បត្តិ = ការកើតឡើងនៃព្រះសទ្ធម្ម;

២- សទ្ធម្មបរិច្ចេទ = ការកំរិតព្រះសទ្ធម្ម;

៣- ពុទ្ធសកដ្ឋបនៈ = ការតាំងពុទ្ធសករាជ;

៤- បញ្ចវត្ថុប្បតិដ្ឋាន = ប្រតិស្ឋានវត្ថុ ៥ យ៉ាង;

៥- បញ្ចអន្តរធាន = អន្តរធាន ៥ យ៉ាង ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

## ១– ពុទ្ធុប្បត្តិ

លោកនៅក្នុងអាណានៃលោកភព គឺ

–អនិច្ចតា សភាពមិនទៀង;

–ទុក្ខតា សភាពលំបាក;

–អនត្តតា សភាពមិនលុះអំណាចខ្លួន ។

ត្រូវលោកភពនោះញាំញីជានិរន្តរ៍ ព្រោះជាប់ចោទបញ្ហាប្រចាំលោក ៣ ខ គឺ

– ជាតិ ការកើតនៃខន្ធ ;

– ជរា ការគ្រាំគ្រានៃខន្ធ ;

– មរណៈ ការបែកធ្លាយស្លាប់នៃខន្ធ ។

លោកមិនអាចដោះស្រាយបញ្ហានោះបានអស់កាលមិនប្រាកដចុងដើម ព្រោះត្រូវមហន្តការ គឺ អវិជ្ជា មានការមិនដឹងហេតុផលនៃសុខទុក្ខជាលក្ខណៈបិទបាំង ម៉្លោះហើយចេះតែបំពានលើផ្លូវខុស នាំគ្នាប្រព្រឹត្តទុច្ចរិតជាសមុដ្ឋាននៃទុក្ខវិនាសអសន្តិភាព សំគាល់ថាសុច្ចរិតនាំមកនូវសុខចំរើនសន្តិភាពទៅវិញ ព្រោះមិនមានបុគ្គលណាម្នាក់យកពន្លឺដ៏រុងរឿងមកបំភ្លឺឲ្យឃើញមាគ៌ាដ៏ត្រង់ដែលនាំទៅកាន់សន្តិភាព ។

យូរអង្វែងណាស់, ទើបមានទុល្លភបុគ្គលម្នាក់មានបញ្ញាចក្ខុកើតឡើងក្នុងលោក ដោះបញ្ហាប្រចាំលោកដោយខ្លួនឯងរួចហើយយកពន្លឺដ៏រុងរឿងបំភ្លឺឲ្យលោកស្គាល់ឧបាយដោះស្រាយបញ្ហានោះរួចហើយ ឲ្យរួចផុតអំពី

AngkorLink.com CambodiaBuddhist.org ABCCambodia.com



អាណាលោកពដទៅកាន់សន្តិភាព ។ ទុល្លភបុគ្គល គឺព្រះពុទ្ធអ្នកត្រាស់ដឹងសច្ចៈ ៤ ហើយឲ្យគេត្រាស់ដឹងតាមផង, អ្នកភ្ញាក់ចេញពីស្រោម គឺអវិជ្ជាមុនគេ, អ្នករីកផុតពីភក់គឺកិលេសដូចផ្កាឈូក ។ កាលត្រាស់ដឹងហើយទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុជាមុនដំបូងបង្អស់ ។

ក្នុងធម្មចក្កនោះ ព្រះអង្គទ្រង់បដិសេធនូវបដិបទាអមពីរ គឺ

១- ការប្រកបខ្លួនឲ្យជាប់ដោយកាមសុខក្នុងកាមទាំងឡាយជាហីន-ធម៌ គ្រាមធម៌ បុថុជ្ជនធម៌ មិនមែនអរិយធម៌ មិនប្រកបដោយប្រយោជន៍;

២-ការប្រកបខ្លួនឲ្យលំបាកទទេៗ នាំមកនូវទុក្ខ មិនមែនអរិយធម៌ មិនប្រកបដោយប្រយោជន៍ ។

ទ្រង់ឲ្យដើរតាមមជ្ឈិមាបដិបទា ដែលព្រះអង្គត្រាស់ដឹងហើយ ធ្វើឲ្យមានចក្ខុ មានញាណ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ កិរិយាដឹងច្បាស់ កិរិយាត្រាស់ដឹងដោយប្រពៃ ដើម្បីកិរិយារលត់ទុក្ខ ។ ទីបំផុតទ្រង់ប្រកាសអរិយសច្ចៈ ៤ គឺ

១ ទុក្ខអរិយសច្ចៈ សេចក្ដីពិតរបស់អរិយៈគឺទុក្ខ បានដល់ធម្មជាតដែលសត្វដឹកគាស់រំលើងបានដោយក្រ ធម្មជាតទទេ ធម្មជាតនាំឲ្យលំ-បាកព្រួយ ពិបាកអត់ទ្រាំ ធម្មជាតដែលអរិយបុគ្គលខ្ពើមឆ្អើមធុញទ្រាន់នឿយណាយនោះ គឺទុក្ខ ១២ កង គឺ

ក) ជាតិទុក្ខ កិរិយាកើត កើតព្រម កិរិយាចុះកាន់គភ៌ កិរិយាកើត

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កិរិយាកើតថ្មី កិរិយាមានប្រាកដនៃខន្ធ កិរិយាបានចំពោះនូវអាយតនៈក្នុងសត្តនិកាយនោះៗ នៃពួកសត្វនោះៗ ៖

ខ) ជរាទុក្ខ កិរិយាទ្រុឌទ្រោម គ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ កិរិយាសាបសូន្យអាយុ កិរិយាចាស់ជុំវិញនៃឥន្ទ្រិយ;

គ) មរណទុក្ខ កិរិយាច្យុតិ ឃ្លាតចេញ បែកធ្លាយ អន្តរធាន សេចក្តីស្លាប់គឺមច្ចុ កាលកិរិយា កិរិយាបែកធ្លាយនៃខន្ធ កិរិយាដាក់ចោលនូវសាកសព កិរិយាផ្តាច់បង់ជីវិតិន្ទ្រិយ ។ (អនិច្ចកម្ម អនិច្ចធម្ម សុគត ទៅកាន់បរលោក);

ឃ) សោកទុក្ខ សំណោក កិរិយាស្តាយ កិរិយាស្រណោះ ស្រណេះស្រណោចខាងក្នុង សង្រេងសង្រែខាងក្នុង នៃបុគ្គលប្រកបដោយសេចក្តីវិនាសអន្តរាយណាមួយ ដែលទុក្ខធម៌ណាមួយមកប៉ះពាល់ ;

ង) បរិទេវទុក្ខ កិរិយាយំទួញរក យំទួញរៀបរាប់ អាការយំទួញរក អាការយំទួញរៀបរាប់ ខ្សឹកខ្សួលអណ្តើតអណ្តក;

ច) ទុក្ខទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយប្រព្រឹត្តក្នុងកាយ កិរិយាទទួលសោយនូវសេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយកើតអំពីការប៉ះពាល់ដោយកាយ ;

ឆ) ទោមនស្សទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយប្រព្រឹត្តក្នុងចិត្ត កិរិយាទទួលសោយនូវសេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយកើតអំពីការប៉ះពាល់ដោយចិត្ត ;

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ជ) ឧបាយាសទុក្ខ សេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង ភាព-ចង្អៀតចង្អល់ ភាពតានតឹង នៃបុគ្គលប្រកបដោយវិនាសអន្តរាយ ណាមួយ ដែលទុក្ខធម៌ណាមួយមកប៉ះពាល់;

ឈ) អប្បិយេហិ សម្បយោគទុក្ខ ការប្រកបព្រមដោយសត្វនិង សង្ខារមិនជាទីស្រឡាញ់ ជាទុក្ខ គឺការសង្គម សមាគម ប្រជុំព្រម លាយឡំដោយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ឬដោយពួកបុគ្គល មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសេចក្ដីចំរើន មិនប្រាថ្នាការនៅសប្បាយ មិនប្រាថ្នាធម៌ក្សេមចាកយោគៈ;

ញ) បិយេហិ វិប្បយោគទុក្ខ ការព្រាត់ប្រាសចាកសង្ខារនិងសត្វ ជាទីស្រឡាញ់ ជាទុក្ខ គឺការមិនមូលមិត្រ មិនជួបជុំ មិនមូលត្រកូល មិននៅលាយឡំគ្នា ដោយរូបសំឡេង ក្លិន រស ផោដ្ឋព្វ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ឬដោយមាតាបិតា បងប្អូនប្រុស បងប្អូនស្រី អមាត្យ ញាតិសាលោហិត ដែលប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្ដីចំរើន ប្រាថ្នាធម៌ក្សេមចាកយោគៈ;

ដ) យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ការដែលប្រាថ្នារបស់ណាមិនបាន របស់នោះ ជាទុក្ខ គឺ ពួកសត្វមានកំណើត ការគ្រាំគ្រា ជម្ងឺជម្កាត់ សេចក្ដីស្លាប់ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខទោមនស្ស សេចក្ដីចង្អៀតចង្អល់ជាធម្មតា មានសេចក្ដីប្រាថ្នាថា «ឱ! ហ្ន៎ ធ្វើម្ដេចយើងទាំងឡាយ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កុំគប្បីមានកំណើត" ការគ្រាំគ្រា ជម្ងឺជម្ងាត់ ។ល។ សេចក្ដីចង្អៀតចង្អល់ទុក្ខ៏ ធ្វើដូចម្ដេចបាន កំណើតការគ្រាំគ្រា ជម្ងឺជម្ងាត់ ។ល។ សេចក្ដីចង្អៀតចង្អល់កុំមកកាន់យើងទាំងឡាយ (ប្រាថ្នានេះមិនសំរេច);

ឋ) សង្ខិត្តេនបញ្ចុបាទានក្ខន្ធា ទុក្ខា ដោយបំព្រួញឧបាទានក្ខន្ធ ៥ ជាទុក្ខ គឺ

- រូបូបាទានក្ខន្ធ គំនរនៃសេចក្ដីប្រកាន់មាំ គឺរូប;
- វេទនូបាទានក្ខន្ធ គំនរនៃសេចប្រកាន់មាំ គឺវេទនា;
- សញ្ញូបាទានក្ខន្ធ គំនរនៃសេចក្ដីប្រកាន់មាំ គឺសញ្ញា;
- សង្ខារូបាទានក្ខន្ធ គំនរនៃសេចក្ដីប្រកាន់មាំ គឺសង្ខារ;
- វិញ្ញាណូបាទានក្ខន្ធ គំនរនៃសេចក្ដីប្រកាន់មាំ គឺវិញ្ញាណ ។

២- ទុក្ខសមុទយអរិយសច្ចៈ សេចក្ដីពិតរបស់អរិយៈ គឺហេតុដែនកើតព្រមនៃទុក្ខ បានដល់តណ្ហាប្រកបដោយនន្ទិរាគត្រេកអរក្នុងភពនោះៗ រឿយៗ មិនដាច់ ញុំាងសត្វឲ្យកើតក្នុងភពថ្មី ៣ គឺ

- កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកន្លែងកើតមានកាម;
- ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងកន្លែងព្រហ្មមានរូប;
- វិភវតណ្ហា សេចក្ដីប្រាថ្នាក្នុងកន្លែងកើតព្រហ្មឥតរូប ។

តណ្ហានោះកើតឡើងក្នុងធម្មជាតជាទីស្រឡាញ់ ជាទីត្រេកអរក្នុងលោក នៅអាស្រ័យក្នុងធម្មជាតនោះគឺ អាយតនៈខាងក្រៅ ៦ អាយតនៈខាងក្នុង ៦, វិញ្ញាណ ៦, សម្ផស្ស ៦, វេទនា ៦, សញ្ញា ៦,

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សញ្ចេតនា ៦, តណ្ហា ៦, វិតក្កៈ ៦, វិចារៈ ៦ ។

៣- ទុក្ខនិរោធអរិយសច្ចៈ សេចក្តីពិតរបស់អរិយគឺកិរិយារំលត់តណ្ហាបណ្តាលទុក្ខ បានដល់កិរិយារំលត់តណ្ហានោះឥតមានសេសសល់ កិរិយាលះបង់ចោល ពោះបង់ចោល កិរិយារួចផុតតណ្ហានោះ មិនមានអាល័យ ។ កិរិយាលះបង់ កិរិយារំលត់តណ្ហាដែលកើតឡើងអាស្រ័យក្នុងធម្មជាតជាទីស្រឡាញ់ជាទីត្រេកអរមានអាយតនៈជាដើមនោះ ។

៤- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ សេចក្តីពិតរបស់អរិយៈ គឺបដិបទានាំទៅកាន់ទីរំលត់តណ្ហាបណ្តាលទុក្ខ បានដល់អរិយមគ្គមានអង្គ ៨ ។

ព្រះធម្មចក្កនេះ ជាព្រះសទ្ធម្មដែលព្រះអង្គទ្រង់សំដែងបំភ្លឺបង្ហាញផ្លូវត្រង់ឆ្ពោះទៅកាន់សន្តិដ្ឋាន ដើម្បីឲ្យស្រាយបញ្ហាប្រចាំលោកជាដំបូងបង្អស់ ។

ព្រះសទ្ធម្មចែកជា ៣ ប្រភេទគឺ

១- បរិយត្តិធម៌ ពុទ្ធវចនៈ ព្រះត្រៃបិដកសំដែងអំពីគោលធម៌របៀបរៀបចែន ដំបូន្មាន ច្បាប់សម្រាប់ប្រតិបត្តិដែលពុទ្ធបរិស័ទត្រូវរៀនសូធ្យាយ ទ្រទ្រង់ បង្ហាត់បង្រៀន សំដែងប្រាប់ដល់អ្នកដទៃ ;

២- បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិប្រព្រឹត្តតាមបានដល់សីលសមាធិ បញ្ញា ឬសេចក្តីប្រតិបត្តិតាមធ្វើតាមកាន់តាម នូវធម៌ដ៏សមគួរដល់ធម៌ដែលខ្លួនបានរៀន បានស្តាប់ បានចេះដឹង ដើម្បីឲ្យដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ឲ្យសំរេចនូវធម៌ដែលខ្លួនមិនទាន់សំរេច ដើម្បីឲ្យជាក់ច្បាស់ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



៣- បដិវេធធម៌ ការត្រាស់ដឹង បាទដល់កិរិយាបានសំរេច បាន ជាក់ច្បាស់ចាក់ធ្លុះនូវបរមត្ថ: គឺមគ្គ ផល និព្វាន ដែលជាផលសំរេចអំពីការរៀនស្តាប់ចេះដឹង និងប្រតិបត្តិនោះ;

វេនេយ្យសត្វដូចអ្នកដំណើរ, ព្រះសម្មាសម្ពុទ្ធដូចអ្នកស្គាល់ផ្លូវបង្ហាញផ្លូវត្រង់, បរិយត្តិធម៌ដូចជាផ្លូវត្រង់, បដិបត្តិធម៌ដូចជាដំណើរទៅតាមផ្លូវត្រង់នៃអ្នកដំណើរ, បដិវេធធម៌ដូចជាដំណើរទៅដល់កន្លែងដែលត្រូវទៅឲ្យដល់នៃអ្នកដំណើរ ។ ព្រះសទ្ធម្មទាំង៣ប្រការនេះបណ្ឌិតគប្បីលើកយកអរិយមគ្គមានអង្គ ៨ មកពិនិត្យឲ្យយល់ច្បាស់ថា :

ការរៀនចេះចាំបង្រៀនសំដែងនូវមគ្គ នោះជាបរិយត្តិ ;

ការប្រឹងប្រែងប្រតិបត្តិប្រព្រឹត្តតាមអង្គមគ្គ នោះជាបដិបត្តិ ;

ការបានសំរេចនូវអង្គមគ្គ នោះជាបដិវេធ: ។

អរិយមគ្គមានអង្គ ៨

១- សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ ;

២- សម្មាសង្កប្ប: សេចក្តីត្រិះរិះត្រូវ ;

៣- សម្មាវាចា សំដីត្រូវ ;

៤- សម្មាកម្មន្ត: ការងារត្រូវ ;

៥- សម្មាអាជីវ: ការចិញ្ចឹមជីវិតត្រូវ ;

៦- សម្មាវាយាម: ព្យាយាមត្រូវ ;

៧- សម្មាសតិ ការរលឹកត្រូវ ;

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



៨- សម្មាសមាធិ ការដំកល់ចិត្តឲ្យនឹងត្រូវ ។

សម្មាទិដ្ឋិ

ប្រាជ្ញាយល់ឃើញត្រូវ បានដល់ប្រាជ្ញាដឹងក្នុងអរិយសច្ចៈ ៤

១-ទុក្ខ ធម្មជាតដែលនាំឲ្យលំបាកព្រួយ មានជាតិជរាមរណៈជាដើម

២-ទុក្ខសមុទយៈ ហេតុបណ្ដាលឲ្យកើតទុក្ខបានដល់តណ្ហា ;

៣-ទុក្ខនិរោធៈ ព្រះនិព្វានរំលត់តណ្ហាបណ្ដាលទុក្ខ ;

៤-ទុក្ខនិរោធគាមិនីបដិបទា មជ្ឈិមាគតិ នាំឲ្យទៅកាន់ទីរំលត់ទុក្ខ ។

សម្មាសង្កប្បៈ

សេចក្ដីត្រិះរិះត្រូវ បានដល់សេចក្ដីត្រិះរិះត្រូវ ៣ យ៉ាង គឺ

១-នេក្ខម្មសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការចេញចាកកាម ;

២-អព្យាទសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនព្យាបាទ ;

៣-អវិហឹសាសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនបៀតបៀន ។

សម្មាវាចា

សំដីត្រូវ បានដល់ការវៀចាករចីទុច្ចរិត ៤ យ៉ាង គឺ

១-មុសាវាទាវេរមណី ការវៀរចាកកិរិយាពោលកុហក ,

២-បិសុណាយវាចាយវេរមណី ការវៀរចាកសំដីញុះញង់;

៣-ផរុសាយ វាចាយ វេរមណី ការវៀរចាកសំដីទ្រគោះ ;

៤-សម្ផប្បលាបា វេរណី ការវៀរចាកកិរិយាពោលរឿងឥតប្រយោជន៍ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

## សម្មាកម្មន្តៈ

ការងារត្រូវបានដល់ការវៀរចាកកាយទុច្ចរិត ៣ យ៉ាង គឺ

១- បាណាតិបាតា វេរមណី ការវៀរចាកកិរិយាបំបាត់ប្រាណសត្វ;

២- អទិន្នាទានា វេរមណី ការវៀរចាកការកាន់យកវត្ថុដែលគេមិនឲ្យ;

៣- កាមេសុមិច្ឆាចារា វេរមណី ការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## សម្មាអាជីវៈ

ការចិញ្ចឹមជីវិតត្រូវ, សម្រាប់គ្រហស្ថ បានដល់ការវៀរចាកជំនួញខុស, កិរិយាលះបង់បំបាត់ដោយផញ្ចឹងជាដើម ការធ្វើជាសាក្សីកោង, ការល្មោភសំណូក ហើយប្រកបអាជីវកម្ម ដោយវណិជ្ជកម្មដែលនាំឲ្យសេដ្ឋកិច្ចជាតិចំរើន, ដោយវិជ្ជាជីវៈដ៏យុត្តិធម៌, ដោយកសិកម្ម ជាឧត្តមកម្ម នឹងគោរក្ខកម្ម; សម្រាប់បព្វជិត, បានដល់ការលះបង់មិច្ឆាជីវៈ ដោយអនេសនៈបាបធម៌ មានទូតកម្ម វេជ្ជកម្មជាដើម ការត្រាច់ទៅកាន់អគោចរដ្ឋាន ហើយចិញ្ចឹមជីវិតដោយកិច្ចាចារិយធម៌ដ៏ស្មើ ឬបច្ច័យកើតឡើងតាមធម៌ ។

## សម្មាវាយាមៈ

ព្យាយាមត្រូវ បានដល់សម្មប្បធាន គឺការបង្កើតឆន្ទៈ ព្យាយាម

ប្រារព្ធវិរិយៈ តាំងបណាន ផ្គងចិត្ត :

- ដើម្បីមិនឲ្យអកុសលធម៌លាមកមិនទាន់កើតឡើង កើតឡើងបាន;

- ដើម្បីលះបង់នូវអកុលសធម៌លាមកកើតឡើងហើយ;

- ដើម្បីឲ្យកុសលធម៌មិនទាន់កើតឡើង កើតឡើង,

- ដើម្បីឲ្យកុសលធម៌កើតឡើងហើយ បិតនៅមិនសាបសូន្យឲ្យចំរើនច្រើនឡើង ឲ្យចំរើនទូលំទូលាយឲ្យបរិបូណ៌ ។

## សម្មាសតិ

### ការរលឹកត្រូវ បានដល់សតិប្បដ្ឋាន៤ គឺ

១- កាយានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិខ្ជាប់ខ្ជួនពិចារណារឿយ ៗ ក្នុងកាយ;

២- វេទនានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួនពិចារណារឿយ ៗ ក្នុងវេទនា;

៣- ចិត្តានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួនពិចារណារឿយ ៗ ក្នុងចិត្ត;

៤- ធម្មានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួនពិចារណារឿយ ៗ ក្នុងធម៌ ។

## សម្មាសមាធិ

សមាធិត្រូវ បានដល់ឈាន ៤ ដែលភិក្ខុស្ងប់ស្ងាត់ចាកកាមទាំង

ឡាយ ចាកអកុសលធម៌ទាំងឡាយ ហើយបានសំរេច គឺ

១- បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិ សុខៈ កើតពីវិវេក;

២- ទុតិយជ្ឈាន រម្ងាប់វិតក្កៈ វិចារៈ ថ្លាល្អខាងក្នុង មានឯកោទិភាពចិត្ត មានបីតិសុខៈកើតពីវិវេក;

៣- តតិយជ្ឈាន ប្រាសចាកបីតិ មានសុខៈនឹងឧបេក្ខា;

៤- ចតុត្ថជ្ឈាន លះបង់សុខទុក្ខ មិនមានសោមនស្សទោមនស្ស ជាអទុក្ខមសុខៈ មានសតិប្រកបដោយឧបេក្ខាដ៏បរិសុទ្ធ ។

បណ្ដាមគ្គទាំង៨

- សម្មាទិដ្ឋិ ញុំាងលោកឲ្យដឹងច្បាស់នូវ អនិច្ចតា ទុក្ខតា អនត្តតា, នូវសមុទ័យនៃលោកបញ្ហា គឺតណ្ហា, នូវឧបាយដោះ នឹងកិរិយាដោះ ។

- សម្មាសង្កប្បៈ ឲ្យស្គាល់សម្ផុដ្ឋានអសន្តិភាព គឺ កាមៈ ព្យាបាទៈ វិហឹសា ហើយឲ្យសាងសន្តិភាពដោយកាមវិរតិ ព្រហ្មវិហារធម៌ ៤ ជាធម៌ស្ងួនលោក;

- សម្មាវាចា ឲ្យមានសច្ចៈ មានសន្តិភាពសាមគ្គីអរិយធម៌ដោយវាចានឹងវាចាប្រកបដោយប្រយោជន៍;

- សម្មាកម្មន្តៈ ឲ្យគោរពសិទ្ធិ សេរីភាព អធិបតេយ្យដែលមានសំរាប់កាយិកចេតសិកសុខជីវិត, សវិញ្ញាណកាវិញ្ញាណកទ្រព្យ, គ្រាមធម៌;

- សម្មាអាជីវៈ ឲ្យប្រកបអាជីវកម្មដោយធម៌,

AngkorLink.com CambodiaBuddhist.org ABCCambodia.com



— សម្មាវាយាមៈ ឲ្យលះបង់ភាពស្សាត (កុំជិល) ជាប្រធានអកុសលធម៌ ;

— សម្មាសតិ ឲ្យមានសតិសម្បជញ្ញៈ ជានិច្ចថា ‹‹លោកមានសភាពទៅវិញទៅមក›› ព្រោះលោកជាទឹក ដី ភ្លើង ខ្យល់ ឋិតនៅក្នុងភាពអនិច្ចតា ទុក្ខតា អនត្តតា ដូចគ្នា ជាប់ទោទលោកបញ្ហាដូចគ្នា;

— សម្មាសមាធិ ឲ្យមានចិត្តស្អាតផូរផង់ តាំងនៅមាំមួនចំពោះសត្វនិងសង្ខារ ។

មគ្គទាំង ៨ នេះចាត់ចូលក្នុងសង្ខារទាំង ៣ គឺ

សម្មាទិដ្ឋិ សម្មាសង្កប្បៈ ចូលក្នុងអធិប្បញ្ញាសិក្ខា;

សម្មាវាចា, សម្មាកម្មន្តៈ សម្មាអាជីវៈ ចូលក្នុងអធិសីលសិក្ខា;

សម្មាវាយាមៈ សម្មាសតិ, សម្មាសមាធិ ចូលក្នុងអធិចិត្តសិក្ខា ។

ព្រះពុទ្ធសាសនា មានគោលធម៌ប៉ុណ្ណេះជាដើម ដែលជាពន្លឺបំភ្លឺលោក ឲ្យភ្លឺស្វាងចាកមហន្ធការគឺអវិជ្ជា ហើយឲ្យស្គាល់មធ្យោបាយសាងសន្តិភាពសម្រាប់សាកលលោក និងឯកត្តសន្តិភាព គឺសន្តិភាពសម្រាប់ខ្លួននាបច្ចុប្បន្ន អនាគត និងសន្តិភាព រួចចាកអាណាលោកភព និងលោកបញ្ហានាអវសានជាតិ ។

រវាងសតវត្សទី ២៥នៃពុទ្ធសករាជ, ពិភពលោកក្នុងកំឡុងការស្ទើអាទិត្យ ត្រូវលោកសង្គ្រាមគំរាមយ៉ាងខ្លាំង ព្រោះខ្វះមនុស្សធម៌ ដល់គំរប់ ២៥០០ វស្សានៃពុទ្ធសករាជ ក៏មានចិត្តស្នេហាសន្តិភាពបាននាំគ្នា

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ធ្វើបុណ្យរំលឹករយៈកាល ២៥០០ វស្សា ដើម្បីសន្តិភាព; ប៉ុន្តែសន្តិភាព មិនមែនមានត្រង់អំនួតថា « ខ្ញុំធ្វើពិធីនេះហើយ » ទេ ព្រោះដំណើរនោះ ជាអាកប្បកិរិយាក្នុងបន្ទុំកំសិងមាន; សន្តិភាពឥតអាម៉ិសមាននៅត្រង់ការ ប្រតិបត្តិតាមគោលព្រះសទ្ធម្ម ៨ ដែលពោលមកហើយនោះពិត ៗ ។

បើលោកត្រូវការសន្តិភាព ស្រឡាញ់សន្តិភាព សូមអញ្ជើញធ្វើ តាមគោលព្រះសទ្ធម្ម ៨ នោះចុះ ។

## ២– សទ្ធម្មបរិច្ឆេទ

ព្រះសទ្ធម្មគឺព្រះពុទ្ធសាសនាដែលព្រះមានជោគប្រកាសដោយប្រពៃ ហើយ យើងជាពុទ្ធបរិស័ទបានដឹងថា នឹងឋិតនៅអស់កំរិត ៥០០០ ឆ្នាំ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សាងព្រះសទ្ធម្មដោយញាណពល ជ្រាបស្ថិត-ពលព្រះសទ្ធម្មដោយអនាគតំសញ្ញាណ ព្រោះអាស្រ័យហេតុនោះ ៗ ដូច ព្រះពុទ្ធដីកាដែលព្រះមានជោគត្រាស់នឹងអានន្ទត្ថេរ ក្នុងភិក្ខុនីខន្ធកៈថា « វស្សសហស្សំ អានន្ទ សទ្ធម្មោ តិដ្ឋេយ្យ សចេ ភិក្ខុនិយោ ន បព្វជិតា អស្ស បញ្ចេវទានិ អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ ម្នាលអានន្ទ ព្រះសទ្ធម្ម គប្បីឋិតនៅអស់ពាន់ឆ្នាំ ប្រសិនបើ ភិក្ខុនីទាំងឡាយ មិនគប្បីបួស, ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅតែ ៥០០ ឆ្នាំវិញ ។

ភិក្ខុនីខន្ធកវណ្ណនាថា បើព្រះមានជោគមិនបញ្ញត្តគរុធម៌មុនភិក្ខុនី បួសទេ ព្រះសទ្ធម្មនឹងឋិតត្រឹម ៥០០ ឆ្នាំ បើបានបញ្ញត្តទុកមុន ព្រះសទ្ធម្ម

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នឹងឋិតនៅ ៥០០ ឆ្នាំទៀត រួមជាមួយពាន់ឆ្នាំ ។ ព្រះសទ្ធម្មចែកជា ៣ ប្រភេទគឺ បរិយត្តិធម៌ បដិបត្តិធម៌ បដិវេធធម៌ ។ ព្រះសទ្ធម្មឋិតនៅ ៥០០០ ឆ្នាំនោះ លោកកំណត់ ១០០០ ឆ្នាំ ៥ ដងដោយអំណាចនៃបុគ្គលសម្រេចបដិវេធធម៌ ៥ ថ្នាក់ គឺ

– ១០០០ ឆ្នាំ ដោយអំណាច ព្រះខីណាស្រពបដិសម្ភិទា ;

– „ „ សុក្ខវិបស្សក: ;

– „ „ អនាគាមិបុគ្គល ;

– „ „ សកទាគាមិបុគ្គល ;

– „ „ សោតាបន្នបុគ្គល ។

ព្រះសទ្ធម្ម គឺ បដិវេធធម៌ នឹងឋិតនៅ៥០០០ឆ្នាំយ៉ាងនេះ ។ ព្រះបរិយត្តិធម៌ បដិបត្តិធម៌ដូចគ្នាដែរ ។ ឯភេទ (ភិក្ខុ) បើបរិយត្តិអន្តរធានក៏ឋិតនៅបានយូរ ។

ព្រះសទ្ធម្មនឹងសាបសូន្យដោយហេតុ ៥ យ៉ាង គឺ

១– ពួកភិក្ខុរៀនសូត្រនូវដែលខ្លួនរៀនខុស ដោយបទនឹងព្យញ្ជនៈដែលរៀបរៀងខុស បទនឹងព្យញ្ជនៈដែលរៀបរៀងខុសរមែងយល់សេចក្តីបានដោយក្រ ;

២– ពួកភិក្ខុជាអ្នកប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ;

៣– ពួកភិក្ខុណា ជាអ្នកចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ចងចាំនូវព្រះធម៌ (សុត្តន្ត) ចងចាំនូវព្រះវិន័យ ចងចាំមាតិកា, ពួកភិក្ខុទាំងនោះ មិនឲ្យភិក្ខុដទៃរៀនសុត្តន្តដោយគោរព លុះអំណើះតពីភិក្ខុទាំងនោះ សុត្តន្តក៏ដាច់ឫសមិនប្រតិស្ឋាននៅ ;

៤– ពួកភិក្ខុជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសំរេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសំរេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់, ប្រជុំជនដែលកើតខាងក្រោយគឺ សទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំជនខាងក្រោយទាំងនោះ ក៏ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ។ល។ សង្ឃបែកគ្នា, កាលបើសង្ឃបែកគ្នា, ការជេរគ្នានឹងគ្នាក៏មាន, ការប្រទេចផ្តាសាគ្នានឹងគ្នាក៏មាន, ការបោះបោកសំដីទៅរកគ្នានឹងគ្នាក៏មាន, ការលះបង់គ្នានឹងគ្នាក៏មាន, ពួកជនដែលមិនទាន់ជ្រះថ្លាក្នុងសង្ឃទាំងនោះក៏មិនមានសេចក្តីជ្រះថ្លា ដែលជ្រះថ្លាស្រាប់ក៏ឆកចិត្តលែងជ្រះថ្លាវិញ ។

ព្រះសទ្ធម្មនឹងឋិតនៅដោយហេតុ៤ យ៉ាងដែលផ្ទុយពីនេះ ។

ព្រះសទ្ធម្ម មិនមានបុគ្គលណាជាសត្រូវឲ្យសាបសូន្យបានទេ, បើពុទ្ធបរិស័ទមានសម្មាបដិបត្តិ ដរាបណា, នឹងឋិតនៅដរាបនោះ ។ ដូចពុទ្ធដីកាដែលព្រះមានជោគត្រាស់នឹងសុភទ្ទថា “ឥមេ ច ភិក្ខូ សុភទ្ទ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សម្មាបដិបត្តី វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ ម្នាលសុភទ្ទ ឲ្យតែពួកភិក្ខុនេះមានសម្មាបដិបត្តិចុះ, លោកមិនសូន្យចាកអរហន្តទាំងឡាយ» ។ នេះ បង្អុលឲ្យឃើញថា អាយុព្រះសទ្ធម្ម ទាក់ទងដោយសម្មាបដិបត្តិ ។ ប៉ុន្តែសម្មាបដិបត្តិ តោងមានបរិយត្តិជាមូល ។

## ៣ – ពុទ្ធសកង្កបនៈ

ការកំណត់រាប់អាយុកាលនៃសាសនាមួយ ៗ ចាប់ដើមអំពីថ្ងៃខែឆ្នាំដែលសាស្តាមួយៗ កើតឡើង ឬ បរិនិព្វាន, ស្លាប់ ហៅថា «សកៈ ឬ-សករាជ» ។ ការកំណត់រាប់អាយុកាលព្រះពុទ្ធសាសនា ហៅថា «ពុទ្ធសករាជ» (ព. ស. ) ។

ចំពោះពុទ្ធសាសនា, ការកំណត់រាប់សករាជ គេរាប់ចាប់ដើមអំពីថ្ងៃពុធ ១ រោច ខែពិសាខ ឆ្នាំម្សាញ់ ជាថ្ងៃក្រោយពុទ្ធបរិនិព្វាន ។ ការរាប់នេះ គេកំណត់ពីថ្ងៃ ១ រោច ខែមួយទៅដល់ ១៤ ឬ ១៥ កើតខែមួយជា ១ ខែ; ១២ ខែ ជា ១ ឆ្នាំ គឺជា ១ សករាជ ។ សម័យពីដើមមិនមានពាក្យថា «សកៈ ឬ សករាជ» ទេ, មានតែពាក្យថា «អំណើះទៅ» ; ប្រហែលជាសម័យមហានគរ ទើបមានពាក្យថា សករាជ ភ្ជាប់ជា «ពុទ្ធសករាជ» ។

ការតាំងពុទ្ធសករាជ កំណត់រាប់នេះ អ្នកសរសេរសូមអាងរឿងដែលមានក្នុងពាហិរកថាមិលិន្ទបញ្ហាដែលព្រះពុទ្ធទ្រង់ព្យាករសាសនប្បតិដ្ឋានក្នុងបរិនិព្វានសម័យថា: នាកាលតថាគតបរិនិព្វានហើយ កស្សបៈ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



រលឹកនូវពាក្យបំរូងចំរះ របស់ពួកបួសចាស់ ទីងសង្គាយនាធម្មវិន័យ ជំរះពុទ្ធវចនៈ ។ ខាងមុខពីនោះ កន្លងទៅ ១០០ ឆ្នាំ យស-កាកណ្ឌបុត្ត ទីងញាំញីពួកភិក្ខុវជ្ជិបុត្តកៈ បានធ្វើទុតិយសង្គីតិ ។ ខាងមុខពីនោះ កន្លងទៅ ២១៨ ឆ្នាំ, មោគ្គលីបុត្ត-តិស្សត្ថេរ ទីងចំលាយនូវវាទៈនៃពួកអន្យ-តិត្ថិយ ទីងធ្វើតតិយសង្គីតិ ។ កាលខាងមុខទៀត ( ២៣០ ) ភិក្ខុមហា-មហិន្ទៈ ទីងប្រតិស្ឋានសាសនាតថាគតក្នុងតាម្ពបណ្ណិទ្វីប (សិរីលង្កា) ។ ខាងមុខពីនោះ កន្លងទៅ ៥០០ ឆ្នាំ អំពីបរិនិព្វាន នៃព្រះសម្មាសម្ពុទ្ធ, មានព្រះរាជាព្រះនាមមិលិន្ទៈ ញាំញីពួកសមណព្រាហ្មណ៍ដោយបញ្ហាដ៏ល្អិត ក្នុងជម្ពូទ្វីបទាំងសាកល ។ មានភិក្ខុមួយរូបនាមនាគសេន ចំលាយវាទៈ របស់ព្រះរាជាបានញាំងព្រះរាជាឲ្យរីករាយព្រះហឫទ័យដោយអនេកូបមា ធ្វើនូវសាសនាមិនឲ្យមោះហ្មង ទីងប្រតិស្ឋានដរាបគ្រប់ ៥០០០ ឆ្នាំ ។

ដូច្នេះ គួរសន្និដ្ឋានថា ការកំណត់រាប់អាយុកាលនៃពុទ្ធសាសនា មុនដំបូងគឺ ព្រះសម្មាសម្ពុទ្ធកំណត់ដោយព្រះអង្គឯង, ដល់ខាងក្រោយ ពួកសង្គីតិកាចារ្យកំណត់រាប់តាមដូច្នោះ ទាំងពួកពុទ្ធបរិស័ទខាងក្រោយ ក៏កំណត់រាប់ដូច្នោះដែរ ។

ការតាំងកំណត់រាប់ពុទ្ធសករាជ ឬសករាជឯទៀតៗ ជាប្រយោជន៍ ដល់ការកំណត់កាល ចំណាំកាល នៃកម្មវិធីផ្សេងៗ ទីងប្រវត្តិសាស្ត្រ អាយុឆ្នាំ នៃមនុស្ស ធម្មជាតិ ស្ថាបនា ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



## ៤. បញ្ចអន្តរធាន

ព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ, ទ្រង់ប្រតិស្ឋានវត្ថុ ៥ យ៉ាង គឺ

ក) បដិមា រូបសំណាកព្រះអង្គ ;

ខ) ពោធិព្រឹក្ស ឈើជាទីត្រាស់ដឹង ;

គ) ស្តូប ចេតិយបញ្ចុះព្រះសារីរិកធាតុ ;

ឃ) ជិនធាតុ ព្រះបរមធាតុព្រះជិនស្រី ;

ង) ធម្មក្ខន្ធ ៨៤.០០០ ព្រះត្រៃបិដក ។

### ក) បដិមា

រូបសំណាកព្រះពុទ្ធ ដែលគេគូរនឹងសំពត់ហៅថាព្រះបដខុះ, គេសាងនឹងឈើ ឬលោហធាតុខុះ តាមពុទ្ធប្បវត្តិ ដើម្បីនមស្ការជាអារម្មណ៍របស់ចិត្ត ។ បដិមានេះ ហៅថា «ឧទ្ទេសចេតិយ» ។

### ខ) ពោធិព្រឹក្ស

ឈើដែលគេចូលទៅជ្រកបាត់សេចក្តីក្រវល់ក្រវាយបាន ដកដង្ហើមស្រួលហៅថាអស្សត្ថព្រឹក្ស ជាសហជាតធម៌របស់ព្រះសម្ពុទ្ធ ជាឈើដែលព្រះពុទ្ធគង់បំពេញភាវនាបានសម្រេចបានត្រាស់ពោធិញ្ញាណ ទើបហៅថា «ពោធិព្រឹក្ស» ។ អស្សត្ថព្រឹក្សនេះដែលយើងហៅថា «ដើមពោធិ៍» នៅប្រទេសយើង ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

## គ) ស្តូប

ចេតិយដែលគេសាងកងដូចគំនរស្រូវខ្លះ ដូចដំបូកខ្លះ កងបួនជ្រុងជមទៅលើខ្លះ សម្រាប់ដំកល់បូជនីយវត្ថុ «ស្តូប» ឬ «ថូប» ៗ ស្តូបនេះបានដល់ពុទ្ធចេតិយ ៣ យ៉ាង គឺ

១) បរិភោគចេតិយ ចេតិយដែលគេដំកល់ឧបករណ៍សម្រាប់ប្រើប្រាស់មានបាត្រជាដើមរបស់ព្រះមានព្រះភាគ ;

២) ធាតុចេតិយ ស្តូបដែលគេបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ដែលប្រតិស្ឋានក្នុងជម្ពូទ្វីប ៨ កន្លែង គឺស្តូប ១ នៅក្រុងរាជគ្រឹះ, ស្តូប ១ នៅក្រុងអល្លកប្បៈ, ស្តូប ១ នៅរាមគ្រាម, ស្តូប ១ នៅក្រុងវេដ្ឋទីបកៈ, ស្តូប ១ នៅបាវេយ្យកៈក្នុងមល្លរដ្ឋជនបទ, ស្តូបមួយនៅក្រុងកុសិនារា ៗ ស្តូបពីរទៀត គឺ ស្តូប ១ កំពស់ ១៦ យោជន៍នៅព្រហ្មលោក, ស្តូប ១ គឺចូឡាមណិចេតិយនៅត្រៃត្រឹង្ស ៗ ព.ស. ២១៨, ព្រះបាទធម្មាសោក បានទ្រង់ព្រះបញ្ជាឲ្យសាងចេតិយ ៨៤.០០០ គ្រប់ក្នុងសាកលជម្ពូទ្វីប ៗ

៣) ធម្មចេតិយ ចេតិយដែលដំកល់ក្បួនលិខិតធម៌មានបដិច្ចសមុប្បាទជាដើម ដូចជាប្រាង្គឬហោត្រ័យសម្រាប់ដំកល់ព្រះត្រៃបិដក ចេតិយមួយទៀត ហៅថា «បទចេតិយ» បានដល់ស្នាមព្រះបាទ ៤ កន្លែងគឺ ១– ស្នាមព្រះបាទលើផ្នូកខ្សាច់ក្បែរស្ទឹងនម្មទា, ២– ស្នាមព្រះបាទលើភ្នំសច្ចពន្ធ, ៣– ស្នាមព្រះបាទលើកំពូលភ្នំសុមនកូដ, ៤– ស្នាមព្រះបាទក្នុងយោនកបុរី ៗ កន្លែងព្រះបាទ ៥ ទៀត គឺភ្នំសុវណ្ណមាលិក១, ភ្នំសុវណ្ណ-

បពិត១, ភ្នំសុមនកូដ១, យោនកបុរី១, ស្ទឹងនម្មទា១ ។ ចេតិយចែកជា ៣ ទៀតគឺ សារីរិកចេតិយ, បរិភោគចេតិយ, ឧទ្ទេសចេតិយ គឺបដិមាករ ។

ឃ) ជិនធាតុ

ព្រះសារីរិកធាតុប្រតិស្ឋាននៅទីផ្សេងៗ គ្នា ចែកជា ៣ ផ្នែក គឺ

១) ព្រះធាតុមិនបែក ៧ អង្គគឺ ព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១, ព្រះទាឋាធាតុ (ចង្កូមកែវ) ៤, ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត) ២ ។ ព្រះទាឋាធាតុស្តាំខាងលើនឹងព្រះអក្ខកធាតុស្តាំប្រតិស្ឋានឯត្រៃត្រិង្ស, ព្រះទាឋាធាតុស្តាំខាងក្រោមនៅសីហឡទ្វីប, ព្រះទាឋាធាតុឆ្វេងខាងលើនៅគន្ធាររដ្ឋ, ព្រះទាឋាធាតុឆ្វេងខាងក្រោមនៅនាគភពន៍, ព្រះអក្ខកធាតុឆ្វេងព្រមទាំងទុស្សធាតុ (សំពត់ស្លៀកចេញបួស) ឃដិការមហាព្រហ្មយកទៅប្រតិស្ឋានឯព្រហ្មលោក;

២) ព្រះធាតុបែកចេញមានខ្នាត គឺ ព្រះធាតុខ្នាតធំទំហំប៉ុនៗ កំណាត់គ្រាប់សណ្តែកបាយ មានពណ៌ដូចមាស វាល់បាន ៥ នាឡិ (គ្រឡោក), ព្រះធាតុខ្នាតកណ្តាលមានទំហំប៉ុនៗ កំណាត់គ្រាប់អង្ករ មានពណ៌ដូចកែវផលិក វាល់បាន ៦ នាឡិ, ព្រះធាតុខ្នាតតូចមានទំហំប៉ុនៗ គ្រាប់ស្ពៃ មានពណ៌ដូចផ្កាពកុល វាល់បាន ៥ នាឡិ ។ ព្រះធាតុទាំងនេះគេបញ្ចុះក្នុងស្តូបទាំង ៨ ក្នុងជម្ពូទ្វីបកាលមុន;

៣) ព្រះទន្តធាតុ ៤០, ព្រះកេសធាតុ, ព្រះលោមធាតុ និងព្រះនខ-

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ធាតុទាំងឡាយ ទេវតាទាំងឡាយនាំយកមួយអង្គ ៗ ទៅកាន់ចក្រវាឡដទៃ ៗ ៗ ឯព្រះកេសធាតុដែលព្រះអង្គកាត់ក្នុងកាលទ្រង់ព្រះផ្នួស ព្រះឥន្ទនាំយកទៅប្រតិស្ឋានក្នុងចូឡាមណីចេតិយឯឋានត្រៃត្រឹង្ស ៗ

ព.ស. ២១៨, ព្រះបាទធម្មាសោកបានយកព្រះធាតុបញ្ចុះក្នុងចេតិយ ៨៤.០០០; ព.ស.២៣០, ព្រះបាទទេវានំបិយតិស្ស បានបញ្ចុះព្រះអក្ខកធាតុខាងលើ ដែលសុមនសាមណេរសុំពីព្រះឥន្ទទុកក្នុងស្តូបក្នុងថូបារាម ឯលង្កាទ្វីប, ព្រះធាតុមួយបាត្រ សុមនសាមណេរ សុំពីព្រះបាទអសោកព្រះមហិន្ទត្ថេរដំកល់លើចេតិយគិរី, ៗ សម័យព្រះបាទទុដ្ឋគាមណី-អភ័យព្រះនត្តាព្រះបាទទេវានំបិយតិស្ស បញ្ចុះព្រះធាតុចំនួន ១ ទោណក្នុងមហាចេតិយ ៗ

### ង) ធម្មក្ខន្ធ ៨៤.០០០

ព្រះបរិយត្តិធម៌ លោកកំណត់ជាខន្ធ ៗ គឺ សូត្រដែលមានអនុសន្ធិ ១ ជា ១ ធម្មក្ខន្ធ, សូត្រដែលមានអនុសន្ធិច្រើនត្រូវរាប់ធម្មក្ខន្ធដោយអំណាចអនុសន្ធិទាំងនោះ; ក្នុងគាថាព័ន្ធទាំងឡាយ បញ្ហាបុច្ឆាជា ១ ធម្មក្ខន្ធ, បញ្ហាវិសជ្ជនាជា ១ ធម្មក្ខន្ធ ៗ ក្នុងអភិធម្ម, តិកទុកភាជនៈមួយ ៗ, ចិត្តវារភាជនៈមួយ ៗ ជា ១ ធម្មក្ខន្ធ ៗ ក្នុងវិន័យ, វត្ថុមាន, មាតិកាមាន, បទភាជនីយមាន, អន្តរាបត្តិមាន, អាបត្តិមាន, អនាបត្តិមាន, អតេកិច្ឆៈមាន, សតេកិច្ឆៈមាន, ៗ ចំណែកមួយ ៗ គប្បីដឹងថាជា ១ ធម្មក្ខន្ធ ៗ ៗ រួបរួមអភិធម្មបិដកមាន ៤២.០០០ ធម្មក្ខន្ធ, វិនយបិដកមាន ២១.០០០ ធម្ម-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ខន្ធ, សុត្តន្តបិដកមាន ២១.០០០ ធម្មក្ខន្ធ ។ ព្រះពុទ្ធវចនៈ ៨៤.០០០ ធម្មក្ខន្ធយ៉ាងនេះ ។

## ៥. បញ្ចអន្តរធាន

ព្រះពុទ្ធសាសនា កាលនឹងសាបសូន្យ នឹងសាបសូន្យព្រោះអន្តរធាន៥ យ៉ាងគឺ

ក)- បរិយត្តិអន្តរធាន សាបសូន្យព្រះបរិយត្តិ;

ខ)- បដិបត្តិអន្តរធាន សាបសូន្យបដិបត្តិ;

គ)- បដិវេធអន្តរធាន សាបសូន្យសេចក្តីត្រាស់ដឹង;

ឃ)- លិង្គអន្តរធាន សាបសូន្យភេទអ្នកបួស;

ង)- ធាតុអន្តរធាន សាបសូន្យព្រះសារីរិកធាតុ ។

### ក) បរិយត្តិអន្តរធាន

ព្រះបរិយត្តិនឹងសាបសូន្យយ៉ាងនេះ : កាលតទៅ ៗ កើតកលិយុគ, មនុស្សក្នុងសាកលលោកប្រាសចាកមនុស្សធម៌ ព្រោះចំលាយអយុត្តិធម៌ ធម្មជាតិដែលជាទុកការមិនប្រព្រឹត្តទៅដោយប្រពៃ ដូចជាភ្លៀងបង្អុរមិនស្រួល ស្រូវមិនសម្រេចផលជាដើម ។ ម៉្លោះហើយ ពាយកអ្នកផ្គង់បច្ច័យសម្រាប់ការសិក្សាមិនអាចប្រគេនបច្ច័យដល់ភិក្ខុសង្ឃ ពួកភិក្ខុលំបាកដោយបច្ច័យ មិនអាចសង្គ្រោះអន្តេវាសិកអ្នកសិក្សាបរិយត្តិបាន ។ កាលតទៅ ៗ ភិក្ខុមិនអាចទ្រទ្រង់អត្ថបាន ទ្រទ្រង់បាន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ត្រឹមបាលី ៗ តទៅ, កាលកន្លងទៅ ៗ ភិក្ខុមិនអាចទ្រទ្រង់បាលីទាំងអស់ ៗ ដំបូង អភិធម្មបិដកសាបសូន្យ ៗ ពីចុងមកមុនគឺ មហាបដ្ឋាន តមក, យមកៈ, កថាវត្ថុ, បុគ្គលប្បញ្ញត្តិ, ធាតុកថា, វិភង្គ, ធម្មសង្គណី ៗ តមក, សុត្តន្តបិដក សាបសូន្យ, អង្គុត្តរនិកាយសាបសូន្យចាប់ដើមអំពីឯកាទសកៈ ដល់ឯកកៈ; តមក, សំយុត្តនិកាយសាបសូន្យចាប់ដើមអំពីចក្កបេយ្យាលៈ ដល់ឱឃតរណៈ; តមក, មជ្ឈិមនិកាយសាបសូន្យចាប់ដើមអំពីឥន្ទ្រិយភាវនៈ ដល់មូលបរិយាយៈ; តមក, ទីឃនិកាយសាបសូន្យចាប់ដើមអំពីទសុត្តរៈ ដល់ព្រហ្មជាលៈ ៗ បុច្ឆាគាថាមួយក្តី ពីរក្តី បិតនៅអស់កាលវែងក៏ដោយ ក៏មិនអាចទ្រទ្រង់សាសនាបាន ដូចជាសភិយបុច្ឆា អាឡវកបុច្ឆា ក្នុងកស្សបពុទ្ធសាសនា ៗ តមក, ពួកលជ្ជីភិក្ខុទ្រទ្រង់វិន័យ, ពួកភិក្ខុប្រាថ្នាលាភ, កាលសុត្តន្តបិដកបិតនៅ ទ្រទ្រង់តែជាតកប៉ុណ្ណោះ ៗ កាលកន្លងទៅ ៗ ភិក្ខុមិនអាចទ្រទ្រង់ជាតក, វេស្សន្តរជាតកសាបសូន្យជាដំបូង, តមក, បុណ្ណកជាតក មហានារទជាតក ដោយលំដាប់ច្រាសមក; អបណ្ណកជាតកសាបសូន្យទីបំផុត ៗ ភិក្ខុនៅទ្រទ្រង់វិន័យ ៗ កាលកន្លងទៅ ៗ វិន័យសាបសូន្យពីចុងមកមុនគឺ បរិវារៈ, តមក, ខន្ធកៈ, ភិក្ខុនីវិភង្គ, មហាវិភង្គ, ភិក្ខុទ្រទ្រង់តែឧបោសថក្ខន្ធកៈ ៗ គាថា ៤ បទប្រព្រឹត្តក្នុងមនុស្សដរាបណា, ដរាបនោះ បរិយត្តិឈ្មោះថា មិនទាន់អន្តរធាន ៗ កាលនោះស្តេចជ្រះថ្លាឲ្យគេដាក់កហាបណៈមួយពាន់ក្នុងប្រអប់ដាក់លើកដំរី ឲ្យវាយ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្គរសួរថា «អ្នកណាចេះគាថា ៤ បទដែលព្រះពុទ្ធទ្រង់សំដែង អ្នកនោះចូរយកកហាបនៈមួយពាន់នេះចុះ» ។ កាលរាជបុរសវាយស្គរ ៣ ដង មិនមានអ្នកណាទទួលយក, ក៏នាំយកថង់ពេញដោយកហាបនៈ ១ ពាន់ ចូលទៅកាន់រាជត្រកូលវិញ ។ កាលនោះឯងហៅថាបរិយត្តិអន្តរធាន ។

ខ) បដិបត្តិអន្តរធាន

បដិបត្តិទីងសាបសូន្យយ៉ាងនេះ : កាលកន្លងទៅ ៗ ពួកភិក្ខុមិនអាចញុំាងឈាន វិបស្សនា មគ្គផលឲ្យកើត, រក្សាតែចាតុប្បារិសុទ្ធិសីល ។ កាលកន្លងទៅ ៗ ពួកភិក្ខុដល់នូវសេចក្តីបន្ធូរបន្ថយថា «យើងរក្សាចាតុប្បារិសុទ្ធិសីលផង ប្រកបរឿយនូវប្រធានផង មិនអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផលបាន, ឥឡូវនេះ អរិយធម្មប្បដិវេធធម៌មិនមាន» ហើយក៏ហ្លោកខ្ជិល មិនដាស់តឿនរំលឹកទៅវិញទៅមក មិនមានសង្ស័យ; តមក, ក៏ញុំាញីខុទ្ទានុខុទ្ទកសិក្ខាបទ ។ កាលកន្លងទៅ ៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ថុល្លច្ច័យ តពីនោះគរុកាបត្តិបារាជិកប៉ិតនៅ ។ កាលបើពួកភិក្ខុរក្សាបារាជិក ៤ មានមួយរយអង្គក្តី មួយពាន់អង្គក្តី, បដិបត្តិមិនទាន់អន្តរធានទេ ។ លុះតែភិក្ខុក្រោយបង្អស់បែកធ្លាយសីលក្តី, អស់អាយុក្តី បដិបត្តិឈ្មោះថា អន្តរធាន ។

គ) បដិវេធអន្តរធាន

បដិវេធៈ គឺអធិគមៈ បានដល់មគ្គ ៤, ផល ៤, បដិសម្ភិទា ៤, វិជ្ជា, អភិញ្ញា ៦ ។ អធិគមៈសាបសូន្យអំពីបដិសម្ភិទាមកមុន ។ លុះសោតា-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បន្ទុគ្គលក្រោយបង្អស់អស់ជីវិត, អធិគមៈឈ្មោះថា អន្តរធាន ។

ឃ) លិង្គអន្តរធាន

កាលកន្លងទៅ ៗ, ការកាន់បាត្រកាន់ចីវរ, បត់ លា ឈាន ឈានទៅមុខ ឈានថយ មើលទៅមុខ មើលឆ្វេង-ស្តាំ មិនសមរម្យ តាមសមណសារុប្យ មិនជាទីជ្រះថ្លា ។ ពួកភិក្ខុដាក់បាត្រត្រង់អគ្គពាហា (ចុងដើមដៃ) ត្រាច់ទៅ ដូចនិគ្គន្ថស្រមណីកាន់បាត្រលោឃ្លោក ។ ប៉ុណ្ណោះ លិង្គមិនទាន់អន្តរធាន ។ កាលកន្លងទៅ ៗ ពួកភិក្ខុដាក់បាត្រ អំពីអគ្គពាហាយួរដោយដៃ ដោយសង្រែកត្រាច់ទៅ ។ កាលកន្លងទៅៗ ភិក្ខុមិនជ្រលក់ចីវរ កាត់សំពត់ធ្វើចីវរពោះតែក្រវិលពិន្ទុកប្បៈប៉ុណ្ណោះប្រើប្រាស់ទៅ ។

គមក, ពោះតែក្រវិល មិនធ្វើពិន្ទុកប្បៈ ។ គមក, មិនធ្វើទាំងពីរ កាត់តែសំពត់ស្បៀកត្រាច់ទៅដូចបរិព្វាជក ។ កាលកន្លងទៅៗពួកភិក្ខុគិត ថា គ្មានប្រយោជន៍អ្វីដោយសំពត់ ក៏ចងខ្ទុកសាដកនឹងដៃខ្លះនឹងកខ្លះ ដៀមសក់ឲ្យទំទឹកខ្លះ ចិញ្ចឹមកូនប្រពន្ធធ្វើស្រែចិញ្ចឹមជីវិត ។ កាលនោះ ជនណាឲ្យទក្ខិណាទានដល់ជនពួកនេះ ឧទ្ទិសចំពោះសង្ឃបានផលច្រើន ព្រះមានជោគត្រាស់សំដៅរឿងនេះថា « ម្នាលអានន្ទ ក្នុងកាលអង្វែង ទៅអនាគតនឹងមានពួកគោត្រភូចងកាសាវៈនឹងក ទុស្សីល មានធម៌អាក្រក់, ពួកជននឹងឲ្យទានក្នុងគោត្រភូទាំងនោះ; ម្នាលអានន្ទ ក្នុងកាលនោះ តថាគតពោលថា សង្ឃគតាទក្ខិណាទាននោះ មានផលរាប់មិនបាន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្នាមមិនត្រូវ ៗ តមក, កាលកន្លងទៅ ពួកជននោះនាំគ្នាធ្វើអំពើផ្សេងៗ គិតថាការនេះនាំយឺតយូរ យើងមានប្រយោជន៍អ្វីដោយវត្ថុនោះ ហើយក៏គ្រវាត់សំពត់កាសាវៈនោះបោលក្នុងព្រៃ ។ ក្នុងកាលនោះ លិង្គ ឈ្មោះថា អន្តរធាន ។

### ង) ធាតុអន្តរធាន

បរិនិព្វានមាន ៣ គឺ

- កិលេសបរិនិព្វាន មានហើយលើពោធិបល្ល័ង្ក ;
- ខន្ធបរិនិព្វាន មានហើយក្នុងក្រុងកុសិនារា ;
- ធាតុបរិនិព្វាន នឹងមានក្នុងកាលអនាគត ។

ធាតុបរិនិព្វាន, ព្រះធាតុទាំងឡាយកាលមិនបានសក្ការៈ រាប់អានក្នុងទីនោះៗ ក៏ទៅកាន់កន្លែងដែលបានសក្ការៈបូជារាប់អាន ដោយកំលាំងអធិដ្ឋានព្រះពុទ្ធទាំងឡាយ ។ កាលកន្លងទៅ សក្ការៈបូជារាប់អានមិនមានសព្វហាន ។ ព្ធថា ក្នុងកាលសាសនាក្រោយទៀត ព្រះធាតុទាំងឡាយទៅប្រជុំក្នុងតាម្ពបណ្ណិទ្វីប នឹងទៅកាន់មហាចេតិយ ចេញពីនោះទៅកាន់រាជាយតនចេតិយក្នុងនាគទ្វីប ចេញពីនោះនឹងទៅកាន់មហាពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយនឹងមកអំពីនាគភពផង ទេវលោកផង ព្រហ្មលោកផង ទៅកាន់ពោធិបល្ល័ង្កដែរ ។ ព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃក៏មិនវិនាសក្នុងចន្លោះ ។ ព្រះធាតុទាំងឡាយ ប្រជុំនៅមហាពោធិបល្ល័ង្ក កាន់យកនូវពុទ្ធរូបផ្ទឹមនឹងពុទ្ធសរីរៈដែលគង់ឰដ៏ពោធិមណ្ឌៈ; មហាបុរិស.

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

លក្ខណៈ ៣២, អនុព្យញ្ជនៈ ៨០ ; ពន្លឺផ្សាយចេញ ១ព្យាមមានគ្រប់ទាំងអស់ ។ លំដាប់នោះ, ព្រះធាតុទាំងឡាយនឹងធ្វើបាដិហារ្យបញ្ចេញឆព្វណ្ណរង្សីដូចក្នុងថ្ងៃយមកបាដិហារ្យ ។ រស្មីទាំងនោះនឹងផ្សាយទៅអស់ ១ ម៉ឺនលោកធាតុ ។ ពួកមនុស្សមិនមានក្នុងទីនោះទេ ។ មានតែពួកទេវតា សន្និបាតក្នុង ១ម៉ឺនចក្រវាឡ ធ្វើនូវការុញ្ញភាពធំជាងក្នុងថ្ងៃបរិនិព្វាននៃព្រះទសពលថា « ព្រះទសពលបរិនិព្វានក្នុងថ្ងៃនេះ សាសនានឹងទុនថយក្នុងថ្ងៃនេះ, នេះជាបច្ឆិមទស្សន៍ នៃពួកយើង „ ។ លើកលែងតែអនាគាមីខីណាសវៈ, ពួកទេវតាដ៏សេសនឹងមិនអាចទ្រទ្រង់ដោយសភាពបាន ។ លំដាប់នោះ តេជោធាតុតាំងឡើងអំពីធាតុសរីរៈ ញុំាងសរីរៈនោះឲ្យដល់នូវអបណ្ណត្តិកភាព ។ អណ្តាតភ្លើងឡើងទៅដល់ព្រហ្មលោក ។ បើព្រះធាតុនៅសល់ប៉ុនគ្រាប់ស្ពៃ អណ្តាតភ្លើងនៅ ។ កាលបើព្រះធាតុទាំងឡាយដល់នូវបរិយាទាន, អណ្តាតភ្លើងនឹងដាច់សូន្យ ។ ព្រះធាតុទាំងឡាយសំដែងអានុភាពធំយ៉ាងនេះ ទើបបរិនិព្វាន ។

កាលនោះ ពួកទេវតា ដែលប្រជុំគ្នាធ្វើសក្ការៈបូជាដោយគ្រឿងក្រអូបប្រេងផ្កាទិព្វនឹងតូរ្យតន្ត្រីទិព្វជាដើម ដូចក្នុងថ្ងៃព្រះពុទ្ធទាំងឡាយធ្វើប្រទក្សិណថ្វាយបង្គំ ៣ ដងហើយពោលថា " បពិត្រព្រះមានជោគ យើងទាំងឡាយនឹងបានឃើញព្រះពុទ្ធទាំងឡាយត្រាស់ឯអនាគត „ ។

បរិយត្តិអន្តរធានជាប្រធាននៃអន្តរធានទាំង ៥ នេះ ព្រោះបរិយត្តិជាប្រមាណនៃសាសនដ្ឋិតិ (ការទ្រទ្រង់ពុទ្ធសាសនា ។)

ព្រះមហា អ៊ុក - អ៊ឹង

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# វគ្គទី ៦

## ចិត្តដឹកនាំលោក

(១)

## ចិត្តេន នីយតិ លោកោ

## លោកត្រូវចិត្តដឹកនាំ

អត្ថបទនេះ មានអត្ថាធិប្បាយជា ៣ បទ គឺអំពីលោក ១ បទ ចិត្ត១ បទ អាការដឹកនាំ ១ បទ ដូចតទៅនេះ :

## លោកគឺអ្វី ?

សភាវៈដែលកកើតមានឡើងហើយ មិនតាំងនូវដោយទៀងទាត់ តែងតែបែរឈមមុខទៅរកសេចក្តីវិនាសបាត់បង់ សូន្យទៅវិញ ក្នុងពេលណាមួយ ហៅថា លោក ។ លោកមានច្រើនជាអនេក តែបើបំប្រួញចុះមកមានត្រឹមតែ ៣ គឺសង្ខារលោក១ សត្តលោក១ ឱកាសលោក ១ ។

រូបធម៌អរូបធម៌ទាំងឡាយដែលកើតឡើង ដូចពួកសត្វទាំងអស់ដែលមានអត្តភាពតាំងនៅបានដោយសារអាហារក្តី នាមនិងរូបក្តី វេទនា ៣ យ៉ាង មានសុខវេទនាជាដើមក្តី អាហារ៤ យ៉ាងមានកវឡិង្ការាហារជាដើមក្តី អាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើម វិញ្ញាណដ្ឋិតិ ៧ មាននានត្តកាយ នានត្តសញ្ញី (ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាក៏

១ ធម្មបទ ខុទ្ទកនិកាយ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com



នៅរដ្ឋភោពាល ប្រទេសឥណ្ឌា តំកល់ព្រះសរីរធាតុ នៃព្រះសារីបុត្រ, ព្រះមោគ្គល្លាន

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ផ្សេងគ្នា ) ជាដើមក្តី លោកធម៌ ៨ យ៉ាងមានលាភៈនិងអលាភៈជាដើមក្តី សត្តាវាសៈ ៩ យ៉ាងមានវិញ្ញាណដ្ឋិតិ ៧ ជាដើមក្តី អាយតនៈ ១២ មានចក្ខាយតនៈនិងរូបាយតនៈជាដើមក្តី ធាតុ ១៨ យ៉ាងមានចក្ខុធាតុជាដើមក្តី ប៉ុណ្ណេះជាដើម ហៅថាសង្ខារលោក ប្រែថា លោក គឺសង្ខារ ដែលជានាទីខាងតាក់តែងឲ្យចំរើន-ឲ្យវិនាស ។

ពួកមនុស្ស ទាំងបុរស ទាំងស្ត្រី ពោះមានបុណ្យ ឬឥតបុណ្យ, មានកិលេសឬឥតកិលេស, មានប្រាជ្ញាឬឥតប្រាជ្ញា, ល្អឬអាក្រក់ក្តី ពួកអមនុស្ស មានទេវតា, មារព្រហ្ម, យក្សនិងគន្ធព្វជាដើមក្តី តែងអាស្រ័យនៅក្នុងលោកទាំងបី ។ ប្រភេទសត្វទាំងអស់នេះ រួមមកតែពាក្យមួយហៅថា សត្តលោក ប្រែថា លោក គឺពួកសត្វ ។

លោកទាំងមូលដូចជាភាជន៍សម្រាប់រងទ្រទ្រង់តៗគ្នា គឺខ្យល់ទ្រទឹក ៗ ទ្រដី ៗ ទ្រឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណ មានមនុស្សសត្វជាដើម និងអនុបាទិន្នកសង្ខារ គឺសង្ខារដែលឥតវិញ្ញាណ មានរុក្ខជាតិ, តិណជាតិ និងភ្នំជាដើម ឬ សំដៅយកផែនក្រវាឡទាំងមូល ឬ ក៏សំ-ដៅយកឱកាសដែលព្រះអាទិត្យ និងព្រះចន្ទដើរបំភ្លឺលោកអស់ទីត្រឹមណា ទីត្រឹមនោះហៅថា ឱកាសលោក ប្រែថា លោក គឺទីឱកាស ។ ពាក្យថា លោកនេះ ខេមរជនយើងច្រើននិយមរាប់អានថាជាពាក្យថ្លៃថ្នូរ ពាក្យគួរសម សម្រាប់ប្រើហៅមនុស្សអ្នកមានបុណ្យយសស័ក្តិអំណាច ឬហៅព្រះសង្ឃផងទៅ តែបើតាមពិតពាក្យថា លោកនេះ ជាពាក្យសាធារណៈ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

អាចហៅបានគ្រប់សត្វនឹងសង្ខារទាំងអស់ ។ អ្នកប្រាជ្ញខាងធម្មសាស្ត្រ មានព្រះពុទ្ធជាដើម តែងប្រមូលយកសង្ខារទាំងមានវិញ្ញាណទាំងឥតវិញ្ញាណ ហៅថា លោក ព្រោះយល់ថាលោកនេះ ដែលកកើតឡើងជារូបរាងហើយ មិនដែលតាំងនៅទៀងទាត់ទេ រមែងតែចម្រើនក្នុងខាងដើម ប្រែប្រួលក្នុងវេលាកណ្ដាល, ហើយត្រូវបាត់បង់ទៅវិញនៅទីបំផុត ។

ន័យមួយទៀត, ពាក្យដែលយើងនិយមប្រើហៅឈ្មោះសត្វ នឹងសង្ខារសព្វថ្ងៃនេះ ដូចពាក្យហៅថាមនុស្ស សត្វ ប្រុស ស្រី ឈើ ភ្នំ ថ្ម ។ល។ សុទ្ធតែជាពាក្យលោកវោហារទាំងអស់ គឺជាសំដីនិយាយហៅដោយការសន្មតិទៅតាមភេទ លក្ខណៈ អាការ លំនាំរបស់សត្វនឹងសង្ខារ ដែលផ្សេងគ្នាប៉ុណ្ណោះ មិនមែនជាសំដីពិតទៅតាមផ្លូវបរមត្ថ-សាស្ត្រទេ, បើនិយាយហៅតាមផ្លូវបរមត្ថសាស្ត្រវិញ ទើបជាពាក្យពិត ។ បើយើងត្រូវការរិះរកសេចក្ដីពិតក្នុងរឿងនេះ ត្រូវយកមនុស្សម្នាក់មកឲ្យនៅក្នុងទីចំពោះមុខ ហើយយើងពិចារណាវែករកពាក្យដែលគេហៅថាមនុស្សនោះមុខជានឹងរកពុំឃើញឡើយ គឺឃើញតែធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ទាំងអស់, បើដូច្នេះ តើពាក្យថា មនុស្សប្រុសស្រី នៅត្រង់ណា ? ឯសង្ខារទាំងពួងក៏ដូច្នោះដែរ ឧទាហរណ៍ដូចពាក្យដែលយើងហៅថាផ្ទះ ថាសាលា បើយើងពិចារណាវែករកទៅឃើញតែសសរផ្ដាង ផ្ទាន បង្កង់ ដៃវណែង ។ល។ មានឈ្មោះដោយឡែក ៗ ពីគ្នាទាំងអស់, បើដូច្នេះតើពាក្យថាផ្ទះ ថាសាលា នោះនៅត្រង់ណា ? ហេតុនោះ

ពាក្យថាមនុស្សសត្វស្រីប្រុសផ្ទះសាលា ។ល។ ជាពាក្យហៅដោយសម្មតិតាមលោកវោហារ មិនមែនជាពាក្យពិតតាមផ្លូវបរមត្ថសាស្ត្រទេ ។ វត្ថុជាតុដែលមានឈ្មោះគេហៅដោយពាក្យជាលោកវោហារក្តី ដោយពាក្យបរមត្ថក្តី រួមមកហៅថា លោក ៗ ដូចគ្នាទាំងអស់ ។

ព្រោះហេតុនោះ លោកទាំង ៣ ដូចបានពណ៌នាមកក្នុងខាងលើ គឺសង្ខារលោក ជាអ្នកកាន់តំណែងខាងបង្កបង្កើតសត្វលោកនិងឱកាស-លោក, ឱកាសលោកដែលកើតឡើងដោយអំណាចសង្ខារលោកនោះ ជាអ្នកកាន់តំណែងខាងស្នូលទ្រសត្វលោក ឬជាលំនៅនៃសត្វលោក ៗ ដែលកើតឡើងអាស្រ័យសង្ខារលោក និងឱកាសលោកជាបង្អែកហើយ ទើបញ៉ាំងជីវភាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមលោកនិយម ៗ ឯលោកដែលខ្ញុំប៉ុនប៉ងនឹងលើកយកមកនិយាយក្នុងផ្នែកអត្ថបទនេះ សំដៅយកសត្វលោក គឺប្រជាជនទូទៅគ្រប់ប្រភេទ ។ ប្រជាជនដែលបានទទួលអំណោយរបស់អំពើ គឺ សេចក្តីល្អ អាក្រក់, សុខទុក្ខ, បុណ្យបាប, គុណទោស, ខុសត្រូវជាដើម អាស្រ័យនូវចិត្តជាប្រធាន ។

## ចិត្តគឺអ្វី ?

បណ្តាពួកសត្វទាំងអស់ក្នុងលោកនេះ មិនមានពួកសត្វណាមួយប្រសើរជាងមនុស្ស, ក្នុងគ្រោងកាយរបស់មនុស្សទាំងមូល មិនមានធម្ម-ជាតអ្វីប្រសើរជាងចិត្ត ។ ធម្មជាតជានាមធម៌មួយយ៉ាងដែលសម្រេចខាងការគិត គឺហទយរូប (បេះដូង) ដែលជាបន្ទប់មួយមានទឹកដក់នៅ

AngkorLink.com CambodiaBuddhist.org ABCCambodia.com



អាចបញ្ចេញចំហាយគឺសេចក្តីដឹង សេចក្តីត្រិះរិះផ្សេង ៗ ជាទីនាំឲ្យកើតវិញ្ញាណនឹងសតិបញ្ញាដែលអាចធ្វើឲ្យរូបកាយមានចលនា (កម្រើក) គ្រប់ឥរិយាបថទៅបានហៅថា ចិត្ត ។ ចិត្តនេះក៏គឺវិញ្ញាណហ្នឹងឯងដែលវិចិត្រដោយកម្មវត្ថុ អារម្មណ៍នឹងកិរិយាជាដើម ឋិតនៅក្នុងមហាភូតរូបគឺគ្រោងកាយរបស់មនុស្ស, ឥតមានសរីរៈខ្លួនប្រាណពណ៌សម្បុរសណ្ឋានទ្រង់ទ្រាយអ្វីជាគ្រឿងប្រាកដសោះទេ ប៉ុន្តែជាធម្មជាតសំខាន់បំផុត អាចនឹងគិតត្រិះរិះរេករែក ឬទទួលយកអារម្មណ៍ផ្សេង ៗ មានរូបារម្មណ៍ជាដើមបាន, អាចស្ទុះត្រាច់ទៅតែម្នាក់ឯងកាន់ទីជិតទីឆ្ងាយបាន ដោយដំណើរដ៏រហ័សក្រៃលែងគ្មានអ្វីប្រៀបប្រដូច, យើងនិយមយល់ថា បណ្តារបស់ដែលមានក្នុងលោក គ្មានរបស់អ្វីលឿនរហ័សក្រៃលែងជាងកម្លាំងអគ្គិសនីទេ សំទុះកម្លាំងអគ្គិសនីនេះលឿនរហ័សក៏ពិតមែន ប៉ុន្តែនៅមិនទាន់ស្មើនឹងសំទុះរបស់ចិត្តឡើយ, ចិត្តនេះមានល្បឿនរហ័សក្រៃលែងជាងកម្លាំងអគ្គិសនីទៅទៀត ។ ចិត្តនេះ បើតាមប្រក្រតីដើមដែលមិនមានឧប-ក្កិលេសអ្វីធ្វើឲ្យវឹកវរទេ, មានពន្លឺថ្លាស្អាតល្អណាស់ ទាំងអាចធ្វើឥន្ទ្រិយគឺរាងកាយទាំងមូល មានទឹកមុខ សាច់ឈាម ពណ៌សម្បុរជាដើមរបស់ខ្លួនឲ្យភ្លឺថ្លាស្រស់បស់ផងដែរ, តួយ៉ាងដូចកូនក្មេងដែលនៅតូច ៗ ដរាបណាកិលេសគ្រឿងសៅហ្មងអាក្រក់ មិនទាន់ដុះចំរើនកើតមានឡើងក្នុងសន្តានចិត្តរបស់វាទេ ដរាបនោះ សាច់ឈាមសម្បុររបស់ក្មេងនោះ ឃើញនៅភ្លឺថ្លាស្អាតស្រស់បស់ល្អ ព្រោះចិត្តថ្លាស្អាតនោះឯងជាហេតុ ឬដូចបុគ្គល

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ដែលបានសម្រេចគុណវិសេសជាន់ខ្ពស់ លោកមានទឹកមុខសាច់ឈាម ឡើងថ្លាស្អាតស្រស់បស់ល្អជាងកាលនៅជាបុថុជ្ជន, រឿងនេះយើងមិនបានឃើញផ្ទាល់ដោយចក្ខុទេ តែបានដឹងតាមសេចក្តីតំណាលក្នុងគម្ពីរផ្សេងៗថា បុគ្គលដែលប្រតិបត្តិអប់រំជុះខាត់ចិត្តឲ្យស្អាតចាកកិលេសគឺ រាគៈ ទោសៈ មោហៈ គ្រឿងសៅហ្មងអស់ពីសន្តានចិត្តហើយ ចិត្តរបស់លោកក៏ឡើងភ្លឺថ្លាស្អាត ទាំងសាច់ឈាមសម្បុរកាយរបស់លោកក៏ឡើងភ្លឺថ្លាស្អាតផងដែរ ទាំងឥន្ទ្រិយរបស់លោកសោតទៀត ក៏ស្រគត់ស្រគំរមទម្យល្អ គួរឲ្យអ្នកដែលបានជួបប្រទះឃើញលោកមានសេចក្តីជ្រះថ្លាក្រៃលែង ។

ចិត្តនេះ ជាធម្មជាតភ្លឺថ្លាស្អាតល្អពិតមែន ប៉ុន្តែដែលទៅជាងងឹតស្រអាប់បាត់ពន្លឺថ្លាស្អាតទៅវិញនោះ ក៏ដោយអំណាចឧបក្កិលេសមានអភិជ្ឈានិងទោមនស្សជាដើម ចូលមកគ្របសង្កត់រួបរឹតញាំញីជានិច្ច ធ្វើឲ្យទៅជាចិត្តវិបរិតប្រែប្រួលខុសអំពីប្រក្រតីដើម ទាំងសាច់ឈាមសម្បុររបស់បុគ្គលនោះសោតទៀត ក៏ទៅជាគ្រោតគ្រាតស្រអាប់អាក្រក់ទៅតាមផងដែរ ដូចបុគ្គលដែលកំពុងមានចិត្តសោមនស្ស សាច់ឈាមសម្បុររបស់បុគ្គលនោះ ក៏ឡើងភ្លឺថ្លាល្អ, ឯបុគ្គលដែលកំពុងមានចិត្តទោមនស្ស សាច់ឈាមសម្បុររបស់បុគ្គលនោះ ក៏ប្រែជាគ្រោតគ្រាតជាំស្រអាប់អាក្រក់ទៅតាមដែរ ព្រោះតែចិត្តដែលថ្លាស្អាតនិងចិត្តដែលសៅហ្មងនោះឯងជាហេតុ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



# អាការរបស់ចិត្ត

ចិត្តជាធម្មជាតក្រឡិបក្រឡុបពិបាករក្សាជាទីបំផុត ជាងរបស់អ្វីៗ ទាំងអស់ ព្រោះចិត្តនេះ មានកលមាយាចេញទៅជាអាការច្រើនយ៉ាងៗ ក្នុងទីនេះ សូមអធិប្បាយដោយសរុបចំពោះតែអាការរបស់ចិត្ត ៤ យ៉ាង គឺចិត្តនេះតែងត្រាច់ស្ទុះស្ទាទ្រេទ្រាវះវើមការរកអារម្មណ៍ដែលមិនធ្លាប់មានឬអារម្មណ៍ដែលមាននៅក្នុងអនាគតខាងមុខៗ នោះ ១ ចិត្តនេះតែងអន្ទះ-សាទ្រេទ្រាទៅមកជានិច្ច មិនចេះនៅនឹងស្ងៀម ទាំងដំណើរដែលស្ទុះចេញទៅនោះសោតទៀតក៏ទៅតែម្នាក់ៗឯង មានសន្ទុះលឿនរហ័សក្រៃលែងគ្មានអ្វីប្រៀបដូចបាន ១ ចិត្តដែលស្ទុះស្ទាទៅមកដោយរហ័សស្វែងរកអារម្មណ៍ក្នុងទិសផ្សេងៗ នោះ ក៏មិនប្រាកដដល់មំសចក្ខុរបស់ខ្លួនឬរបស់អ្នកដទៃ ១ ចិត្តនេះតែងជ្រកសម្ងំសម្រាកអាស្រ័យនៅក្នុងគុហាគឺមហាភូតរូបបួន ១ ។

ចិត្តនេះ ជាធម្មជាតល្អិតឆ្មារយ៉ាងក្រៃលែង ទាំងកើត ទាំងរលត់ក៏រហ័សហួសវិស័យនឹងប្រដូច នឹងឃើញបាន ទាំងការទូន្មានរក្សាចិត្តនោះឲ្យតាំងនៅនឹងជាប្រក្រតីក៏ក្រណាស់ លុះតែអ្នកប្រាជ្ញខាងចិត្ត-សាស្ត្រ ធ្លាប់សិក្សាអប់រំ ធ្លាប់រិះគិតពិនិត្យពិចារណាខាងផ្លូវចិត្ត ទើបអាចឃុំគ្រងរក្សាការពារចិត្ត ឲ្យតាំងនៅនឹងតាមបំណងខ្លួនបាន សមដូចពុទ្ធភាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា :

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ

ចិត្តនេះ ជាធម្មជាតល្អិតឆ្មារណាស់ ផុតវិស័យបុគ្គលនឹងឃើញបានដោយងាយ តែងធ្លាក់ចុះទៅក្នុងអារម្មណ៍ណាមួយតាមបំណងរបស់ខ្លួនដោយឥតបើគិត ឥតដឹងប្រមាណខ្លួន គឺមិនដឹងទីដែលត្រូវបាន នឹងទីដែលមិនត្រូវបាន, មិនដឹងទីដែលគួរ នឹងទីដែលមិនគួរ, មិនបេះគិតថែមើលជាតិ គោត្រ ត្រកូល នឹងវ័យរបស់ខ្លួន ឬរបស់អ្នកដទៃទេ បេះតែតក្សួលជ្រកមមកនៅសព្វកន្លែងឥតមានចន្លោះត្រង់ណាឡើយ ៗ បុគ្គលអន្ធពាលមិនអាចរក្សាចិត្តរបស់ខ្លួនបានទេ រមែងដល់នូវសេចក្ដីវិនាសព្រោះតែធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃចិត្ត, ឯបណ្ឌិតមិនធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃចិត្តទេ គឺលោកធ្វើចិត្តឲ្យលុះក្នុងអំណាចនៃខ្លួនវិញ ទើបរក្សាចិត្តបែបនោះបាន ព្រោះថាចិត្តដែលគេគ្រប់គ្រងឲ្យនៅក្នុងអំណាចនៃខ្លួនបានហើយ រមែងនាំសុខមកប្រគល់ឲ្យ ៗ

## គួរធ្វើចិត្តឲ្យលុះក្នុងអំណាចខ្លួន

ពិតមែន, ចិត្តនេះជាធម្មជាតតែងតម្រើកញាប់ញ័រ ឃ្វេងឃ្វាង ស្ទុះស្ទាទ្ធាតក្សួលជ្រកទៅរកវិសភាគារម្មណ៍មានរូបជាដើម ពិបាកនឹងរក្សា ពិបាកនឹងហាមឃាត់ពត់តម្រង់ឲ្យត្រង់ឬឲ្យស្ងប់ស្ងៀម សូម្បីតែមួយស្របក់ក៏មិនងាយនឹងធ្វើបាន, ដូចកូនក្មេងដែលនៅតូចៗ មិនគាប់នឹងធ្វើវាឲ្យនៅ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្ងៀម តែក្នុងឥរិយាបថមួយៗបាន, ពុំនោះសោត ដូចគោល្មោកស៊ីសំណាបសំទូងនៅក្នុងទីចង្អៀតតាន់ដោយសំណាបសំទូង, ពិបាកម្ចាស់នឹងការពារពាំឲ្យនៅនឹងតែកន្លែងមួយបាន ក៏ដូច្នោះដែរ ៗ ប៉ុន្តែចិត្តនេះ បើទុកជាពិបាកនឹងថែរក្សាដូចពណ៌នាមកហើយនោះក៏ដោយ គង់តែមានបណ្ឌិតអាចធ្វើចិត្តឲ្យលុះក្នុងអំណាចនៃខ្លួនដោយគ្រឿងពត់ផ្សេងៗ ដរាបដល់ត្រង់ស្រួលទៅបាន ប្រៀបដូចជាងព្រួញ យកឈើឬស្សីមួយកំណាត់ មកបកសំបកមកពុះល្អសហើយ លាបទឹកបាយឬប្រេងឲ្យជោកហើយយកទៅពេលផ្អើរលើរងើកភ្លើងឲ្យទន់សាច់ ហើយយកទៅសឹកក្នុងឃ្នាបតាមពត់តម្រង់ឲ្យល្អមិនឲ្យមានវៀចកោង ឲ្យគួរដល់ការបាញ់ សូម្បីបាញ់រោមសត្វដែលជារបស់ល្អិតឆ្មារ ក៏អាចបាញ់បាន, លុះធ្វើបានការហើយ ក៏យកសិល្បៈនោះទៅសំដែងបង្ហាញចំពោះព្រះមហាក្សត្រិយ៍និងរាជមហាមាត្យឲ្យជ្រាបថា ខ្លួនជាអ្នកបាញ់មានថ្វីដៃស្ទាត់ជំនាញមែន ក៏រមែងបានលាភសក្ការៈព្រមទាំងសេចក្ដីកប់អានជាច្រើន សេចក្ដីនេះឧបមាយ៉ាងណា; បុគ្គលអ្នកមានប្រាជ្ញារមែងចាប់យកចិត្តដែលមានសភាពដូច្នោះមកបកសំបកគឺកិលេសដ៏គ្រោតគ្រាតឲ្យប្រាសចាកសន្ដានដោយអំណាចធុតង្គ ហើយលាបទឹកបាយឬប្រេងគឺសទ្ធា (ជំនឿ) រួចយកទៅពេលភ្លើងគឺវីរិយៈ (សេចក្ដីព្យាយាម) ដែលប្រកបក្នុងកាយនិងចិត្ត ហើយទៅសឹកតាមក្នុងឃ្នាប គឺ សមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាន, ពត់តម្រង់ឲ្យទៅជាចិត្តត្រង់ មិនឲ្យមានវៀចកោងមិនឲ្យមានពុតកំណាច, លុះពត់សម្រួលបានការហើយ ក៏ផ្ចង់ចិត្តឡើងរំពឹងពិចារណាសង្ខារទាំងអស់ដោយញាណ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ឲ្យតាល់តែឃើញថាជាត្រៃលក្ខណ៍ពិតៗ ហើយបំបែកទំលាយគំនរអវិជ្ជា សេចក្ដីងងឹតល្ងង់ខ្លៅវង្វេងក័ន្ដប្រឡំឲ្យខ្ចាត់ចេញចាកសន្តានចិត្តហើយ ទាញយកគុណវិសេស គឺវិជ្ជា៣អភិញ្ញា ៦, លោកុត្តរធម៌៩ ឲ្យតាំងនៅក្នុងកណ្ដាប់ដៃរបស់ខ្លួនបានហើយ រមែងបានដល់នូវភាពជាអគ្គទក្ខិណេយ្យ-បុគ្គលប្រសើរក្នុងលោក ជាអ្នកគួរដល់គារវភាពនៃសមានភាពរបស់ទេវតានិងមនុស្សទាំងឡាយខ្លះទៅ ក៏មាន។បរមេយ្យដូច្នោះឯង ។ ព្រោះហេតុនោះ ធម្មតាចិត្តកាលបើឃ្លាតអំពីការសេពគប់បណ្ឌិត ឃ្លាតអំពីការសិក្សាអប់រំថ្មមិនមានសមថធម៌ជាឃ្នាបជាទីពំនាក់ទេ តែងតែឃ្វេងឃ្វាង ត្រឡប់ក្លាយទៅក្នុងផ្លូវវង្វេងនាំឲ្យខូចខុសគន្លងធម៌ក៏មាន, តែងរវើរវាយបម្រាស់ទទៀលទៅរកអារម្មណ៍ផ្សេងៗ ខុសទំនងក៏មាន,តែងតែអន្ទះសារន្ទេះន្ទាប៉ុលរប៉ិចជានិច្ច ឥតដែលបេះនៅនឹងស្ងប់ស្ងៀមម្ដងណាឡើយ; ចិត្តនេះលោកប្រៀបថា មានអាការដូចផ្លែត្រឡាចដែលគេដាក់លើខ្នងសេះ ឬដូចបង្គោលដែលគេបោះលើគំនរអង្កាម ឬក៏ដូចផ្កាកុម្ពុដែលគេដាក់លើក្បាលថ្កែក, ពុំនោះសោតដូចអាការរបស់ស្វា ឬកូនក្មេងតូច ដូច្នោះឯង ។

## បំណង់របស់ចិត្ត

បំណង់របស់ចិត្ត ចំពោះអារម្មណ៍ខាងក្នុងឬខាងក្រៅមិនមានទីបំផុតបប់ទេ, ចិត្តនេះតែងស្រេកឃ្លានជានិច្ចចំពោះអាហារ គឺអកុសលធម៌ទាំងពួង បណ្ដាអកុសលធម៌ទាំងអស់ មាននីវរណធម៌ ៥ ជាដើម ជាអាហាររបស់ចិត្តខាងអាក្រក់, ចំណែកខាងកុសលធម៌មានបុញ្ញកិរិយាវត្ថុ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ទីនសតិប្បដ្ឋាន ៤ ជាដើមជាអាហាររបស់ចិត្តខាងល្អ ដូចគ្នានឹងភោជនា-ហារសម្រាប់រូបកាយដែរ ។ ប៉ុន្តែធម្មតាចិត្តរបស់មនុស្សបុថុជ្ជន ច្រើនតែមានចំណូលលោភជ្រុលទៅខាងវត្ថុកាមនិងកិលេសកាម ដោយមិនបាច់បង្ខំ ព្រោះកាមទាំងនោះជាកំណើតជាលំនៅរបស់ចិត្តដែលធ្លាប់តែប្រា-ស្រ័យមកស្រាប់, បើគេចាប់ទាញចិត្តនោះលើកដាក់ក្នុងធម៌ដែលជាប្រតិ-បក្សនឹងកាមនោះកាលណា, ចិត្តនេះក៏គ្រាញមិនចង់នៅទេ តែងតែបម្រាស់ទទៀលស្ទុះទៅរកកាមគុណជាលំនៅរបស់ខ្លួនដដែលវិញ កាលនោះ ដូចពួកសត្វវារិជាតមានត្រីជាដើម ជាសត្វកើតក្នុងទឹក មានទឹកជាលំនៅ កាលបើគេចាប់វា លើកស្រង់ឡើងផុតពីទឹកមកដាក់លើគោក, ត្រីនោះតែងបម្រាស់ទទៀលបែរមុខទៅរកទឹកវិញ; ព្រោះអ្វី? ព្រោះទឹកនោះ ជាកំណើត ជាលំនៅរបស់ត្រី វាធ្លាប់ប្រាស្រ័យមកស្រាប់ ឬដូចពួកទីឃជាតិមានពស់ជាដើម ធម្មតាសត្វពស់តែងចូលចិត្តនៅត្រង់ទីកៀនកោះទីបង្អៀត ទីដែលមានព្រៃស៊ុបទ្រុប បើទុកជាគេចាប់វាយកមកដាក់ឲ្យនៅទីវាលទីស្រឡះ ពស់នោះមិនពេញចិត្ត មិនដឹងនៅទេ តែងតែផាកវេលូនត្បូលសសុលរុកទៅរកទីកៀនកោះ ទីស៊ុបទ្រុបនោះវិញ ព្រោះទីកៀនកោះទីស៊ុបទ្រុបនោះជាលំនៅ ជាកំណើតរបស់ពស់, ជាទីដែលវាធ្លាប់ជ្រក ធ្លាប់ប្រាស្រ័យជាប់ក្នុងចិត្តតាំងពីកំណើតមក ជាហេតុនាំឲ្យពស់នោះមិនដាច់អាល័យ, សេចក្តីប្រៀបទាំងនេះយ៉ាងណាមិញ; ធម្មតាចិត្តរបស់មនុស្ស សូម្បីកំពុងធ្វើការអ្វីក៏ គិតពីរឿងអ្វីក៏ និយាយសំណេះ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សំណាលពីរឿងផ្សេង ៗ ក្តី ច្រៀងរាំគុកកំប្លែងក្តី សូម្បីប៉ះទង្គិចនឹងអ្វីមួយ ហើយភ្ញាក់ផ្អើលស្មាត់ក្តី ច្រើនតែប្រព្រឹត្តទន់រអិលសសៀរទៅរកតែគ្រឿងកាម, ជាប់ស្អិតតែនឹងគ្រឿងកាម ជ្រកសម្ងំនៅតែក្នុងគ្រឿងកាម បើទុកជាទាញចិត្តនោះឲ្យឃ្លាកឃ្លាតចេញពីគ្រឿងកាមនោះមកដោយពេលខ្លះ ៗ ក៏មិនបានយូរប៉ុន្មានដែរ គង់តែស្ទុះបម្រាស់ទទៀលទៅជ្រកសម្ងំដេកត្រាំនៅក្នុងគ្រឿងកាមនោះដដែលវិញមិនដាច់អាល័យ, ព្រោះហេតុអ្វី ? ព្រោះកំណើតរបស់មនុស្សកើតមកអំពីកាម ធ្លាប់ដេកត្រាំនៅក្នុងកាម មានកាមជាចំណី មានកាមជាលំនៅ ក៏យ៉ាងនោះដែរ; ព្រោះហេតុនោះ បានជាការទូន្មានចិត្តឲ្យលះបំណងក្នុងកាមចេញបានដោយកម្រពេកណាស់ លុះតែបណ្ឌិតអ្នកមានប្រាជ្ញា ធ្លាប់ស្គាល់កលមាយារបស់ចិត្តដោយជាក់ច្បាស់ ទើបអាចប្រើប្រាជ្ញាទូន្មានប្រៀនប្រដៅពត់តម្រង់ចិត្តឲ្យមានបែបបទទៅបាន ។

## លោកត្រូវចិត្តដឹកនាំដូចម្តេច ?

ពាក្យក្នុងមាតិកានេះ ត្រូវចែកជា ៣ បទ គឺលោក ១ បទ ចិត្ត ១ បទ ដឹកនាំ ១បទ ។ ត្រង់ពាក្យថា « លោក » នឹងពាក្យថា « ចិត្ត » បានអធិប្បាយខ្លះមកហើយ, នៅតែពាក្យថា «ដឹកនាំ» ពុំទាន់អធិប្បាយ សូមអធិប្បាយដោយសង្ខេបដូចតទៅនេះ

## ចិត្តដឹកនាំសត្វលោក

មនុស្សម្នាក់ៗដែលនៅក្នុងឱកាសលោក ហៅថា « សត្វលោក »

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មានចិត្តជានាមធម៌ដ៏ត្រកាលគ្រប់គ្រង សម្រាប់ដឹកនាំកាយជារូបធម៌ឲ្យប្រព្រឹត្តទៅដោយអាការផ្សេងៗមានអាការជោគ ថ្លៃ ទាប ខ្ពស់ ខូច ជា អាក្រក់ ល្អជាដើម ។ ខាងអាការជោគ ទាប ខូច អាក្រក់ មានដឹកនាំឲ្យខ្ជិលច្រអូស មិនឲ្យរៀនសូត្រ មិនឲ្យធ្វើការងារជាប្រយោជន៍ផ្សេងៗ ព្រមទាំងដឹកនាំឲ្យប្រព្រឹត្តអាក្រក់ផ្សេងៗបានសម្លាប់លួចប្លន់ ជាដើមទៀតផង ចួនកាលដឹកនាំផ្លូវដល់ទៅសម្លាប់មាតាបិតារបស់ខ្លួនក៏មាន (ព្រោះអាស្រ័យលោភៈ ទោសៈ មោហៈ) ។ ខាងអាការថ្លៃ ខ្ពស់ ជា ល្អ មានដឹកនាំឲ្យខំសង្វាត់រៀនសូត្រវិជ្ជាការផ្លូវលោកផ្លូវធម៌ ឲ្យធ្វើការងារជាប្រយោជន៍ដល់ខ្លួននឹងប្រទេសជាតិ ឲ្យធ្វើទានរក្សាសីលជាដើម រហូតដល់ដឹកនាំឲ្យចម្រើនធម៌លះកិលេសឲ្យបានសម្រេចមគ្គផលនិព្វានជាទីបំផុត (ព្រោះអាស្រ័យអលោភៈ អទោសៈ អមោហៈ) ។ រួមសេចក្ដីថា សត្វលោកនឹងបានសុខឬទុក្ខ ក្នុងលោកនេះ នឹងឡើងសួគ៌ ឬចុះនរកក្នុងលោកខាងមុខ ឬក៏នឹងសម្រេចព្រះនិព្វានជាទីបំផុតលោកបានក៏ព្រោះតែចិត្តដឹកនាំ ។

ឧទាហរណ៍ក្នុងសម័យពុទ្ធកាល ចំពោះអ្នកដែលលុះតាមអំណាចចិត្តដឹកនាំប្រកបដោយអាការជោគ ទាប ខូច អាក្រក់ ដូចទេវទត្តដែលបួសតាមព្រះសម្មាសម្ពុទ្ធ ប៉ុន្តែត្រឡប់ជាព្យាយាមសម្លាប់ព្រះអង្គដោយឧបាយផ្សេងៗ មានប្រមៀលថ្មពីលើភ្នំគិជ្ឈកូដទម្លាក់លើព្រះអង្គធ្វើព្រះពុទ្ធបាទឲ្យពុះពងព្រះលោហិតដែលហៅថា ធ្វើពុទ្ធលោហិតុប្បាទ ជាអនន្តរិយកម្ម លុះស្លាប់ទៅៗ កើតក្នុងអវិចិមហានរក នឹងដូចព្រះបាទអជាតសត្រូវដែល

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សេពគប់នឹងទេវទត្តបាន ធ្វើឃាតព្រះបាទពិម្ពិសារជាព្រះបិតា លុះទ្រង់អស់ព្រះជន្មទៅៗកើតក្នុងលោហកុម្ភីនរក ។ ខាងអ្នកដែលលុះតាមអំណាចចិត្តដឹកនាំប្រកបដោយអាការថ្លៃ ខ្ពស់ ជា ល្អ ក្នុងសម័យពុទ្ធកាលដែលជាសម័យចិត្តនិយម គឺសម័យដែលមនុស្សគ្រប់អាទរការហាត់ពត់ចិត្តជាធំ គេព្យាយាមហ្វឹកហ្វឺនចិត្តឲ្យដល់កម្រិតជាចិត្តខ្ពស់ឯក, ចិត្តដែលគេហ្វឹកហ្វឺនល្អហើយអាចឲ្យគេបានសម្រេចគុណផលដល់ថ្នាក់ខ្ពស់បំផុត គឺសម្រេចអរហត្តបដិសម្ភិទា ជាព្រះខីណាស្រពប្រកបដោយឫទ្ធិដូចព្រះមហាមោគ្គល្លានជាទុតិយសាវ័កនៃព្រះសម្ពុទ្ធជាដើម ។ ចិត្តជាធម្មជាតដ៏ត្រកាលអាចបង្វិលសត្វលោកឲ្យវិលទៅរកសេចក្តីចម្រើនក៏មាន ទៅរកសេចក្តីវិនាសក៏មាន ដូចពណ៌នាមកដោយសង្ខេបនេះ ។

ព្រោះហេតុនេះបានជាព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទេសនាដូចន័យដែលតាំងទុកជាមាតិកាខាងដើមបំផុតថា « ចិត្តេន នីយតិ លោកោ លោកត្រូវចិត្តដឹកនាំ» គឺថា «ចិត្តដឹកនាំសត្វលោក» នុ៎ះឯង ។

## ចិត្តដឹកនាំឱកាសលោក

ចក្រវាឡមួយៗ ដែលជាទីប្រជុំធាតុទាំងពួងមានដីទឹកភ្លើងខ្យល់ជាដើម ជាលំនៅរបស់សត្វលោកហៅថា "ឱកាសលោក" ជាលោកមួយៗពុំមានចិត្តគ្រប់គ្រង តែងទន់ទោរទៅតាមចិត្តគំនិតរបស់សត្វលោក គេចង់ដឹកនាំចង់បង្វិលឲ្យទៅជាយ៉ាងណា ក៏បេះតែទន់ទៅតាមគេយ៉ាងនោះ ដូចក្រមួនត្រូវថ្ងៃ បេះតែវិលដូចកង្ហារត្រូវខ្យល់ គឺស្រេចតែចិត្ត

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



គេត្រូវការ, បានសេចក្ដីថាឱកាសលោក គឺផែនទឹកផែនដី ស្រុកទេស ក្នុងកាលជាអតីតក្ដី បច្ចុប្បន្នក្ដី អនាគតក្ដី នឹងបានចម្រើនឬបានវិនាស ដូចម្ដេចៗ ក៏ស្រេចតែចិត្តគំនិតរបស់ពលរដ្ឋនៃប្រទេសនោះៗ គេចាត់ចែង,ឧទាហរណ៍ដូចក្នុងសម័យបច្ចុប្បន្ននេះ ដែលជាសម័យ សម្ភារនិយម គឺសម័យមនុស្សរាប់អានគ្រឿងសម្ភារៈដ៏ប្រណីតៗ បើគេចូលចិត្តវត្ថុណា គេក៏ខំគិតរិះរករៀនខាងផ្លូវវិទ្យាសាស្ត្រ ហើយគេប្រឹងធ្វើវត្ថុនោះឡើង ដើម្បីជាគ្រឿងប្រើប្រាស់គ្រឿងបរិភោគគ្រឿងមើលគ្រឿងស្ដាប់ ច្រើនមុខ ច្រើនបែប ជាអនេករាប់មិនអស់ ដូចគ្រឿងចក្រ គ្រឿងយន្ត មានរថយន្ត វិទ្យុ វិទ្យុទូរទស្សន៍ជាដើម សម្រាប់មនុស្សប្រើប្រាស់តាមត្រូវការជាសាធារណៈទូទៅ ។

និយាយដោយខ្លី សម័យបច្ចុប្បន្ននេះ គេអាចធ្វើលោហធាតុគ្រឿងធ្ងន់ឲ្យទៅជាស្រាលឲ្យហោះហើរដើរនាផ្ទៃអាកាស លើផែនដី លើផ្ទៃទឹក ឲ្យមុជជ្រែកដីជ្រែកទឹក ដឹកនាំសម្ភារៈនឹងមនុស្សច្រើននាក់ឲ្យធ្វើគមនាគមន៍ជុំវិញលោកបាន ។ល។ ជំនួសសម័យពុទ្ធកាលដែលមានមនុស្សចេះហោះហើរដើរនាអាកាសផ្ទាល់ខ្លួនមួយរូបៗ ។

បើយើងយកព្រឹត្តិការណ៍របស់មនុស្សសម័យពុទ្ធកាលមកជំណាលប្រាប់មនុស្សសម័យបច្ចុប្បន្នថា «សម័យពុទ្ធកាលលោកដែលបានហ្វឹក-ហ្វឺនចិត្តដល់កម្រិតជាចិត្តខ្ពស់ឯក លោកចេះហោះ», ហើយបើមនុស្សបច្ចុប្បន្នគេមិនជឿព្រោះគេមិនបានឃើញជាក់នឹងភ្នែកគេ នោះយើងគប្បី

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



សួរបញ្ចាក់គេវិញថា « ប្រសិនបើយើងកើតក្នុងសម័យពុទ្ធកាលដែលពេលនោះជាសម័យចិត្តនិយមដែលមិនទាន់ចេះហោះនៅឡើយ ហើយបើពេលនោះមាននរណាគេប្រាប់ថា ដល់មកសម័យយើងនេះដែកចេះហោះហើរដើរឯអាកាសបាន តើយើងជឿទេ ?» , ថាយើងមិនជឿដែរ ព្រោះយើងមិនបានឃើញនឹងភ្នែក ; ប៉ុន្តែដល់មកសម័យនេះយើងបានឃើញនឹងភ្នែក យើងក៏ជឿថា មានដែកចេះហោះមែន ព្រោះជាសម័យសម្ភារនិយម ចិត្តរបស់មនុស្សសម័យនេះគេរិះគិតដល់កំរិតមែនទែនទៅ គេអាចប្រឌិដ្ឋឲ្យដែកហោះហើរដើរនាអាកាសជ្រែកទឹកជ្រែកដីបានជាប្រាកដ ។

ដូច្នេះ យើងគប្បីយល់ថាសម័យណាក៏ដោយឲ្យតែចិត្តសត្វលោកដឹកនាំទៅយ៉ាងណា , ឱកាសលោកក៏ទន់ទៅតាមគេយ៉ាងនោះ ។

ព្រោះហេតុនេះ ទើបគួរចាត់លោកជា ២ សម័យ :

ទី ១ សម័យចិត្តនិយម ;

ទី ២ សម័យសម្ភារនិយម ។

សម័យសម្ភារនិយម ចាត់ជាច្រើនយ៉ាងទៅទៀត ជាអាទិ៍ គឺ

ក) សម័យថ្ម បានខាងសម័យដែលមនុស្សលោកនិយមរាប់អានគ្រឿងសម្ភារៈផ្សេងៗដែលធ្វើដោយថ្ម គេយកថ្មធ្វើគ្រឿងប្រើប្រាស់ របស់ណាកើតដោយថ្មគេសំគាល់ថាជារបស់ល្អវិសេស (សម័យនេះប្រាសាទថ្មនគរវត្តខ្មែរយើងបានទទួលកិត្តិយសពីសាកលលោកថាជាវត្ថុ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



អស្ចារ្យទី៧ នៃវត្ថុអស្ចារ្យក្នុងសាកលលោក);

១) សម័យកៅស៊ូ បានខាងសម័យដែលមនុស្សលោកនិយមរាប់អានគ្រឿងសម្ភារៈប្រើប្រាស់ផ្សេងៗ ដែលធ្វើដោយជ័រកៅស៊ូគេយកជ័រកៅស៊ូធ្វើគ្រឿងប្រើប្រាស់ របស់ណាកើតពីជ័រកៅស៊ូគេសំគាល់ថាជារបស់ល្អវិសេស ៗ កាលបើមនុស្សលោកនិយមដូច្នេះ ពួកអ្នកវិទ្យាសាស្ត្រក៏ប្រណាំងប្រជែងគ្នា ធ្វើប្រដាប់ប្រើប្រាស់ដោយជាតិកៅស៊ូឲ្យកើតឡើងថែមទាំងគេយកកៅស៊ូធ្វើជាសាច់សំពត់ ១ បែបហៅថា «នីឡុង» ជាដើមសម្រាប់ធ្វើជាគ្រឿងស្លៀកពាក់គ្រឿងប្រើប្រាស់ផ្សេងៗ ដែលអាចចេញមុខជាសម័យមួយបាន ហៅថា «សម័យនីឡុង» ក្នុងបច្ចុប្បន្ននេះ;

គ) សម័យបរមាណូ បានខាងសម័យដែលមនុស្សលោកនិយមរាប់អានគ្រឿងប្រើប្រាស់ផ្សេងៗ ដែលធ្វើដោយផ្សំធាតុជាតិបរមាណូថាជាវត្ថុវិសេសហើយជាវត្ថុដែលអាចប្រព្រឹត្តទៅបានទាំងខាងការកសាងលោកទាំងខាងការបំផ្លាញលោក ៗ

បច្ចុប្បន្ននេះ ពិភពលោកឃ្លាតចេញចាកសម័យថ្ម ថែរមកជាសម័យកៅស៊ូ ឬសម័យនីឡុង និងសម័យបរមាណូវិញ, ព្រឹត្តិការណ៍នៃសម័យទាំងនេះ កំពុងតែប្រណាំងប្រជែងគ្នាពេញទំហឹងដោយអ្នកវិទ្យាសាស្ត្រគេរិះគិតប្រឌិតធ្វើឲ្យថ្មីៗ ឡើងច្រើនបែបច្រើនយ៉ាងណាស់មិនឈ្នះបើរាប់ ៗ យើងមិនអាចទាយថា ទៅអនាគតតើព្រឹត្តិការណ៍ពិភពលោកនឹងអាចប្រែក្លាយទៅជាសម័យអ្វីទៀតនៅឡើយទេ តែគេអាចសន្និដ្ឋានជាឯកច្ឆន្ទថា ព្រឹត្តិការណ៍ពិភពលោកនោះសម័យណាក៏ដោយ សុទ្ធតែ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ស្រេចលើចិត្តានុភាពរបស់មនុស្សទាំងអស់ ។

ចិត្តអាចបង្ខិលលោកឲ្យទៅជាលោកសង្គ្រាមច្បាំងសម្លាប់គ្នាក៏បាន ដូចសម័យសង្គ្រាមលោកលើកទី ១ និងទី ២ កន្លងទៅហើយ, ឲ្យទៅជាលោកសន្តិភាពស្ងប់ច្បាំងក៏បាន ប្រសិនបើសត្វលោកគេត្រូវការបម្រើនចិត្តខាងផ្លូវនេះមែនទែន, សព្វថ្ងៃប្រទេសជាច្រើនក្នុងអាស៊ីទ្វីបគេបាននាំគ្នាញ៉ាំងបញ្ចសីលា (សីល ៥) តាមលំនាំព្រះពុទ្ធសាសនាឲ្យមានដំហានឈានទៅខាងមុខខ្លះហើយ ដើម្បីទប់ទល់កុំឲ្យកើតសង្គ្រាមលោកលើកទី ៣ តទៅ ព្រោះគេនឿយណាយស្អប់ខ្ពើមសង្គ្រាម គឺថាគេប្រាថ្នាគេព្យាយាមបង្ខិលលោកឲ្យវិលឃ្លាតចាកលោកសង្គ្រាម ទៅជាលោកសន្តិភាពឲ្យទាល់តែបាន ។

ព្រោះហេតុតែចិត្តជាធម្មជាតមានអានុភាពដូច្នេះបានជាព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់ដូចន័យដែលបានស្រង់យកមកតាំងទុកជាមាតិកាខាងដើមបំផុតថា « ចិត្តេន នីយតិ លោកោ លោកត្រូវចិត្តដឹកនាំ » ដូចពណ៌នាមកនេះ ។

រួមសេចក្ដីថា ស្រេចលើចិត្តរបស់មនុស្សគេត្រូវការចាប់អង្រួន ឬបង្ខិលលោកទៅយ៉ាងណា លោកក៏រញ្ជួយ ឬវិលទៅតាមគេយ៉ាងនោះ ឥតប្រកែកបានសោះឡើយ ។

ចិត្តដឹកនាំលោក ចប់ដោយសង្ខេប ។

ព្រះទេពសត្ថា កឹម-ឃួរ

AngkorLink.com CambodiaBuddhist.org ABCCambodia.com

# វគ្គទី ៧

## ការបោះពុម្ពព្រះត្រៃបិដក
## នៅប្រទេសខ្មែរ

ព្រះពុទ្ធសាសនានៅប្រទេសខ្មែរយើង បើតាមការសង្កេតមើលឃើញថា កើតទៅជាទំនៀមទម្លាប់ប្រទេស រលាយជាសាច់ជាឈាមប្រជាជាតិទាំងមូលទៅហើយ ឥតសាសនាណាមួយអាចចូលមករំលាន ឬកកេះកកាយគាស់រំលើងចេញបានសោះឡើយ ។ ឯប្រទេសកម្ពុជាយើងដែលបានយកព្រះពុទ្ធសាសនា ជាសាសនាឯកឥតប្រកែកបានមកធ្វើជាគោលការប្រតិបត្តិរបស់ពលរដ្ឋរហូតដល់បានជាប្រពៃណីរបស់ប្រទេសនេះជាការប្រពៃក្រៃលែង, តែយើងគួរយល់ឃើញទៀតថា ព្រះពុទ្ធ-សាសនាដែលមកប្រតិស្ឋាននៅប្រទេសកម្ពុជាយើងនេះ អស់កាលជាយូរយារណាស់ហើយ, ធម្មតារបស់អ្វីមួយដែលចាស់យូរអង្វែងតែងតែជុះប្រេះស្រឹមនាំឲ្យស្រអាប់ពណ៌រស្មី ឬឃ្លៀងឃ្លាតតក់សេចក្តីដោយអន្ទើ ៗ ជាដរាបពុំខានដូចម្តេចមិញ, ឯព្រះពុទ្ធសាសនារបស់យើងដែលមានគម្ពីរព្រះត្រៃបិដកជាបាវចនាជាគោលនេះឯង ក៏មានសភាពដូច្នោះដែរ ។ អាស្រ័យហេតុដូច្នេះ ទើបយើងត្រូវតែរៀបចំកែប្រែតម្រង់តម្រឹមតម្រូវឲ្យបានត្រឹមត្រូវតាមច្បាប់ដើមឡើងវិញ ដូចយានមានរថឧទឹងនាវាជាដើមដែលយើងប្រើយូរឆ្នាំហើយចាស់គ្រាំគ្រា ត្រូវតែយើងជួសជុលលាបលនឲ្យ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



បានល្អដូចដើមឡើងវិញ ទុកប្រើជាប្រយោជន៍តទៅទៀត ។

ហេតុដូច្នេះ ទើបព្រះរាជរដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឡើងក្នុងព្រះរាជធានីភ្នំពេញពីថ្ងៃទី ២៥ មករា ព.ស. ២៤៧៣ គ.ស. ១៩៣០ ដោយមានគោលបំណងច្រើនប្រការ ជាអាទិ៍ គឺ

– ដើម្បីស្រាវជ្រាវរកគម្ពីរដីកាក្បួនច្បាប់ខ្មែរបុរាណមករក្សាទុកកុំឲ្យវិនាសបាត់ទៅ ;

– ដើម្បីរកគម្ពីរក្បួនខ្នាតបរទេសយកមកជាជំនួយបំពេញសេចក្ដីត្រូវការរបស់យើងដែលខ្វះខាត ;

– ដើម្បីចាត់ការបោះពុម្ពផ្សាយនូវគម្ពីរដីកាក្បួនច្បាប់ទាំងផ្លូវលោកទាំងផ្លូវធម៌ ជាការលើកដម្កើងអក្សរសាស្ត្រជាតិ ប្រយោជន៍ឲ្យពលរដ្ឋយើងមានការចេះដឹងទូលំទូលាយបរិបូណ៌ឡើង ;

– ដើម្បីរៀបចំលើកព្រះពុទ្ធសាសនា ឲ្យបានរុងរឿងឡើងដោយការពង្រីកការសិក្សាព្រះបរិយត្តិធម៌មានបង្កើតសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យឲ្យបានផ្សាយទូលាយទៅគ្រប់ខេត្ត ក្នុងព្រះរាជអាណាចក្រ ;

– ដើម្បីរៀបចំប្រែព្រះត្រៃបិដកហើយចាត់ការបោះពុម្ពទាំងបាលីទាំងសម្រាយឲ្យកើតមានឡើងក្នុងប្រទេសយើង ។

ឥឡូវវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយនូវគម្ពីរដីកាធម៌អាចបំពេញសេចក្ដីត្រូវការរបស់ពលរដ្ឋខ្មែរ ឲ្យជួនល្មមដល់សេចក្ដីត្រូវ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ការហើយ ៗ កិច្ចការដ៏ប្រសើររបស់វិជ្ជាឋាននេះមានច្រើនមុខ មិនអាចនឹងរៀបរាប់ឲ្យសព្វគ្រប់បាន សូមលើកយកតែការផ្ទៀងផ្ទាត់ប្រែហើយបោះពុម្ពព្រះត្រៃបិដកខ្មែរយើងតែមួយមុខមកអធិប្បាយដូចតទៅនេះ ៖

មុននឹងពណ៌នាពីការផ្ទៀងផ្ទាត់ប្រែបោះពុម្ពព្រះត្រៃបិដក របស់យើង គួរលើកយករបៀបសង្គាយនាទាំងឡាយ ពីបុរាណតាំងពីបឋមសង្គាយនា រហូតមកដល់បញ្ចមសង្គាយនា ដែលរាប់ថាជាសង្គាយនាធំ ៗ មកពិចារណាប្រៀបធៀបគ្នាមើលសិន ដើម្បីឲ្យឃើញតម្លៃការបោះពុម្ពព្រះត្រៃបិដកយើង ៗ

តាមប្រវត្តិពុទ្ធសាសនាដែលនិយាយទាក់ទងដោយសង្គាយនា មានសេចក្ដីដំណាលថា ក្រោយព្រះពុទ្ធអង្គបរិនិព្វានទៅបាន ៣ ខែគត់ ព្រះមហាកស្សបត្ថេរជាប្រមុខសង្ឃប្រជុំព្រះអរហន្ត ៤៩៩ អង្គ ជា ៥០០ ទាំងព្រះអង្គលោកធ្វើបឋមសង្គាយនា ព្រះអង្គលោកជាអ្នកចោទដណ្ដឹងសួរព្រះធម៌និងព្រះវិន័យ ព្រះឧបាលិត្ថេរជាអ្នកឆ្លើយព្រះវិន័យ ព្រះអានន្ទត្ថេរជាអ្នកឆ្លើយព្រះធម៌ ៗ ក្នុងការប្រជុំការកសង្ឃជាសង្គីតិកាចារ្យនោះ មានគ្រែពីរ គ្រែមួយហៅថា ថេរាសនៈ សម្រាប់ព្រះមហាកស្សបត្ថេរជាអ្នកសួរ គ្រែមួយទៀត ហៅថា ធម្មាសនៈ សម្រាប់ព្រះថេរៈទាំងពីរអង្គជាអ្នកឆ្លើយតាមលំដាប់ការ ព្រះអរហន្តទាំងអស់អង្គគង់ចាំស្ដាប់ នៅក្នុងទីប្រជុំទាំងអស់ ហើយមានការឃាត់ហាមភិក្ខុសង្ឃដទៃក្រៅពីចំនួន ៥០០ អង្គមិនឲ្យចូលកាន់ទីប្រជុំនោះឡើយ ៗ ព្រះសង្ឃទាំងអស់អង្គមូលមតិគ្នាសូត្រ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ស្វាធ្យាយបញ្ចុះត្រូវគ្នារៀងរាល់ថ្ងៃ ៗ កាលព្រះឧបាលិត្ថេរចុះចេញពីត្រៃ ព្រះមហាអានន្ទត្ថេរឡើងកាន់ត្រៃនោះហើយឆ្លើយព្រះធម៌ ព្រះសង្ឃក៏ស្វាធ្យាយបញ្ចុះគ្នាដូចព្រះវិន័យដែរ ៗ បើយើងពិចារណាតាមសង្គាយនានេះយើងឃើញថាកាលនោះព្រះអរហន្តទាំងឡាយលោកចងក្រងព្រះពុទ្ធ-វចនៈដោយព្រះឱស្ឋហៅថា មុខបាឋ មិនបានចារឹកព្រះពុទ្ធវចនៈជាលាយលក្ខណ៍អក្សរទេ គឺលោកគ្រាន់តែទន្ទេញឲ្យចាំមាត់រាល់អង្គ បានសេចក្តីថាកាលនោះព្រះត្រៃបិដកមិនចារឹកដាក់ស្លឹករឹតឬសៀវភៅទេ ៗ សង្គាយនាទី ២ ទី ៣ និងទី ៤ ក៏មានទំនងដូចគ្នានឹងបឋមសង្គាយនានោះដែរ មិនប្លែកគ្នាទេ មានប្លែកខ្លះតែដោយហេតុដែលនាំឲ្យកើតសង្គាយនា និងធម៌ដែលត្រូវយកមកសង្គាយនាប៉ុណ្ណោះព្រោះគោលបំណងត្រឹមតែរម្ងាប់ហេតុការណ៍ជាចម្រូងចម្រាស់ក្នុងព្រះពុទ្ធសាសនានិងការចេះចាំព្រះពុទ្ធវចនៈឲ្យត្រូវគ្នាតែបែបមួយប៉ុណ្ណោះ ៗ ដល់មកសង្គាយនាទី ៥[(១)] ទើបមានការប្លែកពីកាលមុន ៗ គឺការប្រជុំការកសង្ឃផ្ទៀងផ្ទាត់ចារឹកព្រះត្រៃបិដកដាក់ស្លឹករឹត ៗ ហេតុដែលនាំឲ្យចារឹកជាលាយលក្ខណ៍អក្សរដូច្នេះមកពីអស់លោកដែលចេះចាំព្រះពុទ្ធវចនៈរត់មាត់ស្ទាត់នោះ កាន់តែហោចបន្តិចម្តង ៗ ដោយលំដាប់ ព្រោះហេតុនេះជាដើមក៏លោកចារឹកព្រះពុទ្ធវចនៈ

---

១— លំដាប់តមក ព្រះបរមក្សត្រិយ៍ប្រទេសភូមាមានព្រះបញ្ជាឲ្យចារឹកបាលីព្រះត្រៃបិ-ដកលើផ្ទាំងថ្មកែវប្រតិស្ឋានទុកនៅក្រុងមន្ទលេ អ្នកប្រាជ្ញភូមាកំណត់ការនេះថា សង្គាយនាទី ៥ដែរ, រាប់យកការសង្គាយនា នៅមហាបាសាណគូហាក្រុងរង្គូនដោយប្រជុំតំណាងប្រទេសពុទ្ធសាសនិកទៅរួបរួមជាមួយផង ជាសង្គាយនាទី ៦ ហៅថា ឆដ្ឋសង្គាយនា ៗ

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

ជាលាយលក្ខណ៍អក្សរឡើង បានជាព្រះពុទ្ធវចនៈឋិតថេរហូតមកដល់បច្ចុប្បន្នកាលនេះ ។ គំនិតអស់លោកទាំងនោះ ដែលចារឹកព្រះពុទ្ធ-វចនៈទុកជាគោលដ៏សំខាន់ដូច្នេះឯង ប្រសិនបើមិនចារឹកទុកទេ គ្រាន់តែធ្វើសង្គាយនាហើយទន្ទេញឲ្យចាំមាត់ដូចសង្គាយនាកាលមុនៗ នោះសមព្រះពុទ្ធសាសនានឹងអន្តរធានបាត់ទៅហើយ ។ កាលបើយើងយកសង្គាយនាទាំងនោះមកពិចារណាមើលតទៅទៀត យើងនឹងឃើញមានការសំខាន់ ២ ផ្នែក គឺ

១– ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដែលឋិតថេរហូតមក អាស្រ័យដោយព្រះថេរានុត្ថេរៈទាំងឡាយ ចេះចាំមាត់ស្ទាត់ច្រើនអង្គ, នេះទុកជាលើកទី ១;

២– កាលព្រះថេរានុត្ថេរៈទាំងឡាយដែលចាំស្ទាត់ខ្សត់មិនមានច្រើនអង្គក៏កើតមានការចារឹកព្រះពុទ្ធវចនៈទាំងអស់នោះ ចុះកាន់ស្លឹករឹតទុកតមកទៀត នេះទុកជាលើកទី ២ ។

ការសង្គាយនាតូចៗតៗមកគ្រប់ប្រទេសពុទ្ធសាសនិកដូចលង្កា-ភូមា សៀម ឬទុរ៉ប ក៏មិនមានការប្លែកពីសង្គាយនាទី ៥ គ្រាន់តែបានផ្ទៀងផ្ទាត់ហើយចារឹកចុះកាន់ស្លឹករឹត ឬបោះពុម្ពសៀវភៅទុកតគ្នាដដែលៗប៉ុណ្ណោះ នៅខ្វះការសំខាន់មួយលើកទៀតជាលើកទី ៣ គឺការប្រែព្រះពុទ្ធវចនៈជាភាសារៀងខ្លួន ។

ការប្រែព្រះពុទ្ធវចនៈ ជាភាសារបស់ខ្លួនគ្រប់ប្រទេសនេះ កើតជា

ប្រស្នាមួយធំណាស់ ប្រហែលជាមកពីមានសេចក្ដីយល់ផ្សេងគ្នា. អ្នកខ្លះយល់ថាគួរប្រែចេញជាភាសារបស់ខ្លួន, អ្នកខ្លះយល់ថាមិនត្រូវប្រែចេញជាភាសារបស់ខ្លួនទេ, ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកនេះ ត្រូវទៅជាបាលីដដែល អ្នកណាប្រែចេញជាភាសារបស់ខ្លួន មិនសមគួរទេ ; ម្យ៉ាងហើយប្រទេសណា ក៏ដោយក៏បណ្ដោយ មិនបានប្រែជាភាសារបស់ខ្លួនរហូតតមក, បើទុកជាមានប្រែខ្លះ ក៏មិនពោះតែសេចក្ដីខ្លះ ឬសូត្រខ្លះ បន្តិចបន្តួចប៉ុណ្ណោះ ហើយច្រើនតែប្រែយកសេចក្ដីលើសខ្លះពីបាលីផងទៀត ។ កាលប្រទេសយើងបង្កើតពុទ្ធសាសនបណ្ឌិត្យនោះឡើង ទើបយើងផ្ដើមចាត់ការប្រែព្រះពុទ្ធវចនៈជាភាសាខ្មែរយើងមុនគេបង្អស់ ។ ការដ៏ធំហើយប្រពៃនេះ ក៏ចាប់កំណើតឡើងនៅក្នុងលោកដោយផ្សាយទូទៅ ។ ការបោះពុម្ពព្រះត្រៃបិដកយើងនេះក្នុងភាសាម្ដាយរបស់យើងបានឲ្យឈ្មោះថា " ឧត្តមសង្គាយនា " ដោយការរបស់យើងថ្លៃវិសេសជាងសង្គាយនាមុនៗ ទាំងអស់ គឺយើងបានប្រែជាភាសារបស់យើងហើយបោះពុម្ពជាសៀវភៅមានបាលីនៅទំព័រខាងឆ្វេងសម្រាយខាងស្ដាំ ចុះលេខទំព័រត្រូវគ្នា តែយើងមិនបានដាក់ថាជាសង្គាយនាទីប៉ុន្មានទេ ។

សូមអស់លោកពុទ្ធបរិស័ទសប្បុរសទាំងឡាយជ្រាបរបៀបចាត់ការបោះពុម្ពព្រះត្រៃបិដកនៅប្រទេសយើងដោយល្អិតល្អន់ដូចតទៅនេះ :

ព្រះរាជរដ្ឋាភិបាលរបស់យើងបានធ្វើក្រឹត្យមួយ លេខ ១០៦ ចុះថ្ងៃ ១៤ ខែធ្នូ ព.ស. ២៤៧២ គ.ស. ១៩២៩ តាំងអធិបតី ១ រូប និងក្រុម

ជំនុំច្រើនរូប តមកតែប្រែត្រិត្យថ្មី តាំងអធិបតី ១ រូប អធិបតីរង ២ រូប ក្រុមជំនុំ ៤០ រូប រួមហៅថា ព្រះសង្គីតិកាចារ្យ ៗ ព្រះសង្គីតិកាចារ្យទាំង ៤០ រូប បែកជា ៦ ក្រុម គឺ

១– លោកអ្នកសរសេរចម្លង ១ ក្រុម;

២– លោកអ្នកផ្ទៀងបាលី ១ ក្រុម;

៣– លោកអ្នកប្រែពីបាលីមកជាភាសាខ្មែរ ១ ក្រុម;

៤– លោកអ្នកពិនិត្យសេចក្ដីប្រែជាភាសាខ្មែរ ១ ក្រុម;

៥– លោកអ្នកពិនិត្យសេចក្ដីប្រែជាភាសាខ្មែរសម្រេច ១ ក្រុម;

៦– លោកអ្នកពិនិត្យវិញ្ញាសាបោះពុម្ព ១ ក្រុមទៀត សម្រេចជាសៀវភៅឡើង ៗ

ព្រះសង្គីតិកាចារ្យទាំង ៦ ក្រុមនេះ បានធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ដោយមានការិយាល័យពិសេសហៅថា «ក្រុមជំនុំព្រះត្រៃបិដក» កាលប្រជុំលើកដំបូងក្រុមជំនុំបានសម្រេចថា ក្នុងការផ្ទៀងផ្ទាត់ប្រែនេះត្រូវយកព្រះត្រៃបិដកស្លឹករឹតខ្មែរយើងជាគោល ៗ លុះបានជំនុំព្រមព្រៀងគ្នាហើយ ក្រុមជំនុំអ្នកចម្លងបានចម្លងចេញពីគម្ពីរស្លឹករឹតខ្មែរ ចម្លងហើយបញ្ជូនទៅក្រុមជំនុំផ្ទៀងបាលី ៗ ក្រុមជំនុំផ្ទៀងបាលីចាត់ការផ្ទៀងផ្ទាត់ បានយកព្រះត្រៃបិដកសៀម-ភូមា-លង្កា-ឧរ៉ុប មកផ្ទៀងគ្នាមើលកាលផ្ទៀងបើឃើញមានការប្លែកគ្នាខ្លះដោយអន្លើ ៗ មិនហ៊ានកែប្រែលុបលាងចោលទេ បានធ្វើជាលេខយោងហៅថា នយលក្ខណៈ

AngkorLink.com CambodiaBuddhist.org ABCCambodia.com



មកដាក់នៅខាងក្រោមទំព័រ ដោយដឹកបន្ទាត់ខាន់ដាក់អក្សរអាទិសង្កេតថា « ម » មើលថា មរម្ម គឺព្រះត្រៃបិដកភូមា; « សី » មើលថា សីហឡៈ គឺព្រះត្រៃបិដកកោះលង្កា; « ឲ » មើលថា ឲរ៉ុប គឺព្រះត្រៃបិដក Palitest Society ក្រុមជំនុំផ្ទៀងបាលីពិនិត្យមើលហើយ បញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្ដីប្រែ ៗ ក្រុមជំនុំពិនិត្យសេចក្ដីប្រែនេះ កាលពិនិត្យសេចក្ដីប្រែទីមួយ ៗ បានយកអដ្ឋកថា ដីកា យោជនាមកធ្វើជាគោល មិនមែនប្រែតាមទំនើងខ្លួនឯងទេ ៗ លុះពិនិត្យសេចក្ដីប្រែហើយបញ្ជូនទៅក្រុមជំនុំសរសេរចម្លង ឲ្យសរសេរសំអាត, ចម្លងសំអាតហើយបញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្ដីប្រែវិញ ៗ ក្រុមជំនុំពិនិត្យមើលម្ដងទៀត ឃើញថាត្រឹមត្រូវហើយ ទើបបញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្ដីប្រែសម្រេច ៗ ក្រុមជំនុំនេះពិនិត្យផ្ទៀងផ្ទាត់មើលតាមអដ្ឋកថា ដីកា យោជនា ជដែលទៀត ដើម្បីបញ្ជាក់ឲ្យឃើញថាត្រឹមត្រូវពិតប្រាកដ, លុះពិនិត្យហ្មត់ចត់ហើយ ទើបបញ្ជូនទៅសុំសេចក្ដីយល់ព្រមពីព្រះសង្ឃនាយកទាំងពីរគណៈ, តពីព្រះសង្ឃនាយកទាំងពីរគណៈ បញ្ជូនសំណៅនេះទៅកាន់ការជំនុំរដ្ឋមន្ត្រីជាទីបំផុត ៗ កាលចេញពីជំនុំរដ្ឋមន្ត្រីមកហើយទើបសំណៅនេះអាចផ្ញើទៅរោងពុម្ពចាត់ការបោះពុម្ពបាន ៗ តាំងពីបង្កើតក្រុមជំនុំព្រះត្រៃបិដកយើងកាលពី ព.ស. ២៤៧២ គ.ស. ១៩២៩ មកដល់ ព.ស. ២៥០០ គ.ស. ១៩៥៧ ឃើញរយៈកាលចំនួន ២៩ឆ្នាំ ក្រុមជំនុំប្រែព្រះត្រៃបិដកបានប្រែព្រះត្រៃបិដកជាភាសាខ្មែរយើងចប់សព្វគ្រប់ទាំងអស់ ៗ ក្នុងព.ស. ២៥០០ គ-ស-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



១៩៥៧ បានបោះពុម្ពជាសៀវភៅស្រេចចំនួន ៥០ សៀវភៅ គឺវិន័យ-បិដក ១៣ សៀវភៅ សុត្តន្តបិដក ៣៧ សៀវភៅ នៅសល់ខានមិនទាន់ឡើងកាត់ពុម្ពទៀតចំនួន ៦០ សៀវភៅ គឺសុត្តន្តបិដកខ្លះនិងអភិធម្មបិដកទាំងអស់ ។ ចំនួន ២៩ ឆ្នាំនេះឃើញថាការរបស់យើងនេះយឺតយូរពេក តែដែលយឺតយូរនោះ មិនមែនតែហេតុការណ៍អ្វីទេ គឺមកពីប្រទេសកើតមានកង្វល់ខាងខ្វះខាតគ្រឿងឧបករណ៍និងតម្លៃបោះពុម្ពនោះឯង ។

តាមសេចក្តីពណ៌នាមកប៉ុណ្ណោះ ឃើញថាព្រះត្រៃបិដកយើងឧត្តមប្រសើរជាងព្រះត្រៃបិដកប្រទេសណាៗទាំងអស់ សមឈ្មោះថា ឧត្តម-សង្គាយនា ពិតមែន ដោយហេតុយើងបានប្រែជាសំរាយភាសាខ្មែរពេញ ១ ចប់ ឥតសេសសល់ ។ ការធ្វើដូច្នេះមានតែប្រទេសយើងមួយទេដែលធ្វើបានមុនគេបង្អស់ ទុកជាការប្រសើរបំផុត បំពេញសេចក្តីត្រូវការរបស់ពុទ្ធសាសនិកជនទូទៅ ព្រោះមើលតាមប្រវត្តិឃើញថា ព្រះសង្គីតិកាចារ្យសង្គាយនាមក៤លើក បានគ្រាន់តែចងចាំព្រះត្រៃបិដកទុកមកដោយមុខបាឋយ៉ាងស្ទាត់ លើកទី៥ព្រះសង្គីតិកាចារ្យគ្រាន់តែបានចារឹកព្រះត្រៃបិដកជាលាយល័ក្ខណ៍អក្សរភាសាបាលីប៉ុណ្ណោះ ពុំដែលបានប្រែជាសំរាយឲ្យចប់សព្វគ្រប់ផងទេ ឯប្រទេសខ្មែរយើងបានប្រែជាសំរាយភាសាខ្មែរបំពេញសេចក្តីត្រូវការរបស់ពុទ្ធិកជនទូទៅទាំងកម្ពុជប្រ-ទេស ថែមទាំងបានផ្សាយចេញទៅនានាប្រទេសខ្លះផង ៗ

ដោយការរបស់យើងប្រសើរដូចពោលមកនេះ ព្រះត្រៃបិដកយើង

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



ក៏ត្រូវបានពាក្យសរសើរនានាប្រការពីប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ ទាំងពីនានាប្រទេសដទៃខ្លះ ។ នៅបច្ចុប្បន្នកាលនេះ ព្រះត្រៃបិដកយើងមានកេរ្តិ៍មានឈ្មោះលេចឮសុះសាយពេញសាកលលោក ទាំងអាស៊ី ទាំងអ៊ឺរ៉ុប គេកោតស្ញើចយោបល់របស់យើងដែលបានចាប់ផ្តើមធ្វើមុនគេ ។ កាលពី គ.ស. ១៩៣១ មានអ្នកប្រាជ្ញលង្កាទ្វីប ១ រូប ជាភិក្ខុនាម នារទៈ បានមកកាន់ប្រទេសយើង បានដឹងការងារយើងនេះជាក់ច្បាស់ កាលត្រឡប់ទៅលង្កាទ្វីបវិញ បានព្រះត្រៃបិដកយើងមួយភាគគឺវិនយបិដកភាគទី ១ យកទៅជាមួយខ្លួនផង អ្នកប្រាជ្ញនេះ បានសរសេរផ្សាយតាមសារពត៌មានក្នុងលង្កាទ្វីបថា «ប្រទេសខ្មែរជាប្រទេសតូចស្ទើរតែគេមិនដែលឮឈ្មោះសោះ អ្នកប្រាជ្ញក៏មានតិច តែហ៊ានធ្វើការធំណាស់ គឺហ៊ានបោះពុម្ពព្រះត្រៃបិដកប្រែជាភាសារបស់ខ្លួន ដាក់ទំព័រម្ខាងបាលី ទំព័រម្ខាងជាភាសារបស់ខ្លួន, ការងារនេះថ្លៃក ហើយប្រសើរណាស់ ប្រទេសឯទៀតក្នុងលោកពុំទាន់បានធ្វើនៅឡើយទេ ហើយប្រទេសនេះមិនចេះអួតខ្លួនផង» ។ ក្នុង គ.ស. ១៩៤៨ អ្នកប្រាជ្ញបារាំងម្នាក់ឈ្មោះ សឹង-ហ្វីឡូហ្វ្រាត់ បានមកកាន់មន្ទីរក្រុមជំនុំព្រះត្រៃបិដកបានពិនិត្យមើលការងារហើយពោលសរសើរជាច្រើន ទីបំផុតគេថា «ប្រទេសបារាំងនឹងយកតម្រាប់តាមព្រះត្រៃបិដកខ្មែរនេះ ហើយបោះពុម្ពជាព្រះត្រៃបិដកបារាំង» ។ តមកមិនយូរប៉ុន្មាន ប្រទេសបារាំងបានចេញព្រះត្រៃបិដកភាគមួយ ទំព័រម្ខាងជាបាលីអក្សររ៉ូម៉ាំង ទំព័រម្ខាងសេចក្តីប្រែជាភាសាបារាំង ក្នុងសារម្ភ-

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



កថាដាក់ថា យកតម្រាប់តាមព្រះត្រៃបិដកភ្នំពេញប្រទេសកម្ពុជា » ។ ក្នុងពេលបោះពុម្ពហើយថ្មីៗ ប្រទេសយើងបានផ្ញើព្រះត្រៃបិដកយើងដែលបានបោះពុម្ពរួចហើយទៅដម្កល់ទុកនៅប្រទេសឥណ្ឌា ។ វេលាប្រគល់ព្រះត្រៃបិដកនេះគេបានរៀបពិធីមួយ ជាហេតុនាំឲ្យមានឮដំណឹងខ្ចរខ្ចាយដោយពួកសារពត៌មានទាំងឡាយបោះផ្សាយតៗគ្នាទៅ ។ លំដាប់មកទៀត ប្រទេសឥណ្ឌាបានធ្វើបុតហ្វាយមួយច្បាប់ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដូចមានសេចក្តីនៅក្នុងសារពត៌មាន (Cambodge) លេខ ២·១៧៤ ចុះថ្ងៃទី ១៩,១១,៥២ នោះស្រាប់ ។ ដល់ គ.ស.១៩៥៦ ប្រទេសយើងបានផ្ញើព្រះត្រៃបិដកយើងទៅដម្កល់ទុកនៅលង្កាទ្វីប និងប្រទេសភូមាទៀត ។ នៅប្រទេសទ៉ុបមានអ្នកជ្រះថ្លាជាវយកទៅទុកជាសម្បត្តិរបស់ខ្លួនជាចំនួនច្រើនគ្នា ។ ប្រទេសភូមាបានធ្វើសង្គាយនានៅវេលាពាក់កណ្តាលសាសនា គឺ ព.ស. ២៥០០ ហើយគេហៅឲ្យឈ្មោះសង្គាយនាគេថា ឆដ្ឋសង្គាយនា គឺពីបញ្ចមសង្គាយនានោះមក, គេបានសូមយកព្រះត្រៃបិដកយើងទៅជាគ្រឿងផ្ទៀងធៀបគ្នា ក្នុងការសង្គាយនារបស់គេផង គេបានសុំឲ្យយើងខំប្រឹងបោះពុម្ពព្រះត្រៃបិដកយើងឲ្យឆាប់ចប់ឲ្យទាន់ការគេ តែដោយហេតុសៀវភៅព្រះត្រៃបិដកយើងច្រើនដល់ ១១០ ភាគ យើងបោះពុម្ពឲ្យចប់សព្វគ្រប់ពុំទាន់ យើងបានឲ្យសរសេរចម្លងទាំងបាលី ទាំងសម្រាយ ចងជាសៀវភៅព្រះត្រៃបិដកខ្មែរ ១ ចប់ឲ្យទៅប្រទេសភូមា, ប្រទេសនេះក៏បានទទួលយកដោយរីករាយ ។

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com



នៅ គ.ស. ១៩៥៦ យើងបានផ្ញើព្រះត្រៃបិដកយើងទៅទុកឯវិទ្យាស្ថាននាលន្ទា រដ្ឋពិហារ ប្រទេសឥណ្ឌាទៀត ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យឥតធ្វេសប្រហែសសោះឡើយក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ ខំហើយខំទៀត គិតធ្វើដូចម្ដេចឲ្យឆាប់តែបានសម្រេចឆាប់សមតាមគោលបំណងមិនខាន ទោះបីប្រទេសខ្មែរកំពុងក្រីក្រធនធានយ៉ាងណាក៏ដោយ ។ ការខកខានយឺតយូរមកដល់នេះ ជាការផុតវិស័យដែលឥតកែខៃបាន តែពុទ្ធសាសនបណ្ឌិត្យមិនអស់សង្ឃឹមទេ ។ ដោយការខ្នះខ្នែងរបស់មន្ទីរនេះ ទើបបានអនុញ្ញាតពីព្រះរាជរដ្ឋាភិបាល ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម-សីហនុ កាលព្រះអង្គឋិតក្នុងរាជសម្បត្តិនៅឡើយ បានទ្រង់ព្រះមេត្តាប្រោសឲ្យចំណាយថវិកាជាតិ២លានរៀលក្នុង១ឆ្នាំៗ គិតពីឆ្នាំ ១៩៥៣ មក សម្រាប់ជាជំនួយក្នុងការបោះពុម្ពព្រះត្រៃបិដកនោះ ត្រាតែបានចប់សព្វគ្រប់បរិបូណ៌ ដើម្បីទុកជាវដល់ពុទ្ធសាសនិកជន ។ អាស្រ័យហេតុនេះ យើងសង្ឃឹមថា តទៅមុខមិនយូរប៉ុន្មាន ព្រះត្រៃបិដកយើងនឹងបានសម្រេចសមតាមគោលបំណងយើងពុំខាន, សូមអស់លោកទាំងឡាយរង់ចាំទទួលអនុមោទនា ទទួលអាន ដោយត្រេកអរចំពោះសុភកិច្ចដ៏ឧត្ដមនេះចុះ ។

ឧត្ដមប្រឹជា ហាប-ពិន

Mr. AP. AngkorPost.com ABCKhmer.com CamboBank.com

AngkorLink.com CambodiaBuddhist.org ABCCambodia.com


មានលក់ដុំ និង លក់រាយ

នូវសៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ

“ បណ្ណាគារត្រៃរតន៍ ” ផ្ទះលេខ ១៣៦អឺ០

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០១២ ៧០៦ ៥៨១

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។


Mr. AP. AngkorPost.com ABCKhmer.com CamboBank.com